# តើច្បាប់របស់យើងលើកកម្ពស់ សមភាពយេនឌ័រដែរឬទេ ?

សៀវភៅណែនាំសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW

UN WOMEN
United Nations Entity for Gender Equality
and the Empowerment of Women

អង្គការសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី (UN Women) ផ្តល់ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសដល់កម្មវិធីនិងយុទ្ធសាស្ត្រថ្មីៗដែលលើកកម្ពស់សិទ្ធិមនុស្ស ការចូលរួមផ្នែកនយោបាយ និងសន្តិសុខផ្នែកសេដ្ឋកិច្ច របស់ស្ត្រី ។ UN Women ធ្វើការជាដៃគូជាមួយអង្គការសហប្រជាជាតិ រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) នានា និងបង្កើតបណ្តាញដើម្បីលើកកម្ពស់សមភាពយេនឌ័រ ។ UN Women ផ្សារភ្ជាប់បញ្ហា និងកង្វល់របស់ស្ត្រីទៅនឹងរបៀបវារៈថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកល តាមរយៈការជំរុញកិច្ចសហការ និងការផ្តល់ជំនាញបច្ចេកទេសអំពីការបញ្ជ្រាបយេនឌ័រ និងយុទ្ធសាស្ត្រនានាក្នុងការផ្តល់ភាពអង់អាចដល់ស្ត្រី ។

ទស្សនៈដែលបង្ហាញនៅក្នុងអត្ថបទនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ និងមិនសុទ្ធតែតំណាងអោយទស្សនៈរបស់ UN WOMEN អង្គការសហប្រជាជាតិ ឬអង្គការពាក់ព័ន្ធណាមួយរបស់ខ្លួនឡើយ ។

**តើច្បាប់របស់យើងលើកកម្ពស់សមភាពយេនឌ័រដែរឬទេ ?**

**សៀវភៅណែនាំសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ** CEDAW

រក្សាសិទ្ធិ អង្គការសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី

កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ : ខែមិថុនា ឆ្នាំ២០១០

ការិយាល័យប្រចាំតំបន់អាស៊ីបូពា៌ និងអាស៊ីអាគ្នេយ៏របស់ UN WOMEN
អាគារអង្គការសហប្រជាជាតិជាន់ទី ៥ មហាវិថី រ៉ាតដាំណើន ណក
ក្រុងបាងកក ១០២០០ ប្រទេសថៃ
ទូរស័ព្ទលេខ : ៦៦២-២៨៨-២០៩៣
ទូរសារលេខ : ៦៦២-២៨០-៦០៣០
www.UN Women-eseasia.org

និពន្ធដោយ **Rea Abada Chiongson**
កែសម្រួលដោយ **Sarah Fortuna**

# តើច្បាប់របស់យើងលើកកម្ពស់ សមភាពយេនឌ័រដែរឬទេ ?

## សៀវភៅណែនាំសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ EDAW

UN WOMEN
United Nations Entity for Gender Equality and the Empowerment of Women

# បុព្វកថា

នៅក្នុងអំឡុងបីទសវត្សរ៍កន្លងមក ចាប់តាំងពីមហាសន្និបាតអង្គការសហប្រជាជាតិអនុម័តលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (CEDAW) ប្រជាជាតិនៃតំបន់អាស៊ីបូពា៌ និងអាស៊ីអាគ្នេយ៍បានអនុម័តច្បាប់ជាច្រើនដែលបង្កើតបទដ្ឋានសមភាពយេនឌ័រ និងធានានូវសមភាពយេនឌ័រ និងការមិនរើសអើង ។ បញ្ញត្តិស្តីពីការរើសអើងជាច្រើនលើស្ត្រីនៅក្នុងច្បាប់នានាត្រូវបានលុបចោល ហើយច្បាប់ថ្មីៗដែលលើកកម្ពស់សិទ្ធិស្ត្រី និងប្រយុទ្ធប្រឆាំងនឹងទម្រង់ផ្សេងៗនៃអំពើហិង្សាផ្អែកលើយេនឌ័រជាញឹកញាប់តាមវិធីថ្មីៗ ត្រូវបានអនុម័តនៅទូទាំងតំបន់ ។

នៅទូទាំងពិភពលោក UN WOMEN បានគាំទ្រអ្នកតស៊ូមតិផ្នែកសមភាពយេនឌ័រនៅក្នុងរដ្ឋាភិបាលនានា និងអង្គការសង្គមស៊ីវិលក្នុងការអនុវត្តការពិនិត្យមើលឡើងវិញផ្នែកច្បាប់ទៅលើច្បាប់ជាតិសម្រាប់អនុលោមភាពទៅតាម CEDAW និងការអនុវត្តកំណែទម្រង់ផ្នែកច្បាប់ដែលលើកកម្ពស់សមភាពយេនឌ័រ ។ នៅអាស៊ីអាគ្នេយ៍តែឯង ក្នុងរយៈពេលប្រាំឆ្នាំកន្លងមក ការពិនិត្យមើលឡើងវិញទាំងនេះត្រូវបានគាំទ្រតាមរយៈកម្មវិធីរបស់ CEDAW ប្រចាំអាស៊ីអាគ្នេយ៍ នៅក្នុងប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និងវៀតណាម ។ បទពិសោធន៏ទាំងនេះបានចូលរួមចំណែកចំពោះការកសាងចំណេះដឹងអំពីស្ថានភាពនៃសមភាពពេលលេញផ្នែកយេនឌ័រ ។ សំខាន់ជាងនេះទៀត បទពិសោធន៏ទាំងនេះក៏បាននាំទៅដល់ការអនុម័តច្បាប់ស្តីពីសមភាពយេនឌ័រនៅក្នុងប្រទេសវៀតណាមធម្មនុញ្ញ (Magna Carta) ស្តីពីស្ត្រីនៅក្នុងប្រទេស ហ្វីលីពីន និងវិសោធនកម្មចំពោះច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីការបោះឆ្នោតទូទៅនៅក្នុងប្រទេសឥណ្ឌូនេស៊ី និងក្រមព្រហ្មទណ្ឌ និងរដ្ឋប្បវេណីនៃប្រទេសថៃ ក្នុងចំណោមវិធានការដទៃទៀតជាច្រើន ។

ប៉ុន្តែនៅមានច្បាប់ជាច្រើនទៀតដែលនៅតែរើសអើងយ៉ាងចំហរលើស្ត្រី ផ្អែកលើមូលដ្ឋាននៃភេទរបស់ពួកគេ ។ រដ្ឋាភិបាលជាច្រើនជឿថា ច្បាប់អព្យាក្រឹតផ្នែកយេនឌ័រផ្តល់អត្ថប្រយោជន៏ដល់ស្ត្រី និងបុរសស្មើៗគ្នា ដែលតាមការពិតដោយសារឧបសគ្គដែលចាក់ឫសគុលយ៉ាងជ្រៅផ្អែករចនាសម្ព័ន្ធ ស្ថាប័នសង្គម និងវប្បធម៌ចំពោះស្ត្រី ច្បាប់ទាំងនេះពុំបានផ្តល់អត្ថប្រយោជន៏ស្មើៗគ្នាដល់ស្ត្រី និងបុរសឡើយ ។ ការខកខានមិនបានពិចារណា និងដោះស្រាយភាពខុសគ្នាផ្នែកយេនឌ័រនៅក្នុងច្បាប់បង្កអោយវិសមភាពយេនឌ័រនៅតែមានជាបន្ត ។ដូច្នេះ អ្នកតស៊ូមតិដើម្បីសមភាពយេនឌ័រ ត្រូវតែពុះពារនៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីកំណត់ច្បាប់ដែលមិនមានសង្គតភាពជាមួយ CEDAW ធ្វើការស្នើឡើងនូវការកែតម្រូវចាំបាច់នានា ព្រមទាំងជួយបង្កើតក្របខ័ណ្ឌច្បាប់កាន់តែរឹងមាំសម្រាប់លើកកម្ពស់សមភាពយេនឌ័រ ។

ដើម្បីជួយគាំទ្រនៅក្នុងភារកិច្ចចម្រុះនេះ UN WOMEN បានរៀបចំសៀវភៅណែនាំមួយ ដែលមានចំណងជើងថា តើ

ច្បាប់របស់យើងលើកកម្ពស់សមភាពយេនឌ័រដែរឬទេ ? សម្រាប់ការពិនិត្យមើលឡើងវិញផ្អែកច្បាប់ផ្អែកលើ CEDAW ដោយផ្តល់នូវការណែនាំសមស្របមួយជំហានម្តងៗទាក់ទងនឹងការពិនិត្យមើលឡើងវិញយ៉ាងលម្អិតទៅលើច្បាប់ជាតិព្រមទាំងរួមបញ្ចូលសូចនាករទាំងឡាយដែលរៀបចំឡើង និងសាកល្បង តាមរយៈការពិនិត្យមើលឡើងវិញផ្អែកច្បាប់ជាក់ស្តែង។

យើងខ្ញុំសង្ឃឹមថាសៀវភៅណែនាំនេះ   នឹងផ្តល់ជាឧបករណ៍ដ៏មានប្រយោជន៍សម្រាប់អ្នកតស៊ូមតិផ្នែកសិទ្ធិស្ត្រីនៅក្នុងកិច្ចប្រឹងប្រែងដើម្បីបញ្ឈប់ការរើសលើស្ត្រី ទាំងនៅក្នុងច្បាប់ ទាំងនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។



**Moni Pizani**

នាយកកម្មវិធីប្រចាំតំបន់

ការិយាល័យប្រចាំតំបន់អាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍របស់ UN WOMEN

# សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះ UN WOMEN ដែលបានផ្តល់នូវឱកាស ដើម្បីជាផ្នែកមួយនៃការរៀបចំសៀវភៅនេះឡើង ។ ជាពិសេស សូមថ្លែងអំណរគុណចំពោះ Shoko Ishikawa, Amarsanaa Darisuren, Vu Ngoc Binh, Vanny Prok, Syanfirah Hardani និង Pannin Laptaweesath សម្រាប់ការជួយគាំទ្រ និងការណែនាំជាបន្តរបស់ពួកគេ ។

ដោយសារក្របខ័ណ្ឌវាយតម្លៃនៅក្នុងសៀវភៅណែនាំនេះត្រូវបានធ្វើតេស្តសាកល្បងនៅក្នុងសិក្ខាសាលាចំនួនបួនលើកដែលធ្វើឡើងនៅក្នុងប្រទេសឥណ្ឌូនេស៊ី និងប្រទេសកម្ពុជា អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះអ្នករៀបចំ និងអ្នកចូលរួមនៃសិក្ខាសាលា ជាពិសេសលោកជំទាវ ចាន់ សុធាវី រដ្ឋលេខាធិការក្រសួងយុត្តិធម៌កម្ពុជា និងបុគ្គលិករបស់លោកជំទាវ Ly Vichuta, Musdah Mulia, Rena Herdiyani និងសមាជិកនៃគំនិតផ្តួចផ្តើមក្រុមការងាររបស់ CEDAW ។

អ្នកនិពន្ធក៏សូមថ្លែងអំណរគុណចំពោះបុគ្គលិករបស់ UNWOMEN ប្រចាំប្រទេសចិន និងអ្នកចូលរួមនៅក្នុង "ការបណ្តុះបណ្តាលអំពីការវាយតម្លៃអនុលោមភាពនៃច្បាប់ជាតិទៅនឹង CEDAW" ដែលធ្វើឡើងនៅថ្ងៃទី២៨-៣០ ខែមេសា ឆ្នាំ ២០០៩ ទីក្រុងប៉េកាំងប្រទេសចិន ដែលមតិយោបល់របស់ពួកគេបានរួមចំណែកដល់ការកែលម្អជាបន្ថែមចំពោះក្របខ័ណ្ឌវាយតម្លៃ ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះអ្នកទាំងឡាយណាដែលបានផ្តល់ជាមតិយោបល់ដ៏មានតម្លៃចំពោះសេចក្តីព្រាងនៃសៀវភៅណែនាំនេះ ជាពិសេស Usa Lerdsrisuntad នាយកកម្មវិធីនៃមូលនិធិសម្រាប់ស្ត្រី ។ អ្នកនិពន្ធក៏សូមថ្លែងអំណរគុណផងដែរចំពោះ Sarah Fortuna ចំពោះការកែសម្រួល និងការរចនាទម្រង់សៀវភៅយ៉ាងល្អិតល្អន់របស់គាត់ ។

ជាចុងក្រោយ សូមថ្លែងអំណរគុណជាពិសេសចំពោះ Ricardo, Erlinda, Richelle និង Rolica Chiongson និង Emmett Cunningham ចំពោះការលើកទឹកចិត្ត និងការគាំទ្ររបស់ពួកគេ ។

**Rea Abada Chiongson** ខែកុម្ភៈ ឆ្នាំ២០១០

## អំពីអ្នកនិពន្ធ

Rea Abada Chiongson គឺជាមេធាវីមួយរូប និងជាសមាជិកនៃមហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យ Ateneo de Manila ប្រទេសហ្វីលីពីន ។ គាត់ទទួលបានសញ្ញាប័ត្រវិទ្យាសាស្ត្រនយោបាយ និងច្បាប់ (B.A. and J.D.) ពីសាកលវិទ្យាល័យ Ateneo de Manila ប្រទេសហ្វីលីពីន និងសញ្ញាបត្រអនុបណ្ឌិតច្បាប់ (LL.M.) ផ្នែកច្បាប់អន្តរជាតិ ពីសាកលវិទ្យាល័យ

Columbia ក្រុងញូវយ៉ក សហរដ្ឋអាមេរិក ។

Rea គឺជាអ្នកជំនាញដែលត្រូវបានគេទទួលស្គាល់ទាក់ទងនឹងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ទាំងអស់នៃការរើសអើងលើស្ត្រី (CEDAW) និងបទដ្ឋានអន្តរជាតិដទៃទៀតអំពីសមភាពយេនឌ័រ និងសិទ្ធិមនុស្ស ព្រមទាំងការអនុម័ត បទដ្ឋានទាំងនេះនៅថ្នាក់ជាតិ ។ គាត់បានធ្វើការជាអ្នកពិគ្រោះយោបល់នៅក្នុងប្រទេសជាច្រើន រួមទាំងការរៀបចំច្បាប់ស្តីពីសមភាពយេនឌ័រ ការធ្វើសេចក្តីព្រាងរបាយការណ៍របស់រដ្ឋ និងរបស់អង្គការមិនមែនរដ្ឋាភិបាលចំពោះ CEDAW ការធ្វើសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីសមភាពយេនឌ័រ ការអនុវត្តការវាយតម្លៃយេនឌ័រនៃច្បាប់ និងគោលនយោបាយ ការរួមបញ្ចូលយេនឌ័រទៅក្នុងដំណើរការក្តី និងការងារជំនួយផ្នែកច្បាប់ និងកម្មវិធីបណ្តុះបណ្តាលស្តីពីសមភាពយេនឌ័រចំពោះ រដ្ឋាភិបាល អ្នកជំនាញអង្គការមិនមែនរដ្ឋាភិបាលនិងអ្នកតស៊ូមតិ ។ បច្ចុប្បន្នគាត់ធ្វើការជាអ្នកពិគ្រោះយោបល់ជាមួយUNWOMEN ដោយផ្តល់ជំនួយបច្ចេកទេសនៅក្នុងការវាយតម្លៃអនុលោមភាពនៃច្បាប់ជាតិទៅនឹង CEDAW រៀបចំច្បាប់ស្តីពីសមភាពយេនឌ័រ និងអភិវឌ្ឍសមត្ថភាពជាតិស្តីពីសមភាពយេនឌ័រនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។

# តារាងមាតិកា


**បុព្វកថា**

**សេចក្ដីថ្លែងអំណរគុណ**

**អំពីអ្នកនិពន្ធ**

**សេចក្ដីផ្ដើម**

**ផ្នែកទីមួយ**

CEDAW និងឯកសារពិនិត្យមើលឡើងវិញផ្នែកច្បាប់ ៥

ឯកសារពិនិត្យមើលឡើងវិញផ្នែកច្បាប់ ៥

CEDAW ជាក្របខ័ណ្ឌសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ៥

សារៈសំខាន់នៃការប្រើប្រាស់ CEDAW ជាក្របខ័ណ្ឌពិនិត្យមើលឡើងវិញផ្នែកច្បាប់ ៦

**ផ្នែកទីពីរ**

អ្វីដែលអ្នកគួរដឹងមុនពេលធ្វើការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ៩

CEDAW និងគោលការណ៍គន្លឹះរបស់វា ៩

CEDAW ពីមាត្រា ១ ដល់ ៣០ ១៤

ស្ថានភាពជាក់ស្ដែងរបស់ស្ត្រី និងសមភាពយេនឌ័រ ២០

ច្បាប់ និងការតាក់តែងច្បាប់ ២១

សំណួរដែលត្រូវបានសួរជាញឹកញាប់អំពីច្បាប់ និងការតាក់តែងច្បាប់ ២៤

**ផ្នែកទីបី**

ការធ្វើផែនការសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ២៩

## ផ្នែកទីបួន

ក្របខ័ណ្ឌសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ៣៥

ក្របខ័ណ្ឌសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW (ក្របខ័ណ្ឌវាយ តម្លៃ) ៣៦

ការបង្កើតសូចនាករផ្នែកច្បាប់នៃ CEDAW ៣៨

ការកំណត់អនុលោមភាព និងអនុសាសន៍ ៥៧

## ផ្នែកទីប្រាំ

ការប្រើប្រាស់ឯកសារពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ៧១

ពីការពិនិត្យមើលឡើងវិញរហូតដល់កំណែទម្រង់ ៧១
ការប្រើប្រាស់ឯកសារពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ៧២

## ឧបសម្ព័ន្ធទី I

បញ្ជីសូចនាករផ្នែកច្បាប់នៃ CEDAW ៧៥

## ឧបសម្ព័ន្ធទី II

អនុសញ្ញាស្តីពីការលុបបំបាត់ទម្រង់ទាំងអស់នៃការរើសអើងលើស្ត្រី CEDAW ៨៦

## ឧបសម្ព័ន្ធទី III

ធនធានឯកសារ CEDAW ដែលត្រូវបានណែនាំ ៩៩

ឯកសារយោងដែលត្រូវបានជ្រើសរើស ១០៣

# សេចក្តីផ្តើម

## សនិទានភាព

នៅក្នុងឆ្នាំ២០០៩ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ទាំងអស់នៃការរើសអើងលើស្ត្រី (CEDAW) បានប្រារព្ធខួបលើកទី ៣០ ក្រោយពីអនុសញ្ញានេះត្រូវបានបង្កើតឡើង ដែលត្រូវបានអនុម័តដោយមហាសន្និបាតនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ១៩៧៩។ គិតត្រឹមថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៩ រដ្ឋចំនួន ១៨៦ បានផ្តល់សច្ចាប័នលើ CEDAW ដែលឆ្លុះបញ្ចាំងអំពីការព្រមព្រៀងមតិជាសកលរបស់រដ្ឋនានាក្នុងការចាត់វិធានការម៉ឺងម៉ាត់ដើម្បីសម្រេចបានសមភាពយេនឌ័រ និងដើម្បីលុបបំបាត់ការរើសអើងក្នុងគ្រប់ទម្រង់ទាំងអស់ ។

CEDAW ផ្តល់នូវក្របខ័ណ្ឌលម្អិតសម្រាប់ការលើកកម្ពស់ ការការពារ និងការបំពេញកាតព្វកិច្ចក្នុងការលើកកំពស់សិទ្ធិមនុស្សរបស់ស្ត្រី។ ជាពិសេស CEDAW តម្រូវអោយរដ្ឋនានាមានកាតព្វកិច្ចលុបបំបាត់ការរើសអើងលើស្ត្រី នៅគ្រប់វិស័យទាំងអស់ ដោយមិនត្រូវបង្អែរបង្អង់ និងតាមរយៈរាល់មធ្យោបាយសមស្របទាំងអស់ រួមទាំងផ្នែកនីតិកម្ម ។ ប៉ុន្តែ ទោះជាមានកាតព្វកិច្ចដែលកំណត់ ឡើងដោយ CEDAW ក៏ដោយ ការរើសអើងនៅតែបន្តកើតមាននៅក្នុងគ្រប់វិស័យទាំងអស់ រួមទាំងវិស័យច្បាប់ ។ច្បាប់ដែលមានលក្ខណៈរើសអើងបន្តកំហិតហាមឃាត់ ឬធ្វើមោឃភាពចំពោះសិទ្ធិមនុស្សរបស់ស្ត្រីនិងបង្កអោយមាននិទណ្ឌភាពសម្រាប់អំពើហិង្សាជាបន្ត។ ច្បាប់ទាំងនេះធ្វើអោយស្ត្រីបាត់បង់ការអនុវត្តសិទ្ធិ មនុស្សរបស់ខ្លួន និងការអភិវឌ្ឍបានពេញលេញនូវធនធានមនុស្សរបស់ខ្លួន។

គណៈកម្មាធិការ CEDAW នៅក្នុងការអនុវត្តការអង្កេតនាពេលថ្មីៗរបស់ខ្លួន បានទទូចអោយរដ្ឋជាភាគីសម្រេចអោយបាននូវសង្គតិភាព និងអនុលោមភាពនៃច្បាប់របស់ខ្លួនទៅនឹងអនុសញ្ញា។ គណៈកម្មាធិការនេះក៏បានលើកទឹកចិត្តយ៉ាងខ្លាំងក្លាដល់រដ្ឋនានាអោយធានាថាCEDAW ត្រូវបានអនុវត្តនៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុកហើយបទប្បញ្ញត្តិនៃអនុសញ្ញានេះត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់ជាតិ។

## វត្ថុបំណង

សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងដើម្បីណែនាំអ្នកអនុវត្តវិជ្ជាជីវៈនៅក្នុងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នអប់រំ ទីភ្នាក់ងារអភិវឌ្ឍន៍ និងក្រុមស្ត្រីអោយធ្វើការវាយតម្លៃអនុលោមភាពនៃច្បាប់ជាតិរបស់ខ្លួនទៅនឹង CEDAW ព្រមទាំងផ្តល់អនុសាសន៍សមស្របសម្រាប់សង្គតភាពរបស់ខ្លួន តាមរយៈការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW។ សៀវភៅនេះធ្វើកិច្ចការនេះតាមរយៈការបង្ហាញក្របខ័ណ្ឌសម្រាប់ការវាយតម្លៃលើអនុលោមភាពផ្នែកច្បាប់ (ក្របខ័ណ្ឌវាយតម្លៃ)។ ក្របខ័ណ្ឌវាយតម្លៃកសាងសមត្ថភាពរបស់អ្នកអនុវត្តវិជ្ជាជីវៈក្នុងការកំណត់កាតព្វកិច្ចនៅក្រោម CEDAW ធ្វើសេចក្តីព្រាងសូចនាករច្បាប់ កំណត់បញ្ញត្តិផ្នែកច្បាប់ដែលមានលក្ខណៈរើសអើង ស្នើច្បាប់ ការកែសម្រួល ឬការធ្វើ

វិសោធនកម្មដែលលើកកម្ពស់ដល់សមភាពយេនឌ័រ ព្រមទាំងផ្តល់នូវអនុសាសន៍ដទៃទៀត ដើម្បីធានានូវសង្គតភាពនៃច្បាប់ជាមួយអនុសញ្ញា ។ សៀវភៅណែនាំនេះត្រូវបានផ្តោតគោលដៅជាចម្បងសម្រាប់អ្នកអនុវត្តវិជ្ជាជីវៈនៅអាស៊ីអាគ្នេយ៍ ។ ប៉ុន្តែវាក៏អាចត្រូវបានប្រើប្រាស់នៅក្នុងតំបន់ដទៃទៀតផងដែរ ។

## វិធីសាស្ត្រ

ក្របខ័ណ្ឌវាយតម្លៃត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៧ និងត្រូវបានប្រើប្រាស់ដើម្បីពិនិត្យមើលឡើងវិញលើច្បាប់នៃប្រទេសវៀតណាម ។ ការពិនិត្យមើលឡើងវិញផ្នែកច្បាប់របស់វៀតណាម បានកំណត់សូចនាករសរុបចំនួន ១១៧ និងសូចនាកររងចំនួន ៣៤ ទៅជាវិស័យដូចខាងក្រោម :

១. ការធានាសមភាព និងការរើសអើង
២. ការហាមឃាត់ការរើសអើង
៣. ការការពារផ្នែកច្បាប់ចំពោះស្ត្រី
៤. ស្ថាប័នសម្រាប់អនុវត្ត និងពិនិត្យតាមដាន
៥. ការដាក់បញ្ចូល និងការអនុវត្តសន្ធិសញ្ញា
៦. អំពើហិង្សាផ្អែកលើយេនឌ័រ
៧. វិធានការពិសេសបណ្តោះអាសន្ន
៨. បែបផែននៃការប្រព្រឹត្តផ្នែកសង្គម និងវប្បធម៌
៩. ការជួញដូរ និងការធ្វើអាជីវកម្មលើអំពើពេស្យាចារ
១០. ជីវភាពនយោបាយ និងជីវភាពសាធារណៈ
១១. សញ្ជាតិ
១២. ការអប់រំ
១៣. ការងារ
១៤. សុខភាព
១៥. ជីវភាពសេដ្ឋកិច្ច និងសង្គម
១៦. ស្ត្រីជនបទ
១៧. សមភាពចំពោះមុខច្បាប់
១៨. អាពាហ៍ពិពាហ៍ និងគ្រួសារ

[១] សិក្ខាសាលាទាំងបួន គឺ : (ក) សិក្ខាសាលាស្តីពីការវាយតម្លៃអនុលោមភាពនៃច្បាប់ឥណ្ឌូនេស៊ីស្តីពីអាពាហ៍ពិពាហ៍ នឹងគ្រួសារ ទៅនឹងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ទាំងអស់នៃការរើសអើងលើស្ត្រី ទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ថ្ងៃទី៣០ ខែមិថុនា ដល់ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៨ (ខ) សិក្ខាសាលាផ្តល់សុពលភាពស្តីពីការពិនិត្យឡើងវិញផ្នែកច្បាប់នៃច្បាប់អាពាហ៍ពិពាហ៍លេខ ១/១៩៧៤ ទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ថ្ងៃទី១៦-១៧ ខែកញ្ញា ឆ្នាំ២០០៨ (គ) ការវាយតម្លៃអនុលោមភាពនៃច្បាប់របស់កម្ពុជាទៅនឹងCEDAW ថ្ងៃទី០៨-១២ខែកញ្ញា ឆ្នាំ២០០៨ខេត្តសៀមរាប ប្រទេសកម្ពុជា និង (ឃ) សិក្ខាសាលាស្តីពីការផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវអំពីអនុលោមភាពនៃច្បាប់ជាតិទៅនឹង CEDAW ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៩ ។ សិក្ខាសាលានានានៅក្នុងប្រទេសកម្ពុជា ត្រូវបានរៀបចំឡើងដោយក្រសួងយុត្តិធម៌ ចំណែកឯសិក្ខាសាលានៅក្នុងប្រទេស ឥណ្ឌូនេស៊ី ត្រូវបានរៀបចំឡើងដោយគំនិតផ្តួចផ្តើមរបស់ក្រុមការងារ CEDAW (CWGI) ។

ក្របខ័ណ្ឌវាយតម្លៃត្រូវបានកែលម្អពីខែមិថុនា ឆ្នាំ២០០៨ ដល់ខែកុម្ភៈ ឆ្នាំ២០០៩ តាមរយៈការប្រើប្រាស់វានៅក្នុងការពិនិត្យមើលឡើងវិញផ្នែកច្បាប់នៃប្រទេសឥណ្ឌូនេស៊ី និងប្រទេសកម្ពុជា ដែលរួមមានសិក្ខាសាលាចំនួនបួន[១] ដើម្បីផ្តល់ការគាំទ្រជំនាញចំពោះក្រុមនានាក្នុងមូលដ្ឋាន និងការធ្វើសេចក្តីព្រាងសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ថ្នាក់ជាតិ។ ការគាំទ្រផ្នែកបច្ចេកទេស និងកិច្ចពិភាក្សាជាបន្ត ដើម្បីសម្របសម្រួលការផលិតឯកសារពិនិត្យមើលឡើងវិញទៅលើច្បាប់ក៏ត្រូវបានផ្តល់ជូនផងដែរ។ ការពិនិត្យមើលឡើងវិញរបស់ឥណ្ឌូនេស៊ីបានវាយតម្លៃលើច្បាប់អាពាហ៍ពិពាហ៍ (ច្បាប់លេខ ១/១៩៧៤) របស់ឥណ្ឌូនេស៊ី។ ក្រុមការងារអន្តរវិស័យ ដែលដឹកនាំដោយគំនិតផ្តួចផ្តើមនៃក្រុមការងារ CEDAW (CWGI) កំពុងសរសេរឯកសារពិនិត្យមើលឡើងវិញ។ ការពិនិត្យមើលឡើងវិញផ្នែកច្បាប់របស់កម្ពុជា បានវាយតម្លៃលើច្បាប់នានាស្តីពីអំពើហិង្សាក្នុងគ្រួសារ ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ ការងារ និងអ្នកបម្រើតាមផ្ទះ និងអាពាហ៍ពិពាហ៍។ ក្រសួងយុត្តិធម៌នៃប្រទេសកម្ពុជាកំពុងដឹកនាំគំនិតផ្តួចផ្តើមនេះ។ ឯកសារពិនិត្យមើលឡើងវិញផ្នែក ច្បាប់ទាំងពីរនេះកំពុងត្រូវបានបញ្ចប់ ។ ក្របខ័ណ្ឌវាយតម្លៃក៏ត្រូវបានកែលម្អជាបន្តផងដែរ ក្នុងអំឡុង "ការបណ្តុះបណ្តាលអំពីអនុលោមភាពនៃច្បាប់ជាតិទៅនឹង CEDAW" ដែលធ្វើឡើងនៅថ្ងៃទី២៨-៣០ ខែមេសា ឆ្នាំ២០០៩ នៅទីក្រុងប៉េកាំងប្រទេសចិន ដែលត្រូវបានរៀបចំឡើង ដោយ UN China Gender Facility ។

សៀវភៅណែនាំនេះក៏ដកស្រង់គំនិតផ្តួចផ្តើមមុនៗមួយចំនួនផងដែរអំពី CEDAW និងច្បាប់ ដែលរួមមាន :

ក) ការសិក្សារួមគ្នារវាង UN WOMEN និង UNDP ប្រចាំប៉ាស៊ីហ្វិកពីឆ្នាំ២០០៧ - ការបកស្រាយ CEDAW ទៅជាច្បាប់ : អនុលោមភាពផ្នែកច្បាប់របស់ CEDAW នៅក្នុងប្រទេសកោះប៉ាស៊ីហ្វិកចំនួន៩ - ដែលកំណត់ សំណុំសូចនាករផ្នែកច្បាប់ជាក់លាក់ចំនួន ១១៣ ដែលគូសបញ្ជាក់អំពីល័ក្ខខ័ណ្ឌតម្រូវសម្រាប់ច្បាប់ជាតិក្នុងការ អនុលោមពេញលេញទៅតាម CEDAW ។[២]

ខ) អត្ថបទបោះពុម្ពផ្សាយរបស់ UN WOMEN ប្រចាំអាស៊ីខាងត្បូង និងមជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវរបស់ស្ត្រី (CENWOR) ដែលមានចំណងជើងថា សូចនាករ CEDAW សម្រាប់អាស៊ីខាងត្បូង : គំនិតផ្តួចផ្តើម[៣] ដែលកំណត់លេខសូចនាករដែលបានស្នើឡើងទៅលើច្បាប់ការអប់រំ ការងារ សុខភាព និងស្ត្រីនៅក្នុងវិស័យជនបទ និង

គ) សៀវភៅណែនាំរបស់ UNDP មានចំណងជើងថា ការធ្វើសេចក្តីព្រាងច្បាប់ស្តីពីការយល់ដឹងអំពីយេនឌ័រ របៀបដែលត្រូវ

[២] UNWOMEN និងមជ្ឈមណ្ឌលរបស់UNDP ប្រចាំប៉ាស៊ីហ្វិក ។ការបកស្រាយCEDAW ទៅជាច្បាប់ : អនុលោមភាពផ្នែកច្បាប់របស់CEDAW នៅក្នុងប្រទេសកោះប៉ាស៊ីហ្វិកចំនួន ៩ Suva ២០០៧ ។

[៣] CENWOR និង UN WOMEN ។ សូចនាករ CEDAW សម្រាប់អាស៊ីខាងត្បូង : គំនិតផ្តួចផ្តើមមួយប្រទេសស្រីលង្កា ឆ្នាំ២០០៤ ។

លើកកម្ពស់ និងការពារសមភាពយេនឌ័រនៅអឺរ៉ុបកណ្តាល នឹងអឺរ៉ុបខាងកើត និងក្នុងរដ្ឋសហធន ឯករាជ្យ[៤] ដែលផ្តល់នូវការណែនាំអំពីការដាក់បញ្ចូលបទដ្ឋានអន្តរជាតិទៅក្នុងច្បាប់ជាតិ ។

ទោះជាត្រូវបានរៀបចំជាពិសេសសម្រាប់តំបន់នីមួយៗក៏ដោយ ក៏គំនិតផ្តួចផ្តើមទាំងនេះបានចូលរួមចំណែកចំពោះការបង្កើតសៀវភៅណែនាំនេះ ។

[៤] UNDP ការធ្វើសេចក្តីព្រាងច្បាប់ស្តីពីការយល់ដឹងអំពីយេនឌ័រៈ របៀបលើកកម្ពស់និងការពារសមភាពយេនឌ័រនៅអឺរ៉ុបកណ្តាលនឹងអឺរ៉ុបខាងកើតនិងក្នុងរដ្ឋសហធនឯករាជ្យ (CIS), Bratislava UNDP ឆ្នាំ២០០៣ ។

# ១

## ផ្នែកទីមួយ  :

### CEDAW   និងឯកសារពិនិត្យមើលឡើងវិញផ្នែកច្បាប់

នៅក្នុងផ្នែកនេះ :

- ✓ តើអ្វីទៅជាការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ?
- ✓ CEDAW ជាក្របខ័ណ្ឌមួយសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ។

### ឯកសារពិនិត្យមើលឡើងវិញផ្នែកច្បាប់

ឯកសារពិនិត្យមើលឡើងវិញផ្នែកច្បាប់  បង្ហាញអំពីគម្លាតនៅក្នុងច្បាប់ជាក់លាក់នានា  និងបង្ហាញអំពីរបៀបដែលគម្លាតទាំងនេះអាចត្រូវបានដោះស្រាយ ។   ឯកសារពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្តល់ជាអនុសាសន៍សម្រាប់ដំណោះស្រាយផ្នែកច្បាប់ដែលអាចមាន ដូចជា វិសោធនកម្ម ការកែសម្រួល ឬការលុបចោលច្បាប់ដែលមានស្រាប់ ឬការបង្កើតច្បាប់ថ្មី ។

### CEDAW   ជាក្របខ័ណ្ឌសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់

ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ដែលប្រើប្រាស់ក្របខ័ណ្ឌCEDAW វាយតម្លៃអំពីច្បាប់តាមរយៈកញ្ចក់ឆ្លុះបញ្ចាំងនៃបទដ្ឋានសមភាពយេនឌ័រដែលគេទទួលស្គាល់ជាអន្តរជាតិ ។ CEDAW  ផ្តល់នូវអត្ថប្រយោជន៍ជាច្រើនក្នុងនាមជាក្របខ័ណ្ឌសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ។

ដូចសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សដែរ   CEDAW   លើកកម្ពស់វិធីសាស្ត្រផ្អែកលើសិទ្ធិសម្រាប់ទាមទារសិទ្ធិ ។  CEDAW សង្កត់ធ្ងន់ទៅលើការអនុវត្តសិទ្ធិមនុស្ស ។   CEDAW ក៏គូសបញ្ជាក់ផងដែរអំពីទំនាក់ទំនងទៅវិញទៅមក  និងឋានៈស្មើគ្នានៃសិទ្ធិមនុស្សទាំងអស់ ( ទោះជាផ្នែកស៊ីវិល នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ក្តី) ដូចដែលត្រូវបានធានាដោយសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សដទៃទៀត ។

ក្នុងនាមជាសន្ធិសញ្ញាស្តីពីសមភាព CEDAW :

- ពិចារណាទៅលើការស្ថាបនាផ្នែកសង្គមនៃយេនឌ័រ
- ចែងអំពីការធានាយ៉ាងទូលំទូលាយនូវសមភាពក្នុងគ្រប់វិស័យទាំងអស់  ផ្នែកស៊ីវិល  នយោបាយ  សេដ្ឋកិច្ច  សង្គម វប្បធម៌ និងវិស័យផ្សេងៗទៀត
- មិនត្រឹមតែចែងអំពីសមភាពនៅក្នុងច្បាប់ប៉ុណ្ណោះទេ  ប៉ុន្តែសំខាន់ជាងនេះទៀតសមភាពនៃលទ្ធផល  ( សមភាពតាមព្រឹត្តន័យ ឬតាមការជាក់ស្តែង)
- ចែងអំពីនិយមន័យនៃការរើសអើងដែលដោះស្រាយរាល់ទម្រង់ទាំងអស់នៃការរើសអើង    ជាពិសេសការរើសអើង

ដោយប្រយោល និង

- ផ្តោតទៅលើកាតព្វកិច្ចរបស់រដ្ឋនានាក្នុងការធានានូវសិទ្ធិមនុស្សរបស់ស្ត្រី និងសមភាព

## សារៈសំខាន់នៃការប្រើប្រាស់ CEDAW ជាក្របខ័ណ្ឌពិនិត្យមើលឡើងវិញផ្នែកច្បាប់

ច្បាប់នានាបកស្រាយគោលការណ៍របស់ CEDAW ទៅជាបញ្ញត្តិច្បាប់រឹងមាំ ដែលអាចទទួលបាន និងប្រើប្រាស់យ៉ាងងាយស្រួលនៅថ្នាក់ជាតិ ។ ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ដែលប្រើប្រាស់ក្របខ័ណ្ឌ CEDAW ជួយសម្រួលដល់ដំណើរការនេះ ។

ជាពិសេស ក្របខ័ណ្ឌ CEDAW ៖

- កំណត់អំពីការរើសអើងផ្អែកយេនឌ័រនៅក្នុងច្បាប់
- គូសបញ្ជាក់អំពីកាតព្វកិច្ចរបស់រដ្ឋនៅក្នុងវិស័យជាក់លាក់នៃច្បាប់
- បង្ហាញអំពីគម្លាត ឬចំណុចខ្សោយនៅក្នុងច្បាប់ក្នុងការសម្រេចបានសមភាពយេនឌ័រ
- ចង្អុលបង្ហាញអំពីការផ្លាស់ប្តូរនានាដែលចាំបាច់ត្រូវតែកើតមានឡើង ដើម្បីបង្កើតច្បាប់ដែលយកចិត្តទុកដាក់ និងឆ្លើយតបចំពោះយេនឌ័រ និង
- ផ្តល់អនុសាសន៍អំពីរបៀបដែលការរើសអើងត្រូវបានដោះស្រាយ ។

### *គោលបំណងនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW*

ក្នុងករណីភាគច្រើន ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ដែលប្រើប្រាស់ក្របខ័ណ្ឌ CEDAW ត្រូវបានធ្វើឡើងជាជំហានបឋមឆ្ពោះទៅកាន់កំណែទម្រង់ច្បាប់ ។

គោលបំណងជាបន្ទាន់សម្រាប់ការអនុវត្តការពិនិត្យមើលឡើងវិញអាចមានដូចជា ៖

- គូសបញ្ជាក់អំពីទំហំផ្អែកយេនឌ័រនៅក្នុងវិស័យជាក់លាក់នៃច្បាប់ ។
- ចងក្រងជាឯកសារនូវវឌ្ឍនភាពឆ្ពោះទៅកាន់សមភាពយេនឌ័រ (រួមទាំង ការចុះបញ្ជីសារពើភ័ណ្ឌ) ។
- ធ្វើសុខដុមកម្មអសង្គតភាពនៅក្នុងវិស័យផ្សេងៗនៃច្បាប់ តាមរយៈការអនុវត្តបទដ្ឋានសមភាពយេនឌ័រ (ឧទាហរណ៍ នៅក្នុងប្រទេសវៀតណាម ក្រោយពីការអនុម័តច្បាប់ស្តីពីសមភាពយេនឌ័រនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៦ សេចក្តីបង្គាប់អំពីច្បាប់ស្តីពីសមភាពយេនឌ័រត្រូវបានចេញនៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៧ ។ សេចក្តីបង្គាប់នេះបានគូសបញ្ជាក់ថារដ្ឋាភិបាលត្រូវតែបញ្ចប់ការពិនិត្យមើលឡើងវិញលើឯកសារបទដ្ឋានច្បាប់ដែលមានស្រាប់ដើម្បីវាយតម្លៃតម្រូវការសម្រាប់វិសោធនកម្ម ការកែសម្រួល ឬការលុបចោល ឬការចេញច្បាប់ថ្មី ។ ដើម្បីជួយគាំទ្ររដ្ឋាភិបាលការពិនិត្យមើលឡើងវិញផ្នែកច្បាប់ឯករាជ្យមួយត្រូវបានធ្វើឡើង) ។[៥]
- កំណត់ថាតើច្បាប់ បទប្បញ្ញត្តិរដ្ឋបាល ឬទម្លាប់អនុវត្តន៍ផ្អែកវប្បធម៌សង្គមធ្វើអោយប៉ះពាល់ដល់ការធានាធម្មនុញ្ញ

ភាពនៃសមភាព និងការមិនរើសអើសដែរឬយ៉ាងណា ។

- តម្រូវអោយរដ្ឋមានគណនេយ្យភាពចំពោះការធានានូវសមភាព ។
- កំណត់នូវអនុសាសន៍សម្រាប់ច្បាប់ដែលយកចិត្តទុកដាក់ និងឆ្លើយតបចំពោះយេនឌ័រ ។
- ប្រៀបធៀបវឌ្ឍភាពរវាង និងក្នុងចំណោមរដ្ឋនានា ( ឧទាហរណ៍នៅក្នុងតំបន់ប៉ាស៊ីហ្វិក ការពិនិត្យមើលឡើងវិញនៅនឹងកន្លែងចំនួនពីរត្រូវបានធ្វើឡើងដោយ UN WOMEN ប្រចាំប៉ាស៊ីហ្វិក និងមជ្ឈមណ្ឌល UNDP ប្រចាំប៉ាស៊ីហ្វិកដើម្បីវាយតម្លៃអនុលោមភាពផ្នែកច្បាប់ទៅនឹងCEDAW នៃប្រទេសប៉ាស៊ីហ្វិកចំនួន៩:[៦] រដ្ឋសហព័ន្ធមីក្រូនេស៊ី ហ្វីជី គីរីបាទី Marshall Islands ប៉ាពួញូវហ្គីណេ សាម៉ូ កោះសូឡូម៉ូន ទូវ៉ាលូ និង វ៉ានូអាទូ ។ការពិនិត្យមើលឡើងវិញទាំងនេះបានប្រើប្រាស់សូចនាករស្រដៀងគ្នានិងជួយសម្រួលដល់ការប្រៀប ធៀបរបស់ប្រទេសទាំង ៩ ដែលត្រូវបានពិនិត្យមើលឡើងវិញ) ។
- វាយតម្លៃអនុលោមភាពនៃច្បាប់ទៅនឹងការប្តេជ្ញាចិត្តជាអន្តរជាតិ រួមទាំង CEDAW ។
- ផ្តួចផ្តើមការអនុវត្តអនុសាសន៍ពីស្ថាប័នអន្តរជាតិដែលធ្វើការផ្នែកសមភាពយេនឌ័ររួមទាំងគណៈកម្មាធិការ CEDAW ។

## គណៈកម្មាធិការ CEDAW និងការពិនិត្យមើលឡើងវិញផ្នែកច្បាប់

គណៈកម្មាធិការ CEDAW ទទួលស្គាល់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ថាជាឧបករណ៍ដ៏សំខាន់សម្រាប់អនុលោមភាពCEDAW ។គណៈកម្មាធិការនេះលើកទឹកចិត្តយ៉ាងខ្លាំងដល់ការពិនិត្យមើលឡើងវិញចំពោះច្បាប់នៅក្នុងប្រទេសទាំងអស់ ដើម្បីសម្របសម្រួលកំណែទម្រង់ច្បាប់ និងការអនុវត្ត CEDAW ។ រូបភាពខាងក្រោមបង្ហាញអំពីឧទាហរណ៍មួយចំនួន នៃអនុសាសន៍របស់គណៈកម្មាធិការ CEDAW ទាក់ទងទៅនឹងការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ។

[៥] ការពិនិត្យមើលឡើងវិញផ្នែកច្បាប់មានចំណងជើងថា CEDAW និងច្បាប់ : ការពិនិត្យមើលឡើងវិញផ្នែកលើយេនឌ័រ និងសិទ្ធិទៅលើឯកសារច្បាប់វៀតណាមតាមរយៈកញ្ចក់ឆ្លុះបញ្ចាំងរបស់ CEDAW . UN WOMEN CEDAW SEAP, ២០០៩ ។

[៦] របាយការណ៍អំពីការពិនិត្យមើលឡើងវិញនៅនឹងកន្លែងត្រូវបានបោះពុម្ពផ្សាយក្នុងចំណងជើងការបកស្រាយCEDAWទៅជាច្បាប់: អនុលោមភាពផ្នែកច្បាប់របស់ CEDAW នៅក្នុងប្រទេសកោះប៉ាស៊ីហ្វិកចំនួន ៩ ។



***ប្រទេសថៃ***

"គណៈកម្មាធិការព្រួយបារម្ភថា មិនមែនច្បាប់ដែលមានលក្ខណៈរើសអើងទាំងអស់ត្រូវបានធ្វើវិសោធនកម្ម ដើម្បីធានាថាអនុសញ្ញា និងបញ្ញត្តិរបស់វាអាចអនុវត្តបានពេញលេញនៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុកនោះទេ" ។ (CEDAW ផ្តល់ការសន្និដ្ឋានជាមតិយោបល់អំពីប្រទេសថៃ) ២00៦ កថាខ័ណ្ឌទី ១៣ ។

"គណៈកម្មាធិការផ្តល់អនុសាសន៍ថា រដ្ឋភាគីគួរពិនិត្យមើលឡើងវិញជាលក្ខណៈប្រព័ន្ធលើច្បាប់ទាំងអស់ ដើម្បីធានានូវអនុលោមភាពពេញលេញ តាមបញ្ញត្តិទាំងឡាយនៃអនុសញ្ញា។ គណៈកម្មាធិការចង្អុលបង្ហាញថា រដ្ឋភាគីមានកាតព្វកិច្ចធានាថាអនុសញ្ញានេះអាចអនុវត្តបានទាំងស្រុងនៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក" ។(CEDAW ផ្តល់ការសន្និដ្ឋានជាមតិយោបល់អំពីប្រទេសថៃ) ២00៦ កថាខ័ណ្ឌទី ១៤។

***ប្រទេសកម្ពុជា***

"(គណកម្មាធិការCEDAW) លើកទឹកចិត្តដល់រដ្ឋភាគីអោយទាញយកអត្ថប្រយោជន៍ពីដំណើរការកែទម្រង់ច្បាប់ដែលកំពុងធ្វើឡើងដើម្បីសម្រេចបាននូវសង្គតភាព និងអនុលោមភាពពេញលេញនៃច្បាប់ទាំងអស់តាមបញ្ញត្តិនៃអនុសញ្ញា" ។ (CEDAW ផ្តល់ការសន្និដ្ឋានជាមតិយោបល់អំពីប្រទេសកម្ពុជា) ២00៦ កថាខ័ណ្ឌទី ១២ ។

***ប្រទេសហ្វីលីពីន***

"គណៈកម្មាធិការផ្តល់អនុសាសន៍ថា រដ្ឋភាគីគួរពិនិត្យមើលឡើងវិញជាលក្ខណៈ ប្រព័ន្ធលើច្បាប់ទាំងអស់ និងផ្តួចផ្តើមការកែសម្រួលចាំបាច់នានា ដើម្បីសម្រេចបានអនុលោមភាពពេញលេញតាមបញ្ញត្តិទាំងឡាយនៃអនុសញ្ញា"(CEDAW ផ្តល់ការសន្និដ្ឋានជាមតិយោបល់អំពីប្រទេសហ្វីលីពីន) ២00៦ កថាខ័ណ្ឌទី ១២។

***ប្រទេសឥណ្ឌូនេស៊ី***

"គណៈកម្មាធិការស្វាគមន៍កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកំណត់ច្បាប់ ដែលលម្អៀងផ្នែកយេនឌ័រ និងផ្តួចផ្តើមការកែសម្រួលច្បាប់ទាំងនេះ... ។ ទោះជាយ៉ាងណាក៏ដោយគណៈកម្មាធិការព្រួយបារម្ភថាការកែសម្រួលមិនទាន់ត្រូវបានធ្វើឡើងទៅលើច្បាប់ទាំងអស់ចំនួន ២១ ដែលរដ្ឋាភិបាលបាន កំណត់ថាមានលក្ខណៈរើសអើង និងថាវិសោធនកម្មមួយចំនួននៅតែមានលក្ខណៈរើសអើងប្រឆាំងនឹងស្ត្រីនៅឡើយ ទោះបីជាមានការបង្ហាញពីវឌ្ឍនភាពឆ្ពោះទៅរកសមភាពក៏ដោយ" ។ (CEDAW ផ្តល់ការ សន្និដ្ឋានជាមតិយោបល់អំពីប្រទេសឥណ្ឌូនេស៊ី) ២00៧ កថាខ័ណ្ឌទី ១0។

"គណៈកម្មាធិការទទូចដល់រដ្ឋភាគីអោយផ្តល់អាទិភាពខ្ពស់ចំពោះកំណែទម្រង់ច្បាប់របស់ខ្លួន រួចធ្វើវិសោធនកម្មដោយមិនបង្អែរបង្អង់ និងនៅក្នុងរយៈពេលច្បាស់លាស់ទៅលើច្បាប់ និងបទបញ្ញត្តិដែលមានលក្ខណៈរើសអើង ព្រមទាំងធ្វើអោយច្បាប់ទាំងនេះមានលក្ខណៈស៊ីសង្វាក់ជាមួយអនុសញ្ញា" ។ (CEDAW ផ្តល់ការសន្និដ្ឋានជាមតិយោបល់អំពីប្រទេសឥណ្ឌូនេស៊ី) ២00៧ កថាខ័ណ្ឌទី ១១។

✓ *សូមមើលផ្នែកទី ២ : អ្វីដែលអ្នកគួរដឹងមុនពេលធ្វើការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW* សម្រាប់ព័ត៌មានបន្ថែមអំពីគណៈកម្មាធិការ CEDAW ។

# អ្វីដែលអ្នកគួរដឹងមុនពេលធ្វើការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW

## ជំពូកទីពីរ :

## អ្វីដែលអ្នកគួរដឹងមុនពេលធ្វើការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW

នៅក្នុងផ្នែកនេះ :
- ✓ CEDAW និងគោលការណ៍គន្លឹះរបស់វា
- ✓ ជំនឿ មាត្រា ១-៣០
- ✓ ស្ថានភាពជាក់ស្តែងនៃស្ត្រី និងសមភាពយេនឌ័រ
- ✓ ច្បាប់ និងការតាក់តែងច្បាប់
- ✓ សំណួរដែលត្រូវបានសួរញឹកញាប់អំពីច្បាប់ និងការតាក់តែងច្បាប់

ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ប្រើប្រាស់ចំណេះដឹងលម្អិត និងការយល់ដឹងអំពី :

១. CEDAW

២. ស្ថានភាពជាក់ស្តែងនៃស្ត្រី និងសមភាពយេនឌ័រ និង

៣. ច្បាប់ និងការតាក់តែងច្បាប់

គេត្រូវចងចាំថា ប្រការទាំងបីនេះគឺជាកត្តាចាំបាច់ដែលមិនអាចខ្វះបាន ។

### CEDAW និងគោលការណ៍គន្លឹះរបស់វា

CEDAW ព្យាយាមលុបបំបាត់ការរើសអើងលើស្ត្រីក្នុងគ្រប់ទម្រង់ និងរាល់ការបង្ហាញទាក់ទងនឹងការរើសអើងជាញឹកញាប់ CEDAW ត្រូវបានគេហៅថា ច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្សរបស់ស្ត្រី ។ វាត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ និងចូលជាធរមាននៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៨១ ។ CEDAW មានរដ្ឋភាគីចំនួន ១៨៦ ដែលធ្វើអោយវាក្លាយជាសន្ធិសញ្ញាមួយក្នុងចំណោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលត្រូវបានផ្តល់ សច្ចាប័នខ្ពស់បំផុត ។ CEDAW មានបុព្វកថាចំនួនមួយ និងមាត្រាចំនួន ៣០ ។

**គោលការណ៍នៃ CEDAW**

CEDAW មានគោលការណ៍គន្លឹះចំនួនបី :

- សមភាពពេញលេញ
- ការមិនរើសអើង និង
- កាតព្វកិច្ចរបស់រដ្ឋភាគី

គោលការណ៍ទាំងបីនេះតំណាងអោយក្របខ័ណ្ឌទស្សនាទាននៅពីក្រោយ CEDAW ។ ប្រសិនបើគ្មានការយល់ដឹងអំពី

គោលការណ៍ទាំងនេះទេCEDAW មិនអាចត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវឡើយ ។ គោលការណ៍ទាំងបីរបស់CEDAW សង្កត់ធ្ងន់ថា សមភាពត្រូវតែទទួលបាននៅក្នុងតថភាពជាក់ស្តែងមិនមែនតែ "នៅលើក្រដាស"ប៉ុណ្ណោះទេ។ វាមិនគ្រប់គ្រាន់ទេដែលមានច្បាប់ និងគោលនយោបាយត្រឹមត្រូវ ប៉ុន្តែស្ត្រីមិនអាចទទួលបានសមភាពនោះពីមួយថ្ងៃទៅមួយថ្ងៃទេនោះ ។

សមភាពពេញលេញ

បទដ្ឋានសមភាពរបស់ CEDAW គឺសមភាពពេញលេញ។ វាត្រូវបានបកស្រាយដោយគណៈកម្មាធិការ CEDAW ដែលមានន័យថា សមភាពតាមព្រឹត្តន័យ (សមភាពតាមការជាក់ស្តែង ឬសមភាពជាក់ស្តែង) ឬសមភាពនៃលទ្ធផល ។ ប៉ុន្តែការសម្រេចបាននូវសមភាពពេញលេញ តម្រូវអោយស្ត្រីទទួលបានឱកាសស្មើភាព លទ្ធភាពទទួលបានឱកាសស្មើភាព និងបរិយាកាសអនុគ្រោះ ដើម្បីទទួលបានលទ្ធផលស្មើភាព។

សមភាពជាពេញលេញ សម្លឹងហួសពីការធានាផ្នែកច្បាប់នៃការប្រព្រឹត្តដោយស្មើភាពគ្នា និងការពិនិត្យទៅលើឥទ្ធិពលនៃអន្តរាគមន៍។

ឧទាហរណ៍ ច្បាប់មួយអាចផ្តល់ឱកាសស្មើភាពសម្រាប់ស្ត្រីនិងបុរស ដើម្បីទទួលបានឥណទាន ប្រសិនបើពួកគេអាចដាក់វត្ថុបញ្ចាំ (ការធានាឬវត្ថុធានា)។ ប៉ុន្តែ ប្រសិនបើនៅក្នុងការពិតជាក់ស្តែងស្ត្រីមិនអាចគ្រប់គ្រងចាត់ចែង ឬទទួលមតិកពីទ្រព្យសម្បត្តិទេនោះពួកគេមិនទំនងជាអាចផ្តល់វត្ថុបញ្ចាំបាននោះទេ ដូច្នេះហើយពួកគេមិនអាចទទួលបានឥណទានឡើយ។ ប្រសិនបើគ្មានវិធានការដើម្បីធានានូវការសម្រេចបានជាក់ស្តែងនូវសមភាពទេនោះ មិនអាចមានសមភាពពេញលេញបានឡើយ។

ច្បាប់ទាំងឡាយត្រូវតែនាំមកនូវសមភាពពេញលេញដើម្បីអនុលោមតាម CEDAW ។

**គណៈកម្មាធិការ CEDAW បានគូសបញ្ជាក់នៅក្នុងអនុសាសន៍ទូទៅលេខ ២៥ ថា :**

"...វិធីសាស្ត្រផ្នែកច្បាប់ ឬផ្នែកកម្មវិធីផ្លូវការសុទ្ធសាធមិនគ្រប់គ្រាន់ទេក្នុងការសម្រេចបានសមភាពជាក់ស្តែងរបស់ស្ត្រីជាមួយបុរសដែលគណៈកម្មាធិការបកស្រាយថាជាសមភាពពេញលេញ។ លើសពីនេះអនុសញ្ញាតម្រូវអោយស្ត្រីទទួលបាននូវការចាប់ផ្តើមប្រកបដោយសមភាព និងថាពួកគេត្រូវបានប្រគល់សិទ្ធិអំណាចដោយបរិយាកាសអនុគ្រោះដើម្បីសម្រេចបានសមភាពនៃលទ្ធផល ។វាមិនគ្រប់គ្រាន់ទេក្នុងការធានាអោយមានការប្រព្រឹត្តចំពោះស្ត្រីដែលដូចទៅនឹងការប្រព្រឹត្តចំពោះបុរស។ ប៉ុន្តែភាពខុសគ្នាផ្នែកជីវសាស្ត្រក៏ដូចជាផ្នែកសង្គម និងវប្បធម៌រវាងស្ត្រី និងបុរសត្រូវតែយកមកពិចារណា។ នៅក្នុងកាលៈទេសៈជាក់លាក់មួយចំនួនការប្រព្រឹត្តមិនដូចគ្នាចំពោះស្ត្រី និងបុរសគឺជាការចាំបាច់ដើម្បីដោះស្រាយភាពខុសគ្នាទាំងនេះ។ ដើម្បីសម្រេច

**បញ្ហាប្រឈមចំពោះសមភាពជាចាំបាច់**

ទោះបីជាគោលការណ៍នៃសមភាពត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ក៏ដោយ មានឧទាហរណ៍ជាច្រើនអំពីការបកស្រាយសមភាពដែលមិននាំមកនូវសមភាពពេញលេញ។

(ក) សមភាពជាផ្លូវការ : ជាញឹកញាប់សមភាពត្រូវបានគេយល់ថាជាការផ្តល់ការប្រព្រឹត្តស្រដៀងគ្នាចំពោះមនុស្សស្រដៀងគ្នា។ នេះគឺជាសមភាពជាផ្លូវការ។ នៅក្នុងវិធីសាស្ត្រនេះ បុរស និង

> បានគោលដៅនៃសមភាពពេញលេញ ក៏តម្រូវអោយមានយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព ដែលផ្តោតលើការជំនះការតំណាងមិនគ្រប់គ្រាន់ចំពោះស្ត្រី និងការបែងចែក ឡើងវិញនូវធនធាន និងសិទ្ធិអំណាងរវាងបុរស និងស្ត្រី" ។

ស្ត្រី ត្រូវបានគេយល់ឃើញថាមានលក្ខណៈស្រដៀងគ្នា ដូច្នេះហើយ ពួកគេនឹងត្រូវបានផ្តល់ការប្រព្រឹត្តដូចគ្នា។ ជាលទ្ធផល ភាពខុសគ្នាផ្អែកលើជីវសាស្ត្រ ដូចជាការមានគភ៌ ឬមាតុភាពជាដើម ត្រូវបានគេមិនយកចិត្តទុកដាក់។ ភាពខុសគ្នាផ្អែកសង្គមនិងវប្បធម៌ការយល់ឃើញផ្អែកសង្គមថាស្ត្រីមានភាពទន់ខ្សោយ ពឹងផ្អែកផ្អែកសេដ្ឋកិច្ច និងនៅតែផ្ទះ និងផលប៉ះពាល់របស់វាទៅលើស្ត្រី ក៏ត្រូវបានគេព្រងើយកន្តើយផងដែរ។ តាមរយៈការព្រងើយកន្តើយចំពោះភាពខុសគ្នាទាំងនេះ សេចក្តីត្រូវការជាពិសេសរបស់ស្ត្រីមិនត្រូវបានដោះស្រាយឡើយ។

(ខ) មាគ៌ាការពារនិយម : មាគ៌ាការពារនិយមឆ្ពោះទៅរកសមភាពសន្មត់ថា ស្ត្រីមានភាពទន់ខ្សោយជាងបុរស ដូច្នេះហើយត្រូវការការពារ។ ជម្រើសរបស់ស្ត្រីត្រូវបានរឹតត្បិត ហើយសិទ្ធិរបស់ពួកគេត្រូវបានព្រងើយកន្តើយ ដើម្បីធ្វើអោយពួកគេមានសុវត្ថិភាព។ ឧទាហរណ៍ ស្តីពីមាគ៌ាការពារនិយម រួមមានការហាមប្រាមស្ត្រីមិនអោយធ្វើការពេលយប់ (ឧទាហរណ៍ មាត្រា ១៣០ នៃក្រមការងាររបស់ហ្វីលីពីន) ឬការហាមឃាត់ស្ត្រីមិនអោយធ្វើការងារដែលមានគ្រោះថ្នាក់ (ឧទាហរណ៍ មាត្រា ១១៣ នៃក្រមការងាររបស់វៀតណាម និងបញ្ញត្តិច្បាប់បន្ថែមរបស់វា)។ នៅក្នុងករណីទាំងពីរនេះ ស្ត្រីត្រូវបានយល់ឃើញថាជាបញ្ហាជាជាងបរិយាកាសដែលគ្មានសុវត្ថិភាព ដែលនៅតែមិនត្រូវបានដោះស្រាយ។ ស្ត្រីត្រូវបានស្តីបន្ទោសចំពោះអសមត្ថភាពដែលបានស្នើឡើងរបស់ពួកគេក្នុងការការពារខ្លួនជាជាងបរាជ័យ នៃវិធានការសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ឬកង្វះវិធានការសុខភាព និងសុវត្ថិភាពវិជ្ជាជីវៈសមស្រប។ ទោះជាយ៉ាងណាក៏ដោយបុរសត្រូវបានយល់ឃើញថាមិនចាំបាច់នូវការការពារពីគ្រោះថ្នាក់ឬការងារដែលមានគ្រោះថ្នាក់ឡើយ។ នៅក្នុងករណីភាគច្រើនក្នុងចំណោមករណីទាំងនេះ បរិយាកាសមានគ្រោះថ្នាក់ចំពោះទាំងបុរស ចំពោះទាំងស្ត្រី។ វិធីសាស្ត្រឧបត្ថម្ភនិយមដាក់ទណ្ឌកម្មស្ត្រីចំពោះភាពទន់ខ្សោយដែលត្រូវបានគេយល់ឃើញរបស់ពួកគេ។ មិនត្រឹមតែមិនបានដោះស្រាយបរិយាកាសដែលមានគ្រោះថ្នាក់ និងជួយសម្រួលដល់ដំណើរការឆ្ពោះទៅរកសមភាពប៉ុណ្ណោះទេ មាគ៌ាការពារនិយម ថែមទាំងបានពង្រឹងភាពទន់ខ្សោយរបស់ស្ត្រី និងខកខានក្នុងការនាំមកនូវសមភាពជាក់ស្តែង។

## ការមិនរើសអើង

ការមិនរើសអើង គឺជាគោលការណ៍គន្លឹះនៃ CEDAW ។ ការមិនរើសអើង ត្រូវបានសង្កត់ធ្ងន់ជាពិសេសនៅក្នុងមាត្រា ១ នៃ CEDAW ដែលកំណត់និយមន័យនៃពាក្យការរើសអើង ។ មាត្រានេះបានគូសបញ្ជាក់ថា ការរើសអើងលើស្ត្រី "ត្រូវមានន័យថា ភាពខុសគ្នា ការផាត់ចេញ ឬការរឹតត្បិតណាមួយដែលធ្វើឡើងផ្អែកលើមូលដ្ឋានភេទ ដែលមានឥទ្ធិពល ឬគោលបំណងធ្វើអោយប៉ះពាល់ ឬធ្វើមោឃភាពដល់ការទទួលស្គាល់ការទទួលបាន ឬការប្រើប្រាស់ដោយស្ត្រីនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ ស៊ីវិល ឬវិស័យដទៃទៀត ផ្អែកលើមូលដ្ឋាននៃសមភាពរវាងបុរស និងស្ត្រី ដោយមិនគិតអំពីស្ថានភាពអាពាហ៍ពិពាហ៍" ។ មាត្រានេះសង្កត់ធ្ងន់ថា សកម្មភាព ឬការខកខានមិនបានធ្វើសកម្មភាព គឺជាការរើសអើង ប្រសិនបើវាមាន "ឥទ្ធិពល ឬមានគោលបំណង" រើសអើងលើស្ត្រី ។

CEDAW ហាមឃាត់ទម្រង់នៃការរើសអើងទាំងនេះ :

(ក) ការរើសអើងដោយផ្ទាល់ : សំដៅដល់សកម្មភាព ឬការខកខានមិនបានធ្វើសកម្មភាព ដែលមាន "គោលបំណង" រើសអើងលើស្ត្រី ឧទាហរណ៍អាយុចូលនិវត្តន៍មិនស្មើភាព សិទ្ធិទទួលមត៌កមិនស្មើភាព ការបញ្ឈប់ពីការងារផ្អែកលើមូលដ្ឋាននៃអាពាហ៍ពិពាហ៍ ឬការមានគភ៌ និងអាយុខុសគ្នានៃអាពាហ៍ពិពាហ៍រវាងក្មេងប្រុស និងក្មេងស្រី ។

(ខ) ការរើសអើងដោយប្រយោលៈ សំដៅដល់សកម្មភាពឬការខកខានមិនបានធ្វើសកម្មភាពដែលមាន "ឥទ្ធិពល" រើសអើងលើស្ត្រីទោះបីជាគ្មានចេតនាក្នុងការធ្វើដូច្នោះក៏ដោយ ។ ស្ត្រីមិនអាចប្រឈមមុខនឹងឧបសគ្គជាច្រើនដែលបង្កឡើងដោយវប្បធម៌ និងទម្លាប់អនុវត្តន៍ផ្អែកសាសនា ឬផលប្រយោជន៍របស់បុរស ដែលចាក់ឫសគុលនៅក្នុងស្ថាប័នសំខាន់ៗដូចជា

### បញ្ញត្តិអព្យាក្រឹតផ្នែកយេនឌ័រ

ការបង្ហាញជាទូទៅមួយនៃវិធីសាស្ត្រសមភាពផ្លូវការ គឺបញ្ញត្តិអព្យាក្រឹតផ្នែកយេនឌ័រ ។ នេះគឺជាបញ្ញត្តិដែលមិនញែកភាពខុសគ្នារវាងបុរស និងស្ត្រី ដែលផ្តល់នូវការយល់ឃើញនូវភាពអព្យាក្រឹត ។ ប៉ុន្តែវាអាចមានលក្ខណៈរើសអើង ប្រសិនបើស្ត្រី និង បុរសមិនទទួលបាន អត្ថប្រយោជន៍ស្មើភាពពីបញ្ញត្តិទាំងនេះទេនោះ ។

ឧទាហរណ៍ ក្រមនីតិវិធីរដ្ឋប្បវេណីនៅក្នុងប្រទេសវៀតណាមចែងថា អ្នកណាម្នាក់ដែលស្នើសុំអោយតុលាការអនុវត្តវិធានការបណ្តោះអាសន្ន (នៃការបញ្ចាំទ្រព្យសម្បត្តិរបស់ភាគី ម្ខាងទៀតមុខពេលវិនិច្ឆ័យក្តី) ត្រូវតែតម្កល់ប្រាក់មួយចំនួនឬទ្រព្យសម្បត្តិ ឬឯកសារមានតម្លៃដទៃទៀត ។ បញ្ញត្តិនេះ ទោះបីជាមានភាពអព្យាក្រឹតផ្នែកយេនឌ័រក៏ដោយ អាចមានផលប៉ះពាល់វិសមាមាត្រទៅលើស្ត្រី ដោយ សារ ជាទូទៅស្ត្រីក្រីក្រជាងបុរស (ពោលគឺពួកគេទទួលបានប្រាក់បៀវត្សរ៍តិចជាងបុរស ហើយមានលទ្ធភាពតិចជាងបុរសក្នុងការមានជាកម្មសិទ្ធិគ្រប់គ្រង ឬចាត់ចែងលើទ្រព្យសម្បត្តិ) ។ ដូច្នេះការប្រព្រឹត្តស្រដៀងគ្នាដូចមានចែងនៅ ក្នុងច្បាប់មិនអាចត្រូវបានអះអាងថានាំមកនូវសមភាពបានទេ ។ វិធានការដទៃទៀតដើម្បីអនុញ្ញាតអោយមានលទ្ធភាពប្រសើរឡើងសម្រាប់ស្ត្រីត្រូវតែបង្កើតឡើង ។

សមភាពផ្លូវការមិនអើពើចំពោះផលប៉ះពាល់នៃបញ្ញត្តិអព្យាក្រឹតផ្នែកយេនឌ័រទេ ដូច្នេះហើយមិនអាចនាំមកនូវសមភាពជាក់ស្តែងបានឡើយ ។

គណបក្សនយោបាយ សហជីពកម្មករ ស្ថាប័នសាសនា និងតុលាការ។ ដោយសារកត្តាទាំងនេះ ការធ្វើសកម្មភាព ឬការខកខានមិនបានធ្វើសកម្មភាពអាចហាក់ដូចជាមានលក្ខណៈអព្យាក្រឹតចំពោះឬថែមទាំងមានប្រយោជន៍ចំពោះស្ត្រីទៀតផង ប៉ុន្តែឥទ្ធិពល ឬផលប៉ះពាល់របស់វាអាចមានលក្ខណៈរើសអើង។

(គ) ការរើសអើងច្រើនប្រភេទ៖ ការរើសអើងផ្អែកយេនឌ័រ អាចកើតមានដោយសារមូលហេតុដទៃទៀតដូចជា ដោយសារហេតុផលនៃពូជសាសឋានៈសេដ្ឋកិច្ច ឬសង្គម សាសនា ពិការភាព ឬអាយុ។ អន្តរាគមន៍នានា គួរពិចារណាទៅលើរាល់ទម្រង់ទាំងអស់នៃគុណវិបត្តិ ដើម្បីអាចដោះស្រាយការរើសអើងទាំងនេះអោយបានសមស្រប។ គណៈកម្មាធិការ CEDAW សង្កត់ធ្ងន់ថា "ក្រុមស្ត្រីជាក់លាក់មួយចំនួន ក្រៅពីទទួលរងការរើសអើងទៅលើពួកគេជាស្ត្រី ក៏អាចទទួលរងការរើសអើងច្រើនប្រភេទផ្អែកលើហេតុផលបន្ថែម ដូចជា ពូជសាសន៍ ជាតិពន្ធុ ឬសាសនា ពិការភាព អាយុ វណ្ណៈ ឬកត្តាផ្សេងៗទៀត។ ការរើសអើងច្រើនប្រភេទទាំងនេះអាចប៉ះពាល់ចំពោះក្រុមស្ត្រីទាំងនេះជាចម្បង ឬក្នុងកម្រិតផ្សេងគ្នាឬតាមរបៀបផ្សេងគ្នាជាងចំពោះបុរស"។[៧] ឧទាហរណ៍នៃស្ត្រីដែលទទួលរងការរើសអើងបន្ថែមលើការរើសអើងផ្អែកយេនឌ័ររួមមាន ស្ត្រីជនបទ ស្ត្រីដែលមានពិការភាព ស្ត្រីជនជាតិដើម ស្ត្រីចំណាកស្រុក និងស្ត្រីចំណាស់។

ជាមួយនិយមន័យរបស់ CEDAW ទៅលើពាក្យ "ការរើសអើង" វាមានភាពច្បាស់លាស់ដែលថា ការពិនិត្យតាមដានផលប៉ះពាល់ និងឥទ្ធិពល គឺជាកត្តាសំខាន់ខ្លាំងណាស់។ ការបង្កើតវិធានការសមស្រប ទោះជាមានភាពអព្យាក្រឹតផ្អែកយេនឌ័រក្តី ឬគាំទ្រស្ត្រីក្តី មិនគ្រប់គ្រាន់ទេ ប្រសិនបើវាមិននាំមកនូវសមភាពពេញលេញទេនោះ។

## កាតព្វកិច្ចរបស់រដ្ឋ

គោលការណ៍ទីបីរបស់ CEDAW សង្កត់ធ្ងន់ថា អ្នកទទួលភារកិច្ច យោងតាមអនុសញ្ញានេះ គឺភាគីរដ្ឋ។ នេះមានន័យថា ទោះបីជាទំនួលខុសត្រូវក្នុងការធានានូវសមភាព និងក្នុងការលុបបំបាត់ការរើសអើងត្រូវតែស៊ើបអង្កេតដោយរដ្ឋ និងតួអង្គមិនមែនរដ្ឋក៏ដោយ មានតែរដ្ឋប៉ុណ្ណោះត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះ CEDAW។

រដ្ឋសំដៅដល់អង្គភាព ឬអង្គការទាំងឡាយរបស់រដ្ឋាភិបាលដែលមានរចនាសម្ព័ន្ធនីតិប្រតិបត្តិ នីតិបញ្ញត្តិ តុលាការ និងរដ្ឋបាល ក៏ដូចជាអង្គភាពរដ្ឋាភិបាលថ្នាក់មូលដ្ឋាន។

កាតព្វកិច្ចទូទៅរបស់រដ្ឋមានចែងនៅក្នុងមាត្រា១-៥ នៃCEDAW ចំណែកឯកាតព្វកិច្ចជាក់លាក់របស់រដ្ឋភាគីមានចែងនៅក្នុងមាត្រា ៦-១៦ នៃ CEDAW។

CEDAW បង្កើតកាតព្វកិច្ចនៃមធ្យោបាយនិងលទ្ធផល។ រដ្ឋភាគីសន្យាអនុវត្តតាមមធ្យោបាយជាក់លាក់នៃការអនុវត្តនៅក្នុង CEDAW (កាតព្វកិច្ចនៃមធ្យោបាយ)។ រដ្ឋភាគីក៏មានកាតព្វកិច្ចធានាថា វិធានការដែលបានជ្រើសរើសនាំមកនូវការលុបបំបាត់ (កាតព្វកិច្ចនៃលទ្ធផល)។

---

[៧] នុសាសន៍ទូទៅ លេខ ២៥ កថាខ័ណ្ឌទី ១២ របស់ CEDAW

## CEDAW ពីមាត្រា ១ ដល់ ៣០

កាតព្វកិច្ចជាចាំបាច់នៅក្រោម CEDAW (មាត្រា ១-១៦)

**មាត្រា ១-៥ មានកាតព្វកិច្ចទូទៅរបស់រដ្ឋភាគីដូចខាងក្រោមនៅក្រោម CEDAW :**

(ក) មាត្រា ១ ផ្តល់នូវនិយមន័យអំពីការរើសអើង ។

(ខ) មាត្រា ២ តម្រូវអោយរដ្ឋភាគី :

- បញ្ចូលគោលការណ៍ស្តីពីសមភាពនៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិ (មាត្រា ២ក)
- ហាមឃាត់ការរើសអើងតាមរយៈនីតិកម្ម និងមធ្យោបាយផ្សេងទៀត (មាត្រា ២ខ)
- បង្កើតការការពារផ្នែកច្បាប់ចំពោះស្ត្រី (មាត្រា ២គ)
- ចៀសវាងពីការរើសអើង (មាត្រា ២ឃ)
- លុបបំបាត់ការរើសអើងពីសំណាក់តួអង្គឯកជន ឧទាហរណ៍ បុគ្គល អង្គការ និងសហគ្រាស (មាត្រា ២ង) និង
- កែប្រែ ឬលុបចោលច្បាប់បទប្បញ្ញត្តិ ទំនៀមទម្លាប់ និងទម្លាប់អនុវត្តន៍ដែលមានលក្ខណៈរើសអើង (មាត្រា ២ច) ។

(គ) មាត្រា ៣ តម្រូវអោយរដ្ឋភាគីមានកាតព្វកិច្ចបង្កើតវាល់វិធានការទាំងឡាយ សម្រាប់ការអភិវឌ្ឍពេញលេញរបស់ស្ត្រី

(ឃ) មាត្រា៤ចង្អុលបង្ហាញថាវិធានការពិសេសបណ្តោះអាសន្នក្នុងការពន្លឿនការសម្រេចបាននូវសមភាពជាក់ស្តែង(មាត្រា ៤.១) និងវិធានការដែលអនុគ្រោះដល់មាតុភាព (មាត្រា ៤.២) នឹងមិនត្រូវបានចាត់ទុកជាការរើសអើងឡើយ ។

(ង) មាត្រា ៥ តម្រូវអោយរដ្ឋភាគីធ្វើការកែប្រែបែបផែនសង្គម និងវប្បធម៌នៃការប្រព្រឹត្ត ដែលផ្អែកលើភាពទន់ខ្សោយ ឬឧត្តមភាពនៃភេទ ឬផ្អែកលើតួនាទីជាតួយ៉ាង ។

**មាត្រា ៦-១៦ សំដៅដល់កាតព្វកិច្ចរបស់រដ្ឋភាគីដូចខាងក្រោមនៅក្នុងវិស័យជាក់លាក់ :**

(ក) ការជួញដូរ និងការធ្វើអាជីវកម្មពេស្យាចារ : មាត្រា ៦ តម្រូវអោយរដ្ឋភាគីចាត់វិធានការសមស្រប ដើម្បីបង្ក្រាបការជួញដូរស្ត្រី និងការធ្វើអាជីវកម្មពេស្យាចារលើស្ត្រី ។

(ខ) ជីវភាពនយោបាយ និងជីវភាពសាធារណៈ: មាត្រា ៧ តម្រូវអោយរដ្ឋភាគីលុបបំបាត់ការរើសអើងលើស្ត្រីនៅក្នុងវិស័យនៃជីវភាពនយោបាយ និងជីវភាពសាធារណៈ ។ មាត្រានេះចែងថា ស្ត្រីនិងបុរសមានសិទ្ធិស្មើគ្នាក្នុងការបោះឆ្នោត ឈរឈ្មោះបោះឆ្នោត ចូលរួមនៅក្នុងការបង្កើត និងការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល កាន់កាប់មុខតំណែងសាធារណៈ អនុវត្តមុខងារសាធារណៈទាំងឡាយ និងចូលរួមនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល និងអង្គភាព សាធារណៈ និងនយោបាយ ។ មាត្រា ៨ ចែងថា ស្ត្រីក៏មានសិទ្ធិស្មើគ្នាក្នុងការតំណាងអោយរដ្ឋាភិបាលនៅថ្នាក់អន្តរជាតិ និងចូលរួមនៅក្នុងអង្គការអន្តរជាតិ ។

(គ) សញ្ជាតិ : មាត្រា ៩ ចែងថា ស្ត្រីមានសិទ្ធិទទួលផ្លាស់ប្តូរ ឬរក្សាសញ្ជាតិរបស់ខ្លួន ។ សញ្ជាតិរបស់ភរិយានឹងមិនផ្លាស់ប្តូរដោយស្វ័យប្រវត្តិដោយសារអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬការផ្លាស់ប្តូរសញ្ជាតិដោយស្វាមីឡើយ ។ ស្ត្រីក៏អាចបន្ត

សញ្ជាតិរបស់ខ្លួនដល់កូនរបស់ខ្លួនផ្អែកលើមូលដ្ឋានស្មើភាពដូចបុរសដែរ។

(ឃ) ការអប់រំ : មាត្រា ១០ ចែងថា រដ្ឋត្រូវតែធានានូវសិទ្ធិស្មើគ្នាក្នុងវិស័យអប់រំ។ មាត្រានេះចែងថា បុរស និងស្ត្រីត្រូវមានលក្ខខណ្ឌដូចគ្នាក្នុងការទទួលបានការសិក្សា និងសញ្ញាប័ត្រ។ ប្រការនេះគួរត្រូវបានធានានៅក្នុងការអប់រំថ្នាក់មត្តេយ្យ ការអប់រំទូទៅ ការអប់រំជំនួស ការអប់រំផ្នែកបច្ចេកទេស វិជ្ជាជីវៈ និងបច្ចេកទេសជាន់ខ្ពស់ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ វាក៏បានចែងថា ស្ត្រី និងបុរសមានសិទ្ធិទទួលបានកម្មវិធីអប់រំដូចគ្នាការប្រឡង បុគ្គលិកបង្រៀន ទីធ្លា និងបរិក្ខារសាលារៀនដូចគ្នា ។ ស្ត្រី និងក្មេងស្រីត្រូវតែទទួលបានឱកាសដូចគ្នាក្នុងការទាញយកអត្ថប្រយោជន៍ពីអាហារូបករណ៍ និងកម្មវិធីនានានៃការបន្តការសិក្សា ។ វាក៏ជំរុញដល់កិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយអត្រាបោះបង់ការសិក្សាសម្រាប់សិស្សស្រី និងដោះស្រាយបញ្ហាក្មេងស្រីដែលបោះបង់ការសិក្សាមុនកាលកំណត់ផងដែរ។

មាត្រា ១០ ក៏បានគូសបញ្ជាក់ផងដែរអំពីសេចក្តីត្រូវការក្នុងការលុបបំបាត់ទស្សនាទានបុរេវិនិច្ឆ័យនៅក្នុងការអប់រំជាពិសេសតាមរយៈការកែសម្រួលសៀវភៅអាន និងកម្មវិធីសាលា។

(ង) ការងារៈ មាត្រា ១១ ចែងថា រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្របទាំងអស់ ដើម្បីលុបបំបាត់ការរើសអើងនៅក្នុងការងារ។ ស្ត្រី និងបុរសមានសិទ្ធិដូចគ្នាក្នុងការធ្វើការ និងសិទ្ធិក្នុងការទទួលបានឱកាសការងារដូចគ្នា។ មាត្រានេះធានានូវប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារដែលមានតម្លៃស្មើគ្នា និងសមភាពនៃការប្រព្រឹត្តក្នុងការវាយ តម្លៃការងារ។ មាត្រា ១១ ក៏ធានាផងដែរនូវសិទ្ធិជ្រើសរើសការងារដោយសេរី សិទ្ធិទទួលបានការតម្លើងឋានៈ និងស្ថិរភាពការងារ សិទ្ធិទទួលបាននិរភ័យសង្គម (ក្នុងករណីនៃការចូលនិវត្តន៍

**ភាពខុសគ្នារវាងវិធានការពិសេសបណ្តោះអាសន្ន (មាត្រា ៤.១) និងវិធានការពិសេស ដែលអនុគ្រោះដល់មាតុភាព (មាត្រា ៤.២)**

អនុសាសន៍ទូទៅទី ២៥ ចែងថា :

កថាខ័ណ្ឌទី ១៥ : មានភាពខុសគ្នាយ៉ាងច្បាស់រវាងគោលបំណងនៃ"វិធានការពិសេស"នៅក្នុងមាត្រា៤ កថាខ័ណ្ឌទី ១ និងវិធានការនៃ កថាខ័ណ្ឌទី ២។ គោលបំណងនៃមាត្រា៤ កថាខ័ណ្ឌទី១ គឺដើម្បីពន្លឿនការលើកកម្ពស់ស្ថានភាពស្ត្រីក្នុងការសម្រេចបាននូវសមភាពជាក់ស្តែង និងសមភាពជាចាំបាច់ជាមួយបុរស និងធ្វើអោយមានប្រសិទ្ធភាពចំពោះការផ្លាស់ប្តូរផ្នែករចនាសម្ព័ន្ធ សង្គម និងវប្បធម៌ ដែលចាំបាច់ដើម្បីកែតម្រូវទម្រង់ និងឥទ្ធិពលនៅក្នុងអតីតកាល និងបច្ចុប្បន្ននៃការរើសអើងប្រឆាំង នឹងស្ត្រីក៏ដូចជាផ្តល់អោយពួកគេនូវសំណង។ វិធានការទាំងនេះគឺមានលក្ខណៈបណ្តោះអាសន្ន។

កថាខ័ណ្ឌទី ១៦ : មាត្រា ៤ កថាខ័ណ្ឌទី ២ ចែងអំពីការប្រព្រឹត្តមិនដូចគ្នាចំពោះស្ត្រី និងបុរសដោយសារភាពខុសគ្នាផ្នែកជីវសាស្ត្ររបស់ពួកគេ ។ វិធានការទាំងនេះមានលក្ខណៈអចិន្ត្រៃយ៍ យ៉ាងហោចណាស់រហូតទាល់តែដល់ ពេលដែលចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលរៀបរាប់នៅក្នុងមាត្រា១១ កថាខ័ណ្ឌទី៣ តម្រូវអោយមានការពិនិត្យមើលឡើងវិញ។

ភាពគ្មានការងារធ្វើ ជំងឺ ពិការភាព និងវ័យចំណាស់) និងសិទ្ធិទទួលបានបរិស្ថានការងារប្រកបដោយសុខភាព និងសុវត្ថិភាព។

ការរើសអើងផ្អែកលើមូលហេតុនៃស្ថានភាពអាពាហ៍ពិពាហ៍និងមាតុភាពត្រូវបានហាមឃាត់ ។មាត្រា១១តម្រូវអោយមានការដាក់ទណ្ឌកម្មសម្រាប់ការបណ្តេញចេញដោយសារស្ថានភាពអាពាហ៍ពិពាហ៍ការមានគភ៌ឬការឈប់សម្រាកលំហែមាតុភាព។ វាក៏តម្រូវអោយមានការឈប់សម្រាកលំហែមាតុភាពមានប្រាក់ឈ្នួល ដោយមិនបាត់បង់អត្ថប្រយោជន៏ ឬអតីតភាពការងារនិងសេវាគាំទ្រសម្រាប់ការថែទាំកូនផងដែរ ។ការការពារពិសេសពីការងារដែលមានគ្រោះថ្នាក់ដល់ស្ត្រីមានគភ៌ក៏ត្រូវផ្តល់ផងដែរ ។ ច្បាប់ដែលមានលក្ខណៈការពារក៏ត្រូវពិនិត្យមើលឡើងវិញ ជាទៀងទាត់ផងដែរ ។

(ច) ការថែទាំសុខភាព: មាត្រា ១២ ចែងថា រដ្ឋភាគីត្រូវតែធានាអោយមានលទ្ធភាពស្មើភាពក្នុងការទទួលបានសេវាថែទាំសុខភាព ទាំងសម្រាប់បុរស និងស្ត្រី។ រដ្ឋភាគី ត្រូវតែផ្តល់អោយស្ត្រីនូវសេវាសមស្របទាក់ទងនឹងការមានគភ៌ និងអាហារូបត្ថម្ភគ្រប់គ្រាន់ក្នុងអំឡុងពេលមានគភ៌ និងការបំបៅដោះកូន។

(ឆ) ជីវភាពផ្នែកសេដ្ឋកិច្ច និងសង្គម: មាត្រា ១៣ តម្រូវអោយមានសមភាពនៅក្នុងគ្រប់ផ្នែកទាំងអស់នៃជីវភាពផ្នែកសេដ្ឋកិច្ចនិងសង្គម រួមទាំងសិទ្ធិស្មើគ្នាក្នុងការទទួលបានអត្ថប្រយោជន៏ពីគ្រួសារ និងកម្ចី និងឥណទាន ។វាក៏តម្រូវអោយមានសិទ្ធិក្នុងការចូលរួមនៅក្នុងសកម្មភាពលំហែកីឡា និងវប្បធម៌ផងដែរ ។

(ជ) ស្ត្រីជនបទ: មាត្រា ១៤ គូសបញ្ជាក់អំពីតម្រូវការក្នុងការធានាអោយមានការអនុវត្ត CEDAW ចំពោះស្ត្រីជនបទ ។ វាតម្រូវអោយរដ្ឋភាគីធានានូវសិទ្ធិរបស់ស្ត្រីជនបទ ក្នុងការចូលរួមនៅក្នុង និងទទួលអត្ថប្រយោជន៏ពីការអភិវឌ្ឍជនបទ។ ប្រការនេះរួមបញ្ចូលទាំងការចូលរួមនៅក្នុងការធ្វើសេចក្តីលម្អិត និងការអនុវត្តការធ្វើផែនការអភិវឌ្ឍក៏ដូចជានៅក្នុងសកម្មភាពសហគមន៏។ វាក៏មានន័យថា ជាលទ្ធភាពទទួលបានការថែទាំសុខភាពគ្រប់គ្រាន់ ការអប់រំ ឥណទាន និង កម្ចីកសិកម្ម បរិក្ខារម៉ាកឃីតធីង និងបច្ចេកវិទ្យា។ មាត្រា ១៤ តម្រូវអោយមានការប្រព្រឹត្តដោយស្មើភាពនៅក្នុងគម្រោងកែទម្រង់ដីធ្លី និងកសិកម្ម និងគម្រោងតាំងទីលំនៅឡើងវិញ។ ស្ត្រីជនបទត្រូវតែទទួល បាននូវល័ក្ខខ័ណ្ឌរស់នៅសមស្រប ។

(ឈ) សមភាពចំពោះមុខច្បាប់ : មាត្រា ១៥ ធានានូវសមភាពចំពោះមុខច្បាប់។ ស្ត្រីមានសមត្ថភាពផ្លូវច្បាប់ដូចគ្នានឹងបុរសដែរ។ ពួកគេមានសិទ្ធិដូចគ្នាក្នុងការចុះកិច្ចសន្យា គ្រប់គ្រងទ្រព្យសម្បត្តិ សេរីភាពនៃការដើរហើរ និងជ្រើសរើសកន្លែងរស់នៅ និងលំនៅដ្ឋាន។ ពួកគេត្រូវទទួលបានការប្រព្រឹត្តដោយស្មើភាពនៅក្នុងតុលាការ និងសាលាក្តី។ កិច្ចសន្យាដែលរឹតត្បិតសមត្ថភាពផ្លូវច្បាប់របស់ស្ត្រីត្រូវចាត់ទុកជាមោឃៈ។

(ញ) ជីវិតអាពាហ៍ពិពាហ៍ និងគ្រួសារ: មាត្រា ១៦ តម្រូវអោយរដ្ឋភាគីធានានូវសមភាពនៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ក្នុងគ្រួសារ ។ វាធានានូវសិទ្ធិស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ ជ្រើសរើសភរិយា/ស្វាមីដោយសេរី និងធ្វើឡើងដោយស្ម័គ្រចិត្តទាំងស្រុង។ មាត្រានេះហាមឃាត់អាពាហ៍ពិពាហ៍ និងការភ្ជាប់ពាក្យកុមារ។ ស្ត្រី និងបុរសមានសិទ្ធិ និងទំនួល

ខុសត្រូវដូចគ្នាក្នុងអំឡុងអាពាហ៍ពិពាហ៍ និងការរំលាយអាពាហ៍ពិពាហ៍ ។ ពួកគេមានសិទ្ធិដូចគ្នាក្នុងនាមជា ឪពុកម្តាយ ។ ពួកគេក៏មានសិទ្ធិដូចគ្នាផងដែរចំពោះភាពជាអាណាព្យាបាល ភាពស្ថិតក្រោមអាណាព្យាបាល អាណត្តិព្យាបាលភាព និងការសុំកូន ។

ស្ត្រី និងបុរសមានសិទ្ធិដូចគ្នាក្នុងការសម្រេចអំពីចំនួនកូន និងការពន្យារកំណើតកូន ។ ស្វាមី/ភរិយាមានសិទ្ធិដូចគ្នាក្នុងការជ្រើសរើសនាមត្រកូល វិជ្ជាជីវៈ ឬមុខរបរ ។ ពួកគេមានសិទ្ធិដូចគ្នាទាក់ទងទៅនឹងកម្មសិទ្ធិ ការទិញ ការចាត់ចែង ការគ្រប់គ្រង ការអាស្រ័យផល និងការលក់ទ្រព្យសម្បត្តិ ។

### គណៈកម្មាធិការ CEDAW មុខងារ និងនីតិវិធីនៃគណៈកម្មាធិការនេះ (មាត្រា ១៧-២២)

ការអនុវត្ត CEDAW ត្រូវបានពិនិត្យតាមដានដោយគណៈកម្មាធិការទទួលបន្ទុកលុបបំបាត់ការរើសអើងលើស្ត្រី (គណៈកម្មាធិការ CEDAW) ។ គណៈកម្មាធិការនេះមានសមាសភាពជាអ្នកជំនាញចំនួន ២៣ រូប មកពីតំបន់ផ្សេងៗដែលត្រូវបានតែងតាំងដោយរដ្ឋាភិបាលនីមួយៗ និងបោះឆ្នោតជ្រើសរើសដោយរដ្ឋភាគីសម្រាប់រយៈពេល ៤ ឆ្នាំ ។ អ្នកជំនាញទាំង នេះបម្រើការងារដោយឯករាជ្យ និងក្នុងឋានៈផ្ទាល់ខ្លួនរបស់ពួកគេ ។ គណៈកម្មាធិការនេះ :

- តម្រូវអោយ រដ្ឋភាគីដាក់ជូននូវរបាយការណ៍
- ចូលរួមនៅក្នុងកិច្ចពិភាក្សាស្ថានាជាមួយរដ្ឋភាគី
- ចេញការអង្កេតសន្និដ្ឋាន និង
- ធ្វើសេចក្តីព្រាងអនុសាសន៍ទូទៅ

(ក) ដំណើរការរាយការណ៍: រដ្ឋភាគីនៃ CEDAW ត្រូវបានតម្រូវអោយដាក់របាយការណ៍បឋមក្នុងរយៈពេលមួយឆ្នាំក្រោយពីការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក និងរបាយការណ៍ទៀងទាត់រៀងរាល់បួនឆ្នាំម្តងបន្ទាប់ពីនេះ ។ ក្នុងការវាយតម្លៃរបាយការណ៍របស់រដ្ឋ ព័ត៌មាននានាដូចជា របាយការណ៍ពីអង្គការមិនមែនរដ្ឋាភិបាល (ត្រូវបានហៅថារបាយការណ៍ស្រមោល ឬរបាយការណ៍ជំនួសផងដែរ) ទីភ្នាក់ងារជំនាញ និងគណៈកម្មការសិទ្ធិមនុស្សជាតិឯករាជ្យ ត្រូវបានស្វាគមន៍ដោយគណៈកម្មាធិការ ។

(ខ) កិច្ចពិភាក្សាជាមួយរដ្ឋភាគី: ក្រោយពីការដាក់របាយការណ៍របស់ខ្លួន គណៈប្រតិភូនៃរដ្ឋភាគីត្រូវបានអញ្ជើញអោយចូលរួមនៅក្នុងកិច្ចពិភាក្សាស្ថាបនាជាមួយគណៈកម្មាធិការ CEDAW ដើម្បីដាក់ជូនរបាយការណ៍ ពិភាក្សាអំពីខ្លឹមសារនៃរបាយការណ៍ ផ្លាស់ប្តូរទស្សនៈអំពីបញ្ហាប្រឈមចំពោះការអនុវត្ត និងផ្តល់អនុសាសន៍ ។

(គ) ការអង្កេតសន្និដ្ឋាន: ការអង្កេតសន្និដ្ឋាន គឺជាមតិយោបល់ និងអនុសាសន៍ដែលចេញដោយគណៈកម្មាធិការ CEDAW ក្រោយពីការពិចារណារបស់ខ្លួនទៅលើរបាយការណ៍របស់រដ្ឋភាគី និងកិច្ចពិភាក្សាស្ថាបនាជាមួយគណៈប្រតិភូរបស់រដ្ឋភាគី ។ ការអង្កេតទាំងនេះត្រូវបានចេញជាក់លាក់ចំពោះប្រទេសនីមួយៗ ។ មុនពាក់កណ្តាលឆ្នាំ ២០០៨ ការអង្កេត

សន្និដ្ឋានត្រូវបានហៅថា មតិយោបល់សន្និដ្ឋាន។

(ឃ) អនុសាសន៍ទូទៅៈ អនុសាសន៍ទូទៅ គឺជាការបកស្រាយគួរអោយទុកចិត្តបាន ដែលចេញដោយគណៈកម្មាធិការ CEDAW អំពីមាត្រាជាក់លាក់នានានៃសន្ធិសញ្ញា ឬបញ្ហាបណ្តោះអាសន្ន ឬបញ្ហាដែលកំពុងកើតមានឡើង។

### រដ្ឋបាល ការបកស្រាយ និងបញ្ហាដទៃទៀត (មាត្រា ២៣-៣០)

មាត្រាចុងក្រោយនៃ CEDAW ចែងអំពីបញ្ហានានាទាក់ទងទៅនឹងរដ្ឋបាល និងការបកស្រាយរួមទាំងៈ

(ក) បទដ្ឋានអប្បបរមាៈ CEDAW ចែងនៅក្នុងមាត្រា ២៣ ថា អនុសញ្ញានេះមិនប៉ះពាល់ដល់ច្បាប់របស់រដ្ឋភាគីណាមួយ ឬសន្ធិសញ្ញាណាមួយដែលកំពុងមានឥទ្ធិពលនៅក្នុងរដ្ឋណាមួយដែលមានលក្ខណៈអនុគ្រោះជាងចំពោះការសម្រេចបានសមភាព។ ប្រការនេះសង្កត់ធ្ងន់ថា CEDAW ចែងអំពីបទដ្ឋានអប្បបរមានៃសមភាពយេនឌ័រ។

(ខ) ខ បម្រុងៈ មាត្រា ២៨ ចែងថា ខ បម្រុងទាំងឡាយណាដែលមិនសមស្របតាមកម្មវត្ថុ និងគោលបំណងរបស់ CEDAW នឹងមិនត្រូវបានអនុញ្ញាតឡើយ។ ខបម្រុងគឺជាសេចក្តីថ្លែងការណ៍របស់រដ្ឋភាគីដែលកំហិតឥទ្ធិពលផ្នែកច្បាប់ ឬការអនុវត្តសន្ធិសញ្ញានៅក្នុងរដ្ឋដែលធ្វើ

> **គណៈកម្មាធិការ CEDAW និងអនុសាសន៍ទូទៅ**
>
> បច្ចុប្បន្នគណៈកម្មាធិការ CEDAW បានចេញអនុសាសន៍ទូទៅចំនួន ២៦ :
>
> ១. ការរាយការណ៍ដោយ រដ្ឋភាគី (១៩៨៦)
> ២. ការរាយការណ៍ដោយ រដ្ឋភាគី (១៩៨៧)
> ៣. យុទ្ធនាការអប់រំ និងយុទ្ធនាការព័ត៌មានសាធារណៈ (១៩៨៧)
> ៤. ខ បម្រុង (១៩៨៧)
> ៥. វិធានការពិសេសបណ្តោះអាសន្ន (១៩៨៨)
> ៦. ក្បាលម៉ាស៊ីនជាតិដ៏មានប្រសិទ្ធភាព និងការផ្សព្វផ្សាយជាសាធារណៈ (១៩៨៨)
> ៧. ធនធាន (១៩៨៨)
> ៨. ការអនុវត្តមាត្រា ៨ នៃអនុសញ្ញា (១៩៨៨)
> ៩. ទិន្នន័យជាស្ថិតិទាក់ទងទៅនឹងស្ថានភាពស្ត្រី (១៩៨៩)
> ១០. ពិធីរំលឹកខួបលើកទី ១០ នៃការអនុម័ត ជខៀ (១៩៨៩)
> ១១. សេវាប្រឹក្សាយោបល់ផ្នែកបច្ចេកទេសសម្រាប់កាតព្វកិច្ចរាយការណ៍ (១៩៨៩)
> ១២. អំពើហិង្សាលើស្ត្រី (១៩៨៩)
> ១៣. ប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារដែលមានតម្លៃស្មើគ្នា (១៩៨៩)
> ១៤. ការកាត់ចុងប្រដាប់ភេទស្ត្រី (១៩៩០)
> ១៥. ជំងឺអេដស៍ (១៩៩០)
> ១៦. កម្មករស្ត្រីមានប្រាក់ឈ្នួលនៅក្នុងសហគ្រាសគ្រួសារជនបទនិងទីក្រុង (១៩៩១)
> ១៧. សកម្មភាពក្នុងផ្ទះដែលគ្មានប្រាក់ឈ្នួលរបស់ស្ត្រី (១៩៩១)
> ១៨. ស្ត្រីពិការ (១៩៩១)
> ១៩. អំពើហិង្សាលើស្ត្រី (១៩៩២)
> ២០. ខ បម្រុង (១៩៩២)
> ២១. សមភាពនៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ និងគ្រួសារ (១៩៩៤)

ខ បម្រុងនោះ ។

(គ) មជ្ឈត្តការៈ មាត្រា ២៩ ចែងថា វិវាទណាមួយដែលកើតឡើងរវាងរដ្ឋភាគីអំពីការបកស្រាយឬការអនុវត្តសន្ធិសញ្ញា អាចត្រូវបានដាក់ជូនតុលាការយុត្តិធម៌អន្តរជាតិ សម្រាប់ការធ្វើមជ្ឈត្តការ ។

២២. ការធ្វើវិសោធនកម្មមាត្រា ២០ (កិច្ចប្រជុំនៃគណៈកម្មាធិការ CEDAW) (១៩៩៥)
២៣. ជីវភាពនយោបាយ និងជីវភាពសាធារណៈ (១៩៩៧)
២៤. ស្ត្រី និងសុខភាព (១៩៩៩)
២៥. វិធានការពិសេសបណ្តោះអាសន្ន (២០០៤)
២៦. កម្មករស្ត្រីចំណាកស្រុក (២០០៨)

សម្រាប់អត្ថបទទាំងស្រុងនៃអនុសាសន៍ទូទៅ :
http://www2.ohchr.org/english/bodies/CEDAW/comments.htm

## បញ្ជីផ្ទៀងផ្ទាត់

### ការបង្កើនការយល់ដឹងរបស់អ្នកអំពី ជមៀ

- ✓ យល់ដឹងអំពីឯកសារ CEDAW ។ អានអត្ថបទនៃ CEDAW អនុសាសន៍ទូទៅ និងការអង្កេតសន្និដ្ឋាននៃ CEDAW សម្រាប់ប្រទេសរបស់អ្នកផ្ទាល់ ។
- ✓ ស្គាល់មនុស្ស និងអង្គការដែលធ្វើការជាមួយ CEDAW ។ ប្រការនេះអាចរួមបញ្ចូលមនុស្ស ទាំងឡាយដែលបានទទួលការបណ្តុះបណ្តាលអំពី CEDAW ចូលរួមនៅក្នុងដំណើរការរាយការណ៍របស់ CEDAW ឬពិនិត្យតាមដានការអនុវត្ត CEDAW ។ លើកទឹកចិត្តអោយពួកគេចែក រំលែកចំណេះដឹងរបស់ខ្លួន និងរៀនសូត្រពីបទពិសោធន៍របស់ខ្លួន ។
- ✓ ស្វែងរកធនធានអំពីCEDAW ជាពិសេស បទពិសោធន៍ទាក់ទងនឹងរបៀបដែលCEDAW ត្រូវបានចេញដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅក្នុងប្រទេសរបស់អ្នក និងនៅបរទេស ។ អានឯកសារទាំងនេះអោយបានចប់ ។ (សូមមើលឧបសម្ព័ន្ធទី សម្រាប់ឯកសារធនធានដែលត្រូវបានណែនាំ) ។
- ✓ ចូលរួមនៅក្នុងវគ្គ CEDAW ឬកម្មវិធីបណ្តុះបណ្តាលដើម្បីទទួលបានការយល់ដឹងស៊ីជម្រៅអំពី CEDAW លក្ខណៈពិសេសគោលការណ៍ និងការអនុវត្តក្នុងស្រុករបស់ CEDAW ។
- ✓ ស្នើសុំការដាក់បញ្ចូល CEDAW នៅក្នុងសិក្ខាសាលា ឬកម្មវិធីបណ្តុះបណ្តាលអំពីសិទ្ធិមនុស្សរបស់ស្ត្រី សមភាពយេនឌ័រសិទ្ធិមនុស្ស និងបញ្ហាផ្សេងៗទៀតដែលទាក់ទងនឹងស្ត្រី ដូចជាសុខភាព លំនៅដ្ឋាន ឬការអប់រំ ។
- ✓ កំណត់សកម្មភាព ឬការងារដទៃទៀតដែលទាក់ទងនឹង CEDAW នៅក្នុងប្រទេសរបស់អ្នក ។ ចូលរួមនៅក្នុងសកម្មភាព ឬការងារទាំងនេះ ។
- ✓ ពិគ្រោះយោបល់ជាមួយអ្នកជំនាញ CEDAW ថ្នាក់ជាតិ ឬអន្តរជាតិ ។

## ស្ថានភាពជាក់ស្តែងរបស់ស្ត្រី និងសមភាពយេនឌ័រ

CEDAW តម្រូវអោយរដ្ឋភាគីអនុម័តច្បាប់នានា ដើម្បីធានាអោយមានការសម្រេចបានជាក់ស្តែងនូវគោលការណ៍ស្តីពីសមធម៌ ។ដូច្នេះការយល់ដឹងអំពីស្ថានភាពជាក់ស្តែងរបស់ស្ត្រីនិងសមភាពយេនឌ័រគឺជាកត្តាចាំបាច់សម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ។ នេះមានន័យថា ការដឹងនូវចំណុចដូចខាងក្រោម :

(ក) ទម្រង់ និងការស្តែងចេញនៃការរើសអើង: ការរើសអើងអាចត្រូវបានស្តែងឡើង និងជួបប្រទះតាមរបៀបជាច្រើន ។ វាអាចទាក់ទងទៅនឹងភាពខុសគ្នាគុណវិបត្តិ ការរឹតត្បិត ការផាត់ចេញ ការកេងប្រវ័ញ្ច និងសូម្បីតែអំពើហិង្សាលើស្ត្រី ។ វាអាចស្តែងឡើងដោយខ្លួនឯងនៅក្នុងការខកខានក្នុងការទទួលស្គាល់ប្រើប្រាស់ទាមទារ ឬទ្រទ្រង់សិទ្ធិ ។

(ខ) តើអ្នកណាកំពុងត្រូវបានរើសអើង? ប្រការនេះទាក់ទងនឹងការកំណត់ជនរងគ្រោះដោយសារការរើសអើង ។ ដើម្បីធ្វើដូច្នេះ វាមិនគ្រប់គ្រាន់ទេក្នុងការគ្រាន់តែកំណត់ស្ត្រីថាជាក្រុមដែលកំពុងទទួលការរើសអើង ។ ជាការសំខាន់ដែលត្រូវកំណត់កត្តាដទៃទៀត និងអត្តសញ្ញាណដែលរួមចំណែក ឬធ្វើអោយធ្ងន់ធ្ងរដល់បទពិសោធន៍នៃការរើសអើង ។ គេត្រូវតែយកចិត្តទុកដាក់ជាពិសេសជានិច្ចកាលទៅលើថា តើក្រុមស្ត្រីងាយរងគ្រោះទទួលរងផលប៉ះពាល់ជាពិសេសដោយច្បាប់ គោលនយោបាយកម្មវិធី និងទម្លាប់អនុវត្តន៍ដែលមានលក្ខណៈរើសអើងដែរឬយ៉ាងណា ។

(គ) ផលប៉ះពាល់នៃការរើសអើង: ប្រការនេះតម្រូវអោយមានការកំណត់សិទ្ធិទាំងឡាយដែលត្រូវបានរំលោភបំពាន និងផលប៉ះពាល់នៃការរំលោភបំពាននេះ ។ វាក៏មានន័យថា ជាការដឹងអំពីផលប៉ះពាល់នៃការរើសអើងនៅទូទាំងវិស័យផ្សេងៗ (ឧទាហរណ៍ ស្ត្រីដែលត្រូវបានដកហូតសិទ្ធិទទួលមតកមិនត្រឹមតែត្រូវបានរើសអើងនៅក្នុងវិស័យទ្រព្យសម្បត្តិប៉ុណ្ណោះទេ ប៉ុន្តែវាអាចនាំអោយមានការលំបាកនានាក្នុងការទទួលបានឥណទាន ការចាប់ផ្តើមអាជីវកម្ម ការចូលរួមនៅក្នុងជីវភាពនយោបាយ ឬការបន្តការសិក្សានៅឧត្តមសិក្សាទៀតផង) ព្រមទាំងស្ថាប័ន (ស្ត្រីដែលត្រូវបានរើសអើងនៅក្នុងគ្រួសារក៏ត្រូវបានរើសអើងផ្អែកលើមូលដ្ឋាននៃរចនាសម្ព័ន្ធសង្គមដូចគ្នានេះដែរនៅក្នុងកន្លែងធ្វើការ និងសហគមន៍) ។

(ឃ) មូលហេតុ និងកត្តារួមចំណែក: ទាំងនេះគឺជាកត្តានានាដែលបង្ក ឬរួមចំណែកអោយមានការរើសអើងលើស្ត្រី ។ ក្នុងករណីជាច្រើនកត្តានានាត្រូវបានកំណត់យ៉ាងទូលំទូលាយ ដូចជាភាពក្រីក្រ ភាពគ្មានការងារធ្វើ ឬសកលភាវូបនីយកម្ម ។ នៅពេលណាដែលអាចធ្វើទៅបាន កត្តាទាំងនេះត្រូវតែមានភាពជាក់លាក់បំផុត ដើម្បីអនុញ្ញាតអោយមានការវិភាគកាន់តែប្រសើរ ។

(ង) អន្តរាគមន៍របស់រដ្ឋភាគី: អន្តរាគមន៍ទាំងនេះរួមមានច្បាប់គោលនយោបាយកម្មវិធីសេវាកម្មនិងសកម្មភាពរបស់រដ្ឋភាគី និងប្រសិទ្ធិភាពនៃអន្តរាគមន៍ទាំងនេះ ។

(ច) អន្តរាគមន៍របស់ភាគីមិនមែនរដ្ឋ: ទាំងនេះសំដៅដល់អន្តរាគមន៍ដោយតួអង្គមិនមែនរដ្ឋ និងប្រសិទ្ធិភាពនៃអន្តរាគមន៍ទាំងនេះ ។

## ច្បាប់ និងការតាក់តែងច្បាប់

### និយមន័យអំពីច្បាប់

ច្បាប់ត្រូវបានផ្តល់និយមន័យថា ជាសំណុំនៃវិធាន ដែលមានលក្ខណៈជាកាតព្វកិច្ច ដែលអនុម័តដោយអាជ្ញាធរស្របច្បាប់ សម្រាប់ការអនុវត្ត និងអត្ថប្រយោជន៍រួម។[៨] ក្នុងន័យទូទៅ ច្បាប់អាចសំដៅដល់ :

- រដ្ឋធម្មនុញ្ញ
- ឯកសារអនុម័តរបស់អង្គនីតិបញ្ញត្តិជាតិ (សភា រដ្ឋសភា ឬសមាជ) និងអង្គនីតិបញ្ញត្តិក្នុងស្រុក។
- អត្ថបទដែលចេញដោយអង្គនីតិប្រតិបត្តិ (រួមទាំង ប្រធានាធិបតី នាយករដ្ឋមន្ត្រី និងមន្ត្រី និង
- សេចក្តីសម្រេចរបស់តុលាការ)។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងយុត្តាធិការជាច្រើនពាក្យ "ច្បាប់" សំដៅទាំងស្រុងដល់នីតិកម្មដែលជាអត្ថបទចេញដោយអង្គនីតិបញ្ញត្តិជាតិ ។ ច្បាប់ក៏អាចត្រូវបានហៅថាលក្ខន្តិកៈ ក្រមច្បាប់ ឬក្រឹត្យច្បាប់ផងដែរ។

ប្រទេសនីមួយកំណត់អ្វីដែលខ្លួនគិតថាជាច្បាប់។ ឧទាហរណ៍នៅក្នុងប្រទេសវៀតណាម ច្បាប់ ឬ "ឯកសារច្បាប់" ត្រូវបានផ្តល់និយមន័យនៅក្នុងមាត្រា ១ នៃច្បាប់ស្តីពីឯកសារច្បាប់ និងគ្រប់ដណ្តប់ :

(ក) ឯកសារដែលប្រកាសអោយប្រើដោយរដ្ឋសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍របស់ខ្លួន។

(ខ) រដ្ឋធម្មនុញ្ញ ច្បាប់ និងសេចក្តីសម្រេចរបស់រដ្ឋសភា និងបទបញ្ជា និងសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។

(គ) ឯកសារដែលចេញដោយទីភ្នាក់ងាររដ្ឋមានសមត្ថកិច្ចដទៃទៀតនៅក្នុងថ្នាក់កណ្តាល ដូចជាបទបញ្ជា និងសេចក្តីសម្រេចរបស់ប្រធានាធិបតីរបស់រដ្ឋសេចក្តីសម្រេច និងសេចក្តីបង្គាប់របស់នាយករដ្ឋមន្ត្រី សេចក្តីសម្រេច និងក្រឹត្យរបស់រដ្ឋាភិបាល សេចក្តីសម្រេច សេចក្តីបង្គាប់ និងសារាចរណែនាំរបស់រដ្ឋមន្ត្រី និងប្រធានទីភ្នាក់ងារ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាយុត្តិធម៌នៃតុលាការជាន់ខ្ពស់របស់ប្រជាជននិងសេចក្តីសម្រេចសេចក្តីបង្គាប់និងសារាចរណែនាំរបស់ប្រធានការិយាល័យជាន់ខ្ពស់របស់ប្រជាជន។

(ឃ) ឯកសារដែលប្រកាសអោយប្រើដោយក្រុមប្រឹក្សាប្រជាជន និងគណៈកម្មាធិការប្រជាជនៈ ដូចជាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជាជន និងសេចក្តីសម្រេច និងសេចក្តីបង្គាប់របស់គណៈកម្មាធិការប្រជាជន។

### ឋានានុក្រមនៃច្បាប់

យុត្តាធិការមួយចំនួនមានវិធានជាក់លាក់គ្រប់គ្រងលើឋានានុក្រមនៃច្បាប់ ចំណែកឯយុត្តាធិការដទៃទៀតពុំមានវិធានគ្រប់គ្រងឋានានុក្រមនៃច្បាប់ឡើយ។ ប៉ុន្តែ នៅក្នុងករណីទាំងពីរ យុត្តាធិការទាំងនេះ ជាទូទៅអនុវត្តតាមគោលការណ៍ច្បាប់ដែលកំណត់នូវឋានានុក្រមដូចខាងក្រោមទាក់ទងនឹងច្បាប់ :

[៨] Rufus Rodriguez ការណែនាំអំពីច្បាប់ ក្រុងម៉ានិល បណ្ណាគារ ជ្រេ ឆ្នាំ២០០១ ទំព័រទី ២

(ក) រដ្ឋធម្មនុញ្ញ គឺជាច្បាប់ខ្ពស់បំផុត ឬច្បាប់កំពូលរបស់ប្រទេស ។ រដ្ឋធម្មនុញ្ញចែងអំពីក្របខ័ណ្ឌទូទៅនៃរចនាសម្ព័ន្ធចាត់តាំងរបស់រដ្ឋអំណាច និងមុខងាររបស់រដ្ឋ ហើយក្នុងករណីភាគច្រើនចែងអំពីសិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋខ្លួន ។ ពុំមានច្បាប់ណាមួយនៅក្នុងប្រទេសអាចប្រឆាំងរដ្ឋធម្មនុញ្ញបានឡើយ ។និយាយម្យ៉ាងទៀត វាគឺជាបទដ្ឋានដែលតាមរយៈនេះច្បាប់ដទៃទៀតត្រូវបានវាស់វែង ។

(ខ) ច្បាប់ (ពោលគឺច្បាប់ដែលអនុម័តដោយអង្គនីតិបញ្ញត្តិជាតិ) ដែលរៀបរាប់នៅក្នុងរដ្ឋធម្មនុញ្ញ ។[៨] នៅគ្រប់ពេលទាំងអស់ច្បាប់ត្រូវតែអនុលោមតាមរដ្ឋធម្មនុញ្ញ បើមិនដូច្នោះទេច្បាប់អាចត្រូវបានប្រកាសថា ពុំមានធម្មនុញ្ញភាព ។

(គ) អត្ថបទដែលចេញដោយផ្នែកនីតិប្រតិបត្តិ ទោះជាត្រូវបានហៅថា វិធាន បទបញ្ជា ឬក្រឹត្យផ្នែករដ្ឋបាល ក្រសួង ឬនាយកដ្ឋានក្តី ចែងលម្អិតអំពីច្បាប់ ។ អត្ថបទទាំងនេះត្រូវតែអនុលោមតាមរដ្ឋធម្មនុញ្ញ និងច្បាប់គ្រប់ពេលវេលា ។

(ឃ) ឯកសារដែលអនុម័តដោយអង្គនីតីបញ្ញត្តិក្នុងស្រុកពេលខ្លះត្រូវបានហៅថាបទបញ្ជាចែងលម្អិតបន្ថែមអំពីការអនុវត្តច្បាប់នៅក្នុងដែនដីកំណត់នៃឯកសារទាំងនេះ ។ ឯកសារទាំងនេះត្រូវបានអនុម័តនៅក្នុងព្រំដែននៃអំណាច និងសិទ្ធិដែលផ្តល់អោយឯកសារទាំងនេះដោយរដ្ឋធម្មនុញ្ញ ឬច្បាប់ ។ ដូច្នេះហើយ ឯកសារទាំងនេះត្រូវអនុលោមតាម បទដ្ឋានដែលកំណត់ដោយរដ្ឋធម្មនុញ្ញ និងច្បាប់ ។

(ង) នៅក្នុងប្រទេសខ្លះ សេចក្តីសម្រេចរបស់តុលាការត្រូវបានចាត់ទុកថា ជាផ្នែកមួយនៃច្បាប់របស់ប្រទេស ។ ដោយសារសេចក្តីសម្រេចនេះត្រូវបានបកស្រាយថាជាច្បាប់ វាត្រូវបានអានរួមជាមួយនឹងបញ្ញត្តិច្បាប់ដែលបកស្រាយវា ។

(ច) សន្ធិសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិ ដែលធ្វើឡើងជាលាយលក្ខណ៍អក្សររវាង ឬក្នុងចំណោមរដ្ឋនានាមានទំនាក់ទំនងខុសៗគ្នាចំពោះច្បាប់ជាតិ ។ ការដាក់សន្ធិសញ្ញាទាំងនេះនៅក្នុងឋានានុក្រមនៃច្បាប់ជាតិប្រែប្រួលពីមានឧត្តមភាពជាងរដ្ឋធម្មនុញ្ញ មានឧត្តមភាពជាងច្បាប់ ឬស្មើនឹងច្បាប់ ។ ក្នុងករណីភាគច្រើន សន្ធិសញ្ញាមិនត្រូវបានអនុវត្តភ្លាមៗ ឡើងលុះត្រាតែត្រូវបានបកប្រែ ឬដាក់បញ្ចូលនៅក្នុងច្បាប់ ។ ដូច្នេះ ឋានៈនៃសន្ធិសញ្ញានៅក្នុងឋានានុក្រមននៃច្បាប់ គ្រាន់តែជាទ្រឹស្តីប៉ុណ្ណោះ ប្រសិនបើសន្ធិសញ្ញាទាំងនេះមិនអាចត្រូវបានប្រើប្រាស់ និងដាក់អោយអនុវត្តដោយផ្ទាល់ទេ ។ នៅពេលដែលសន្ធិសញ្ញាត្រូវបានដាក់បញ្ចូល វាត្រូវបានចាត់ទុកថាជាច្បាប់ ដូច្នេះហើយត្រូវបានដាក់អោយអនុវត្ត ។

## រចនាសម្ព័ន្ធ និងខ្លឹមសារនៃច្បាប់

ជាទូទៅ ច្បាប់អាចមានផ្នែកដូចខាងក្រោម :

(ក) ចំណងជើង : ចំណងជើងបង្ហាញអំពីអាជ្ញាធរអនុម័តច្បាប់ និងសម័យប្រជុំដែលច្បាប់ត្រូវបានអនុម័ត ។

(ខ) លេខច្បាប់ : នេះគឺជាលេខដែលកំណត់អោយច្បាប់ដោយអាជ្ញាធរអនុម័តច្បាប់ ។

(គ) ឈ្មោះ : ឈ្មោះបង្ហាញអំពីប្រធានបទនៃច្បាប់ ។

---

[៨] Rufus Rodriguez ការណែនាំអំពីច្បាប់ ក្រុងម៉ានិល បណ្ណាគារ ជ្រខ ឆ្នាំ២០០១ ទំព័រទី ២

(ឃ) កំណត់ពន្យល់ ឬបុព្វកថា : វាពិភាក្សាអំពីសនិទានភាពនៃច្បាប់ និងកម្មវត្ថុនៃច្បាប់ ។

(ង) អនុប្រយោគអំពីការអនុម័ត : វាចែងអំពីការអនុម័តច្បាប់ និងកំណត់ថាតើច្បាប់ត្រូវបានអនុម័តដោយអាជ្ញាធរណាមួយ ។

(ច) តួសេចក្តី : នេះគឺជាផ្នែកចម្បងនៃច្បាប់ ដែលមានបញ្ញត្តិជាចាំបាច់ បញ្ញត្តិនីតិវិធី និងបញ្ញត្តិដទៃទៀត ។

(ឆ) អនុប្រយោគអំពីការលុបចោល : ផ្នែកនេះនៃច្បាប់បង្ហាញថាតើច្បាប់ដែលមានស្រាប់ណាខ្លះនឹងត្រូវលុបចោល ។

(ជ) អនុប្រយោគអំពីធរមានភាព : វាប្រកាសអំពីកាលបរិច្ឆេទចូលជាធរមាននៃច្បាប់ ។

អ្វីដែលអាចជាប្រធានបទដែលមានសុពលភាពនៃច្បាប់ អាចប្រែប្រួលពីប្រទេសមួយទៅប្រទេសមួយទៀត ។ ប៉ុន្តែលើកលែងតែត្រូវបានកំហិតដោយរដ្ឋធម្មនុញ្ញ ឬច្បាប់ខ្ពស់ជាងនេះ ច្បាប់អាចមានប្រធានបទណាមួយក៏បាន ។ច្បាប់អាចចែងអំពីសេចក្តីប្រកាសនៃគោលនយោបាយរបស់រដ្ឋ ។ ច្បាប់អាចធានានូវសិទ្ធិជាចាំបាច់ ។ ច្បាប់អាចបង្កើតនីតិវិធី និងដំណើរការ ។ ច្បាប់អាចបង្កើតយន្តការ និងអង្គភាពនានា ព្រមទាំងបែងចែកទំនួលខុសត្រូវ ។ ច្បាប់អាចចែងអំពីដំណោះស្រាយសម្រាប់បណ្តឹងសាទុក្ខ ។ ច្បាប់អាចដាក់ទណ្ឌកម្ម ។

## ការអនុម័តច្បាប់

ប្រទេសផ្សេងៗគ្នាមាននីតិវិធីផ្ទាល់ខ្លួនសម្រាប់ការអនុម័តច្បាប់ ។ ដើម្បីធ្វើការពិនិត្យមើលឡើងវិញផ្នែកច្បាប់ អ្នកគួរយល់ ដឹងអំពីដំណើរការនៃរបៀបដែលច្បាប់ផ្សេងៗត្រូវបានអនុម័ត ។

### ការអនុម័តច្បាប់នៅក្នុងប្រទេសហ្វីលីពីន

នៅក្នុងប្រទេសហ្វីលីពីន ច្បាប់ដែលអនុម័តដោយអង្គនីតិបញ្ញត្តិជាតិជាធម្មតា ឆ្លងកាត់ការពិនិត្យចំនួនបីលើកនៅថ្ងៃផ្សេងៗគ្នានៅក្នុងសភាចំនួនពីរ: រដ្ឋសភា និងព្រឹទ្ធសភា ។ ការពណ៌នាត្រួសៗអំពីដំណើរការនីតិកម្មមានដូចខាងក្រោម :

**ការដាក់ជូន :** សេចក្តីព្រាងច្បាប់ត្រូវបានដាក់ជូន និងដាក់លេខដោយលេខាធិការដ្ឋាន ។ វាត្រូវបានដាក់លេខតាម ប្រតិទិនសម្រាប់ការពិនិត្យលើកដំបូង ។

**ការពិនិត្យលើកដំបូង:** នៅពេលពិនិត្យលើកដំបូងសេចក្តីព្រាងច្បាប់ត្រូវបានអានដោយលេខឈ្មោះនិងអ្នកតាក់តែងច្បាប់ ។

**ការយោងដល់គណៈកម្មាធិការសមស្រប :** ក្រោយពីការពិនិត្យលើកដំបូង សេចក្តីព្រាងច្បាប់ត្រូវបានបញ្ជូនទៅកាន់គណៈកម្មាធិការសមស្របដើម្បីពិចារណា ។ គណៈកម្មាធិការដែលត្រូវបានចាត់តាំងអាចកំណត់កាលវិភាគសម្រាប់សវនាការ និងការពិគ្រោះយោបល់ជាសាធារណៈ ។ គណៈកម្មាធិការនេះអាចជ្រើសរើសអនុម័តសេចក្តីព្រាងច្បាប់ដោយមាន ឬគ្មានវិសោធនកម្ម ជំនួសវត្ថុដែលខុសគ្នា ពង្រឹងសេចក្តីព្រាងច្បាប់នេះដោយសេចក្តីព្រាងច្បាប់ដែលស្រដៀងគ្នា ឬមិនអនុម័តសេចក្តីព្រាងច្បាប់ ។ សេចក្តីព្រាងច្បាប់ដែលអនុម័តរួចដោយគណៈកម្មាធិការត្រូវបានដាក់ជូនគណៈកម្មាធិការទទួលបន្ទុកវិន័យ ដែលនឹងកំណត់ពេលវេលាសម្រាប់ការពិនិត្យលើកទីពីរ ។

**ការពិនិត្យលើកទីពីរ :** សេចក្តីព្រាងច្បាប់ឆ្លងកាត់ការពិភាក្សាដេញដោលជាទូទៅ និងការធ្វើវិសោធនកម្ម ។

**ការបោះពុម្ព និងការចែកចាយ :** សេចក្តីព្រាងច្បាប់ដែលអនុម័តរួចត្រូវបានបោះពុម្ពក្នុងទម្រង់ចុងក្រោយរបស់វា រួចចែកជូនដល់សមាជិកទាំងអស់នៃសភាក្នុងរយៈពេលបីថ្ងៃ មុនពេលពិនិត្យមើលឡើងវិញលើកទីបី ។

**ការពិនិត្យលើកទីបី :** នៅពេលពិនិត្យលើកទីបី ការបោះឆ្នោតសម្លេងធម្មតាត្រូវបានធ្វើឡើងចំពោះសេចក្តីព្រាងច្បាប់ ។

**ការយោងដល់សភាពដទៃទៀត:** សេចក្តីព្រាងច្បាប់ដែលបានអនុញ្ញាតរួច ត្រូវបានបញ្ជូនទៅកាន់សភាពនីតិបញ្ញត្តិដទៃទៀត ដើម្បីឆ្លងកាត់ដំណើរការស្រដៀងគ្នា ។

**ការដាក់ជូនគណៈកម្មាធិការអន្តរសភា:** ក្នុងករណីដែលមានបញ្ញត្តិចម្រូងចម្រាស់ណាមួយ គណៈកម្មាធិការសន្និសីទអន្តរសភាព ដែលមានសមាជិកមកពីរដ្ឋសភា និងព្រឹទ្ធសភា ត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលភាពចម្រូងចម្រាស់នៃបញ្ញត្តិនេះ ។

**ការអនុម័ត :** សេចក្តីព្រាងច្បាប់ដែលអនុម័តរួចត្រូវបានបញ្ជូនត្រឡប់ទៅកាន់សភាទាំងពីរ ដើម្បីអនុម័ត ។

**ការដាក់ជូនប្រធានាធិបតី :** បន្ទាប់មក សេចក្តីព្រាងច្បាប់ត្រូវបានបញ្ជូនទៅកាន់ប្រធានាធិបតី ដើម្បីចុះហត្ថលេខាទៅជាច្បាប់ ។លើកលែងតែប្រធានាធិបតីអនុវត្តអំណាចវេតូរបស់ខ្លួនសេចក្តីព្រាងច្បាប់នឹងក្លាយជាច្បាប់នៅពេលចុះហត្ថលេខា ។

**ការបោះពុម្ពផ្សាយ :** ដើម្បីមានប្រសិទ្ធភាព ច្បាប់ត្រូវតែបោះពុម្ពផ្សាយនៅក្នុងសារព័ត៌មានចំនួនពីរ ដែលសារាចរជាទូទៅ ។

**ប្រភព :** រដ្ឋធម្មនុញ្ញនៃប្រទេសហ្វីលីពីន ផ្នែកទី២៦-២៧ និង De Leon, Hector សៀវភៅអានអំពីរដ្ឋធម្មនុញ្ញនៃ ប្រទេសហ្វីលីពីន (២០០៥) ទំព័រ ១៩១-១៩២

## សំណួរដែលត្រូវបានសួរជាញឹកញាប់អំពីច្បាប់ និងការតាក់តែងច្បាប់

អ្នកមិនចាំបាច់ជាអ្នកជំនាញផ្នែកច្បាប់ឡើយក្នុងការអនុវត្តការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ប៉ុន្តែ អ្នកត្រូវតែយល់ដឹងអំពីមូលដ្ឋាននៃការតាក់តែងច្បាប់នៅក្នុងប្រទេសរបស់អ្នក ។ ប្រសិនបើអ្នកមិនដឹងអំពីដំណើរការតាក់តែងច្បាប់ទេនោះ អ្នកប្រហែលជាមានសំណួរមួយចំនួនដែលមានភាពច្បាប់លាស់ចំពោះមេធាវី ប៉ុន្តែមិនសុទ្ធតែច្បាស់លាស់ចំពោះអ្នកដទៃទៀតឡើយ ។ ខាងក្រោមនេះគឺជាសំណួរដែលត្រូវបានសួរញឹកញាប់មួយចំនួនពីបុគ្គលដែលមិនមែនជាមេធាវីទាក់ទងនឹងការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ។

***សំណួរ : តើជាការពិតឬទេដែលថា ច្បាប់នាពេលអនាគតត្រូវតែអនុលោមតាមច្បាប់ដែលមានស្រាប់គ្រប់ពេល ?***

នេះមិនមែនជាការពិតទេ ។ អង្គនីតិបញ្ញត្តិមួយមិនអាចអនុម័តច្បាប់ដែលមិនអាចលុបចោល ឬធ្វើវិសោធនកម្មបានឡើយ ។ បើមិនដូច្នោះទេ វានឹងរឹតត្បិតសិទ្ធិអំណាចក្នុងការតាក់តែងច្បាប់នៃអង្គនីតិបញ្ញត្តិលើកក្រោយ ។ ដូច្នេះច្បាប់នាពេលអនាគតអាចធ្វើវិសោធនកម្ម កែសម្រួលឬលុបចោលច្បាប់ដែលមានស្រាប់ ។ វាគ្រាន់តែត្រូវអនុលោមតាមរដ្ឋធម្មនុញ្ញប៉ុណ្ណោះ ។ ប៉ុន្តែ ច្បាប់នាពេលអនាគតអាចពិចារណាច្បាប់ដែលមានស្រាប់ ដើម្បីធានាសង្គតិភាព ។

ឧទាហរណ៍ នៅក្នុងប្រទេសវៀតណាមក្រមការងារ និងច្បាប់ស្តីពីនិរភ័យសង្គមចែងអំពីអាយុចូលនិវត្តន៍មិនស្មើគ្នារវាងស្ត្រី និងបុរស ដែលតាមរយៈនេះស្ត្រីចូលនិវត្តន៍ឆាប់ជាងបុរស ៥ ឆ្នាំ ។ សេចក្តីព្រាងច្បាប់ស្តីពីសមភាពយេនឌ័រ បានស្នើឡើងនូវអាយុចូលនិវត្តន៍ស្មើគ្នាសម្រាប់ស្ត្រី និងបុរស ។ ការជំទាស់មួយក្នុងចំណោមការជំទាស់នានាដែលត្រូវបានលើកឡើង គឺថា ច្បាប់ ស្តីពីសមភាពយេនឌ័រត្រូវតែអនុលោមតាមបទដ្ឋាននៃក្រមការងារ និងច្បាប់ស្តីពីនិរភ័យសង្គម ដើម្បីធានានូវភាពស៊ីសង្វាក់គ្នានៃច្បាប់ ។ ប៉ុន្តែ នៅពេលដែលច្បាប់ស្តីពីសមភាពយេនឌ័រត្រូវបានអនុម័តរួចភ្លាម វាអាចធ្វើវិសោធនកម្ម ឬកែសម្រួលបទដ្ឋានដែលមានកំណត់នៅក្នុងច្បាប់ទាំងពីរ ។

***សំណួរ : ប្រសិនបើច្បាប់ពីរដែលមានឋានានុក្រមដូចគ្នា គ្របដណ្តប់លើប្រធានបទតែមួយ តើច្បាប់ណាមួយនឹងមានឧត្តមានុភាព ?***

សំណួរនេះត្រូវបានគ្របដណ្តប់ដោយផ្នែកមួយនៃច្បាប់ដែលគេហៅថា ការបកស្រាយ និងការបង្កើតលក្ខន្តិកៈ ។ វិធានទូទៅ ទាក់ទងនឹងច្បាប់ដែលមានភាពចម្រូងចម្រាស់ (ឬបញ្ញត្តិច្បាប់ដែលមានភាពចម្រូងចម្រាស់នៅក្នុងច្បាប់ផ្សេងៗ) ដែលពុំមានការលុបចោលច្បាស់លាស់គឺថានៅពេលណាដែលអាចធ្វើទៅបានច្បាប់ទាំងនេះត្រូវតែទទួលបានការសម្របសម្រួលជាដំបូង ដើម្បីផ្តល់សុពលភាពដល់ច្បាប់ទាំងពីរ ។ ឧទាហរណ៍ ប្រសិនបើច្បាប់មួយគ្របដណ្តប់លើប្រធានបទ ដែលមានលក្ខណៈទូទៅហើយច្បាប់មួយទៀតគ្របដណ្តប់លើប្រធានបទក្នុងលក្ខណៈជាក់លាក់ច្បាប់ទីពីរអាចដំណើរការជាលក្ខណៈលម្អិតការអធិប្បាយក្បោះក្បាយ ឬការលើកលែងចំពោះច្បាប់ទូទៅ ។

ប្រសិនបើមិនអាចធ្វើទៅបាននោះទេ ពេលនោះ មានការជួយជ្រោមជ្រែងជាច្រើន ដើម្បីសម្រេចថាតើច្បាប់ណាមួយនឹងមានឧត្តមានុភាព ។ ការជួយជ្រោមជ្រែងមួយចំនួនក្នុងចំណោមជំនួយដទៃ មានដូចខាងក្រោម :

- ច្បាប់ទីពីរមានឧត្តមានុភាពលើច្បាប់ទីមួយ ។
- ច្បាប់ពិសេសមានឧត្តមានុភាពលើច្បាប់ទូទៅ ។ [១០]
- បញ្ញត្តិពិសេសមានឧត្តមានុភាពលើបញ្ញត្តិទូទៅ (ទោះជាបញ្ញត្តិទាំងនេះត្រូវបានរកឃើញនៅក្នុងច្បាប់ទូទៅ ឬច្បាប់ពិសេសក្តី ដោយមិនគិតអំពីកាលបរិច្ឆេទនៃការអនុម័តច្បាប់ទាំងនេះឡើយ) និង
- ច្បាប់ជាចាំបាច់មិនអាចត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ផ្អែកនីតិវិធីឡើយ ។

***សំណួរ : តើអ្វីទៅគឺជាការលុបចោលយ៉ាងច្បាស់លាស់ ? តើវាតែងតែជាការចាំបាច់ជានិច្ចឬ ?***

ការលុបចោលយ៉ាងច្បាស់លាស់ គឺជាការធ្វើមោឃភាពនៃច្បាប់ដែលមានស្រាប់ពីមុន តាមរយៈការអនុម័តច្បាប់ថ្មីដែលប្រកាសអំពីការលុបចោលច្បាប់ដែលមានស្រាប់ពីមុន ។ ការលុបចោលដោយប្រយោលកើតឡើងនៅពេលដែលច្បាប់ថ្មីមានបញ្ញត្តិផ្ទុយទៅនឹង និងមិនអាចសម្របសម្រួលជាមួយច្បាប់ពីមុន ដើម្បីអោយច្បាប់តែមួយប៉ុណ្ណោះមានប្រសិទ្ធិភាព ។

---

[១០] ច្បាប់ទូទៅគឺជាច្បាប់ដែលប៉ះពាល់ដល់សហគមន៍ទាំងមូល ឬច្បាប់ដែលទាក់ទងនឹងប្រធានបទណាមួយដែលមានលក្ខណៈទូទៅ ឧទាហរណ៍ក្រុមការងារ ។ ច្បាប់ពិសេស គឺជាច្បាប់ដែលត្រូវបានរៀបចំឡើងសម្រាប់គោលបំណងជាក់ (ឧទាហរណ៍ច្បាប់ស្តីពីការបៀតបៀនផ្លូវភេទ) ឬក្រុមមនុស្សជាក់លាក់ណាមួយ ។

វិធានទូទៅ ជាធម្មតា គឺប្រឆាំងទៅនឹងការលុបចោលដោយប្រយោល ដូច្នេះ ភាពស្រពេចស្រពិលនាពេលអនាគតអាចត្រូវបានចៀសវាង ។ គេតែងតែចូលចិត្តជាងចំពោះការលុបចោលយ៉ាងច្បាស់លាស់នូវបញ្ញត្តិច្បាប់ ឬច្បាប់ ។

ឧទាហរណ៍មួយនៃការលុបចោលយ៉ាងច្បាស់លាស់អាចរកឃើញនៅក្នុមាត្រា ៥០ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទនៃប្រទេសកម្ពុជា (ឆ្នាំ២០០៨) ដែលចែងថា :

"មាត្រា ៥០ : ការលុបចោលច្បាប់ ។ ច្បាប់ស្តីពីការបង្ក្រាបការចាប់ជំរិត ការជួញដូរមនុស្ស/ការលក់ដូរមនុស្ស និងការធ្វើអាជីវកម្មលើមនុស្ស ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : ជស/រកម/០២៩៦/០១ នឹងត្រូវលុបចោលដោយច្បាប់នេះ" ។

***សំណួរ : ប្រសិនបើច្បាប់មានភាពចំណាស់ តើវានៅតែមានសុពលភាពឬទេ ?***

ច្បាប់មួយមានសុពលរហូត លុះត្រាតែវាត្រូវបានលុបចោលដោយច្បាប់មួយទៀត ឬត្រូវបានប្រកាសថាគ្មានសុពលភាពដោយ អាជ្ញាធរសមស្រប (ឧទាហរណ៍តុលាការ) ។ ដូច្នេះ ទោះបីច្បាប់មានភាពចំណាស់យ៉ាងណាក្តី វានៅតែមានសុពលភាព ។

***សំណួរ : ប្រសិនបើច្បាប់មិនកំពុងត្រូវបានដាក់អោយអនុវត្តទេនោះ តើវានៅតែជាច្បាប់ឬទេ ?***

ត្រឹមត្រូវហើយកង្វះការដាក់អោយអនុវត្តមិនធ្វើអោយអសុពលភាពដល់ច្បាប់ឡើយ ។ ដូចមានចង្អុលបង្ហាញខាងលើ ច្បាប់មានសុពលភាព ប្រសិនបើវាមិនត្រូវបានលុបចោល ឬប្រកាសថាគ្មានសុពលភាពដោយអាជ្ញាធរសមស្របទេនោះ ។

***សំណួរ : នៅក្នុងកំណែទម្រង់ច្បាប់ និងការតស៊ូមតិ តើខ្ញុំគួរផ្តោតទៅលើកំណែទម្រង់រដ្ឋធម្មនុញ្ញ កំណែទម្រង់ផ្នែកនីតិបញ្ញត្តិ កំណែទម្រង់ការអនុម័តផ្នែកនីតិប្រតិបត្តិ ឬកំណែទម្រង់បទបញ្ជា ?***

ចម្លើយដែលប្រសើរបំផុតគឺការផ្តោតទៅលើច្បាប់ដែលមានលក្ខណៈរើសអើងទាំងឡាយទោះជាវាជារដ្ឋធម្មនុញ្ញច្បាប់ការអនុម័តផ្នែកនីតិប្រតិបត្តិឬបទបញ្ជាក៏ដោយ ។ទោះជាយ៉ាងណាក៏ដោយផ្អែកលើឱកាសវាជាការសំខាន់ដែលត្រូវធ្វើផែនការ និងធ្វើសេចក្តីសម្រេចចិត្តអំពីថាតើការតស៊ូមតិណាមួយមានភាពបន្ទាន់ជាង និងទំនងជាមានប្រសិទ្ធិភាពជាងក្នុងការសម្រេចបានផលប៉ះពាល់ដែលគួរអោយចង់បាន ។

**បញ្ជីផ្ទៀងផ្ទាត់**
**ការយល់ដឹងអំពីរបៀបដែលច្បាប់ត្រូវបានតាក់តែង**

ចូរប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់នេះដើម្បីកែលម្អការយល់ដឹងរបស់អ្នកអំពីបញ្ហាប្រឈមនឹងឧបសគ្គក្នុងការអនុម័ត ឬធ្វើវិសោធនកម្មច្បាប់ ។

- ✓ ពិនិត្យមើលបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និងបញ្ញត្តិច្បាប់អំពីការអនុម័តច្បាប់ ។
- ✓ ពិគ្រោះយោបល់ជាមួយអ្នកតាក់តែងច្បាប់អំពីដំណើរការនៃការអនុម័តច្បាប់ ។

- ✓ យល់ដឹងអំពីរចនាសម្ព័ន្ធ និងខ្លឹមសារនៃច្បាប់ ។
- ✓ ចូលរួមក្នុងសម័យប្រជុំនៃអង្គនីតិបញ្ញត្តិ ឬចូលរួមនៅក្នុងសវនាការសាធារណៈ និងការពិគ្រោះយោបល់អំពីសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ។
- ✓ យល់ដឹងអំពីចំណុចអន្តរាគមន៍នៅក្នុងដំណើរការតាក់តែងច្បាប់ (ពោលគឺរបៀប និងពេលដែលអ្នកអាចធ្វើអន្តរាគមន៍នៅក្នុងដំណើរការ) ។
- ✓ ដឹងអំពីរបៀបវារៈតាក់តែងច្បាប់បច្ចុប្បន្ន (ជាធម្មតា របៀបវារៈ ឬកម្មវិធីការងារត្រូវបានព្រាងដោយអង្គនីតិបញ្ញត្តិ និងក្រសួងនានា)
- ✓ ដឹងអំពីពេលវេលាដែលច្បាប់ទាក់ទងនឹងការពិនិត្យមើលឡើងវិញផ្នែកច្បាប់របស់ អ្នកត្រូវបានអនុម័ត (ប្រសិនបើច្បាប់ពាក់ព័ន្ធទើបតែត្រូវបានអនុម័តវាមិនទំនងជាត្រូវបានចុះក្នុងបញ្ជីសម្រាប់វិសោធនកម្មឬការលុបចោលឡើយ) ។

## កំណត់សម្គាល់ :

ការធ្វើផែនការសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW

## ផ្នែកទីបី :

### ការធ្វើផែនការសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW

នៅក្នុងផ្នែកនេះ :

- ✓ កំណត់វត្ថុបំណង វិសាលភាព ដែនកំណត់ អ្នកទទួលផលគោលដៅវិធីសាស្ត្រ និងរយៈពេលនៃការពិនិត្យមើលឡើងវិញ ផ្នែកច្បាប់ផ្អែកលើ CEDAW របស់អ្នក ។
- ✓ តើអ្នកណាជាអ្នកស្ថិតក្នុងស្ថានភាពប្រសើរជាងគេដែលត្រូវអនុវត្តការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW?

នៅក្នុងដំណើរការនៃការអនុវត្តការពិនិត្យមើលឡើងវិញផ្នែកច្បាប់វាជួយដល់ការរៀបចំផែនការច្បាស់លាស់មុនពេលអ្នកចាប់ផ្តើម ចូរពិចារណាអំពីចំណុចដូចខាងក្រោមនៅពេលធ្វើផែនការពិនិត្យមើលឡើងវិញផ្នែកច្បាប់របស់អ្នក :

(ក) វត្ថុបំណង: កំណត់អំពីវត្ថុបំណងជាក់លាក់នៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់របស់អ្នក។ វត្ថុបំណងកាន់តែច្បាស់លទ្ធផលកាន់តែប្រសើរ ។ ជាការសំខាន់ដែលត្រូវដឹងថាតើអ្វីដែលអ្នកកំពុងព្យាយាមសម្រេចអោយបានជាមួយនឹងការពិនិត្យមើលឡើងវិញផ្នែកច្បាប់របស់អ្នក។ (សូមមើលផ្នែកទី ១: គោលបំណងនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW សម្រាប់វត្ថុបំណងដែលអាចមាន) ។

(ខ) វិសាលភាព (ផ្នែក ឬប្រធានបទនៃការគ្របដណ្តប់): អ្នកចាំបាច់ត្រូវតែសម្រេចថាតើការពិនិត្យមើលឡើងវិញផ្នែកច្បាប់របស់អ្នកនឹងត្រូវមានភាពទូលំទូលាយ ឬជាក់លាក់។ ការគ្របដណ្តប់ទូលំទូលាយមានន័យថា ការវាយតម្លៃទៅលើអនុលោមភាពនៅក្នុងគ្រប់វិស័យទាំងអស់ដែលប៉ះពាល់ដល់សមភាពយេនឌ័រ ទោះជាវិស័យស៊ីវិល នយោបាយ សេដ្ឋកិច្ចសង្គម ឬវប្បធម៌ក្តី ។នេះមានន័យថាការពិនិត្យមើលបញ្ញត្តិជាចាំបាច់ទាំងអស់នៃCEDAW (មាត្រា១-១៦) ។ការគ្របដណ្តប់ជាក់លាក់មានន័យថា ការវាយតម្លៃអនុលោមភាពនៅក្នុងប្រធានបទ/វិស័យដែលត្រូវបាន ជ្រើសរើសមួយចំនួន (ឧទាហរណ៏ ការងារ អាពាហ៏ពិពាហ៏ និងគ្រួសារ ឬការចូលរួមផ្នែកនយោបាយ) ឬមាត្រារបស់ CEDAW (ឧទាហរណ៏ មាត្រា ១២ ស្តីពីសុខភាព) ។

(គ) វិសាលភាព (ច្បាប់ពាក់ព័ន្ធ): អ្នកក៏ចាំបាច់ត្រូវតែសម្រេចថាតើច្បាប់ណាខ្លះនឹងត្រូវបានវាយតម្លៃនៅក្នុងការពិនិត្យមើលឡើងវិញផ្នែកច្បាប់របស់អ្នក។ តើការពិនិត្យមើលឡើងវិញនឹងវាយតម្លៃតែលើច្បាប់ដែលចេញដោយអង្គនីតិបញ្ញត្តិប៉ុណ្ណោះ ឬវាយតម្លៃលើច្បាប់ទាំងអស់ (ពោលគឺច្បាប់ដែលចេញដោយអង្គនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ)? តើការពិនិត្យមើលឡើងវិញនេះគ្របដណ្តប់លើច្បាប់នៅគ្រប់លំដាប់ថ្នាក់ ឬគ្របដណ្តប់តែច្បាប់នៅថ្នាក់ជាតិប៉ុណ្ណោះ? (សូមមើលការកំណត់វិសាលភាពនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ (ច្បាប់ពាក់ព័ន្ធ) ខាងក្រោម ឬការណែនាំបន្ថែមអំពីបញ្ហានេះ) ។

(ឃ) អ្នកទទួលផលៈ ដឹងអំពីអ្នកទទួលផលនៅពេលដែលអ្នកធ្វើការពិនិត្យមើលឡើងវិញផ្នែកច្បាប់។ តើការពិនិត្យមើលឡើងវិញនេះសម្រាប់តែអ្នកតស៊ូមតិដែលជាស្ត្រី បញ្ញវ័ន្ត អ្នកឯកទេស មន្ត្រីរដ្ឋាភិបាល អ្នកតាក់តែងច្បាប់ ឬសម្រាប់សាធារណជនទូទៅ ? ការកំណត់អ្នកទទួលផល ជួយអោយអ្នកសម្រេចអំពីភាសា និងទម្រង់បែបបទនៃការពិនិត្យមើលឡើងវិញ (ឧទាហរណ៍ តើអ្នកនឹងប្រើប្រាស់ភាសាសាមញ្ញ ឬភាសាឯកទេស ?) ។

(ង) រយៈពេលៈការពិនិត្យមើលឡើងវិញផ្នែកច្បាប់ត្រូវការពេលវេលាដើម្បីសរសេរ ។ កំណត់រយៈពេលសមរម្យ ។

(ច) អ្នកសរសេរ និងអ្នកផ្តួចផ្តើមៈ ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW អាចត្រូវបានធ្វើឡើងដោយមនុស្សជាច្រើនដូចជា រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ទីភ្នាក់ងារខាងក្រៅ មនុស្សមួយក្រុមមកពីវិស័យផ្សេងៗគ្នា ។ទោះជាបុគ្គលណាក៏ដោយដែលធ្វើការពិនិត្យមើលឡើងវិញ ជាការសំខាន់ដែលពួកគេត្រូវមានជំនាញអំពី CEDAW ច្បាប់ និងស្ថានភាពជាក់ស្តែងនៃសមភាពយេនឌ័រ និងស្ត្រី។ (សូមមើល តើអ្នកណាជាអ្នកស្ថិតក្នុងស្ថានភាពល្អជាងគេក្នុងការអនុវត្តការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ខាងក្រោម) ។

(ឆ) ភាពមានកំរិតៈ ច្បាប់គ្រាន់តែជាវិធានការមួយក្នុងចំណោមវិធានការនានាដើម្បីនាំមកនូវអនុលោមភាពតាម CEDAW ប៉ុណ្ណោះ ។កាតព្វកិច្ច CEDAW មួយចំនួនត្រូវបានដោះស្រាយយ៉ាងសមស្របជាងនេះតាមរយៈវិធានការគោលនយោបាយ អន្តរាគមន៍កម្មវិធី ឬតាមរយៈការអនុវត្តផ្នែកច្បាប់ ។ដូច្នេះហើយ កំណែទម្រង់នៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់គ្រាន់តែដោះស្រាយទម្រង់មួយនៃអន្តរាគមន៍ដែលរដ្ឋភាគីចាំបាច់ត្រូវបង្កើតឡើងដើម្បីអោយខ្លួនអាចលុបបំបាត់ការរើសអើងផ្នែកយេនឌ័រប៉ុណ្ណោះ ។

(ជ) វិធីសាស្ត្រៈ ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ត្រូវបានធ្វើឡើងជាចម្បងជាការស្រាវជ្រាវនៅនឹងកន្លែង។ សិក្ខាសាលានានាដែលមានអ្នកចូលរួមធ្វើការទាក់ទងនឹងសិទ្ធិមនុស្សរបស់ស្ត្រី ដើម្បីកំណត់រួមគ្នាអំពីសូចនាករ និងអនុសាសន៍ផ្នែកច្បាប់សំខាន់ៗ និងដើម្បីធ្វើអោយមានសុពលភាពដល់គំហើញនានានៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់គឺជាការបំពេញបន្ថែមយ៉ាងធំធេងចំពោះការស្រាវជ្រាវនៅនឹងកន្លែង។ ជំនាញ និងបទពិសោធន៍របស់ពួកគេ នឹងជួយបន្ថែមល្បឿនដល់ការពិនិត្យមើលឡើងវិញនេះ។ ការពិគ្រោះយោបល់ជាមួយស្ត្រី ជាពិសេស ជាមួយបុគ្គលទាំងឡាយណាដែលនឹងទទួលឥទ្ធិពលពីអនុសាសន៍នៃការពិនិត្យមើលឡើងវិញក៏ត្រូវបានណែនាំផងដែរ។

បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមនានាដែលចាំបាច់ត្រូវតែពិចារណានៅក្នុងការកំណត់វិធីសាស្ត្រ គឺលទ្ធភាពមានកម្រិតក្នុងការទទួលបានច្បាប់ ឬទិន្នន័យមិនគ្រប់គ្រាន់អំពីឥទ្ធិពលនៃបញ្ញត្តិច្បាប់។ ប្រសិនបើព័ត៌មានត្រូវបានរកឃើញ វាអាចពុំមានលក្ខណៈលម្អិតតាមភេទ ឬពុំមានការវិភាគផ្នែកយេនឌ័រឡើយ។

### ការកំណត់វិសាលភាពនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ (ច្បាប់ពាក់ព័ន្ធ)

ឆ្លើយសំណួរនេះរួចពិចារណាអំពីកត្តាខាងក្រោមនៅពេលសម្រេចអំពីវិសាលភាពនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់របស់អ្នក ។

***វិស័យ ឬប្រធានបទនៃការគ្របដណ្តប់***

សំណួរៈ តើការពិនិត្យមើលឡើងវិញផ្នែកច្បាប់របស់អ្នកគឺជាក) ការគ្របដណ្តប់ទូលំទូលាយ ឬខ) ការគ្របដណ្តប់ជាក់លាក់?

- ប្រសិនបើអ្នកឆ្លើយយកចំណុច ក ត្រូវតែវាយតម្លៃលើច្បាប់ទាំងអស់ ។
- ប្រសិនបើអ្នកឆ្លើយយកចំណុច ខ មានតែច្បាប់ដែលគ្របដណ្តប់វិស័យជាក់លាក់ប៉ុណ្ណោះនឹងត្រូវដាក់បញ្ចូលនៅក្នុងការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ។

ឧទាហរណ៍ នៅក្នុងប្រទេសវៀតណាម ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ទូលំទូលាយត្រូវបានធ្វើឡើង ។ ជាលទ្ធផល ច្បាប់ជាង ២០០ ដែលគ្របដណ្តប់លើវិស័យចំនួន ១៨ ដែលឆ្លើយតបទៅនឹងមាត្រានីមួយៗរបស់ CEDAW ត្រូវបានវាយតម្លៃ ។

***កម្រិតនៃការគ្របដណ្តប់***

សំណួរ : តើគោលបំណងនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ គឺដើម្បី ក) វាយតម្លៃច្បាប់ជាតិ ឬ ខ) វាយតម្លៃច្បាប់ថ្នាក់មូលដ្ឋាន (ឧទាហរណ៍ ថ្នាក់ខេត្ត ឬថ្នាក់ឃុំ) ប៉ុណ្ណោះ ?

- ប្រសិនបើអ្នកឆ្លើយយកចំណុច ក មានតែច្បាប់ជាតិប៉ុណ្ណោះត្រូវបានដាក់បញ្ចូលនៅក្នុងការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ។
- ប្រសិនបើអ្នកឆ្លើយយកចំណុច ខ ទាំងច្បាប់ជាតិ ទាំងច្បាប់ថ្នាក់មូលដ្ឋាននឹងត្រូវដាក់បញ្ចូលនៅក្នុងការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ។

***ភាពពេញលេញនៃច្បាប់***

សំណួរៈ តើច្បាប់នៅក្នុងប្រទេសរបស់អ្នក ក) រួមបញ្ចូលនូវបទដ្ឋានទាំងអស់ ដើម្បីអោយច្បាប់ទាំងនេះមានភាពពេញលេញដោយខ្លួនឯងឬទេ? ឬ ខ) តើច្បាប់ទាំងនេះត្រូវបានបំពេញ ឬបន្ថែមដោយការអនុម័តផ្នែកនីតិប្រតិបត្តិ ឬតុលាការឬទេ ?

- ប្រសិនបើអ្នកឆ្លើយយកចំណុចក ការផ្តោតតែទៅលើច្បាប់គឺគ្រប់គ្រាន់សម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ។
- ប្រសិនបើអ្នកឆ្លើយយកចំណុច ខ ការរួមបញ្ចូលការអនុម័តផ្នែកនីតិប្រតិបត្តិ ឬតុលាការ គឺជាការចាំបាច់ ដើម្បីផ្តល់នូវទិដ្ឋភាពទូលំទូលាយ ។

***ទម្ងន់នៃច្បាប់***

សំណួរ : តើឯកសារដែលចេញដោយអង្គនីតិប្រតិបត្តិមានធរមានភាព និងទម្ងន់ដូចឯកសារដែលចេញដោយអង្គនីតិបញ្ញត្តិឬទេ ?

- ប្រសិនបើអ្នកឆ្លើយយក បាទ/ចាស ការរួមបញ្ចូលឯកសារដែលចេញដោយស្ថាប័នទាំងពីរត្រូវបានណែនាំ ។

### *តើអ្នកណាជាអ្នកស្ថិតក្នុងស្ថានភាពប្រសើរជាងគេដែលត្រូវអនុវត្តការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ?*

តែងតែមានការពិភាក្សាអំពីថា តើអ្នកណាជាអ្នកស្ថិតក្នុងស្ថានភាពប្រសើរជាងគេដែលត្រូវអនុវត្តការពិនិត្យមើលឡើងវិញ ផ្នែកច្បាប់ផ្អែកលើ CEDAW ។ ប្រការនេះអាស្រ័យលើបរិបទនៅក្នុងប្រទេសនីមួយៗ ។ ប៉ុន្តែ ជាការសំខាន់ដែលត្រូវដឹងអំពីអត្ថប្រយោជន៍ និងដែនកំណត់នៃតួអង្គមួយលើតួអង្គមួយទៀត ។

ខាងក្រោមនេះ គឺជាបញ្ជីសង្ខេបនៃតួអង្គផ្សេងៗ ដែលអាចអនុវត្តការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW គុណសម្បត្តិ និងគុណវិបត្តិជាទូទៅរបស់ពួកគេ និងសំណូមពរដើម្បីដោះស្រាយគុណវិបត្តិទាំងនេះ ។

<table>
<tr><td colspan="2">រដ្ឋាភិបាល<br>ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW អាចត្រូវបានអនុវត្តជាផ្លូវការដោយរដ្ឋាភិបាល ។ នៅក្នុងករណីភាគច្រើនក្រសួងយុត្តិធម៌ ឬក្បាលម៉ាស៊ីនថ្នាក់ជាតិរបស់ស្ត្រីដឹកនាំ ឬអនុវត្តដំណើរការនេះ ។</td></tr>
<tr><td>គុណសម្បត្តិ<br>ដោយសារវាគឺជាគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលមានភាពជាកម្មសិទ្ធិរបស់រដ្ឋចំពោះដំណើរការនេះ ។ រដ្ឋទំនងជាទទួលស្គាល់គំហើញនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ និងការងារឆ្ពោះទៅកាន់ការអនុវត្តអនុសាសន៍ ។</td><td>គុណវិបត្តិ<br>ទោះបីជាត្រូវបានស្វាគមន៍ក៏ដោយ ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ទាំងនេះពេលខ្លះត្រូវបានចាត់ទុកថា មានលក្ខណៈលម្អៀងបម្រើខ្លួនឯង ឬ "ទន់ភ្លន់" ចំពោះរដ្ឋាភិបាល ។</td></tr>
<tr><td colspan="2">សំណូមពរ<br>ដើម្បីដោះស្រាយគុណវិបត្តិ រដ្ឋាភិបាលអាចរៀបចំអោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធមិនមែនរដ្ឋាភិបាល និងដាក់បញ្ចូលទស្សនៈរបស់ពួកគេទៅក្នុងការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ។ពួកគេក៏អាចបង្កើតគណៈកម្មការពហុវិស័យនៃទីប្រឹក្សា ឬអ្នកជំនាញ ដើម្បីផ្តល់នូវជំនួយបច្ចេកទេស និងការត្រួតពិនិត្យ ។</td></tr>
<tr><td colspan="2">អង្គការមិនមែនរដ្ឋាភិបាល<br>អង្គការមិនមែនរដ្ឋាភិបាល តាមការផ្តួចផ្តើមផ្ទាល់របស់ខ្លួនក៏អាចអនុវត្តការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ផងដែរ ។</td></tr>
</table>

| **គុណសម្បត្តិ** | **គុណវិបត្តិ** |
| --- | --- |
| ការពិនិត្យមើលឡើងវិញផ្អែកច្បាប់ផ្អែកលើCEDAW ដោយអង្គការមិនមែនរដ្ឋាភិបាលអាចបញ្ជាក់អះអាងគំនិតផ្តួចផ្តើមរបស់រដ្ឋ ឬអាចពិនិត្យមើលបញ្ហានានាដែលអាចមើលរំលងដោយរដ្ឋាភិបាល ។ នៅក្នុងប្រទេសជាច្រើន អង្គការមិនមែនរដ្ឋាភិបាលមានការយល់ដឹងច្រើនជាងអំពីស្ថានភាពជាក់ស្តែងព្រមទាំងអាចឆ្លុះបញ្ចាំងទិដ្ឋភាពនេះបានល្អ។ អង្គការមិនមែនរដ្ឋាភិបាលក៏អាចដាក់បញ្ចូលការតស៊ូ មិតយ៉ាងងាយស្រួលនៅក្នុងកម្មវិធីរបស់ខ្លួនសម្រាប់ អនុសាសន៍នៅក្នុងការពិនិត្យមើលឡើងវិញ។ | នៅក្នុងប្រទេសដែលរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលមិនធ្វើការជាមួយគ្នាដោយរលូន ការពិនិត្យមើលឡើងវិញផ្អែកច្បាប់ដែលធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាលអាចត្រូវបានចាត់ទុកថាមានលក្ខណៈលម្អៀងឬមានលក្ខណៈរិះគន់ហួសហេតុ។ រដ្ឋាភិបាលអាចបដិសេធមិនទទួលស្គាល់លទ្ធផលនៃការពិនិត្យមើលឡើងវិញ។ ជាងនេះទៅទៀតដោយសាររដ្ឋាភិបាលពុំមានការចូលរួម ឬមានការចូលរួមតិចតួចនៅក្នុងដំណើរការ អាចមិនមានភាពជាកម្មសិទ្ធិរបស់រដ្ឋចំពោះការពិនិត្យមើលឡើងវិញ។ |

**សំណូមពរ**

ដើម្បីដោះស្រាយគុណវិបត្តិ តំណាងរដ្ឋាភិបាលអាចត្រូវបានជូនដំណឹងអំពីដំណើរការអោយបានឆាប់រហ័ស និងត្រូវបានលើកទឹកចិត្តអោយចែករំលែកព័ត៌មានរបស់ខ្លួនជាមួយអ្នកពិនិត្យមើលឡើងវិញ។ ពួកគេក៏អាចត្រូវបានអញ្ជើញអោយចែករំលែកយោបល់របស់ខ្លួនអំពីរបៀបបង្កើតភាពជាកម្មសិទ្ធិរបស់រដ្ឋាភិបាល ។ វាក៏នឹងមានប្រយោជន៍ផងដែរដែលត្រូវមានសកម្មភាពរួមគ្នាទៅលើ CEDAW ដើម្បីអនុញ្ញាតិអោយមានការយល់ដឹងអំពីបរិស្ថាននៃអនុសញ្ញា និងដំណើរការជាវិធានការកសាងទំនុកចិត្តសម្រាប់ទាំងរដ្ឋាភិបាល ទាំងអង្គការមិនមែនរដ្ឋាភិបាល។ ប្រសិនបើអាចធ្វើទៅបាន អង្គការមិនមែនរដ្ឋាភិបាលត្រូវតែធានានូវការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលអោយបានឆាប់រហ័ស ដើម្បីគាំទ្រតំហើញនៃការពិនិត្យមើលឡើងវិញផ្អែកច្បាប់។

**ទីភ្នាក់ងារខាងក្រៅ**

ការពិនិត្យមើលឡើងវិញផ្អែកច្បាប់ CEDAW អាចត្រូវបានអនុវត្តផងដែរដោយក្រុមពីខាងក្រៅដូចជា ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងទីភ្នាក់ងារអន្តរជាតិដទៃទៀត ។

| **គុណសម្បត្តិ** | **គុណវិបត្តិ** |
| --- | --- |
| ការពិនិត្យមើលឡើងវិញនេះដំណើរការជាការវាយតម្លៃពីខាងក្រៅ។ នៅក្នុងប្រទេសមួយចំនួន ដោយសារការរឹតត្បិតរបស់រដ្ឋាភិបាលក្រុមក្នុងស្រុកដូចជា អង្គការមិនមែនរដ្ឋា | ប្រសិនបើពុំមានការគាំទ្រខ្លាំងក្លាពីសំណាក់ដៃគូក្នុងស្រុក ការពិនិត្យមើលឡើងវិញនេះអាចមានការខ្វះខាតភាពជាកម្មសិទ្ធិពីសំណាក់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល |

| | |
|---|---|
| មិនអាចផ្តល់នូវការវិភាគល្អិតល្អន់បានទេ។ ដូច្នេះការពិនិត្យមើលឡើង វិញរបស់ពួកគេអាចដំណើរការជា "ការបំពេញចន្លោះប្រហោង" តាមរយៈការផ្តល់ឯកសារយោងផ្អែកច្បាប់អំពីស្ថានភាពនៅក្នុងប្រទេស។ | អំពីគំហើញនៃការពិនិត្យមើលឡើងវិញផ្អែកច្បាប់។ |

***សំណូមពរ***

ដើម្បីដោះស្រាយគុណវិបត្តិ រៀបចំកិច្ចពិគ្រោះយោបល់ជាមួយរដ្ឋាភិបាល និងភាគីពាក់ព័ន្ធមិនរដ្ឋាភិបាលអំពីការពិនិត្យមើលឡើងវិញផ្អែកច្បាប់ផ្អែកលើ CEDAW។ ស្វាគមន៍ចំពោះសំណូមពរ និងដំបូន្មានរបស់ពួកគេ។ ប្រសិនបើអាចធ្វើទៅបាន ធានាថា ការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការគាំទ្រគំហើញនៃការពិនិត្យមើលឡើងវិញ។

***ក្រុមចម្រុះ***

ការពិនិត្យមើលឡើងវិញផ្អែកច្បាប់ផ្អែកលើ CEDAW អាចមានសមាសភាពចម្រុះ។ វាអាចត្រូវបានអនុវត្តដោយក្រុមអន្តរវិស័យ ដែលមានសមាសភាពមកពីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អ្នកជំនាញក្នុងចំណោមអ្នកដទៃទៀត។

| ***គុណសម្បត្តិ*** | ***គុណវិបត្តិ*** |
|---|---|
| ការពិនិត្យមើលឡើងវិញនេះអនុញ្ញាតអោយមានការចូលរួមពីសំណាក់ក្រុមជាច្រើន ដែលត្រូវបានតំណាងនៅក្នុងក្រុមការងារ។ ដូច្នេះហើយ មានភាពជាកម្មសិទ្ធិទូលំទូលាយទៅលើដំណើរការ និងគំហើញនៃការពិនិត្យមើលឡើងវិញផ្អែកច្បាប់ផ្អែលើ CEDAW។ | អាស្រ័យលើថាមភាពក្នុងចំណោមសមាជិកក្រុម ការពិនិត្យមើលឡើងវិញនេះអាចនាំមកនូវការមិនចុះសម្រុង ឬការសម្រុះសម្រួលដោយសារអាទិភាពខុសៗគ្នា។ ប្រសិនបើមិនត្រូវបានចាត់ចែងអោយបានត្រឹមត្រូវទេនោះ វានឹងធ្វើអោយទន់ខ្សោយដល់ភាពអាចទុកចិត្តបាន និងបទដ្ឋាននៃការពិនិត្យមើលឡើងវិញផ្អែកច្បាប់ផ្អែកលើ CEDAW។ |

***សំណូមពរ***

សូមមើលទៅលើ*កង្វល់អំពីការវាយតម្លៃអនុលោមភាព និងសំណូមពរ ដើម្បីដោះស្រាយកង្វល់ទាំងនេះ នៅក្នុងផ្នែកទី ៤ ជំហានទី ៦* ដើម្បីដោះស្រាយគុណវិបត្តិដែលមានរៀបរាប់នៅទីនេះ។

# ក្របខ័ណ្ឌសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW

## ផ្នែកទីបួន :

### ក្របខ័ណ្ឌសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW

នៅក្នុងផ្នែកនេះ :

- ✓ ក្របខ័ណ្ឌសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ( ក្របខ័ណ្ឌវាយតម្លៃ)
- ✓ ការបង្កើតសូចនាករផ្នែកច្បាប់នៃ CEDAW
- ✓ ការកំណត់អនុលោមភាព និងអនុសាសន៍

ក្រោយពីការធ្វើផែនការយ៉ាងលម្អិតអំពីការពិនិត្យមើលឡើងវិញផ្នែកច្បាប់របស់អ្នក អ្នកអាចចាប់ផ្តើមធ្វើការទៅលើការពិនិត្យមើលឡើងវិញផ្នែកច្បាប់ដោយខ្លួនឯង។ ខាងក្រោមគឺជាជំហានសំខាន់ៗចំនួនពីរនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ដែលជំហាននីមួយៗមានជំហានតូចៗជាច្រើន។

### ១. ការបង្កើតសូចនាករផ្នែកច្បាប់នៃ CEDAW

ជំហានទី ១ : កំណត់កាតព្វកិច្ចនៃ CEDAW → ជំហានទី ២ : កំណត់ស្ថានភាព បញ្ហា និងកង្វល់ → ជំហានទី ៣ : បញ្ជាក់អះអាងចំណុចចាំបាច់នានានៅក្នុងច្បាប់ → ជំហានទី ៤ : កំណត់សូចនាករផ្នែកច្បាប់នៃ CEDAW

### ២. ការកំណត់អនុលោមភាព និងអនុសាសន៍

ជំហានទី ៥ : វាយឈ្មោះច្បាប់ដែលពាក់ព័ន្ធ → ជំហានទី ៦ : វិភាគអនុលោមភាព → ជំហានទី ៧ : ធ្វើសេចក្តីព្រាងការពន្យល់ និងមតិយោបល → ជំហានទី ៨ : រៀបចំអនុសាសន៍

→ នៅក្នុងផ្នែកនេះ ជំហាននីមួយៗនឹងត្រូវបានពន្យល់ និងបង្ហាញដោយប្រើប្រាស់ឧទាហរណ៍។ ឧទាហរណ៍ទាំងនេះត្រូវបានបង្ហាញជារូបភាពតែប៉ុណ្ណោះ និងពុំមានបំណងជាការពន្យល់ជាការបង្គាប់បញ្ជាឡើយ។

## ក្របខ័ណ្ឌសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW (ក្របខ័ណ្ឌវាយតម្លៃ)

មុនពេលចាប់ផ្តើម អ្នកចាំបាច់ត្រូវតែសម្រេចអំពីរបៀបរៀបចំព័ត៌មានអំពីការពិនិត្យមើលឡើងវិញផ្នែកច្បាប់។ ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ អាចត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ។

(ក) ក្នុងទម្រង់ពណ៌នា

(ខ) ក្នុងទម្រង់ម៉ាទ្រីស ឬ

(គ) ក្នុងទម្រង់ពណ៌នាផង និងម៉ាទ្រីសផង

### ជម្រើសទី ១ : ទម្រង់ពណ៌នា

គុណសម្បត្តិនៃទម្រង់ពណ៌នា គឺថាវាអនុញ្ញាតអោយមានព័ត៌មានជាច្រើនដែលត្រូវដាក់បញ្ចូលនៅក្នុងការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ។វាក៏អនុញ្ញាតអោយអ្នកធ្វើសេចក្តីព្រាងការពិនិត្យមើលឡើងវិញផ្នែកច្បាប់ធ្វើការបង្ហាញយ៉ាងលម្អិតអំពីរបៀបដែលការវិភាគត្រូវបានធ្វើឡើង ។ ប៉ុន្តែ គុណវិបត្តិគឺថា ទម្រង់នេះអាចមានភាពវែងអន្លាយ និងពុំអនុញ្ញាតអោយមានការពិនិត្យមើលឆាប់រហ័សតាមរយៈក្របខ័ណ្ឌវាយតម្លៃ។

### ជម្រើសទី ២ : ទម្រង់ម៉ាទ្រីស

គុណសម្បត្តិនៃទម្រង់ម៉ាទ្រីស គឺថា វាបង្ហាញយ៉ាងច្បាស់អំពីរបៀបដែលជំហាននីមួយៗទាក់ទងនឹងជំហានបន្ទាប់។ វាក៏បង្ខំអោយអ្នកធ្វើសេចក្តីព្រាងការពិនិត្យមើលឡើងវិញផ្នែកច្បាប់ត្រូវមានការសង្ខេបសមរម្យ។ វាផ្តល់អោយអ្នកអាននូវរបៀបដ៏ងាយស្រួលនៃការពិនិត្យមើលក្របខ័ណ្ឌ។ គុណវិបត្តិនៃទម្រង់ម៉ាទ្រីស គឺថា ទំនងជាមានលក្ខណៈមិនសូវលម្អិត និងមិនសូវមានការពន្យល់ ដែលអាចមានសារៈសំខាន់យ៉ាងខ្លាំងដល់ការយល់ដឹងរបស់អ្នកអានអំពីការវាយតម្លៃ និងអនុសាសន៍ ។

### ជម្រើសទី ៣ : ទម្រង់ពណ៌នាផង និងម៉ាទ្រីសផង

គុណវិបត្តិនៃទម្រង់ចម្រុះនេះ គឺថា វាបង្កើតនូវគុណសម្បត្តិនៃទម្រង់ពណ៌នា និងទម្រង់ម៉ាទ្រីស។ គុណវិបត្តិ គឺថា វាអាចមានលក្ខណៈច្រំដែល។ វាមានភាពទូទៅចំពោះការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ក្នុងការប្រើប្រាស់ទម្រង់ពណ៌នាជាមួយលទ្ធផលដែលសង្ខេបនៅក្នុងទម្រង់ម៉ាទ្រីស។ នេះគឺជាជម្រើសប្រសើរបំផុតប្រសិនបើពេលវេលាអនុញ្ញាតិ។

ខាងក្រោមនេះគឺជារូបភាពនៃទម្រង់ម៉ាទ្រីស

| ការបង្កើតសូចនាករផ្នែកច្បាប់នៃ CEDAW | | | | ការកំណត់អនុលោមភាព និងអនុសាសន៍ | | | |
|---|---|---|---|---|---|---|---|
| ជំហានទី ១ កាតព្វកិច្ច CEDAW | ជំហានទី ២ ស្ថានភាព បញ្ហា និង កង្វល់ | ជំហានទី ៣ ចំណុចចាំបាច់ នៅក្នុងច្បាប់ | ជំហានទី ៤ សូចនាករ ផ្នែកច្បាប់នៃ CEDAW | ជំហានទី ៥ ច្បាប់ពាក់ព័ន្ធ | ជំហានទី ៦ អនុលោភាព | ជំហានទី ៧ ការពន្យល់ និងមតិ យោបល់ | ជំហានទី ៨ អនុសាសន៍ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

## សូចនាករផ្នែកច្បាប់នៃ CEDAW

### តើអ្វីទៅជាសូចនាករ ?

សូចនាករ គឺជាឧបករណ៍សម្រាប់វាស់វែង។ សូចនាករវាស់វែងអំពីអនុលោមភាពទៅនឹងបទដ្ឋានដែលបានកំណត់។ សូចនាករក៏វាស់វែងផងដែរអំពីវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅជាក់លាក់។

### តើអ្វីទៅជាសូចនាករផ្នែកច្បាប់ ?

សូចនាករផ្នែកច្បាប់ គឺជាសូចនាករដែលផ្ដោតទៅលើការវាស់វែងអនុលោមភាពនៃច្បាប់នៅក្នុងក្របខ័ណ្ឌដែលបានកំណត់ ។

### តើអ្វីទៅជាសូចនាករ CEDAW ?

សូចនាករ CEDAW គឺជាសូចនាករដែលវាស់វែងអនុលោមភាពនៃសកម្មភាព ឬការខកខានមិនបានធ្វើសកម្មភាពរបស់រដ្ឋធៀបទៅនឹង CEDAW។ សូចនាករទាំងនេះប្រើប្រាស់ CEDAW ជាក្របខ័ណ្ឌក្នុងការវិភាគថាតើអន្តរាគមន៍របស់រដ្ឋប្រកាន់ខ្ជាប់ទៅនឹង CEDAW គោលការណ៍គន្លឹះរបស់ CEDAW (សមភាពជាចាំបាច់ ការមិនរើសអើង និងកាតព្វកិច្ចរបស់រដ្ឋ) អនុសាសន៍ទូទៅ និងការអង្កេតសន្និដ្ឋានរបស់ CEDAW ដែរឬយ៉ាងណា។

### តើអ្វីទៅគឺជាសូចនាករផ្នែកច្បាប់នៃ CEDAW ?

សូចនាករផ្នែកច្បាប់នៃ CEDAW វាស់វែងអំពីអនុលោមភាពនៃច្បាប់ទៅនឹង CEDAW។ សូចនាករទាំងនេះមានប្រយោជន៍នៅក្នុងការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ដោយសារវាកំណត់នូវបទដ្ឋានសម្រាប់វាស់វែងអនុលោមភាព ឬ វិឌ្ឍនភាព។

## សូចនាករផ្នែកច្បាប់នៃ CEDAW

### តើអ្វីទៅជាសូចនាករ ?

សូចនាករ គឺជាឧបករណ៍សម្រាប់វាស់វែង។ សូចនាករវាស់វែងអំពីអនុលោមភាពទៅនឹងបទដ្ឋានដែលបានកំណត់។ សូចនាករក៏វាស់វែងផងដែរអំពីវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅជាក់លាក់។

### តើអ្វីទៅជាសូចនាករផ្នែកច្បាប់ ?

សូចនាករផ្នែកច្បាប់ គឺជាសូចនាករដែលផ្តោតទៅលើការវាស់វែងអនុលោមភាពនៃច្បាប់នៅក្នុងក្របខ័ណ្ឌដែលបានកំណត់។

### តើអ្វីទៅជាសូចនាករ CEDAW ?

សូចនាករ CEDAW គឺជាសូចនាករដែលវាស់វែងអនុលោមភាពនៃសកម្មភាព ឬការខកខានមិនបានធ្វើសកម្មភាពរបស់រដ្ឋធៀបទៅនឹង CEDAW។ សូចនាករទាំងនេះប្រើប្រាស់ CEDAW ជាក្របខ័ណ្ឌក្នុងការវិភាគថាតើអន្តរាគមន៍របស់រដ្ឋប្រកាន់ខ្ជាប់ទៅនឹង CEDAW គោលការណ៍គន្លឹះរបស់ CEDAW (សមភាពជាចាំបាច់ ការមិនរើសអើង និងកាតព្វកិច្ចរបស់រដ្ឋ) អនុសាសន៍ទូទៅ និងការអង្កេតសន្និដ្ឋានរបស់ CEDAW ដែរឬយ៉ាងណា។

### តើអ្វីទៅគឺជាសូចនាករផ្នែកច្បាប់នៃ ជំនឿ ?

សូចនាករផ្នែកច្បាប់នៃ CEDAW វាស់វែងអំពីអនុលោមភាពនៃច្បាប់ទៅនឹង CEDAW។ សូចនាករទាំងនេះមានប្រយោជន៍នៅក្នុងការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ដោយសារវាកំណត់នូវបទដ្ឋានសម្រាប់វាស់វែងអនុលោមភាព ឬវឌ្ឍនភាព។ ការ

## បង្កើតសូចនាករផ្នែកច្បាប់នៃ CEDAW

| | | | |
|---|---|---|---|
| **ជំហានទី ១ : កំណត់កាតព្វកិច្ចនៃ CEDAW** | ជំហានទី ២ : កំណត់ស្ថានភាពបញ្ហា និងកង្វល់ | ជំហានទី ៣ : បញ្ជាក់អះអាងចំណុចចាំបាច់នានា នៅក្នុងច្បាប់ | ជំហានទី ៤ : កំណត់សូចនាករផ្នែកច្បាប់នៃ CEDAW |

ឥឡូវនេះយើងមានភាពរួចរាល់ក្នុងការចាប់ផ្តើមការពិនិត្យមើលឡើងវិញផ្នែកច្បាប់។ ជំហានដំបូងនៅក្នុងការបង្កើតសូចនាករ ផ្នែកច្បាប់នៃ CEDAW មានដូចខាងក្រោម :

### ១. កំណត់កាតព្វកិច្ច ឬការសន្យាដែលតម្រូវដោយ CEDAW ចំពោះប្រធានបទ ឬមាត្រាដែលត្រូវបានជ្រើសរើស

កិច្ចការនេះត្រូវបានធ្វើឡើង តាមរយៈការពិនិត្យមើលឯកសារសំខាន់ៗចំនួនបី :

- CEDAW
- អនុសាសន៍ទូទៅ
- ការអង្កេតសន្និដ្ឋាន (ឬមតិយោបល់សន្និដ្ឋាន) នៃប្រទេសរបស់អ្នក

ឯកសារទាំងនេះគួរត្រូវបានពិចារណាទាក់ទងទៅនឹងគោលការណ៍គន្លឹះនៃសមភាពជាចាំបាច់ការមិនរើសអើង និងកាតព្វកិច្ចរបស់រដ្ឋ។ ជាងនេះទៅទៀត មាត្រា ៦-១៦ នៃ CEDAW គួរត្រូវបានអានជានិច្ច រួមជាមួយនឹងកាតព្វកិច្ចទូទៅរបស់រដ្ឋនៅក្នុងមាត្រា ១-៥ និង ២៤។

**២.បង្ហាញព័ត៌មានតាមរបៀបដែលត្រូវបានរៀបចំជាមុន**

អាស្រ័យលើគោលបំណងនៃការពិនិត្យមើលឡើងវិញ ព័ត៌មានតាមលំដាប់អាចត្រូវបានរៀបចំឡើងតាមរបៀបបីយ៉ាង :

***ជម្រើសទី ១ : អត្ថបទពេញលេញ***

នេះមានន័យថា ការលើកឡើងនូវអត្ថបទរបស់ CEDAW អនុសាសន៍ទូទៅ និងការអង្កេតសន្និដ្ឋានពេញលេញ។

- គុណសម្បត្តិ : អ្នកអានអាចយល់ភ្លាមៗអំពីកាតព្វកិច្ចរបស់រដ្ឋ ដោយមិនចាំបាច់អានឯកសារដទៃទៀត។ វាក៏ងាយស្រួលផងដែរក្នុងការបង្ហាញពាក្យពេចន៍ពិតប្រាកដនៃបញ្ញត្តិទាំងឡាយ។
- គុណវិបត្តិ : បញ្ជីកាតព្វកិច្ចអាចមានលក្ខណៈវែងអន្លាយ និងច្រំដែល។

***ជម្រើសទី ២ : ការលើកឡើងសង្ខេប***

នេះមានន័យថា ការលើកឡើងនូវអត្ថបទរបស់ CEDAW អនុសាសន៍ទូទៅ និងការអង្កេតសន្និដ្ឋាននៅក្នុងទម្រង់សង្ខេប។ ជំនួសអោយការប្រើប្រាស់អត្ថបទពេញលេញ មានតែមាត្រា ឬកថាខ័ណ្ឌជាក់លាក់ប៉ុណ្ណោះត្រូវបានដាក់បញ្ចូល (ឧទាហរណ៍ មាត្រា ៥ នៃ CEDAW ឬកថាខ័ណ្ឌទី ៥ នៃអនុសាសនទូទៅទី ២៤)។ ឯកសារពាក់ព័ន្ធអាចត្រូវបានបន្ថែមជាសេចក្តីបន្ថែម ឬជាឧបសម្ព័ន្ធ។

- គុណសម្បត្តិ : វិធីសាស្ត្រនេះចៀសវាងអត្ថបទដែលមានលក្ខណៈវែងអន្លាយ និងច្រំដែល។
- គុណវិបត្តិ : ខ្លឹមសារជាចាំបាច់នៃកាតព្វកិច្ច CEDAW ពុំមាននៅពេលពិនិត្យមើលត្រួសៗលើកដំបូងទេ។ ការពិនិត្យមើលចុះឡើងរវាងឯកសារពិនិត្យមើលឡើងវិញផ្នែកច្បាប់ និងឧបសម្ព័ន្ធអាចធ្វើអោយអាក់ខានដល់ភាពរលូននៃការអាន។

***ជម្រើសទី ៣ : សង្ខេបប្រធានបទ***

នេះមានន័យថា ការសង្ខេបចំណុចសំខាន់ៗនៃ CEDAW អនុសាសន៍ទូទៅ និងការអង្កេតសន្និដ្ឋានទៅជាប្រធានបទ និងការលើកឡើងនូវឯកសារដែលត្រូវគ្នា។

- គុណសម្បត្តិ : អត្ថបទដែលមានលក្ខណៈវែងអន្លាយ និងច្រំដែលត្រូវបានចៀសវាងនៅក្រោមវិធីសាស្ត្រនេះ ។ជាងនេះទៅទៀតអ្នកអានអាចមើលឃើញចំណុចសំខាន់ភ្លាមៗនៃកាតព្វកិច្ច CEDAW។
- គុណវិបត្តិ : វិធីសាស្ត្រនេះតម្រូវអោយមានកិច្ចប្រឹងប្រែង និងពេលវេលាច្រើនជាង ដោយសារអត្ថបទរបស់ CEDAW អនុសាសន៍ទូទៅ និងការអង្កេតសន្និដ្ឋានត្រូវបានសំយោគ។

ជម្រើស ឬសន្សំការគួបផ្សំនៃជម្រើសដែលអ្នកជ្រើសរើស គឺអាស្រ័យលើគោលបំណងនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់

និងអ្នកទទួល ផលដែលបានកំណត់របស់ខ្លួន។ ការពិគ្រោះយោបល់ជាមួយអ្នកទទួលផលដែលបានកំណត់ និងអ្នកជំនាញនឹងជួយដល់ការជ្រើសរើសជម្រើសដែលប្រសើរបំផុត។

ឧទាហរណ៍នៅក្នុងការធ្វើសេចក្តីព្រាងចំពោះការពិនិត្យមើលឡើងវិញផ្នែកច្បាប់ទៅលើច្បាប់របស់ប្រទេសវៀតណាម[១១] កិច្ចពិភាក្សាដំបូងមួយក្នុងចំណោមកិច្ចពិភាក្សានានា គឺទាក់ទងទៅនឹងថា តើត្រូវប្រើជម្រើសណាមួយក្នុងការបង្ហាញកាតព្វកិច្ច CEDAW។ ការពិគ្រោះយោបល់ជាមួយអ្នកទទួលផលជាពិសេសអ្នកធ្វើសេចក្តីព្រាងច្បាប់នៅក្នុងក្រសួងរដ្ឋាភិបាល និងសភា បានគូសបញ្ជាក់អំពីសេចក្តីត្រូវការរបស់ពួកគេក្នុងការស្វែងយល់ផ្ទាល់ខ្លួនអំពីអ្វីដែល CEDAW អនុសាសន៍ទូទៅ និងមតិយោបល់សន្និដ្ឋានរបស់ CEDAW បានគូសបញ្ជាក់ទាក់ទងទៅនឹងប្រធានបទជាក់លាក់។ ពួកគេក៏គូសបញ្ជាក់ផងដែរថាវានឹងមានភាពងាយស្រួលសម្រាប់ពួកគេក្នុងការយល់ដឹងអំពីកាតព្វកិច្ចទាំងនេះ និងធ្វើអោយអ្នកធ្វើសេចក្តីព្រាងច្បាប់ដទៃទៀតមានការជឿជាក់ ប្រសិនបើពួកគេអាចទទួលបានអត្ថបទពិតប្រាកដភ្លាមៗ។ ដូចេះក្នុងចំណោមជម្រើសទាំងបីពួកគេចូលចិត្តជម្រើសទី ១។

**ការបង្ហាញជំហានទី ១**

ដោយប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារជាផ្នែកនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ខាងក្រោមគឺជារូបភាពនៃជំហានទី ១។ សូមមើលទំព័របន្ទាប់សម្រាប់ឧទាហរណ៍ទី ១

[១១] ការពិនិត្យមើលឡើងវិញនេះមានចំណងជើងថា CEDAW និងច្បាប់ : ការពិនិត្យមើលឡើងវិញផ្អែកលើយេនឌ័រ និងសិទ្ធិនៃឯកសារច្បាប់វៀតណាម តាមរយៈកញ្ចក់ឆ្លុះបញ្ចាំងរបស់ CEDAW។

ឧទាហរណ៍ទី ១ : ការបង្ហាញជម្រើសផ្សេងៗនៃជំហានទី ១ ( កំណត់កាតព្វកិច្ច CEDAW ) ដោយប្រើប្រាស់អំពើហិង្សា ក្នុងគ្រួសារ ជាផ្នែកនៃការពិនិត្យមើលឡើងវិញ

| ជម្រើសទី ១ : អត្ថបទពេញលេញ | ជម្រើសទី ២ : ការលើកឡើងសង្ខេប | ជម្រើសទី ៣ : សង្ខេបប្រធានបទ |
|---|---|---|
| **មាត្រា ១**<br>សម្រាប់គោលបំណងនៃអនុសញ្ញាបច្ចុប្បន្នពាក្យ "ការរើសអើងលើស្ត្រី" ត្រូវមានន័យថា ភាពខុសគ្នា ការផាត់ចេញ ឬការរឹតត្បិតណាមួយដែលធ្វើឡើងផ្អែកលើមូលដ្ឋានភេទដែលមានឥទ្ធិពល ឬគោលបំណងធ្វើអោយប៉ះពាល់ ឬធ្វើមោឃភាពដល់ការទទួលស្គាល់ ការទទួលបានឬការប្រើប្រាស់ដោយ ស្ត្រីនូវសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាននៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ ស៊ីវិល ឬវិស័យដទៃទៀត ផ្អែកលើមូលដ្ឋាននៃសមភាពរវាងបុរស និងស្ត្រី ដោយមិនគិតអំពីស្ថានភាពអាពាហ៍ពិពាហ៍ ។<br>**មាត្រា ២**<br>ភាគរដ្ឋថ្កោលទោសចំពោះការរើសអើងលើស្ត្រីនៅក្នុងគ្រប់ទម្រង់ទាំងអស់យល់ព្រមអនុវត្តគោលនយោបាយលុបបំបាត់ការរើសអើងលើស្ត្រីតាមគ្រប់មធ្យោបាយសមស្របទាំងអស់ ដោយមិនបង្អែរបង្អង់ ហើយដើម្បីសម្រេចគោលដៅនេះសន្យា:<br>( ក ) បញ្ចូលគោលការណ៍ស្តីពីសមភាពរវាងបុរស និងស្ត្រីនៅក្នុងរដ្ឋធម្មនុញ្ញជាតិ ឬច្បាប់សមស្របដទៃទៀតប្រសិនបើមិនទាន់ត្រូវបានដាក់បញ្ចូល ព្រមទាំងធានានូវការសម្រេចបានជាក់ស្តែងចំពោះគោលការណ៍នេះតាមរយៈច្បាប់ និងមធ្យោបាយសមស្របដទៃទៀត ។<br>( ខ ) អនុម័តវិធានការច្បាប់ និងវិធានការដទៃទៀតដែលសមស្រប រួមទាំងការដាក់ទណ្ឌកម្ម ប្រសិនបើសមស្របដោយហាមឃាត់រាល់ទម្រង់ទាំងអស់នៃការរើសអើងលើស្ត្រី ។<br>( គ ) បង្កើតការការពារផ្នែកច្បាប់ចំពោះសិទ្ធិស្ត្រីផ្អែកលើមូលដ្ឋានស្មើភាពជាមួយបុរស និងធានានូវការការពារស្ត្រី ប្រកបដោយប្រសិទ្ធភាពប្រឆាំងនឹងអំពើរើសអើងណាមួយតាមរយៈសាលាក្តីថ្នាក់ជាតិមានសមត្ថកិច្ច និងស្ថាប័ន សាធារណៈដទៃទៀត ។<br>( ឃ ) ចៀសវាងការចូលរួមនៅក្នុងអំពើឬការអនុវត្តណាមួយដែលរើសអើងលើស្ត្រីព្រមទាំងធានាថាអាជ្ញាធរ និងស្ថាប័នសាធារណៈត្រូវធ្វើសកម្មភាពស្របតាមកាតព្វកិច្ចនេះ ។<br>( ង ) ចាត់រាល់វិធានការសមស្របទាំងឡាយដើម្បីលុបបំបាត់ការរើសអើងលើស្ត្រីដោយបុគ្គលណាម្នាក់ អង្គការ ឬសហគ្រាសណាមួយ ។<br>( ច ) ចាត់រាល់វិធានការសមស្របទាំងឡាយ រួមទាំងនីតិកម្ម ដើម្បីកែប្រែ ឬលុបចោលច្បាប់ បទប្បញ្ញត្តិ ទំនៀមទម្លាប់ និងទម្លាប់អនុវត្តន៍ដែលមានស្រាប់ ដែលបង្កើតបានជាការរើសអើងលើស្ត្រី ។<br>( ឆ ) លុបចោលរាល់បញ្ញត្តិព្រហ្មទណ្ឌជាតិទាំងអស់ដែលបង្កើតបានជាការរើសអើងលើស្ត្រី ។ | CEDAW មាត្រា ១, ២, ៥ និង ១៦<br><br>អនុសាសន៍ទូទៅទី ១៩ កថាខ័ណ្ឌទី ១, ៦, ២៣ និង ២៤ ( ខ, គ, ច, ឈ, ដ, ណ, ត, ថ, ទ និង ធ )<br><br>ការអង្កេតសន្និដ្ឋានអំពីប្រទេស ប្រសិនបើពាក់ព័ន្ធ | **និយមន័យ និងវិសាលភាព**<br>មាត្រា១,២( ខ,គ,ឃ,ង ) ៥និង១៦អនុសាសន៍ទូទៅទី ១៩ កថាខ័ណ្ឌទី ១, ៦ និង ២៣ និងការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ ។<br>អំពើហិង្សាផ្អែកលើយេនឌ័រគឺជាទម្រង់មួយនៃការរើសអើង ដែលរារាំងយ៉ាងធ្ងន់ធ្ងរដល់សមត្ថភាពរបស់ស្ត្រីក្នុងការប្រើប្រាស់សិទ្ធិ និងសេរីភាពរបស់ខ្លួនដោយសមភាព ។<br>អំពើហិង្សាផ្អែកលើយេនឌ័រ រួមមានអំពើដែលបង្កគ្រោះថ្នាក់ ឬការឈឺចាប់ផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទ ការគំរាមកំហែងនៃអំពើទាំងនេះ ការបង្ខិតបង្ខំ និងការដកហូតសេរីភាពដទៃទៀត ។<br>អំពើហិង្សាក្នុងគ្រួសារ គឺជាទម្រង់មួយនៃអំពើហិង្សាផ្អែកលើយេនឌ័រ រួមទាំងការវាយដំ ការរំលោភសេពសន្ថវៈ ទម្រង់ដទៃទៀតនៃការបៀតបៀនផ្លូវភេទផ្លូវចិត្ត និងទម្រង់ដទៃទៀតនៃអំពើហិង្សា កង្វះភាពឯករាជ្យផ្នែកសេដ្ឋកិច្ច និងការលុបចោលទំនួលខុសត្រូវក្នុងគ្រួសារ ។<br>**ការការពារ និងការគាំទ្រ**<br>មាត្រា ២ ( ខ, គ, ឃ, ង ) អនុសាសន៍ទូទៅទី ១៩ កថាខ័ណ្ឌទី ២៤ ( ខ, ច, ឈ, ដ, ឌ, ឍ, ណ និង ថ ) និងការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ ។<br><br>CEDAW តម្រូវអោយរដ្ឋ :<br>( ក ) អនុម័តទណ្ឌកម្ម ដើម្បីហាមឃាត់ការរើសអើង រួមទាំងទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ ។<br>( ខ ) បង្កើតការការពារផ្លូវច្បាប់ និងធានានូវការកាពារយ៉ាងមានប្រសិទ្ធភាព ប្រឆាំងនឹងការរើសអើង ។ |

| | | |
|---|---|---|
| ***មាត្រា ៥***<br>រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្របទាំងឡាយ :<br>(ក) កែប្រែបែបផែនសង្គម និងវប្បធម៌នៃការប្រព្រឹត្តចំពោះបុរស និងស្ត្រី ដោយមានគោលបំណងសម្រេចអោយបាននូវការលុបបំបាត់បុរេនិច្ឆ័យ និងទម្លាប់អនុវត្តន៍ជាប្រពៃណី និងទម្លាប់អនុវត្តន៍ផ្សេងៗទៀតទាំងអស់ ដែលផ្អែកលើគំនិតអំពីភាពទន់ខ្សោយ ឬឧត្តមភាពនៃភេទណាមួយ ឬផ្អែកលើតួនាទីជា តួយ៉ាងសម្រាប់បុរស និងស្ត្រី ។<br>(ខ) ធានាថា ការអប់រំប្រចាំគ្រួសាររួមមាន ការយល់ដឹងត្រឹមត្រូវអំពីមាតុភាពថា ជាមុខងារសង្គមមួយ និងការទទួលស្គាល់ទំនួលខុសត្រូវរួមរបស់បុរស និងស្ត្រីក្នុងការចិញ្ចឹមបីបាច់និងអភិវឌ្ឍកូនរបស់ខ្លួនដោយយល់ថាផលប្រយោជន៍របស់កូនគឺជាការពិចារណាចម្បងនៅក្នុងគ្រប់ករណីទាំងអស់ ។<br>***មាត្រា ១៦***<br>១. រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្របទាំងឡាយ ដើម្បីលុបបំបាត់ការរើស អើងលើស្ត្រីនៅក្នុងគ្រប់បញ្ហាទាំងអស់ទាក់ទងនឹងទំនាក់ទំនងអាពាហ៍ពិពាហ៍ និងគ្រួសារ ហើយជាពិសេស ត្រូវធានា ផ្អែកលើមូលដ្ឋាននៃសមភាព រវាងបុរស និងស្ត្រី ។<br>***អនុសាសន៍ទូទៅទី ១៩***<br>១. អំពើហិង្សាផ្អែកលើយេនឌ័រ គឺជាទម្រង់មួយនៃការរើសអើងដែលរារាំងយ៉ាងធ្ងន់ធ្ងរដល់សមត្ថភាពរបស់ស្ត្រីក្នុងការប្រើប្រាស់សិទ្ធិនិងសេរីភាពផ្អែកលើ មូលដ្ឋាននៃសមភាពជាមួយបុរស ។<br>៦. មាត្រា១នៃអនុសញ្ញានេះកំណត់អំពីការរើសអើងលើស្ត្រី ។និយមន័យនៃការរើសអើងរួមមានអំពើហិង្សាផ្អែកលើយេនឌ័រ ពោលគឺអំពើហិង្សាដែលមានទិសដៅប្រឆាំងនឹងស្ត្រី ដោយសារគាត់គឺជាស្ត្រី ឬដែលប៉ះពាល់ដល់ស្ត្រី ដោយមិនស្មើភាព ។ អំពើហិង្សារួមមានអំពើដែលបង្កគ្រោះថ្នាក់ ឬការឈឺចាប់ ផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទ ការគំរាមកំហែងនៃអំពើទាំងនេះ ការបង្ខិតបង្ខំនិង ការដកហូតសេរីភាពដទៃទៀត ។អំពើហិង្សាផ្អែកលើយេនឌ័រអាចរំលោភលើ បញ្ញត្តិជាក់លាក់នៃអនុសញ្ញា ដោយមិនគិតអំពីថាតើបញ្ញត្តិទាំងនោះរៀបរាប់ យ៉ាងច្បាស់អំពិហិង្សា ឬមិនរៀបរាប់ក៏ដោយ ។<br>២៣. អំពើហិង្សាក្នុងគ្រួសារ គឺជាទម្រង់មួយដ៏គ្រោះថ្នាក់បំផុតនៃអំពើហិង្សាលើស្ត្រី ។ វាកើតមានគ្រប់ទីកន្លែងនៅក្នុងសង្គមទាំងអស់ ។ នៅក្នុងទំនាក់ទំនងគ្រួសារ ស្ត្រីគ្រប់វ័យទទួលរងអំពើហិង្សាគ្រប់ប្រភេទ រួមទាំងការវាយដំ ការរំលោភសេពសន្ថវៈ ទម្រង់ដទៃទៀតនៃការបៀតបៀនផ្លូវភេទ ផ្លូវចិត្ត និងទម្រង់ដទៃទៀតនៃអំពើហិង្សាដែលបន្តកើតមានឡើងដោយសារឥរិយាបថជាប្រពៃណី ។ កង្វះភាពឯករាជ្យផ្នែកសេដ្ឋកិច្ចបង្ខំអោយស្ត្រីជាច្រើនរស់នៅក្នុងទំនាក់ ទំនងប្រកបដោយអំពើហិង្សា ។ ការលុបចោលទំនួលខុសត្រូវក្នុង គ្រួសារ របស់ខ្លួនដោយបុរសអាចជាទម្រង់មួយនៃអំពើហិង្សា និងការបង្ខិតបង្ខំ ។ ទម្រង់ទាំងនេះនៃអំពើហិង្សាធ្វើអោយសុខភាពស្ត្រីស្ថិតក្នុងហានិភ័យ និងធ្វើអោយប៉ះពាល់ដល់សមត្ថភាពក្នុងការចូលរួមនៅក្នុងជីវភាពគ្រួសារ និងជីវភាពសាធារណៈផ្អែកលើមូលដ្ឋានសមភាព ។<br>២៤. ដោយសារមតិយោបល់ទាំងនេះ គណៈកម្មាធិការទទួលបន្ទុកលុបបំបាត់អំពើ ហិង្សាលើស្ត្រីបានផ្តល់អនុសាសន៍ : | | (គ) ធានាថា អាជ្ញាធរសាធារណៈចៀសវាងការប្រើអំពើហិង្សា ។<br>(ឃ) លុបបំបាត់ការរើសអើងពីសំណាក់ បុគ្គល អង្គការ ឬសហគ្រាស ។<br>(ង) នីតិវិធីបណ្តឹងប្រកបដោយប្រសិទ្ធភាព និងដំណោះស្រាយ រួមទាំងសំណង ។<br>(ច) ផ្តល់នូវសេវាការពារ និងគាំទ្រសមស្របសម្រាប់ជនរងគ្រោះ រួមទាំងកន្លែងស្នាក់នៅ ឬជំរក ជាពិសេសបុគ្គលិកសុខាភិបាលដែលទទួលបានការបណ្តុះបណ្តាល ការស្តារនីតិសម្បទា និងការផ្តល់ប្រឹក្សា ។<br>(ឆ) ផ្តល់នូវកម្មវិធីស្តារនីតិសម្បទារសម្រាប់ជនប្រព្រឹត្តអំពើហិង្សា និង<br>(ជ) គាំទ្រសេវានានាសម្រាប់គ្រួសារដែលអំពើស្មន្ធការ និងការរំលោភផ្លូវភេទបានកើតឡើង ។<br>**ការរៀបចំផ្នែកស្ថាប័ន**<br>មាត្រា២ (គ, ឃ, ង) និងមាត្រា ៥ អនុសាសន៍ទូទៅទី ១៩ កថាខ័ណ្ឌទី២៤ (ខ, គ, ច, ត, ទ និង ធ ) និងការអង្កេត សន្និដ្ឋានអំពីប្រទេស ប្រសិនបើពាក់ព័ន្ធ ។<br>CEDAW តម្រូវអោយរដ្ឋ :<br>(ក) បង្កើតការការពារផ្លូវច្បាប់ និងធានានូវការការពារយ៉ាងមានប្រសិទ្ធិភាពប្រឆាំងនឹងការរើសអើង ។<br>(ខ) ធានាថា អាជ្ញាធរសាធារណៈចៀសវាងការរើសអើង ។<br>(គ) លុបបំបាត់ការរើងអើងពីសំណាក់បុគ្គល អង្គការ ឬសហគ្រាស ។<br>(ឃ) អនុវត្តការបណ្តុះបណ្តាលស្វែងយល់អំពីយេនឌ័រចំពោះមន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីសាធារណៈ ដទៃទៀតអំពីការអនុវត្ត CEDAW ។<br>(ង) ចងក្រងស្ថិតិនិងស្រាវជ្រាវអំពីអំពើហិង្សាក្នុងគ្រួសារ ។ |

| | | |
|---|---|---|
| (ខ) រដ្ឋភាគីគួរធានាថា ច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានការរំលោភសេពសន្ថវៈ ការបៀតបៀនផ្លូវភេទ និងអំពើហិង្សាផ្អែកលើយេនឌ័រដទៃទៀត គួរផ្តល់ការការពារគ្រប់គ្រាន់ចំពោះស្ត្រីទាំងអស់ ព្រមទាំងគោរពបូរណភាព និងភាពថ្លៃថ្នូររបស់ពួកគេ។ សេវាការពារ និងគាំទ្រសមស្របគួរត្រូវបានផ្តល់អោយសម្រាប់ជនរងគ្រោះ។ ការបណ្តុះបណ្តាលស្វែងយល់ អំពីយេនឌ័រចំពោះមន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់និងមន្ត្រីសាធារណៈដទៃទៀត គឺជាកត្តាចាំបាច់សម្រាប់ការអនុវត្តសន្ធិសញ្ញាអោយមានប្រសិទ្ធភាព។<br>(គ) រដ្ឋភាគីគួរលើកទឹកចិត្តដល់ការចងក្រងស្ថិតិ និងការស្រាវជ្រាវអំពីកម្រិតមូលហេតុ និងឥទ្ធិពលនៃអំពើហិង្សា និងអំពីប្រសិទ្ធភាពនៃវិធានការនានាក្នុងការទប់ស្កាត់ និងដោះស្រាយអំពើហិង្សា។<br>(ច) វិធានការប្រកបដោយប្រសិទ្ធភាពនានា គួរត្រូវបានធ្វើឡើងដើម្បីជំនះឥរិយាបថ និងទម្លាប់អនុត្តន៏ទាំងនេះ។ រដ្ឋគួរណែនាំអោយប្រើប្រាស់កម្មវិធីអប់រំ និងកម្មវិធីព័ត៌មានសាធារណៈដើម្បីជួយលុបបំបាត់បុរេវិនិច្ឆ័យដែលរារាំងដល់សមភាពរបស់ស្ត្រី (អនុសាសន៏ទី ៣, ១៩៨៧)។<br>(ឈ) នីតិវិធីបណ្តឹងដ៏មានប្រសិទ្ធភាព និងឧបាស្រ័យ រួមទាំង សំណងគួរត្រូវបានចែង។<br>(ដ) រដ្ឋភាគីគួរបង្កើតឬគាំទ្រសេវាកម្មសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ ការបៀតបៀនផ្លូវភេទ និងទម្រង់ដទៃទៀតនៃអំពើហិង្សាផ្អែកលើយេនឌ័ររួមទាំងកន្លែងស្នាក់នៅជាពិសេសបុគ្គលិកសុខាភិបាលដែលទទួលបានការបណ្តុះបណ្តាល ការស្តារនីតិសម្បទា និងការផ្តល់ប្រឹក្សា។<br>(ឋ) រដ្ឋភាគីគួរធានាថា សេវាកម្មសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាអាច ទទួលបានពីសំណាក់ស្ត្រីជនបទ និងថាប្រសិនបើចាំបាច់សេវាកម្មពិសេសគួរផ្តល់ជូនសហគមន៏ដាច់ស្រយាល។<br>(ឍ) រដ្ឋភាគីគួររាយការណ៏អំពីហានិភ័យចំពោះស្ត្រីជនបទ ទំហំ និងលក្ខណៈនៃអំពើហិង្សា និងការរំលោភបំពានដែលពួកគេទទួលរង សេចក្តីត្រូវការរបស់ពួកគេ និងលទ្ធភាពក្នុងការទទួលបានការគាំទ្រ និងសេវាផ្សេងៗទៀត ព្រមទាំងប្រសិទ្ធភាពនៃវិធានការ ដើម្បីជំនះអំពើហិង្សា។<br>(ណ) វិធានការនានាដែលចាំបាច់ ដើម្បីជំនះអំពើហិង្សាក្នុងគ្រួសារគួររួមមាន :<br>ការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ ប្រសិនបើចាំបាច់ និងដំណោះស្រាយរដ្ឋប្បវេណីក្នុងករណីអំពើហិង្សាក្នុងគ្រួសារ។<br>ច្បាប់ដើម្បីលុបចោលការការពារកិត្តិយស ទាក់ទងនឹងការយាយី ឬការធ្វើឃាតសមាជិកគ្រួសារដែលជាស្ត្រី។<br>សេវានានាដើម្បីធានាសុវត្ថិភាព និងសន្តិសុខរបស់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសាររួមទាំងកន្លែងស្នាក់នៅ ការផ្តល់ប្រឹក្សា និងកម្មវិធីស្តារនីតិសម្បទា។<br>កម្មវិធីស្តារនីតិសម្បទាសម្រាប់ជនប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ។<br>សេវាគាំទ្រសម្រាប់គ្រួសារដែលអំពើស្មន្ធការ ឬការរំលោភផ្លូវភេទបានកើតឡើង។<br>(ត) រដ្ឋភាគីគួររាយកាណ៏អំពីទំហំនៃអំពើហិង្សាក្នុងគ្រួសារ និងការរំលោភផ្លូវភេទ និងអំពីវិធានការបង្ការដាក់ទណ្ឌកម្ម និងដោះស្រាយដែលត្រូវបានធ្វើឡើង។ | | (ច) បង្កើតវិធានការនានាដើម្បីជំនះឥរិយាបថ និងទម្លាប់អនុវត្តន៏ តាមរយៈការអប់រំ និងកម្មវិធិព័ត៌មានសាធារណៈ ដើម្បីលុបបំបាត់ការរើសអើង។ |

| | | |
|---|---|---|
| (ថ) រដ្ឋភាគីគួរចាត់វាល់វិធានការផ្លូវច្បាប់ទាំងអស់ និងវិធានការដទៃទៀតដែលចាំបាច់ ដើម្បីផ្តល់នូវការការពារយ៉ាងមានប្រសិទ្ធភាពចំពោះស្ត្រីប្រឆាំងនឹងអំពើហិង្សាផ្អែកលើយេនឌ័ររួមមានដូចជា :<br>វិធានការផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាពរួមទាំងការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌបញ្ញត្តិស្តីពីសំណងទាក់ទងនឹងដំណោះស្រាយរដ្ឋប្បវេណី ដើម្បីការពារស្ត្រីប្រឆាំងនឹងអំពើហិង្សាគ្រប់ប្រភេទ រួមទាំងអំពើហិង្សា និងការរំលោភបំពានក្នុងគ្រួសារការបៀតបៀនផ្លូវភេទ និងការយាយីផ្លូវភេទនៅក្នុងកន្លែងធ្វើការ ។<br>វិធានការបង្ការរួមមាន ព័ត៌មានសាធារណៈ និងកម្មវិធីអប់រំ ដើម្បីផ្លាស់ប្តូរឥរិយាបថទាក់ទងនឹងតួនាទី និងឋានៈរបស់បុរស និងស្ត្រី ។<br>វិធានការការពាររួមមានកន្លែងស្នាក់នៅ ការផ្តល់ប្រឹក្សា ការស្តារនីតិសម្បទា និងសេវាគាំទ្រនានាសម្រាប់ស្ត្រីដែលជាជនរងគ្រោះដោយសារអំពើហិង្សា ឬដែលស្ថិតក្នុងហានិភ័យនៃអំពើហិង្សាក្នុងគ្រួសារ ។<br>(ទ) រដ្ឋភាគីគួររាយការណ៍អំពីរាល់ទម្រង់ទាំងអស់នៃអំពើហិង្សាផ្អែកលើយេនឌ័រ និង ថារបាយការណ៍ទាំងនេះគួររួមបញ្ចូលរបាយការណ៍ដែលមានស្រាប់អំពីឧបទវហេតុនៃទម្រង់នីមួយៗនៃអំពើហិង្សា និងអំពីផលប៉ះពាល់នៃអំពើហិង្សាទាំងនេះទៅលើស្ត្រីដែលជាជនរងគ្រោះ ។<br>(ធ) របាយការណ៍របស់ រដ្ឋភាគី គួររួមបញ្ចូលព័ត៌មានអំពីវិធានការផ្លូវច្បាប់ វិធានការបង្ការ និងវិធានការការពារ ដែលត្រូវបានធ្វើឡើងដើម្បីជំនះអំពើហិង្សាប្រឆាំងនឹងស្ត្រី និងព័ត៌មានអំពីប្រសិទ្ធភាពនៃវិធានការទាំងនេះ ។<br><br>**ការអង្កេតសន្និដ្ឋានអំពីប្រទេស ប្រសិនបើពាក់ព័ន្ធ** | | |

→ សូមមើលឧទាហរណ៍ទី ៣ ៥ និងទី ៦ សម្រាប់ការពន្យល់ជារូបភាពបន្ថែមអំពីជំហានទី ១

| | | | |
|---|---|---|---|
| ជំហានទី ១ : កំណត់កាតព្វកិច្ចនៃ CEDAW | **ជំហានទី ២ : កំណត់ស្ថានភាព បញ្ហា និងកង្វល់** | ជំហានទី ៣ : បញ្ជាក់អះអាងចំណុចចាំបាច់នានានៅក្នុងច្បាប់ | ជំហានទី ៤ : កំណត់សូចនាករផ្នែកច្បាប់នៃ CEDAW |

ក្រោយពីអ្នកបានកំណត់កាតព្វកិច្ច ឬការសន្យាដែលតម្រូវដោយ CEDAW អ្នកអាចកំណត់នូវបញ្ហា និងកង្វល់នានាអំពីស្ត្រីនៅក្នុងប្រទេសរបស់អ្នកសម្រាប់កាតព្វកិច្ច CEDAW នីមួយៗ ។ ដើម្បីធ្វើកិច្ចការនេះអ្នកចាំបាច់ត្រូវ :

**១. ស្រាវជ្រាវទៅលើស្ថានភាពជាក់ស្តែងរបស់ស្ត្រី និងសមភាពយេនឌ័រ**

ចំណេះដឹងអំពីបទពិសោធន៍ពិតប្រាកដរបស់ស្ត្រី និងសមភាពយេនឌ័រ គឺជាប្រការសំខាន់ណាស់ សម្រាប់ការពិនិត្យមើលឡើងវិញផ្នែក ច្បាប់ផ្អែកលើ CEDAW ។

**២. បំផុសគំនិតអំពីបញ្ហា និងកង្វល់ទាក់ទងនឹងស្ត្រី និងសមភាពយេនឌ័រនៅក្នុងប្រទេស**

ធ្វើកិច្ចការនេះ ដោយផ្អែកលើចំណេះដឹងរបស់អ្នកអំពីកាតព្វកិច្ច CEDAW (ជំហានទី ១) និងស្ថានភាពជាក់ស្តែង។ ជាដំបូង កំណត់បញ្ហាទូទៅ រួចបន្ទាប់មក ទទួលបានបញ្ហាជាក់លាក់។

**៣. រៀបចំបញ្ហាដែលអ្នកបានកំណត់ជាឃ្លាច្បាស់លាស់ និងស៊ីសង្វាក់គ្នា**

មានជម្រើសផ្សេងៗអំពីរបៀបដែលត្រូវរៀបចំឃ្លានៃបញ្ហានៃកង្វល់។

**ជម្រើសទី ១ : ភាសាអព្យាក្រឹត**

ជម្រើសនេះមានន័យថា ជាការប្រើភាសាអព្យាក្រឹត ដើម្បីគូសបញ្ជាក់អំពីបញ្ហាមួយ។

- គុណសម្បត្តិ: វាមានប្រយោជន៍យ៉ាងខ្លាំងសម្រាប់គោលបំណងនៃការរក្សាទុក។ ការប្រើភាសាអព្យាក្រឹតអនុញ្ញាតអោយអ្នកធ្វើសេចក្តីព្រាងការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ដើម្បីដោះស្រាយទិន្នាការវិជ្ជមាន និងអវិជ្ជមាន។
- គុណវិបត្តិ: វិធីសាស្ត្រនេះអាចធ្វើអោយអ្នកធ្វើសេចក្តីព្រាងងាកចេញពីការផ្តោតទៅលើបញ្ហាអាទិភាព (ជាធម្មតា ស្តែង ឡើងនៅក្នុងទិន្នាការអវិជ្ជមាន)។

**ជម្រើសទី ២ : ភាសាដែលផ្អែកលើបញ្ហា**

ជម្រើសនេះមានន័យថា នៅពេលកំណត់បញ្ហាមួយ ភាសាសង្កត់ធ្ងន់ទៅលើបញ្ហា។

- គុណសម្បត្តិ: ការប្រើប្រាស់វិធីសាស្ត្រនេះអនុញ្ញាតអោយអ្នកធ្វើសេចក្តីព្រាងការពិនិត្យមើលឡើងវិញផ្នែកច្បាប់អាចកំណត់បញ្ហានានាដែលជាកង្វល់ និងត្រូវការការយកចិត្តទុកដាក់ជាបន្ទាន់។
- គុណវិបត្តិ: វិធីសាស្ត្រនេះអាចនាំអោយមានការព្រងើយកន្តើយចំពោះការអភិវឌ្ឍជាវិជ្ជមាន។

ជម្រើសឬបន្សំការគួបផ្សំនៃជម្រើសក្នុងការប្រើប្រាស់គឺអាស្រ័យលើគោលបំណងនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់និងអ្នកទទួលផលគោលដៅរបស់ខ្លួន។ ការពិគ្រោះយោបល់ជាមួយអ្នកទទួលផលនិងអ្នកជំនាញគឺជាការចាំបាច់ដើម្បីធានាថាជម្រើសប្រសើរបំផុតនឹងត្រូវបានអនុម័តសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់។

**៤. ជ្រើសរើស និងកំណត់អាទិភាពចំពោះបញ្ហា និងកង្វល់សម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់**

មានបញ្ហា និងកង្វល់ជាច្រើននៅក្នុងប្រទេសដែលទាក់ទងទៅនឹងកាតព្វកិច្ច CEDAW។ នៅក្នុងករណីជាច្រើន ការកំណត់អាទិភាព គឺជាការចាំបាច់ ដើម្បីអនុញ្ញាតអោយមានការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ដែលមានការផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង និងការតស៊ូមតិ។ នៅក្នុងករណីដទៃទៀត ពេលវេលាមានកំណត់តម្រូវអោយមានការកំណត់អាទិភាពចំពោះបញ្ហា និងកង្វល់។

## ការពន្យល់ដោយអោយជាឧទាហរណ៍អំពីជំហានទី ២

ដោយប្រើប្រាស់ការបញ្ចូលទៅក្នុងអាពាហ៍ពិពាហ៍ជាវិស័យដែលត្រូវពិនិត្យមើលឡើងវិញ ខាងក្រោមនេះគឺជារូបភាពនៃជំហានទី ២ ។

**ឧទាហរណ៍ទី២ : ការពន្យល់ដោយអោយជាឧទាហរណ៍អំពីជម្រើសផ្សេងៗនៃការបង្ហាញជំហានទី២ ( កំណត់បញ្ហា និងកង្វល់)**

| កាតព្វកិច្ច CEDAW | ជម្រើសទី ១ : ភាសាអព្យាក្រឹត* | ជម្រើសទី ២ : ភាសាផ្អែកលើបញ្ហា* |
|---|---|---|
| ការបញ្ចូលទៅក្នុងអាពាហ៍ពិពាហ៍<br>មាត្រា ១៦.១ ( ក និង ខ) អនុសាសន៍ទូទៅទី ២១ កថាខ័ណ្ឌទី ១៤, ១៦, ២៥-៣៩ និងការអង្កេតសន្និដ្ឋានអំពីប្រទេស ប្រសិនបើពាក់ព័ន្ធ ។ | ១. យល់ព្រមរៀបអាពាហ៍ពិពាហ៍<br>២. អាយុរៀបអាពាហ៍ពិពាហ៍<br>៣. ការភ្ជាប់ពាក្យ<br>៤. ការចុះបញ្ជីអាពាហ៍ពិពាហ៍<br>៥. ការចុះបញ្ជីកំណើត<br>៦. អាពាហ៍ពិពាហ៍របស់ស្ត្រីមេម៉ាយ | ១. អាពាហ៍ពិពាហ៍ដោយគ្មានការយល់ព្រមពីសាមីខ្លួន<br>២. អាពាហ៍ពិពាហ៍វ័យក្មេង<br>៣. ការភ្ជាប់ពាក្យក្រោយអាយុ ១៨ ឆ្នាំ<br>៤. ការមិនចុះបញ្ជីអាពាហ៍ពិពាហ៍<br>៥. ការមិនចុះបញ្ជីកំណើត<br>៦. ការមិនរៀបការជាថ្មីសម្រាប់ស្ត្រីមេម៉ាយ |

* ចម្លើយអាចត្រូវបានលម្អិតបន្ថែមទៅតាមបញ្ហាតូចៗ ។

→ **សូមមើលឧទាហរណ៍ទី ៣ ៥ និងទី ៦** សម្រាប់ការពន្យល់ជារូបភាពបន្ថែមនៃជំហានទី ២

| | | | |
|---|---|---|---|
| ជំហានទី ១ : កំណត់កាតព្វកិច្ចនៃ CEDAW | ជំហានទី ២ : កំណត់ស្ថានភាពបញ្ហា និងកង្វល | **ជំហានទី ៣ : បញ្ជាក់អះអាងចំណុចចាំបាច់នានានៅក្នុងច្បាប់** | ជំហានទី ៤ : កំណត់សូចនាករផ្នែកច្បាប់នៃ CEDAW |

នៅពេលដែលស្ថានភាពជាក់ស្តែង ព្រមទាំងបញ្ហា និងកង្វល់អំពីស្ត្រី និងសមភាពយេនឌ័រនៅក្នុងប្រទេសត្រូវបានកំណត់រួចភ្លាម អ្នកអាចចាប់ផ្តើមគិតអំពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់ ។ ខាងក្រោមនេះ គឺជាជំហានទាំងឡាយ ។

### ១. កំណត់ចំណុចសំខាន់ៗ ដើម្បីអោយច្បាប់មានអនុលោមភាពតាមកាតព្វកិច្ច CEDAW

ផ្អែកលើស្ថានភាព បញ្ហា និងកង្វល់ ដែលមានរៀបរាប់នៅក្នុងជំហានទី ២ កំណត់ចំណុចសំខាន់ៗអ្វីខ្លះដែលត្រូវដាក់បញ្ចូលនៅក្នុងច្បាប់ ដើម្បីអោយច្បាប់នេះមានអនុលោមភាពតាមកាតព្វកិច្ច CEDAW ( ត្រូវបានកំណត់នៅក្នុងជំហានទី ១) ។

ឧទាហរណ៍ប្រសិនបើអាពាហ៍ពិពាហ៍វ័យក្មេងឬអាពាហ៍ពិពាហ៍កុមារត្រូវបានរៀបរាប់ថាជាបញ្ហាដើម្បីអនុលោមតាម CEDAW វាជាការសំខាន់ដែលច្បាប់នៃប្រទេសមួយត្រូវ :

- ចែងអំពីអាយុអប្បបរមានៃអាពាហ៍ពិពាហ៍ មិនអោយក្រោម ១៨ ឆ្នាំ
- បង្កើតបញ្ជីកំណើត និងបញ្ជីអាពាហ៍ពិពាហ៍
- ចែងអំពីទណ្ឌកម្មសម្រាប់ការរំលោភបំពាន និងធានាអោយមានការធ្វើមោឃភាពចំពោះអាពាហ៍ពិពាហ៍បែបនេះក្នុងចំណោមអាពាហ៍ពិពាហ៍ដទៃទៀត ។

ជំហានទី ៣ គួរទាក់ទងជាពិសេសអំពីចំណុចនានាដែលត្រូវតែដាក់បញ្ចូលនៅក្នុងច្បាប់ និងមិនគួរទាក់ទងអំពីគោលនយោបាយ កម្មវិធី និងអន្តរាគមន៍ដទៃទៀតឡើយ ។ កម្រិតនៃភាពជាក់លាក់នៃចំណុចនានានៅក្នុងជំហានទី ៣ អាចប្រែប្រួលផ្អែកលើវិសាលភាព និងអាទិភាពនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ។

### ២. ធានាអោយមានចំណងជើងដែលត្រូវគ្នាសម្រាប់បញ្ចូល

ធានាថា បញ្ហា និងកង្វល់នីមួយៗមានចំណងជើងសម្រាប់បញ្ចូលដែលត្រូវគ្នានៅក្នុងជំហានទី ៣ ។ ក្នុងករណីមួយចំនួនអាចមានចំណងជើងត្រូវគ្នាច្រើនជាងមួយនៅក្នុងជំហានទី ៣ សម្រាប់បញ្ហា ឬកង្វល់ណាមួយនៅក្នុងជំហានទី ២ ។

### ការពន្យល់ជារូបភាពនៃជំហានទី ៣

→ **សូមមើលឧទាហរណ៍ទី ៣, ៥ និងទី ៦** សម្រាប់ការពន្យល់ជារូបភាពនៃជំហានទី ៣

| ជំហានទី ១ : កំណត់កាតព្វកិច្ចនៃ CEDAW | ជំហានទី ២ : កំណត់ស្ថានភាពបញ្ហា និងកង្វល់ | ជំហានទី ៣ : បញ្ជាក់អះអាងចំណុចចាំបាច់នានានៅក្នុងច្បាប់ | **ជំហានទី ៤ : កំណត់សូចនាករផ្នែកច្បាប់នៃ CEDAW** |
|---|---|---|---|

ឥឡូវនេះអ្នករួចរាល់ក្នុងការកំណត់សូចនាករនានា ដើម្បីវាស់វែងអនុលោមភាពផ្នែកច្បាប់ ។ ដើម្បីធ្វើកិច្ចការនេះ អ្នកចាំបាច់ត្រូវ :

**១. កែលម្អចំណុចដែលបានកំណត់រួចនៅក្នុងជំហានទី ៣ ទៅជាសូចនាករផ្នែកច្បាប់នៃ CEDAW**

- បង្កើតចំណុចទាំងឡាយអោយទៅជាសំណួរដែលអាចឆ្លើយដោយចម្លើយ បាទ/ចាស ឬទេ។ (ចម្លើយ "បាទ/ចាស" មានន័យថា មានអនុលោមភាព ចំណែកឯចម្លើយ "ទេ" មានន័យថា ពុំមានអនុលោមភាព) ។
- ធានាថា សំណួរទាំងឡាយត្រូវបានរៀបចំជាឃ្លា ដើម្បីសាកសួរអំពីអត្ថិភាពនៃបួលក្ខខណ្ឌតម្រូវនៅក្នុងច្បាប់ ឬបញ្ញត្តិច្បាប់ ជាជាងអំពីគោលនយោបាយផែនការ ឬកម្មវិធី ។

ឧទាហរណ៍ : សំណួរ "តើមានជម្រកសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាដែរឬទេ ?" គឺជាការសាកសួរដែលផ្ដោតទៅលើអន្តរាគមន៍ផ្នែកកម្មវិធីជាជាងច្បាប់ ។ សំណួរនេះអាចត្រូវបានរៀបចំជាឃ្លាប្រសើរជាងនេះថា "តើមានបញ្ញត្តិច្បាប់ដែលតម្រូវអោយមានការបង្កើតជម្រកពីសំណាក់ទីភ្នាក់ងាររដ្ឋាភិបាលសមស្របឬទេ ?" ឬ "តើច្បាប់តម្រូវអោយមានការបង្កើតជម្រកសម្រប់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារឬទេ ?" ។

**២. ធ្វើអោយសូចនាករមានលក្ខណៈជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន និងពាក់ព័ន្ធ**

សូចនាករផ្នែកច្បាប់នៃ CEDAW ត្រូវតែមានលក្ខណៈជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន និងពាក់ព័ន្ធ ។

- ជាក់លាក់ : សូចនាករជាក់លាក់នាំអោយមានចម្លើយផ្ទាល់ ។ម្យ៉ាងទៀត សូចនាករទូលំទូលាយ មិនច្បាស់លាស់ ឬទូទៅអាចនាំអោយមានការបកស្រាយខុស ឬនាំអោយមានការវិភាគនិងអនុសាសន៍ស្រពេចស្រពិល ។ប្រសិនបើអាចធ្វើទៅបានធានាថាមានវិធីតែម្យ៉ាងគត់ដើម្បីឆ្លើយទៅនឹងសូចនាករ ។ប្រសិនបើសូចនាករតម្រូវអោយមានវិធីច្រើនយ៉ាងក្នុងការឆ្លើយ វានឹងមានការលំបាកក្នុងការវាយតម្លៃអនុលោមភាព ។

  ឧទាហរណ៍ សូចនាករមួយសួរថា: "តើច្បាប់កំណត់និយមន័យ អំពើហិង្សាក្នុងគ្រួសារ ស្របតាមបទដ្ឋានរបស់ CEDAW ឬទេ?" មានលក្ខណៈទូលំទូលាយទូទៅ និងតម្រូវអោយមានវិធីច្រើនយ៉ាងក្នុងការឆ្លើយ ។គេអាចវាយតម្លៃអនុលោមភាពតាមរយៈការពិនិត្យមើលអំពើទាំងឡាយណាដែលត្រូវបានចាត់ទុកថា ជាអំពើហិង្សា ឬទៅលើបុគ្គលដែលត្រូវបានចាត់ទុកថា ជាជនរងគ្រោះដោយសារអំពើហិង្សា ។ ក្នុងករណីនេះ វាជាការប្រសើរជាងដែលត្រូវមាន សូចនាករជាក់លាក់ចំនួនពីរ : "តើច្បាប់កំណត់និយមន័យអំពើហិង្សាក្នុងគ្រួសារ ដើម្បីរួមបញ្ចូលគ្រោះថ្នាក់ផ្នែករាងកាយ ផ្លូវចិត្ត ផ្លូវភេទនិងផ្នែកសេដ្ឋកិច្ចឬទេ?" និង "តើច្បាប់កំណត់និយមន័យអំពើហិង្សាក្នុងគ្រួសារ ដើម្បីគ្របដណ្ដប់សហព័ទ្ធ អតីតសហព័ទ្ធនិងបុគ្គលទាំងឡាយ

ណាដែលមានទំនាក់ទំនងជិតស្និទ្ធឬទេ ?" ។

- អាចវាស់វែងបានៈ ធ្វើសេចក្តីព្រាងសូចនាករដើម្បីងាយស្រួលក្នុងការវាស់វែងអនុលោមភាពឬវឌ្ឍនភាព ។ សូចនាករផ្នែកច្បាប់នៃ CEDAW គួរអាចឆ្លើយបានដោយចម្លើយ "បាទ/ចាស" ឬ "ទេ" ជំនួសអោយសំណួរដែលនាំអោយមានការពិភាក្សាដេញដោល ។ សូចនាករជាក់លាក់ងាយស្រួលក្នុងការវាស់វែងជាងសូចនាករដែលមានលក្ខណៈទូលំទូលាយ ឬទូទៅ ។
  ឧទាហរណ៍ សូចនាករមួយដែលថែងថាៈ "តើសិទ្ធិអ្វីខ្លះត្រូវបានផ្តល់អោយស្ត្រីក្នុងអំឡុងមាតុភាព ?" មានការពិបាកក្នុងការវាស់វែង បើប្រៀបធៀបទៅនឹងសំណួរ "តើច្បាប់មានចែងអំពីការឈប់សម្រាកលំហែមាតុភាពមានប្រាក់ឈ្នួលសម្រាប់រយៈពេលសមស្របដោយមិនបាត់បង់អតីតភាពការងារ ឬអត្ថប្រយោជន៍ឬទេ ?" និង "តើច្បាប់ហាមឃាត់ការបណ្តេញចេញដោយសារអាពាហ៍ពិពាហ៍ ការមានគភ៌ ឬការឈប់សម្រាកលំហែមាតុភាពឬទេ ?" ។ សូចនាករចុងក្រោយអាចឆ្លើយបានដោយចម្លើយ "បាទ/ចាស" ឬ "ទេ" ដែលធ្វើអោយមានភាពងាយស្រួលជាងក្នុងការវាស់វែងអនុលោមភាព ។
- អាចសម្រេចបានៈ នៅពេលសូចនាករផ្នែកច្បាប់នៃ CEDAW ព្យាយាមសម្រាប់កំណែទម្រង់ច្បាប់សូចនាករទាំងនេះត្រូវតែធានានូវបញ្ហានានាដែលអាចសម្រេចបានដោយច្បាប់ ។
  ឧទាហរណ៍ ច្បាប់មិនដាក់ទណ្ឌកម្មចំពោះការគិតទេ ប៉ុន្តែ ដាក់ទណ្ឌកម្មតែទៅលើទង្វើ និងការខកខានមិនបានធ្វើប៉ុណ្ណោះ ។ ដូច្នេះសូចនាករដែលថែងថា ៈ "តើច្បាប់ដាក់ទណ្ឌកម្មចំពោះគំនិតដែលរើសអើងទៅលើស្ត្រីឬទេ ?" មិនមែនជាសូចនាករល្អទេ ដោយសារវាមិនវាស់វែងអំពីអ្វីដែលច្បាប់អាចសម្រេចបាន ។ ផ្ទុយទៅវិញវាអាចត្រូវបានរៀបចំជាឃ្លាឡើងវិញថា "តើមានច្បាប់ដែលតម្រូវអោយព័ត៌មានសាធារណៈ និងការអប់រំអំពីការរើសអើងផ្នែកយេនឌ័រដែរឬទេ ?" ។ សូចនាករចុងក្រោយនេះសាកសួរអំពីការវាស់វែងជាក់លាក់ ដើម្បីអនុញ្ញាតអោយមានការផ្លាស់ប្តូរចំពោះឥរិយាបថ និងគំនិត ។ វិធីមួយទៀតនៃការរៀបចំឃ្លាឡើងវិញ គឺការសាកសួរអំពីថាតើសកម្មភាពរើសអើង ឬការខកខានមិនបានធ្វើសកម្មភាពត្រូវបានដាក់ទណ្ឌកម្មដែរឬយ៉ាងណាពោលគឺ "តើមានទណ្ឌកម្មសម្រាប់សកម្មភាពឬការខកខានមិនបានធ្វើសកម្មភាពដែលនាំអោយមានការរើសអើងផ្នែកយេនឌ័រដែរឬទេ ?" ។
- ភាពពាក់ព័ន្ធៈ សូចនាករនានាត្រូវតែពាក់ព័ន្ធទៅនឹងរដ្ឋ ។ ប្រការមួយក្នុងចំណោមប្រការទាំងឡាយដែលបណ្តាលមកពីការចម្លងសូចនាករដែលរៀបចំរួចសម្រាប់ប្រទេសផ្សេងទៀតគឺថាសូចនាករមួយចំនួនអាចមិនមានភាពពាក់ព័ន្ធចំពោះរដ្ឋដែលច្បាប់របស់ខ្លួនកំពុងត្រូវបានពិនិត្យមើលឡើងវិញ ។
  ឧទាហរណ៍ នៅក្នុងប្រទេសមួយដែលបណ្ណាការមិនមែនជាទម្លាប់អនុវត្តន៍សូចនាករអំពីថា តើច្បាប់ហាមឃាត់បណ្ណាការមិនមែនជាអាទិភាពដែរឬទេ ហើយនឹងធ្វើអោយអ្នកតាក់តែងច្បាប់មានភាពស្មុគស្មាញអំពីតម្រូវការអោយមានការវាស់វែងបែបនេះ ។

ប៉ុន្តែ ត្រូវកត់សម្គាល់ថា អ្នកគួរប្រយ័ត្នប្រយែងអំពីការលុបចោលសូចនាករភ្លាមៗដែលមិនពាក់ព័ន្ធ ។ ឧទាហរណ៍ប្រសិនបើពុំមានព័ត៌មានអំពីប្រធានបទជាក់លាក់ទេនោះ ការស្រាវជ្រាវគួរត្រូវបានធ្វើឡើងដើម្បីបង្ហាញអំពីស្ថានភាពជាក់ស្តែង

ជាមុន មុនពេលចាត់ទុកថា បញ្ហាមួយពុំមានភាពពាក់ព័ន្ធ។ សូមមើលផងដែរនូវនយោបាយស្តីពីការជ្រើសរើសសូចនាករខាងក្រោមសម្រាប់ការពិភាក្សាបន្ថែម។

**៣. ប្រសិនបើចាំបាច់ ធ្វើសេចក្តីព្រាងសូចនាកររង**

ដើម្បីធ្វើអោយសូចនាករមានភាពជាក់លាក់តាមដែលអាចធ្វើទៅបានសូចនាកររងអាចត្រូវបានបង្កើតឡើង។ សូចនាកររងលម្អិតបន្ថែមសូចនាករទៅជាផ្នែកផ្សេងៗ ដើម្បីផ្តល់នូវការណែនាំក្នុងការឆ្លើយតបទៅនឹងសូចនាករ។
ឧទាហរណ៍សូចនាករមួយដែលសួរថា: "តើច្បាប់ចែងអំពីវិធានការការពារបន្ទាន់សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារដែរឬទេ ?" អាចត្រូវបានលម្អិតបន្ថែមទៅជាសូចនាកររងដូចខាងក្រោម:

- តើវិធានការការពារបន្ទាន់ហាមឃាត់ជនល្មើសមិនអោយប្រព្រឹត្តអំពើហិង្សាបន្ថែមដែរឬទេ ?
- តើវិធានការការពារបន្ទាន់ហាមឃាត់ជនល្មើសមិនអោយប៉ះពាល់ឬយាយីជនរងគ្រោះឬសមាជិកគ្រួសាររបស់ជនរងគ្រោះដែរឬទេ ?
- តើវិធានការនេះអនុញ្ញាតអោយមានការបណ្តេញចេញបណ្តោះអាសន្នចំពោះជនល្មើសពីលំនៅដ្ឋានរបស់ជនរងគ្រោះដែរឬទេ ដោយមិនគិតអំពីភាពជាកម្មសិទ្ធិលើលំនៅដ្ឋាន ?
- តើវិធានការការពារបន្ទាន់អនុញ្ញាតអោយមានសេចក្តីសម្រេចអំពីការគ្រប់គ្រងកុមារជាបណ្តោះអាសន្នដែរឬទេ ?
- តើវិធានការការពារបន្ទាន់អនុញ្ញាតអោយមានការបង់ប្រាក់ឧបត្ថម្ភសម្រាប់ជនរងគ្រោះដែរឬទេ ?
- តើវិធានការនេះអនុញ្ញាតអោយមានការបង់ប្រាក់បណ្តោះអាសន្នសម្រាប់ចំណាយវេជ្ជសាស្ត្រដែលកើតឡើងដោយសារអំពើហិង្សាដែរឬទេ ?
- តើវិធានការការពារបន្ទាន់មានសុពលភាពសម្រាប់រយៈពេលគ្រប់គ្រាន់ដើម្បីអនុញ្ញាតអោយជនរងគ្រោះធានាបាននូវសុវត្ថិភាពផ្ទាល់ខ្លួន និងការការពារដែរឬទេ ?
- តើវិធានការការពារបន្ទាន់ត្រូវបានចេញនៅថ្ងៃតែមួយដូចកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដែរឬទេ ?
- តើវិធានការការពារបន្ទាន់ត្រូវបានចេញតែចំពោះភាគីម្ខាងដែរឬទេ ? (សេចក្តីសម្រេចតែម្ខាង គឺជាសេចក្តីសម្រេចដែលធ្វើឡើងដោយចៅក្រម ដោយមិនតម្រូវអោយភាគីទាំងអស់នៃវិវាទមានវត្តមានឡើយ)។
- តើវិធានការការពារបន្ទាន់ត្រូវបានចេញដោយអាជ្ញាធរដែលងាយស្រួលចូលទៅដល់ដែរឬទេ ?
- តើច្បាប់អនុញ្ញាតអោយមានការចេញវិធានការការពារបន្ទាន់ដោយឯករាជ្យពីការដាក់បណ្តឹងដែរឬទេ ?

**៤. ជ្រើសរើសលេខសូចនាករសមស្រប**

ជាញឹកញាប់ សំណួរនានាត្រូវបានលើកឡើងទាក់ទងទៅនឹងថាតើសូចនាករផ្នែកច្បាប់នៃ CEDAW ចំនួនប៉ុន្មានគួរត្រូវបានកំណត់។ ចូរពិចារណាចំណុចខាងក្រោម ដើម្បីជួយអ្នកក្នុងការសម្រេច :

- វិសាលភាពនៃការពិនិត្យមើលឡើងវិញ : ម្យ៉ាងប្រសិនបើការពិនិត្យមើលឡើងវិញទូលំទូលាយទៅលើអនុលោមភាពនៃ

CEDAW ត្រូវបានធ្វើឡើងសូចនាករកាន់តែច្រើនត្រូវបានជ្រើសរើស ។ ប៉ុន្តែ ទោះបីជាមានសូចនាករច្រើនសម្រាប់ការពិនិត្យមើលឡើងវិញទូលំទូលាយក៏ដោយក៏វាមានសូចនាករកាន់តែតិចអំពីបញ្ហាឬប្រធានបទនីមួយៗ ។ម្យ៉ាងទៀតការពិនិត្យមើលឡើងវិញលើវិសាលភាពដែលបានផ្តោតអាចកំណត់សូចនាករកាន់តែច្រើនអំពីបញ្ហានោះ ។

ឧទាហរណ៍ ការពិនិត្យមើលឡើងវិញទូលំទូលាយអាចកំណត់សូចនាករចំនួន ១៥០ ប៉ុន្តែសម្រាប់បញ្ហានីមួយៗ (ឧទាហរណ៍ សុខភាព អប់រំអាពាហ៍ពិពាហ៍ និងគ្រួសារ) វាអាចមានត្រឹមតែ ១០ប៉ុណ្ណោះ ។ ចូរប្រៀបធៀបបញ្ហានេះទៅនឹងការពិនិត្យមើលឡើងវិញ ដែលធ្វើឡើងតែទៅលើបញ្ហាអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលអាចកំណត់សូចនាករចំនួន ៥០ យ៉ាងងាយស្រួល ។

- អាទិភាពដែលផ្តល់ចំពោះបញ្ហា ឬបញ្ហាតូចៗ : បញ្ហាអាទិភាពនានាទំនងជាមានសូចនាករច្រើន ដែលមានលក្ខណៈជាក់លាក់ ។ បញ្ហាដែលមិនសូវមានអាទិភាពត្រូវបានផ្តល់នូវសូចនាករមួយចំនួនតូច ។
- ការកំហិតផ្នែកពេលវេលាៈ នៅពេលដែលពេលវេលាមានកម្រិតក្នុងការធ្វើអោយការពិនិត្យមើលឡើងវិញអាចគ្រប់គ្រងបាន សូចនាករអាទិភាពត្រូវបានជ្រើសរើសលើសូចនាករដែលមិនសូវមានអាទិភាព ។ មាននិន្នាការក្នុងការកំណត់ចំនួនសូចនាករផងដែរ ។

### ៥. ធានានូវការដាក់បញ្ចូលក្នុងចំណងជើងដែលត្រូវគ្នា

ធានាថា ការដាក់បញ្ចូលនៅក្នុងចំណងជើងនីមួយៗក្នុងជំហានទី ៣ (បញ្ជាក់អះអាងអំពីចំណុចចាំបាច់នៅក្នុងច្បាប់) មានចំណងជើងត្រូវគ្នានៅក្នុងជំហានទី ៤ (កំណត់សូចនាករផ្នែកច្បាប់នៃ CEDAW) ។ ក្នុងករណីខ្លះអាចមានចំណងជើងត្រូវគ្នាច្រើនជាងមួយ ។

### គោលការណ៏នៃការជ្រើសរើសសូចនាករ

"ខណៈដែលការវាស់វែង ជាញឹកញាប់ គឺជាលំហាត់បច្ចេកទេស សេចក្តីសម្រេចក្នុងការវាស់វែងវឌ្ឍនភាព ដំណើរការនៃការសម្រេចថាតើទិដ្ឋភាពអ្វីខ្លះនៃសមភាពយេនឌ័រដែលត្រូវវាស់វែង មានលក្ខណៈពាក់ព័ន្ធទៅនឹងនយោបាយ" ។ [១២]
ការពិភាក្សាអំពីថាតើសូចនាករណាខ្លះគួរត្រូវបានផ្តល់អាទិភាព លុបចោល គូសបញ្ជាក់ ឬធ្វើអោយសាមញ្ញឱភាសកម្មត្រូវឆ្លងកាត់កិច្ចពិភាក្សា និងការចរចា ។ ដើម្បីធានាថា សូចនាករផ្នែកច្បាប់នៃ CEDAW ឆ្លុះបញ្ចាំងអំពីអាទិភាពរបស់ស្ត្រីនៅក្នុងប្រទេសរបស់អ្នក និងមិនត្រូវបានធ្វើអោយចុះខ្សោយដោយការចរចាផ្នែកនយោបាយទេនោះ សំណូមពរមានប្រយោជន៏មួយចំនួន មានដូចខាងក្រោម :
ការផ្សារភ្ជាប់ : បង្ហាញអោយបានច្បាស់លាស់នូវការផ្សារភ្ជាប់ទំនាក់ទំនងរវាងកាតព្វកិច្ច CEDAW បញ្ហា និងកង្វល់របស់ស្ត្រី និងសូចនាករដែលបានកំណត់ ។
ការង្កេតសន្និដ្ឋាន : បញ្ហានានាដែលលើកឡើងនៅក្នុងការអង្កេតសន្និដ្ឋាននៃប្រទេសរបស់អ្នក គឺជាប្រភពដ៏ល្អនៃការកំណត់អាទិភាព ។ ជាងនេះទៅទៀត ដោយសាររដ្ឋត្រូវបានរំពឹងអោយរាយការណ៏អំពីការអនុវត្តបញ្ហាទាំងនេះ ការដាក់បញ្ចូលសូចនាករ ជាក់លាក់ទាក់ទងនឹងបញ្ហាទាំងឡាយ គឺជាកត្តាសំខាន់ ។
សិក្ខាសាលា និងការពិគ្រោះយោបល់: ការរៀបចំសិក្ខាសាលា និងការពិគ្រោះយោបល់ជាមួយអ្នកជំនាញ អ្នកឯកទេស អ្នកអនុវត្តវិជ្ជាជីវៈ អ្នកតស៊ូមតិសម្រាប់ស្ត្រី និងភាគីពាក់ព័ន្ធដទៃទៀតអំពីអ្វីដែលពួកគេកំណត់ថាជាបញ្ហាអាទិភាព និងសូចនាករ សម្រាប់កំណែទម្រង់ច្បាប់ មានសារៈប្រយោជន៏ក្នុងការអះអាងសម្រាប់ការដាក់បញ្ចូល ឬការផាត់ចេញនូវសូចនាករជាក់លាក់ ។
ការសរសេរ និងការបង្ហាញ : ការសរសេរ ការបោះពុម្ពផ្សាយ និងការបង្ហាញដោយអ្នកជំនាញ ជាពិសេស អ្នកឯកទេសអំពីយេនឌ័រ និងច្បាប់ និងអ្នកតស៊ូមតិដើម្បីស្ត្រីអំពីតម្រូវការក្នុងការកែទម្រង់ច្បាប់ជាក់លាក់មួយចំនួន ដើម្បីសម្រេចបានសមភាព ក៏មានសារៈសំខាន់ផងដែរ ។

### ការពន្យល់ដោយអោយជាឧទាហរណ៏ទៅលើជំហានទី ៤

សូមមើល**ឧទាហរណ៏ទី ៣, ៥ និងទី ៦** សម្រាប់ការពន្យល់ទៅលើជំហានទី ៤។ សម្រាប់ឧទាហរណ៏នៃសូចនាករនានា ដែលបានមកពីមាត្រានីមួយៗនៃ CEDAW សូមមើលឧបសម្ព័ន្ធទី ១។

## ការពន្យល់ដោយអោយជាឧទាហរណ៍ទៅលើជំហានទី ១-៤

ដោយប្រើប្រាស់អាពាហ៍ពិពាហ៍ជាប្រធានបទនៅក្រោមការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ខាងក្រោមគឺជាឧទាហរណ៍អំពីរបៀបដែលជំហានទី ១-៤ មានរូបរាងនៅក្នុង ទម្រង់ម៉ាទ្រីស។

### ឧទាហរណ៍ទី ៣ : ការពន្យល់ដោយអោយជាឧទាហរណ៍ទៅលើជំហានទី ១-៤ សម្រាប់សិទ្ធិស្មើគ្នាក្នុងអាពាហ៍ពិពាហ៍

| ជំហានទី ១<br>កាតព្វកិច្ច CEDAW* | ជំហានទី ២<br>ស្ថានភាព បញ្ហា និងកង្វល់** | ជំហានទី ៣<br>ចំណុចចាំបាច់នៅក្នុងច្បាប់ | ជំហានទី ៤<br>សូចនាករផ្អែកច្បាប់នៃ CEDAW |
|---|---|---|---|
| **ការរៀបអាពាហ៍ពិពាហ៍**<br>មាត្រា ១៦.១( ក និង ខ) អនុសាសន៍ទូទៅទី ២១ កថាខ័ណ្ឌទី ១៤-១៦, ២៥-៣៩ និងការអង្កេតសន្និដ្ឋានអំពីប្រទេស ប្រសិនបើពាក់ព័ន្ធ។<br>CEDAW តម្រូវអោយរដ្ឋធានាវិធានការសមស្របទាំងឡាយដើម្បីធានា :<br>- សិទ្ធិដូចគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍<br>- សិទ្ធិដូចគ្នាក្នុងការជ្រើសរើសគូស្រករដោយសេរី<br>- សិទ្ធិដូចគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ដោយគ្មានការបង្ខិតបង្ខំ និងដោយស្ម័គ្រចិត្ត<br>- អាយុអប្បបរមានៃអាពាហ៍ពិពាហ៍និងការភ្ជាប់ពាក្យនៅអាយុ ១៨ ឆ្នាំ<br>- ការចុះបញ្ជីអាពាហ៍ពិពាហ៍ជាកាតព្វកិច្ច។ | • អាពាហ៍ពិពាហ៍ដោយគ្មានការយល់ព្រមពីសាមីខ្លួន<br>• ពហុពន្ធភាព<br>• អាពាហ៍ពិពាហ៍វ័យក្មេង/អាពាហ៍ពិពាហ៍កុមារ (អាយុអប្បបរមាក្រោម ១៨ ឆ្នាំ)<br>• អាយុខុសគ្នានៃអាពាហ៍ពិពាហ៍ (បុរសនិងស្ត្រីពុំមានអាយុដូចគ្នា)<br>• ការភ្ជាប់ពាក្យក្មេងស្រីមុនអាយុ ១៨ ឆ្នាំ<br>• ប្រព័ន្ធចុះបញ្ជីអាពាហ៍ពិពាហ៍ពុំមានប្រសិទ្ធភាព<br>• ប្រព័ន្ធចុះបញ្ជីកំណើតពុំមានប្រសិទ្ធភាព<br>• បណ្ណាការ<br>• ការហាមឃាត់អាពាហ៍ពិពាហ៍ឡើងវិញសម្រាប់ស្ត្រីមេម៉ាយ<br>• ការយល់ព្រមរបស់ម្តាយមិនមានទម្ងន់ស្មើគ្នានៅក្នុងអាពាហ៍ពិពាហ៍របស់កូនខ្លួន។ | • អាពាហ៍ពិពាហ៍ដោយមានការយល់ព្រមពីសាមីខ្លួនប៉ុណ្ណោះ<br>• ការហាមឃាត់អាពាហ៍ពិពាហ៍ជំនួស<br>• ការហាមឃាត់ពហុពន្ធភាព<br>• ពុំមានអាពាហ៍ពិពាហ៍មានសុពលភាពក្រោមអាយុ ១៨ ឆ្នាំ<br>• អាយុដូចគ្នាក្នុងអាពាហ៍ពិពាហ៍សម្រាប់បុរសនិង ស្ត្រី<br>• ពុំមានការភ្ជាប់ពាក្យក្រោមអាយុ ១៨ ឆ្នាំ<br>• ការចុះបញ្ជីកំណើតអាពាហ៍ពិពាហ៍ និងការលែងលះ គឺជាការចាំបាច់<br>• ការហាមឃាត់បណ្ណាការ<br>• ពុំមានការហាមឃាត់ចំពោះការរៀបអាពាហ៍ពិពាហ៍ឡើងវិញនៃស្ត្រីមេម៉ាយ<br>• ការយល់ព្រមរបស់ម្តាយមានទម្ងន់ស្មើគ្នានៅក្នុងអាពាហ៍ពិពាហ៍របស់កូនខ្លួន។ | ១. តើច្បាប់តម្រូវអោយមានការយល់ព្រមពីសាមីខ្លួនទាំងពីរ នាក់ចំពោះអាពាហ៍ពិពាហ៍ឬទេ ?<br>២. តើទ្វេពន្ធភាព និងពហុពន្ធភាពត្រូវបានហាមឃាត់ឬទេ ?<br>៣. តើមានអាយុអប្បបរមា១៨ឆ្នាំស្មើគ្នាសម្រាប់អាពាហ៍ពិពាហ៍ឬទេ ?<br>៤. តើការចុះបញ្ជីកំណើតនៅការិយាល័យអត្រានុកូលដ្ឋានផ្លូវការ គឺជាការចាំបាច់ឬទេ ?<br>៥. តើច្បាប់តម្រូវអោយមានការចុះបញ្ជីអាពាហ៍ពិពាហ៍នៅការិយាល័យអត្រានុកូលដ្ឋានផ្លូវការឬទេ ?<br>៦. តើការប្រើបណ្ណាការជាលក្ខខណ្ឌសម្រាប់អាពាហ៍ពិពាហ៍ ត្រូវបានហាមឃាត់ឬទេ ?<br>៧. តើគ្មានការកំហិតណាមួយលើការរៀបអាពាហ៍ពិពាហ៍ឡើង វិញសម្រាប់ស្ត្រីមេម៉ាយទេឬ?<br>៨. ប្រសិនបើជំរុំទាន ឬការយល់ព្រមពីឪពុកម្តាយ គឺជាការចាំបាច់ តើការយល់ព្រមរបស់ឪពុកម្តាយមានចំនួនស្មើគ្នាឬទេ ? |

| | | | |
|---|---|---|---|
| **សិទ្ធិក្នុងអំឡុង និងក្រោយអាពាហ៍ពិពាហ៍**<br>មាត្រា ១៦ ត, ន និង ជ មាត្រា ១៥ អនុសាសន៍ទូទៅទី ២១ កថាខ័ណ្ឌទី ១៧-១៨, ២៤-២៩ និង ការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ ។<br>សិទ្ធិផ្ទាល់ខ្លួន<br>CEDAW តម្រូវអោយរដ្ឋជាភាគីធានាការសមស្របទាំងឡាយដើម្បីធានា :<br>- សិទ្ធិ និងទំនួលខុសត្រូវដូចគ្នាក្នុងអាពាហ៍ពិពាហ៍<br>- សិទ្ធិ និងទំនួលខុសត្រូវផ្ទាល់ខ្លួនដូចគ្នានៅពេលរំលាយអាពាហ៍ពិពាហ៍ សិទ្ធិផ្ទាល់ខ្លួនដូចគ្នាក្នុងនាមជាស្វាមី និងភរិយាក្នុងការជ្រើសរើសនាមត្រកូល ។<br>***សិទ្ធិលើទ្រព្យសម្បត្តិ***<br>CEDAW តម្រូវអោយរដ្ឋជាភាគីធានាការសមស្របទាំងឡាយ ដើម្បីធានា :<br>- សិទ្ធិដូចគ្នាក្នុងនាមជាស្វាមីភរិយាទាក់ទងនឹងភាពជាកម្មសិទ្ធិ ការទិញ ការចាត់ចែង ការគ្រប់គ្រង ការអាស្រ័យផល និងការលក់ទ្រព្យសម្បត្តិ<br>- សមត្ថភាពផ្លូវច្បាប់ស្មើគ្នា និងឱកាសស្មើគ្នាក្នុងការអនុវត្តសមត្ថភាពនោះ រួមទាំងសិទ្ធិបញ្ចប់កិច្ចសន្យា វិជ្ជាជីវៈ និងមុខរបរ ។ | • អសមត្ថភាពក្នុងការផ្តួចផ្តើមបណ្តឹងដោយគ្មានការយល់ព្រមពីស្វាមី<br>• លំនៅដ្ឋានរបស់ស្វាមី ត្រូវបានចាត់ទុកដោយស្វ័យប្រវត្តិថាជាលំនៅដ្ឋានរបស់ភរិយា<br>• ការប្រើប្រាស់ដោយបង្ខំនូវនាមត្រកូលរបស់ប្តី<br>• អសមត្ថភាពក្នុងការចូលរួមនៅក្នុងវិជ្ជាជីវៈ ប្រសិនបើគ្មានការអនុញ្ញាតពីសហព័ទ្ធ ឬគ្រួសារ<br>• មូលហេតុផ្សេងៗគ្នាសម្រាប់ការលែងលះ (បុរស និងស្ត្រីពុំមានមូលហេតុដូចគ្នាសម្រាប់ការលែងលះ)<br>• សិទ្ធិមានកម្រិតក្នុងការចាត់វិធានការលែងលះ<br>• ចំណែកមិនស្មើគ្នានៅក្នុងទ្រព្យសម្បត្តិ អាពាហ៍ពិពាហ៍<br>• ពុំមានសិទ្ធិក្នុងការទិញ ប្រើប្រាស់ ចាត់ចែង ឬលក់ ទ្រព្យសម្បត្តិ<br>• មិនចាំបាច់មានការយល់ព្រមពីភរិយាក្នុងការលក់ទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ | • សិទ្ធិស្មើគ្នាក្នុងការផ្តួចផ្តើមបណ្តឹង<br>• សិទ្ធិស្មើគ្នាក្នុងការជ្រើសរើសលំនៅដ្ឋាន<br>• សិទ្ធិស្មើគ្នាក្នុងការអនុវត្តវិជ្ជាជីវៈ ឬមុខរបរដោយមិនចាំបាច់ការយល់ព្រមពីសហព័ទ្ធ ឬគ្រួសារ<br>• មូលហេតុដូចគ្នាសម្រាប់ការលែងលះ<br>• សិទ្ធិស្មើគ្នាក្នុងការចាត់វិធានការលែងលះ<br>• ចំណែកស្មើគ្នានៅក្នុងទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍<br>• សមត្ថភាពក្នុងការទិញ ប្រើប្រាស់ ចាត់ចែង និងលក់ទ្រព្យសម្បត្តិ ដោយមិនគិតអំពីស្ថានភាពអាពាហ៍ពិពាហ៍<br>• ការយល់ព្រមពីសំណាក់ស្វាមីភរិយា គឺជាការចាំបាច់សម្រាប់ការលក់ទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍<br>• ការរួមចំណែកជាហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុផ្តល់ទម្ងន់ស្មើគ្នាក្នុងការបែងចែកទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍<br>• ច្បាប់ស្តីពីការចុះបញ្ជីទ្រព្យសម្បត្តិតម្រូវថាទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ត្រូវចុះបញ្ជីក្នុងឈ្មោះរបស់សហព័ទ្ធទាំងពីរ<br>• ឋានៈស្មើគ្នាក្នុងនាមជាអ្នកទទួលមរតក<br>• ចំណែកមរតកស្មើគ្នា<br>• សិទ្ធិដូចគ្នាចំពោះទ្រព្យសម្បត្តិជាមរតកក្នុងនាមជាអ្នកទទួលមរតក<br>• ទម្ងន់ស្មើគ្នាត្រូវបានផ្តល់ចំពោះការរួមចំណែកជាហិរញ្ញវត្ថុ និងមិនមែនជាហិរញ្ញវត្ថុក្នុងអំឡុងពេលបែងចែកទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងការរួមរស់ជាមួយគ្នា ។ | ៩. តើស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាក្នុងការផ្តួចផ្តើមបណ្តឹងដោយមិនគិតអំពីស្ថានភាពអាពាហ៍ពិពាហ៍ឬទេ ?<br>១០. តើច្បាប់អនុញ្ញាតអោយស្ត្រីបង្កើតលំនៅដ្ឋានផ្ទាល់ខ្លួន ដោយមិនគិតអំពីស្ថានភាពអាពាហ៍ពិពាហ៍ឬទេ ?<br>១១. តើបុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់នាមត្រកូល ឬទេ ?<br>១២. តើស្វាមីភរិយាមានសិទ្ធិស្មើគ្នាក្នុងការជ្រើសរើស និងអនុវត្តវិជ្ជាជីវៈរបស់ខ្លួនឬទេ ?<br>១៣. តើច្បាប់ចែងអំពីការបែងចែកស្មើគ្នានូវទ្រព្យសម្បត្តិ និង ចំណូលដែលរកបានក្នុងអំឡុងអាពាហ៍ពិពាហ៍ដែរឬទេ ជាពិសេសតើផ្តល់ទម្ងន់ស្មើគ្នាដល់ការរួមចំណែកផ្នែកហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ (ឧទាហរណ៍ ការងារផ្ទះ និងការមើលថែទាំកូន) ចំពោះគ្រួសារឬទេ ?<br>១៤. តើសហព័ទ្ធទាំងពីរ (ស្វាមី និងភរិយា) មានភាពស្មើគ្នានៅក្នុងកម្មសិទ្ធិការទិញ ការចាត់ចែងការគ្រប់គ្រងការប្រើប្រាស់និងការលក់ទ្រព្យសម្បត្តិឬទេ ?<br>១៥. តើច្បាប់តម្រូវអោយមានការយល់ព្រមពីសហព័ទ្ធទាំងពីរសម្រាប់ការលក់ទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ឬទេ ?<br>១៦. តើច្បាប់តម្រូវអោយទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ត្រូវបានចុះបញ្ជីក្នុងឈ្មោះរបស់សហព័ទ្ធទាំងពីរឬទេ ?<br>១៧. តើស្ត្រី និងបុរសមានឋានៈស្មើគ្នាក្នុងនាមជាអ្នកទទួលមរតក ឬទេ ?<br>១៨. តើស្ត្រី និងបុរសមានសិទ្ធិទទួលចំណែកមរត |

| | | | |
|---|---|---|---|
| | | | កស្មើគ្នាឬទេ ?<br>១៩. តើស្ត្រី និងបុរសមានសិទ្ធិដូចគ្នាចំពោះទ្រព្យសម្បត្តិជាមរតក ឬទេ ?<br>២០. តើច្បាប់ចែងអំពីការបែងចែកស្មើគ្នានូវទ្រព្យសម្បត្តិ និងចំណូលដែលរកបានក្នុងអំឡុងការរួមរស់ជាមួយគ្នា ដោយមិនគិតពីអាពាហ៍ពិពាហ៍ (ការរស់នៅជាមួយគ្នាជាក់ស្តែង) ផ្តល់ទម្ងន់ស្មើគ្នាចំពោះការរួមចំណែកជាហិរញ្ញវត្ថុ និងមិនមែនជាហិរញ្ញវត្ថុឬទេ ?<br>២១. តើច្បាប់ចែងអំពីការថែទាំ ឬការឧបត្ថម្ភចំពោះអតីតសហព័ទ្ធ ក្រោយពីការលែងលះដែរឬទេ ផ្អែកលើសេចក្តីត្រូវការទ្រព្យសម្បត្តិ និងសមត្ថភាពរកចំណូល ? |
| **សិទ្ធិទាក់ទងនឹងកុមារ**<br>មាត្រា ១៦ ឃ និង ឆ និងអនុសាសន៍ទូទៅទី ២១ កថាខ័ណ្ឌទី ១៩-២០ និង ការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ ។<br>CEDAW តម្រូវអោយរដ្ឋធានាទ្បានការសមស្រប ទាំងឡាយ ដើម្បីធានា :<br>- សិទ្ធិ និងទំនួលខុសត្រូវដូចគ្នាក្នុងនាមជាឪពុកម្តាយ ដោយមិនគិតពីស្ថានភាពអាពាហ៍ពិពាហ៍<br>- សិទ្ធិ និងទំនួលខុសត្រូវដូចគ្នាទាក់ទងនឹងអាណាព្យាបាលភាព ភាពស្ថិតក្រោមអាណាព្យាបាល អាណត្តិព្យាបាលភាព និងការសុំកូន ។ | • ពុំមានទំនួលខុសត្រូវរួមក្នុងការថែរក្សាការពារ និងថែទាំកូន<br>• ពុំមានភាពជាអាណាព្យាបាលរួមគ្នាចំពោះកូនរួម (ឪពុកគឺជាអាណាព្យាបាលរបស់កូន)<br>• អសមត្ថភាពក្នុងការសុំកូនចិញ្ចឹម (ស្ត្រីមិនអាចសុំកូនចិញ្ចឹម)<br>• ការឧបត្ថម្ភកូនមិនត្រូវបានផ្តល់អោយក្រោយពីការលែងលះ ។ | • ទំនួលខុសត្រូវស្មើគ្នាក្នុងការថែរក្សាការពារ និងថែទាំកូន<br>• សិទ្ធិស្មើគ្នាចំពោះអាណាព្យាបាលភាព<br>• ស្ត្រីត្រូវបានអនុញ្ញាតអោយសុំកូនចិញ្ចឹមដោយមិនគិតពីស្ថានភាពអាពាហ៍ពិពាហ៍<br>• ការឧបត្ថម្ភកូន គឺជាការចាំបាច់ ។ | ២២. តើច្បាប់តម្រូវអោយឪពុកម្តាយឧបត្ថម្ភកូនរួមដោយមិនគិតអំពីស្ថានភាពអាពាហ៍ពិពាហ៍ឬទេ ?<br>២៣. តើការគ្រប់គ្រង និងការទទួលបានកូនផ្អែកលើឧត្តមប្រយោជន៍ របស់កូនឬទេផ្អែកលើស្ថានភាពអាពាហ៍ពិពាហ៍របស់ ឪពុកម្តាយ?<br>២៤. តើស្ត្រីនិងបុរសមានសិទ្ធិអាណាព្យាបាលភាពស្មើគ្នាឬទេ ?<br>២៥. តើស្ត្រីត្រូវបានអនុញ្ញាតអោយសុំកូនចិញ្ចឹមដែរឬទេ ដោយមិនគិតពីស្ថានភាពអាពាហ៍ពិពាហ៍ ?<br>២៦. តើច្បាប់ចែងអំពីការផ្តល់ប្រាក់ឧបត្ថម្ភចំពោះកូនក្រោយពេល លែងលះដែរឬទេ ? |

| | | | |
|---|---|---|---|
| **សិទ្ធិផ្លូវភេទ និងសិទ្ធិបន្តពូជ**<br>មាត្រា ១៦.៦ អនុសាសន៍ទូទៅ កថាខ័ណ្ឌទី ២១-២៣<br>CEDAW តម្រូវអោយរដ្ឋចាត់វិធានការសមស្រប ទាំងឡាយដើម្បីធានា :<br>- សិទ្ធិដូចគ្នាក្នុងនាមជាឪពុកម្តាយក្នុងការសម្រេចចិត្តដោយសេរី និងដោយមានទំនួលខុសត្រូវចំពោះចំនួនកូន និងការពន្យារកំណើត ។<br>- សិទ្ធិដូចគ្នាក្នុងការទទួលបានព័ត៌មានការអប់រំ និងមធ្យោបាយប្រើប្រាស់សិទ្ធិខាងលើ ។ | • ការចងដៃស្បូនដោយបង្ខំ<br>• កង្វះព័ត៌មានអំពីសិទ្ធិផ្លូវភេទ និងសិទ្ធិបន្តពូជ ។ | • ទណ្ឌកម្មសម្រាប់ការចងដៃស្បូនដោយបង្ខំ<br>• ព័ត៌មានពេញលេញអំពីសិទ្ធិផ្លូវភេទ និងសិទ្ធិបន្តពូជចាំបាច់ត្រូវតែផ្តល់ជូនអតិថិជនដែលស្វែងរកសេវាសុខភាព<br>• យុទ្ធនាការព័ត៌មានសាធារណៈអំពីសិទ្ធិផ្លូវភេទ និងសិទ្ធិបន្តពូជ ។ | ២២. តើច្បាប់តម្រូវអោយឪពុកម្តាយឧបត្ថម្ភកូនរួមដោយមិនគិតអំពីស្ថានភាពអាពាហ៍ពិពាហ៍ឬទេ ?<br>២៣. តើការគ្រប់គ្រង និងការទទួលបានកូនផ្អែកលើឧត្តមប្រយោជន៍ របស់កូនឬទៅផ្អែកលើស្ថានភាពអាពាហ៍ពិពាហ៍របស់ ឪពុកម្តាយ?<br>២៤. តើស្ត្រីនិងបុរសមានសិទ្ធិអាណាព្យាបាលភាពស្មើគ្នាឬទេ ?<br>២៥. តើស្ត្រីត្រូវបានអនុញ្ញាតអោយសុំកូនចិញ្ចឹមដែរឬទេ ដោយមិនគិតពីស្ថានភាពអាពាហ៍ពិពាហ៍ ?<br>២៦. តើច្បាប់ចែងអំពីការផ្តល់ប្រាក់ឧបត្ថម្ភចំពោះកូនក្រោយពេល លែងលះដែរឬទេ ? |

*នៅក្នុងឧទាហរណ៍នេះ ជម្រើសទី ៣ (សង្ខេបប្រធានបទ) សម្រាប់ជំហានទី ១ ត្រូវបានប្រើប្រាស់ ។

**នៅក្នុងឧទាហរណ៍នេះ ជម្រើសទី ២ (ភាសាផ្អែកលើបញ្ហា) សម្រាប់ជំហានទី ២ ត្រូវបានប្រើប្រាស់ ។

## ការកំណត់អនុលោមភាព និងអនុសាសន៍

**ជំហានទី ៥ : វាយឈ្មោះច្បាប់ដែលពាក់ព័ន្ធ** → ជំហានទី ៦ : វិភាគអនុលោមភាព → ជំហានទី ៧ : ធ្វើសេចក្តីពាងការពន្យល់ និងមតិយោបល់ → ជំហានទី ៨ : រៀបចំអនុសាសន៍

ដោយមានសូចនាករផ្អែកច្បាប់នៃ CEDAW ឥឡូវនេះអ្នករួចរាល់ក្នុងការចូលទៅកាន់ជំហានបន្ទាប់ ដើម្បីកំណត់ថាតើច្បាប់ពាក់ព័ន្ធអនុលោមតាមសូចនាករឬទេ ។

**១. កំណត់ច្បាប់ដែលពាក់ព័ន្ធនឹងសូចនាករនីមួយៗ**

ប្រភេទនៃច្បាប់ដែលនឹងត្រូវកំណត់ គឺអាស្រ័យលើសេចក្តីសម្រេចដែលធ្វើឡើងជាមុនអំពីវិសាលភាពនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ។ ( សូមមើលផ្នែកទី ៣)

**២. បង្ហាញច្បាប់តាមរបៀបដែលត្រូវបានរៀបចំរចនាសម្ព័ន្ធជាមុន**

អ្នកអាចជ្រើសរើសសរសេរ ( ក) អត្ថបទពេញលេញ ( ខ) ការដកស្រង់ដោយសង្ខេប ឬ ( គ) ការដកស្រង់ដោយសង្ខេបជាមួយសេចក្តីសង្ខេបនៃខ្លឹមសារនៃបញ្ញត្តិ ។

***ជម្រើសទី ១ : អត្ថបទពេញលេញ :*** នេះមានន័យថា ការបង្ហាញអត្ថបទពេញលេញនៃច្បាប់ ។

- គុណសម្បត្តិ : អ្នកអានអាចយល់ភ្លាមៗអំពីថាតើអ្វីទៅជាបញ្ញត្តិពិតប្រាកដនៃច្បាប់ ដោយមិនចាំបាច់ទទួលបានឯកសារដទៃទៀត ។
- គុណវិបត្តិ : បញ្ញត្តិនៃច្បាប់អាចមានលក្ខណៈវែងអន្លាយ ឬច្រំដែល ។ ក្នុងករណីជាច្រើន ភាសាច្បាប់មានការពិបាកយល់សម្រាប់អ្នកទាំងឡាយណាដែលមិនពាក់ព័ន្ធក្នុងវិស័យច្បាប់ ។

***ជម្រើសទី ២ : ការដកស្រង់ដោយសង្ខេប :*** នេះមានន័យថា គ្រាន់តែជាការដកស្រង់ច្បាប់ និងមាត្រា ឬផ្នែកជាក់លាក់នៃច្បាប់ប៉ុណ្ណោះ ឧទាហរណ៍មាត្រា ៥ នៃរដ្ឋធម្មនុញ្ញ ឬផ្នែកទី ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ អ្នកស្នើជម្រើសទី ២ ចង្អុលបង្ហាញថា ឯកសារពាក់ព័ន្ធអាចត្រូវបានបន្ថែមនៅក្នុងសេចក្តីបន្ថែម ឬឧបសម្ព័ន្ធ ។

- គុណសម្បត្តិ : វិធីសាស្ត្រនេះចៀសវាងបញ្ញត្តិវែងអន្លាយ និងច្រំដែល ។ វាអាចសន្សំទំព័រ ។
- គុណវិបត្តិ : បញ្ញត្តិនៃច្បាប់មិនអាចរកបាននៅពេលក្រឡេកមើលដំបូងទេ ។ ការធ្វើបែបនេះរារាំងដល់ការអានច្បាប់អោយបានស៊ីជំរៅ ។ វាក៏ដាក់បន្ទុកផងដែរទៅលើអ្នកអានក្នុងការពិនិត្យមើលច្បាប់ដែលបានដកស្រង់ ។ ប្រការនេះអាចមានលក្ខណៈមិនងាយស្រួលសម្រាប់ពួកគេ ប្រសិនបើពួកគេមិនអាចទទួលបានច្បាប់យ៉ាងងាយស្រួល ឬមិនដឹងអំពីរបៀបទទួលបានច្បាប់ទាំងនេះ ។

***ជម្រើសទី ៣ : ការសង្ខេបដកស្រង់ខ្លីៗ និងសេចក្តីសង្ខេប :*** នេះមានន័យថា ការដកស្រង់ដោយសង្ខេបខ្លីៗ និងសេចក្តីសង្ខេបនៃចំណុច សំខាន់ៗនៃច្បាប់ ។

ការដកស្រង់នេះអាចត្រូវបានធ្វើឡើងតាមវិធីពីរយ៉ាង : (ក) ការដកស្រង់ដោយសង្ខេបសិន រួចហើយសេចក្តីសង្ខេបត្រួសៗអំពីបញ្ញត្តិដែលត្រូវបានដកស្រង់ ឬ (ខ) សេចក្តីសង្ខេបត្រួសៗសិន រួចហើយបញ្ញត្តិដែលត្រូវបានដកស្រង់ ។

- គុណសម្បត្តិ : អត្ថបទវែងអន្លាយ និងច្រំដែលត្រូវបានចៀសវាងនៅពេលប្រើប្រាស់វិធីសាស្រ្តនេះ ។ ជាងនេះទៅទៀតអ្នកអានអាចយល់ភ្លាមៗអំពីចំណុចសំខាន់ៗនៃច្បាប់ ។ វាក៏អាចងាយស្រួលយល់ចំពោះអ្នកអានដែលមិនសូវដឹងភាសាច្បាប់ ។
- គុណវិបត្តិ : វិធីសាស្រ្តនេះតម្រូវអោយមានកិច្ចប្រឹងប្រែង និងពេលវេលាបន្ថែម ដោយសារបញ្ញត្តិច្បាប់នឹងត្រូវសំយោគ ។

ជម្រើស ឬបន្សំនៃជម្រើសដែលអ្នកប្រើ អាស្រ័យលើគោលបំណងនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ និងអ្នកទទួលផលគោលដៅរបស់ខ្លួន ។ ការពិគ្រោះយោបល់ជាមួយអ្នកទទួលផល និងអ្នកជំនាញ នឹងជួយដល់ដំណើរការជ្រើសរើសជម្រើសដែលប្រសើរបំផុតសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់របស់អ្នក ។

**៣. ពិនិត្យមើលច្បាប់ទាក់ទងនឹងស្រ្តី ឬច្បាប់ដែលមានភាពជាក់លាក់ផ្នែកយេនឌ័រ និងច្បាប់ដែលអនុវត្តជាទូទៅ**

មាននិន្នាការមួយឆ្ពោះទៅរកការផ្តោតលើច្បាប់ទាក់ទងនឹងស្រ្តីឬច្បាប់ដែលមានភាពជាក់លាក់ផ្នែកយេនឌ័រនិងមិនអើពើចំពោះច្បាប់ដែលអនុវត្តជាទូទៅ ។ ប្រការនេះគប្បីត្រូវចៀសវាង ។ ក្នុងករណីខ្លះ ច្បាប់ដែលអនុវត្តជាទូទៅអាចមានការការពារផ្នែកច្បាប់គ្រប់គ្រាន់ ។[១៣] ផ្ទុយមកវិញច្បាប់ទាំងនេះអាចមិនអើពើចំពោះស្ថានភាពជាក់ស្តែងរបស់ស្រ្តី ។[១៤] ដូច្នេះការវិភាគច្បាប់ទាំងនេះបន្ថែមលើច្បាប់ទាក់ទងនឹងស្រ្តី ឬច្បាប់ដែលមានភាពជាក់លាក់ផ្នែកយេនឌ័រ គឺជាការសំខាន់ ។ ក្នុងករណីដែលពុំមានច្បាប់ពាក់ព័ន្ធ វាគួរត្រូវបានឆ្លុះបញ្ចាំងនៅក្នុងជំហានទី ៥ ។

[១៣] ឧទាហរណ៍សូចនាករមួយដែលថែងថា: "តើជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារមានសិទ្ធិទទួលបានសំណងឬទេ?" អាចតម្រូវអោយមានចម្លើយដែលមិនមាននៅក្នុងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសាររបស់ប្រទេស ។ ផ្ទុយមកវិញ ចម្លើយអាចមាននៅក្នុងក្រមរដ្ឋប្បវេណីក្រមព្រហ្មទណ្ឌ ឬក្រមនីតិវិធីរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ដែលចែងអំពីវិធានស្តីពីសំណង ។

[១៤] ឧទាហរណ៍សូចនាករមួយដែលសួរថា: "តើសហព័ទ្ធមានសិទ្ធិស្មើគ្នាឬទេក្នុងការចុះបញ្ជីទ្រព្យសម្បត្តិរួមក្នុងឈ្មោះរបស់ពួកគេ?" តម្រូវអោយគេពិនិត្យមើលច្បាប់ស្តីពីការចុះបញ្ជី ឬច្បាប់ស្តីពីទ្រព្យសម្បត្តិ ជាពិសេស នៅពេលដែលច្បាប់ទាក់ទងនឹងស្រ្តី ឬច្បាប់ដែលមានភាពជាក់លាក់ផ្នែកយេនឌ័រមិនបានគ្របដណ្តប់លើប្រធានបទនេះ ។ ក្នុងករណីជាច្រើន ច្បាប់ស្តីពីការចុះបញ្ជី ឬច្បាប់ស្តីពីទ្រព្យសម្បត្តិអាចមានបញ្ញត្តិទូទៅអំពីសិទ្ធិស្មើគ្នាក្នុងការចុះបញ្ជី ប៉ុន្តែអាចមិនអើពើចំពោះទ្រព្យសម្បត្តិមួយចំនួនតូចដែលចុះបញ្ជីរួមគ្នានៅក្នុងឈ្មោះរបស់សហព័ទ្ធទាំងពីរ ។

## ការពន្យល់ដោយអោយជាឧទាហរណ៍ទៅលើជំហានទី ៥

### ឧទាហរណ៍ទី ៤ : ការបង្ហាញជាឧទាហរណ៍ទៅលើជម្រើសផ្សេងៗនៃជំហានទី ៥ (វាយឈ្មោះច្បាប់ពាក់ព័ន្ធ) ដោយប្រើច្បាប់កម្ពុជា

| ជម្រើសទី ១ : អត្ថបទពេញលេញ | ជម្រើសទី ២ : ការដកស្រង់ដោយសង្ខេប | ជម្រើសទី ៣ : ការដកស្រង់ ដោយសង្ខេប និងសេចក្តីសង្ខេប |
|---|---|---|
| **មាត្រា ៣១ រដ្ឋធម្មនុញ្ញ :** "...ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ មិនត្រូវអោយប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់" ។<br>**មាត្រា ១២ ច្បាប់ស្តីពីការងារ :** "វៀរលែងតែមានបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនេះបញ្ជាក់ច្បាស់ ឬអត្ថបទដទៃទៀតដែលមានលក្ខណៈជាច្បាប់ ឬជាបទបញ្ជាដែលការពារស្ត្រី និងកូនក្មេង ក៏ដូចជាបទបញ្ញត្តិទាំងឡាយដែលទាក់ទងនឹងការចូលមកក្នុងប្រទេស និងការស្នាក់នៅនៃជនបរទេសបញ្ជាក់ច្បាស់ គ្មាននិយោជកណាម្នាក់អាចយកបញ្ហា :<br>• ពូជសាសន៍<br>• ពណ៌សម្បុរ<br>• ភេទ<br>• ជំនឿ<br>• សាសនា<br>• គំនិតនយោបាយ<br>• ជាតិកំណើត<br>• ដើមកំណើតសង្គម<br>• ការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីព<br>ដើម្បីជាលេសធ្វើសេចក្តីសម្រេចអំពី :<br>• ការជួល<br>• ការកំណត់ និងការបែងចែកការងារ<br>• ការបណ្តុះបណ្តាលវិជ្ជាជីវៈ<br>• ការតម្លើងថ្នាក់<br>• ការតម្លើងឋានន្តរស័ក្តិ | **មាត្រា ៣១ រដ្ឋធម្មនុញ្ញ**<br>**មាត្រា ១២ ច្បាប់ស្តីពីការងារ** | **មាត្រា ៣១ រដ្ឋធម្មនុញ្ញ :** (មាត្រានេះធានានូវសិទ្ធិសេរីភាព និងករណីយកិច្ចស្មើគ្នាដោយឥតប្រកាន់ពូជសាសន៍ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់មិនត្រូវអោយប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ) ។<br>**មាត្រា ១២ ច្បាប់ស្តីពីការងារ :** (វៀរលែងតែមានច្បាប់ឬបទបញ្ញត្តិផ្ទុយពីនេះគ្មាននិយោជកណាម្នាក់អាចយកបញ្ហាពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា គំនិតនយោបាយ ជាតិកំណើត ដើមកំណើតសង្គម ការចូលជាសមាជិកសហជីពកម្មករ និយោជិត ឬការធ្វើសកម្មភាពក្នុងសហជីព ដើម្បីធ្វើសេចក្តីសម្រេចអំពីការជួល ការបែងចែកការងារ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការតម្លើងថ្នាក់ ការតម្លើងឋានន្តរស័ក្តិ ការផ្តល់កម្រៃ ការផ្តល់អត្ថប្រយោជន៍សង្គមវិន័យ ឬការផ្តាច់កិច្ចសន្យាការងារ ។<br>ប៉ុន្តែការបែងចែក ការបដិសេធ ឬការព្រមទទួល ដែលផ្អែកលើ លក្ខណៈសម្បត្តិជាកំណត់សម្រាប់មុខរបរណាមួយ មិនត្រូវចាត់ ទុកជាការរើសអើងឡើយ) ។ |

| | | |
|---|---|---|
| • ការផ្តល់កម្រៃ<br>• ការផ្តល់អត្ថប្រយោជន៍សង្គម<br>• វិន័យ ឬការផ្តាច់កិច្ចសន្យាការងារ<br>ការបែងចែក ការបដិសេធ ឬការព្រមទទួល ដែលផ្អែកលើលក្ខណៈសម្បត្តិជាកំណត់សម្រាប់មុខរបរណាមួយ មិនត្រូវចាត់ទុកជាការរើសអើងឡើយ ”។ | | |

→ សូមមើលឧទាហរណ៍ទី ៥ និងទី ៦ សម្រាប់ការពន្យល់ដោយងាយជាឧទាហរណ៍បន្ថែមទៅលើជំហានទី ៥

| ជំហានទី ៥: វាយឈ្មោះច្បាប់ដែលពាក់ព័ន្ធ | **ជំហានទី ៦: វិភាគអនុលោមភាព** | ជំហានទី ៧: ធ្វើសេចក្តីព្រាងការពន្យល់និងមតិយោបល់ | ជំហានទី: រៀបចំអនុសាសន៍ |
|---|---|---|---|

ជំហានបន្ទាប់ គឺការវិភាគច្បាប់ពាក់ព័ន្ធធៀបទៅនឹងសូចនាករនៃច្បាប់ CEDAW ។

### ១. វិភាគថាតើច្បាប់ពាក់ព័ន្ធអនុលោមតាមសូចនាករឬទេ

ជម្រើសនានា ដើម្បីបង្ហាញអំពីកម្រិតនៃអនុលោមភាពអាចមានចាប់ពី :

- អនុលោមភាពពេញលេញ
- អនុលោមភាពដោយផ្នែក រហូតដល់
- គ្មានអនុលោមភាព

ខាងក្រោមនេះ គឺជាគោលការណ៍ណែនាំមួយចំនួនអំពីការសម្រេចថាតើមានអនុលោមភាពពេញលេញ អនុលោមភាពមួយផ្នែក ឬគ្មានអនុលោមភាព :

- ការគ្មានអនុលោមភាព មានន័យថា ការគ្មានបញ្ញត្តិច្បាប់ដែលឆ្លើយតបទៅនឹងសូចនាករ ។ វាក៏អាចមានន័យថា ជាអត្ថិភាពនៃច្បាប់ដែលផ្ទុយទៅនឹងសូចនាករ ឬច្បាប់ដែលមានលក្ខណៈមិនសមស្រប ។
- អនុលោមភាពមួយផ្នែកមានន័យថា បញ្ញត្តិច្បាប់មានអត្ថិភាព ប៉ុន្តែមិនគ្រប់គ្រាន់ ។ ការបង្ហាញអំពីភាពមិនគ្រប់គ្រាន់អាចមានន័យថា មានច្បាប់ល្អ ដែលមិនត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធិភាព ឬថាស្ថានភាពជាក់ស្តែងតម្រូវអោយមានការធានាផ្នែកច្បាប់បន្ថែម ។
- អនុលោមភាពពេញលេញមានន័យថា អត្ថិភាពនៃបញ្ញត្តិច្បាប់ដែលឆ្លើយតបទៅនឹងសូចនាករ ហើយពុំចាំបាច់មានបញ្ញត្តិច្បាប់បន្ថែមដើម្បីអនុលោមភាពឡើយ ។

### ២. ត្រៀមជាស្រេចសម្រាប់ទំនាស់ និងកង្វល់ដែលអាចកើតមានឡើងក្នុងអំឡុងកិច្ចពិភាក្សាអំពីអនុលោមភាពកង្វល់ជាក់លាក់ដូចខាងក្រោម ជាធម្មតាកើតមានឡើងក្នុងអំឡុងកិច្ចពិភាក្សាអំពីអនុលោមភាព :

***កង្វល់ទី ១ : កង្វះជំនាញអំពី CEDAW និងស្ថានភាពជាក់ស្តែងរបស់ស្ត្រី***

អ្នកធ្វើសេចក្តីព្រាងមួយចំនួនអនុវត្តការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ដោយមិនចាំបាច់មានចំណេះដឹងល្អអំពី CEDAW និងស្ថានភាពជាក់ស្តែងរបស់ស្ត្រីឡើយ ។ ជាលទ្ធផល ការវិភាគរបស់ពួកគេមានភាពមិនគ្រប់គ្រាន់ និងមិនមានភាពពាក់ព័ន្ធ ។ ឧទាហរណ៍ ដើម្បីឆ្លើយតបទៅនឹងសូចនាករ "តើច្បាប់ធានានូវសិទ្ធិទទួលបានមរតកស្មើគ្នាឬទេ ?" មាននិន្នាការមួយក្នុងការឆ្លើយតបថា "អនុលោមភាពពេញលេញ" ប្រសិនបើមានបញ្ញត្តិអព្យាក្រឹតផ្នែកយេនឌ័រដែលមានចែងអំពីការធានាទូទៅអំពីសិទ្ធិទទួលបានមរតកស្មើគ្នាប៉ុណ្ណោះ ។ ការវាយតម្លៃនេះអាចមិនអើពើចំពោះស្ថានភាពជាក់ស្តែងដែលស្ត្រីមិនអាចទទួលបានសិទ្ធិបែប

នេះដោយសារប្រពៃណីទំនៀមទម្លាប់ និងកង្វះការអនុវត្តរបស់រដ្ឋ។ បញ្ហានេះបង្ហាញថា មានកង្វះការយល់ដឹងអំពីបទដ្ឋាននៃ CEDAW និងលក្ខខណ្ឌតម្រូវនៃសមភាពជាពេញលេញ និងកង្វះចំណេះដឹងអំពីស្ថានភាពជាក់ស្តែង។ ចម្លើយដ៏ត្រឹមត្រូវ គឺ "អនុលោមភាពមួយផ្នែក" ដោយសារមានបញ្ញត្តិច្បាប់អំពីសិទ្ធិស្មើគ្នា ប៉ុន្តែពុំមានការធានាផ្នែកច្បាប់បន្ថែមទៀត ដើម្បីធានានូវការអនុវត្តច្បាប់ក្នុងការជំនះប្រពៃណី ឬទំនៀមទម្លាប់ដែលផ្ទុយនឹងច្បាប់។

***កង្វល់ទី ២ : កង្វះចំណេះដឹងអំពីច្បាប់ និងការតាក់តែងច្បាប់***

ដោយប្រើប្រាស់សូចនាករដូចគ្នាខាងលើ និន្នាការមួយទៀតក្នុងការឆ្លើយថា "អនុលោមភាពពេញលេញ" គឺកង្វះការយល់ដឹងអំពីច្បាប់ និងការតាក់តែងច្បាប់ ជាពិសេស អំពីអ្វីដែលអាចជាខ្លឹមសារនៃច្បាប់។ ក្នុងករណីភាគច្រើន អំណះអំណាងដែលផ្តល់អោយ គឺថា ច្បាប់មានលក្ខណៈល្អ ប៉ុន្តែការអនុវត្ត គឺជាបញ្ហា។ នៅក្នុងករណីនេះ គេចាំបាច់ត្រូវតែពិនិត្យមើលថាតើច្បាប់មានលក្ខណៈគ្រប់គ្រាន់ក្នុងការតម្រូវអោយមានការអនុវត្តប្រកបដោយប្រសិទ្ធភាពដែរឬទេ។ តើមានសេចក្តីលម្អិតសមស្របត្រូវបានចែងនៅក្នុងច្បាប់ ដើម្បីធានានូវការអនុវត្តសិទ្ធិទទួលបានមរតកស្មើគ្នាឬទេ ? ប្រសិនបើគ្មានទេ មានន័យថាមានអនុលោមភាពតែមួយផ្នែកប៉ុណ្ណោះ ដោយសារគេត្រូវការបញ្ញត្តិច្បាប់បន្ថែម ដើម្បីអនុញ្ញាតអោយមានការប្រើប្រាស់សិទ្ធិពេញលេញ។

**ការដោះស្រាយកង្វល់ទី ១ និង ២ :** ធានាថាជំនាញ និងសម្ភារៈដែលចាំបាច់អាចរកបាន មុនពេលចាប់ផ្តើមការពិនិត្យមើលឡើងវិញផ្នែកច្បាប់។ ជំនាញអំពី CEDAW ស្ថានភាពជាក់ស្តែងរបស់ស្ត្រីព្រមទាំងច្បាប់ និងការតាក់តែងច្បាប់ គឺជាកត្តាចាំបាច់ដែលមិនអាចខ្វះបានក្នុងការធ្វើសេចក្តីព្រាងការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើCEDAW។ ប្រសិនបើជំនាញមិនអាចរកបានភ្លាមៗទេត្រូវអញ្ជើញអ្នកជំនាញអោយចូលរួមនៅក្នុងក្រុមធ្វើសេចក្តីព្រាងឬអោយផ្តល់ជំនួយបច្ចេកទេស។ ប្រសិនបើសម្ភារមិនអាចទទួលបានយ៉ាងងាយស្រួលទេ ត្រូវចូលរួមនៅក្នុងការស្រាវជ្រាវ ដើម្បីស្វែងរកឯកសារទាំងនេះ។

**កង្វល់ទី ៣ : ទិន្នន័យមិនគ្រប់គ្រាន់ក្នុងការវាស់វែងការអនុវត្តច្បាប់ជាក់ស្តែង**

ប្រសិនបើគ្មានទិន្នន័យគ្រប់គ្រាន់ដើម្បីវាស់វែងការអនុវត្តច្បាប់ជាក់ស្តែងទេនោះ ការវាយតម្លៃឥទ្ធិពល និងប្រសិទ្ធភាពរបស់វាមានការលំបាក។

**ការដោះស្រាយកង្វល់ទី ៣ :** ស្វែងរកទិន្នន័យដែលវាស់វែងការអនុវត្តជាក់ស្តែងនៃច្បាប់អោយបានឆាប់នៅក្នុងដំណើរការពិនិត្យមើលឡើងវិញ។ នៅក្នុងប្រទេសជាច្រើន ទិន្នន័យនេះមិនអាចរកបានភ្លាមៗទេ។ ការស្រាវជ្រាអោយបានឆាប់រហ័សទៅលើបញ្ហានេះនឹងអនុញ្ញាតអោយមានពេលវេលាគ្រប់គ្រាន់ដើម្បីបង្ហាញព័ត៌មានដែលចាំបាច់ឬផ្តួចផ្តើមការប្រមូលទិន្នន័យថ្មីៗ ឬការប្រៀបធៀបទិន្នន័យ។

*កង្វល់ទី ៤ : សេចក្ដីត្រូវការដើម្បីអោយមានតុល្យភាព*

អ្នកធ្វើសេចក្ដីព្រាងមួយចំនួននៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ជឿថា ដើម្បីអោយការពិនិត្យមើលឡើងវិញផ្នែកច្បាប់អាចត្រូវបានអនុវត្តប្រកបដោយការស្ថាបនានិងដើម្បីប្រមូលការគាំទ្រដ៏ទូលំទូលាយ (ឧទាហរណ៍ពីរដ្ឋាភិបាលឬក្រុមប្រឆាំង) ពួកគេត្រូវតែបង្កើត "លក្ខណៈយុត្តិធម៌" ពោលគឺការមានតុល្យភាពល្អនៃចម្លើយអនុលោមភាពពេញលេញ និងគ្មានអនុលោមភាព ។

*កង្វល់ទី ៥ : និន្នាការក្នុងការបន្ធូរបន្ថយការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ឬក្នុងការចៀសវាងចម្លើយ "គ្មានអនុលោមភាព"*

អាចមាននិន្នាការក្នុងការចៀសវាងចម្លើយ "គ្មានអនុលោមភាព" ដោយសារវាជាការខ្មាសអៀនសម្រាប់ ឬទំនងជាធ្វើអោយមានកំហឹងពីសំណាក់រដ្ឋាភិបាល ។ ឧទាហរណ៍ មន្ត្រីរដ្ឋាភិបាលនៅក្នុងប្រទេសមួយបានចូលរួមនៅក្នុងការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ។ ពួកគេបានសំណូមពរថាការវាយតម្លៃមិនគួរមានលក្ខណៈតឹងរ៉ឹងពេកទេដោយសារវាអាចនឹងមិនត្រូវបានស្វាគមន៍ដោយថ្នាក់លើ និងអាចនាំអោយមានការមិនឯកភាពចំពោះការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ជាជាងកិច្ចសហប្រតិបត្តិការ ។

*កង្វល់ទី ៦ : ការសម្រុះសម្រួល*

នៅពេលក្រុមធ្វើសេចក្ដីព្រាងសម្រាប់ការពិនិត្យមើលឡើងវិញផ្នែកច្បាប់មានសមាសភាពជាបុគ្គល ឬក្រុមដែលមានផលប្រយោជន៍ និងការតស៊ូមតិផ្សេងៗគ្នា ការសម្រេចបាននូវការព្រមព្រៀងមតិអាចមានការលំបាកទៅលើបញ្ហារសើប ។ ដូច្នេះការវាយតម្លៃអនុលោមភាពអាចជាការសម្រុះសម្រួលជាជាងការវិភាគ ។

**ការដោះស្រាយកង្វល់ទី ៤, ៥ និង ៦ :** នៅតែជាការពិតចំពោះ CEDAW ។ ការពិចារណា និងការចរចាផ្នែកនយោបាយទំនងជាផ្នែកមួយនៃដំណើរការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ភាគច្រើន ។ ប៉ុន្តែការថ្លឹងថ្លែងតុល្យភាព និងការគាំទ្រទូលំទូលាយមិនគួរធ្វើអោយអ្នកឃ្លាតចេញពីបទដ្ឋានដែលបានកំណត់ដោយ CEDAW ឡើយ ។ ដើម្បីរៀបចំសម្រាប់កិច្ចចរចា និងកិច្ចពិភាក្សាផ្នែកនយោបាយ ជំហានទាំងនេះអាចមានប្រយោជន៍ :

- ស្វែងរកការគាំទ្រ និងកិច្ចសហប្រតិបត្តិការពីវិស័យពាក់ព័ន្ធមុនពេលចាប់ផ្ដើមធ្វើការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ។
- រៀបចំអោយបានច្បាស់លាស់នូវការប្រើប្រាស់ CEDAW ជាក្របខ័ណ្ឌសម្រាប់ការពិនិត្យមើលឡើងវិញ និងអ្វីដែលវានឹងពាក់ព័ន្ធ ។ ប្រការនេះចាំបាច់ត្រូវតែពន្យល់ដល់វិស័យពាក់ព័ន្ធទាំងអស់ ជាពិសេស វិស័យដែលកំពុងស្វែងរកជំនួយ ។ ពន្យល់ថា អាចមានទិដ្ឋភាពដែលអាចកើតឡើងថា ការវាយតម្លៃអាចមានលក្ខណៈអវិជ្ជមាន ប៉ុន្តែអនុសាសន៍នឹងត្រូវបានផ្ដល់អោយ ដើម្បីផ្ដល់ការណែនាំសម្រាប់វឌ្ឍនភាព ។ ពន្យល់ផងដែរថា ការបន្ធូរបន្ថយគំហើញនៃការវាយតម្លៃអាចមានលក្ខណៈប្រឆាំងនឹងផលិតភាព ដោយសារវានាំមកនូវការបន្ទាបគុណភាពនៃការ វាយតម្លៃ និងធ្វើអោយស្ថិតក្រោមបទដ្ឋានរបស់ CEDAW ។ គួសបញ្ជាក់ថា វាជាការប្រសើរជាងដែលការពិនិត្យមើលឡើងវិញផ្នែកច្បាប់បានកំណត់បញ្ហានានាជាមួយច្បាប់ ដើម្បីអោយដំណើរការផ្លាស់ប្ដូរ អាចចាប់ផ្ដើម ។

- ធ្វើការស្រាវជ្រាវទៅលើអង្គហេតុ និងច្បាប់អោយបានល្អ និងបង្កលទ្ធភាពអោយធ្វើការស្រាវជ្រាវបានយ៉ាងងាយ។ ក្នុងករណីភាគច្រើន ការជំទាស់ទៅនឹងការវាយតម្លៃរបស់អ្នក នឹងអះអាងថា វាខកខានមិនបានពិចារណាព័ត៌មានជាក់លាក់ ឬពឹងផ្អែកលើទិន្នន័យចាស់ៗ។ ត្រូវធានាថា អង្គហេតុ និងច្បាប់ពាក់ព័ន្ធទាំងអស់ត្រូវបានលើកយកមកពិចារណា។ ត្រូវធ្វើអោយប្រការទាំងនេះមានភាពច្បាស់លាស់ និងអាចប្រើប្រាស់បានយ៉ាងងាយស្រួល។
- បង្ហាញយ៉ាងច្បាស់អំពីរបៀបដែលការវាយតម្លៃត្រូវបានធ្វើឡើង តាមរយៈការអនុវត្តពីជំហានទី ១ ដល់ទី ៦ នៃក្របខ័ណ្ឌប្រកបដោយលក្ខណៈត្រឹមត្រូវ។
- កសាងសមត្ថភាពអំពី CEDAW។ នៅក្នុងវិស័យជាច្រើន ពុំសូវមានការយល់ដឹងថាតើ CEDAWតម្រូវអោយមានអ្វីខ្លះឡើយ។ ប្រការនេះអាចនាំអោយការវាយតម្លៃត្រូវបានមើលឃើញថា មានភាពមិនគួរទុកចិត្ត ឬមានការអន់ចិត្ត។ ចូរបំពេញបន្ថែមការពិនិត្យមើលឡើងវិញផ្នែកច្បាប់ជាមួយការកសាងសមត្ថភាពអំពី CEDAW។ កសាងសមត្ថភាពរបស់បុគ្គលដែលធ្វើការផ្នែកយេនឌ័រ និង CEDAW ជាពិសេសនៅក្នុងវិស័យពាក់ព័ន្ធនានា (ឧទាហរណ៍ មន្ត្រីរដ្ឋាភិបាល) ដើម្បីយល់ដឹងអំពី CEDAW ព្រមទាំងការពារបទដ្ឋានរបស់វាចំពោះមុខថ្នាក់លើរបស់ខ្លួន មណ្ឌលបោះឆ្នោតរបស់ខ្លួន និងក្រុមដទៃទៀត។

## ការពន្យល់ដោយអោយជាឧទាហរណ៍ទៅលើជំហានទី ៦

→ សូមមើល**ឧទាហរណ៍ទី ៥ និងទី ៦** សម្រាប់ការពន្យល់ទៅលើជំហានទី ៦ (វិភាគអនុលោមភាព)

| ជំហានទី ៥: វាយឈ្មោះច្បាប់ដែលពាក់ព័ន្ធ | ជំហានទី ៦: វិភាគអនុលោមភាព | **ជំហានទី ៧: ធ្វើសេចក្តីព្រាងការពន្យល់ និងមតិយោបល** | ជំហានទី ៨: រៀបចំអនុសាសន៍ |
|---|---|---|---|

ក្រៅពីការគូសបញ្ជាក់ថាតើច្បាប់មានអនុលោមភាពពេញលេញអនុលោមភាពមួយផ្នែកឬគ្មានអនុលោមភាពទៅនឹង CEDAW ឬយ៉ាងណា អ្នកចាំបាច់ត្រូវតែផ្តល់ការពន្យល់អំពីមូលហេតុដែលច្បាប់ពាក់ព័ន្ធអនុលោម ឬមិនអនុលោមតាមសូចនាករ ។

**១. ពន្យល់ចម្លើយរបស់អ្នកចំពោះជំហានទី ៦ (វិភាគអនុលោមភាព)**

អាស្រ័យលើការឆ្លើយតបរបស់អ្នកទៅនឹងជំហានទី ៦ ខ្លឹមសារក្រោមជំហានទី ៧ អាចប្រែប្រួល ។

- ប្រសិនបើចម្លើយរបស់អ្នក គឺ "គ្មានអនុលោមភាព" ជំហានទី ៧ នឹងគូសបញ្ជាក់អំពីអវត្តមាននៃបញ្ញត្តិច្បាប់ ដែលឆ្លើយតបទៅនឹងសូចនាករអត្ថិភាពនៃច្បាប់ដែលផ្ទុយនឹងសូចនាករ ឬច្បាប់មិនសមស្របជាមូលហេតុសម្រាប់ការឆ្លើយតប ។ វាត្រូវតែផ្តល់នូវការពន្យល់បន្ថែមអំពីមូលហេតុដែលច្បាប់ពាក់ព័ន្ធមានលក្ខណៈផ្ទុយ ឬមិនសមស្រប ។
- ប្រសិនបើចម្លើយរបស់អ្នក គឺ "មានអនុលោមភាពមួយផ្នែក" ជំហានទី ៧ នឹងផ្តល់មតិយោបល់អំពីមូលហេតុដែលច្បាប់នេះមានភាពមិនគ្រប់គ្រាន់ ដែលអាចរួមបញ្ចូលមតិយោបល់ទៅលើការអនុវត្តខ្សោយ ។
- ប្រសិនបើចម្លើយរបស់អ្នក គឺ "អនុលោមភាពពេញលេញ" ជំហានទី ៧ នឹងគូសបញ្ជាក់អំពីអត្ថិភាពនៃបញ្ញត្តិច្បាប់ ដែលឆ្លើយតបទៅនឹងសូចនាករ និងថា គេមិនចាំបាច់មានបញ្ញត្តិច្បាប់បន្ថែមសម្រាប់អនុលោមភាពឡើយ ។
- ក្នុងករណីខ្លះ ការពន្យល់មានភាពច្បាស់លាស់ដោយខ្លួនឯង ដូច្នេះពុំចាំបាច់មានការពន្យល់ ឬមតិយោបល់បន្ថែមឡើយ ។

**២. ដាក់បញ្ចូលព័ត៌មានដទៃទៀតដែលមានឥទ្ធិពលលើចម្លើយរបស់អ្នកចំពោះជំហានទី ៦ (វិភាគអនុលោមភាព)**

ព័ត៌មានដទៃទៀតដែលអាចមានប្រយោជន៍ក្នុងការដាក់បញ្ចូលទៅក្នុងជំហានទី ៧ រួមមាន :

- ការវិភាគដែលធ្វើឡើងក្នុងការសម្រេចអនុលោមភាពតាមសូចនាករ ។
- ទិន្នន័យ ឬព័ត៌មានច្បាស់លាស់ ដើម្បីគាំទ្រការវាយតម្លៃ ។
- ការខ្វះចន្លោះ ការកំហិត និងបញ្ហាប្រឈម ដែលទាក់ទងនឹងការអនុវត្ត និងការដាក់អោយអនុវត្ត
- ឥទ្ធិពល ឬផលប៉ះពាល់នៃច្បាប់ទៅលើស្ថានភាពជាក់ស្តែងរបស់ស្ត្រី ។

## ការពន្យល់ដោយអោយជាឧទាហរណ៍ទៅលើជំហានទី ៧

→ សូមមើលឧទាហរណ៍ទី ៥ និងទី ៦ សម្រាប់ការពន្យល់ទៅលើជំហានទី ៧

| ជំហានទី ៥ : វាយឈ្មោះច្បាប់ដែលពាក់ព័ន្ធ | ជំហានទី ៦ : វិភាគអនុលោមភាព | ជំហានទី ៧ : ធ្វើសេចក្តីព្រាងការពន្យល់និងមតិយោបល់ | ជំហានទី ៨ : រៀបចំអនុសាសន៍ |
|---|---|---|---|

ជាចុងក្រោយ អ្នកចាំបាច់ត្រូវតែរៀបចំអនុសាសន៍ ដោយចងចាំនូវប្រការដូចខាងក្រោម ។

**១. ផ្តល់អនុសាសន៍អំពីថាតើច្បាប់គួរមានលក្ខណៈបែបណា ប្រសិនបើពុំមានអនុលោមភាព ឬមានអនុលោមភាពមួយផ្នែក (អនុសាសន៍ផ្នែកច្បាប់)**

អនុសាសន៍ទាំងនេះគួរផ្តោតទៅលើកំណែទម្រង់ច្បាប់ ជាពិសេស :

- ការកែប្រែបញ្ញត្តិដែលមានស្រាប់
- ការបន្ថែម ឬលុបចោលបញ្ញត្តិណាមួយនៃច្បាប់
- ការលុបចោលច្បាប់ ឬការចេញច្បាប់ថ្មី

**២. មានលក្ខណៈជាក់លាក់**

នៅពេលរៀបចំអនុសាសន៍ អ្នកត្រូវតែមានលក្ខណៈជាក់លាក់។ ឧទាហរណ៍ វាមិនគ្រប់គ្រាន់ទេក្នុងការចង្អុលបង្ហាញថា វិសោធនកម្ម ឬច្បាប់ថ្មី គឺជាការចាំបាច់។ អ្នកគួរតែគូសបញ្ជាក់លក្ខណៈសំខាន់ៗនៃវិសោធនកម្ម ឬច្បាប់។

**៣. អាចជាជម្រើសមួយដែរ ធ្វើការណែនាំអំពីវិធានការបំពេញបន្ថែម**

វាជាការមានប្រយោជន៍ដែលត្រូវដាក់បញ្ចូលអនុសាសន៍ទាំងនោះដែលបំពេញបន្ថែមចំពោះអនុសាសន៍ដែលត្រឹមត្រូវនៃបញ្ញត្តិស្តីពីសមភាពយេនឌ័រ។ ប្រសិនបើមានអនុលោមភាពរួចហើយ វិធានការទាំងនេះធានាបន្ថែមនូវការអនុវត្ត និងការដាក់អោយអនុវត្ត។ ប្រសិនបើមានអនុលោមភាពមួយផ្នែក ឬគ្មានអនុលោមភាព វិធានការទាំងនេះបន្ថែមលើការជួយជំរុញដល់ការអនុវត្ត និងការដាក់អោយអនុវត្ត ក៏នឹងគាំទ្រដល់អនុសាសន៍ផ្នែកច្បាប់ដែលធ្វើឡើងផងដែរ ។ អនុសាសន៍ទាំងនេះត្រូវតែបែងចែកជាក្រុមដាក់ដោយឡែកពីអនុសាសន៍ផ្នែកច្បាប់។

## ការពន្យល់ដោយអោយជាឧទាហរណ៍ទៅលើជំហានទី ៨

→ សូមមើលឧទាហរណ៍ទី ៥ និងទី ៦ សម្រាប់ការពន្យល់ទៅលើជំហានទី ៨

## ការពន្យល់ដោយអោយជាឧទាហរណ៍ទៅលើជំហានទី ១-៨

### ឧទាហរណ៍ទី ៥ : ការពន្យល់ដោយអោយជាឧទាហរណ៍ទៅលើជំហានទី ១ ដល់ទី ៨ សម្រាប់អាយុអប្បបរមានៃអាពាហ៍ពិពាហ៍

ដោយប្រើប្រាស់អាយុអប្បបរមានៃអាពាហ៍ពិពាហ៍ជាផ្នែកមួយនៃការផ្តោតនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW និងជាសូចនាករតែមួយគត់ ខាងក្រោមនេះគឺជាឧទាហរណ៍ មួយនៃរបៀបដែលក្របខ័ណ្ឌពិនិត្យមើលឡើងវិញផ្នែកច្បាប់មានដំណើរការ ។ បញ្ជីនេះមានលក្ខណៈពន្យល់ជាឧ និងពុំមានគោលបំណងជាការបង្គាប់ទេ ។ ចម្លើយអាចប្រែប្រួលអាស្រ័យលើស្ថានភាពប្រទេស និងអត្ថិភាព ។

| ការរៀបចំសូចនាករផ្នែកច្បាប់នៃ CEDAW | | | | ការកំណត់អនុលោមភាព និងអនុសាសន៍ | | | |
|---|---|---|---|---|---|---|---|
| ជំហានទី ១ : កាតព្វកិច្ចនៃ CEDAW | ជំហានទី ២ : ស្ថានភាព បញ្ហា និងកង្វល់ | ជំហានទី ៣ : អះអាងចំណុចខ្វះខាតផ្សេងៗ នៅក្នុងច្បាប់ | ជំហានទី ៤ : សូចនាករផ្នែកច្បាប់នៃ CEDAW | ជំហានទី ៥ : ច្បាប់ដែលពាក់ព័ន្ធ | ជំហានទី ៦ : អនុលោមភាព | ជំហានទី ៧ : ការពន្យល់ និងមតិយោបល់ | ជំហានទី ៨ : អនុសាសន៍ |
| • អាយុអប្បបរមានៃអាពាហ៍ពិពាហ៍<br>• មាត្រា ១៦.២<br>• អនុសាសន៍ទូទៅទី ២១ កថាខ័ណ្ឌ ៣៦-៣៨<br>• ការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ | • អាយុអប្បបរមាដែលអាចរៀបការបាន គឺ១៦ឆ្នាំសម្រាប់ស្ត្រី<br>• អាយុអាពាហ៍ពិពាហ៍មិនដូចគ្នាទេសម្រាប់ស្ត្រីនិងបុរស | • អាយុអប្បបរមាដែលបានកំណត់សម្រាប់ អាពាហ៍ពិពាហ៍មិនត្រូវក្រោម ១៨ ឆ្នាំ<br>• ស្ត្រី និងបុរសត្រូវមានអាយុអប្បបរមាដូចគ្នាសម្រាប់អាពាហ៍ពិពាហ៍ | តើមានអាយុអាពាហ៍ពិពាហ៍អប្បបរមា ១៨ ឆ្នាំ ស្មើគ្នាសម្រាប់ស្ត្រីនិងបុរសឬទេ ? | • មាត្រា ៧នៃច្បាប់អាពាហ៍ពិពាហ៍ (បុរសត្រូវមានអាយុយ៉ាងហោចណាស់ ១៨ ឆ្នាំ ហើយស្ត្រីត្រូវមានអាយុយ៉ាងហោចណាស់ ១៦ ឆ្នាំ ដើម្បីរៀបអាពាហ៍ពិពាហ៍បាន) | ពុំមានអនុលោមភាព | ពុំមានអនុលោមភាពដោយសារ (ក) អាយុអាពាហ៍ពិពាហ៍សម្រាប់ស្ត្រី គឺក្រោម ១៨ ឆ្នាំ និង (ខ) អាយុអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រីគឺមិនដូចគ្នា ។ | កែប្រែច្បាប់ដើម្បីចែងអំពីអាយុអាពាហ៍ពិពាហ៍អប្បបរមា ១៨ ឆ្នាំ សម្រាប់ស្ត្រីនិងបុរស |

**ឧទាហរណ៍ទី ៦ : ការពន្យល់ដោយអោយជាឧទាហរណ៍ទៅលើជំហានទី ១ ដល់ទី ៨ សម្រាប់សញ្ជាតិ**

ដោយប្រើប្រាស់សញ្ជាតិជាផ្នែកមួយនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ខាងក្រោមនេះគឺជាឧទាហរណ៍មួយនៃរបៀបដែលក្របខ័ណ្ឌពិនិត្យមើលឡើងវិញផ្នែកច្បាប់មានដំណើរការ។ បញ្ជីនេះមានលក្ខណៈពន្យល់ជារូបភាព និងពុំមានគោលបំណងជាការបង្គាប់ទេ។ ចម្លើយអាចប្រែប្រួលអាស្រ័យលើស្ថានភាពប្រទេស និងអត្ថិភាព។

| ការរៀបចំសូចនាករផ្នែកច្បាប់នៃ CEDAW | | | | ការកំណត់អនុលោមភាព និងអនុសាសន៍ | | | |
|---|---|---|---|---|---|---|---|
| **ជំហានទី ១ : កាតព្វកិច្ចនៃ CEDAW** | **ជំហានទី ២ : ស្ថានភាពបញ្ហា និងកង្វល់** | **ជំហានទី ៣ : អះអាងចំណុចចាំបាច់នានានៅក្នុងច្បាប់** | **ជំហានទី ៤ : សូចនាករផ្នែកច្បាប់នៃ CEDAW** | **ជំហានទី ៥ : ច្បាប់ដែលពាក់ព័ន្ធ** | **ជំហានទី ៦ : អនុលោមភាព** | **ជំហានទី ៧ : ការពន្យល់ និងមតិយោបល់** | **ជំហានទី ៨ : អនុសាសន៍** |
| • មាត្រា ៩.<br>CEDAW<br>• អនុសាសន៍ទូទៅទី ២១ កថាខ័ណ្ឌទី ៦<br>• ការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ។ | ការរក្សាសញ្ជាតិ (ស្ត្រីអាចរក្សាសញ្ជាតិរបស់ខ្លួន ទោះបីជារៀបការជាមួយជនបរទេស ឬផ្លាស់ប្តូរទៅជាសញ្ជាតិរបស់ស្វាមីក៏ដោយ)។ | ស្ត្រី និងបុរសអាចរក្សាសញ្ជាតិរបស់ខ្លួនដោយមិនគិតពីអាពាហ៍ពិពាហ៍ ឬការប្តូរសញ្ជាតិរបស់សហព័ទ្ធខ្លួន។ | តើច្បាប់អនុញ្ញាតអោយស្ត្រីរក្សាសញ្ជាតិរបស់ខ្លួន ទោះបីជារៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬមានការផ្លាស់ប្តូរទៅជាសញ្ជាតិរបស់ស្វាមីឬទេ ? | • មាត្រា ៩ នៃច្បាប់ស្តីពីសញ្ជាតិ (អាពាហ៍ពិពាហ៍ ការលែងលះ ឬការលុបចោលរវាងពលរដ្ឋ និងជនបរទេស មិនបានកែប្រែសញ្ជាតិរបស់ពលរដ្ឋឡើយ)។<br>• មាត្រា ១០នៃច្បាប់ស្តី ពីសញ្ជាតិ (ការបាត់បង់សញ្ជាតិដោយសារសហព័ទ្ធមួយមិនកែប្រែសញ្ជាតិរបស់សហព័ទ្ធម្នាក់ទៀត)។ | អនុលោមភាពពេញលេញ | ច្បាប់តម្រូវអោយមានការអនុវត្តដូចគ្នា ទោះបីជាពលរដ្ឋគឺជាបុរស ឬស្ត្រីក៏ដោយ។ ការអនុវត្តច្បាប់នេះក៏ត្រូវមានលក្ខណៈដូចគ្នាដែរ។ ពុំមានភាពខុសគ្នារវាងស្ត្រី និងបុរសក្នុងការទទួលបាន និងប្រើប្រាស់សិទ្ធិនេះឡើយ។ | គ្មាន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | សិទ្ធិស្មើគ្នាសម្រាប់ម្តាយក្នុងការផ្ទេរសញ្ជាតិរបស់ខ្លួនទៅអោយកូន ។ | ស្ត្រីត្រូវតែមានសិទ្ធិស្មើគ្នាក្នុងការផ្ទេរសញ្ជាតិរបស់ខ្លួនទៅអោយកូនរបស់ខ្លួនដោយមិនគិតពីអាពាហ៍ពិពាហ៍ ។ | តើស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាក្នុងការផ្ទេរសញ្ជាតិរបស់ខ្លួនទៅអោយកូនឬទេ ? | • មាត្រា ១៧ នៃច្បាប់ស្តីពីសញ្ជាតិ ( កូនដែលកើតជាមួយពលរដ្ឋ និងជនបរទេសអាចទទួលបានសញ្ជាតិរបស់ពលរដ្ឋប្រសិនបើត្រូវបានឯកភាពជាលាយលក្ខណ៍អក្សរដោយឪពុកម្តាយនៅពេលចុះបញ្ជីកំណើត) ។ | គ្មានអនុលោមភាព | ច្បាប់មានឥទ្ធិពលមិនស្មើភាពគ្នាទៅលើស្ត្រី ពីព្រោះ : មានប្រវ៉ាឡង់នៃទំនាក់ទំនងដោយគ្មានអាពាហ៍ពិពាហ៍ នៅពេលដែលឪពុកជាជនបរទេសចាកចេញពីប្រទេស មិនអាចរកឃើញ ឬបដិសេធមិនចុះកិច្ចព្រមព្រៀងអំពីសញ្ជាតិរបស់កូន ។ ប្រការនេះធ្វើអោយកូនបាត់បង់សញ្ជាតិរបស់ពលរដ្ឋ ។ មានករណីជាច្រើននៃការជួញដូរ ដែលកុមារកើតនៅក្រៅប្រទេសរបស់ឪពុកដែលជាជនបរទេស និងម្តាយដែលជាពលរដ្ឋ ។ នៅក្នុងករណីនេះ មាត្រា ១២ អាចចាត់ទុកថាកុមារគ្មានសញ្ជាតិ ។ ស្ត្រីជនបទដែលមិនដឹងអំពីសិទ្ធិរបស់ខ្លួនទៅក្រោមច្បាប់ធ្វើអោយពួកគេមិនអើពើក្នុងការចុះបញ្ជី កូនរបស់ខ្លួនជាពលរដ្ឋទោះបីជាមានការព្រមព្រៀងពីឪពុកក៏ដោយ ។ | កែប្រែច្បាប់ដើម្បីអោយពលរដ្ឋអាចផ្ទេរសញ្ជាតិរបស់ខ្លួនដល់កូនរបស់ខ្លួនដោយមិនចាំបាច់មានការយល់ព្រមពីឪពុក/ម្តាយ ។ អនុសាសន៍ខាងលើត្រូវតែបំពេញបន្ថែមដោយ: បង្កើនការយល់ដឹងរបស់ពលរដ្ឋ ជាពសេសស្ត្រីអំពីសិទ្ធិក្នុងការផ្ទេរសញ្ជាតិទៅអោយកូនដែលកើតជាមួយពលរដ្ឋ និងជនបរទេស ។ បង្កើនការយល់ដឹងរបស់មន្ត្រីរដ្ឋាភិបាលដែលពាក់ព័ន្ធអំពីសិទ្ធិរបស់ពលរដ្ឋក្នុងការផ្ទេរសញ្ជាតិទៅអោយកូនដែលកើតជាមួយពលរដ្ឋ និងជនបរទេស ។ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | សិទ្ធិស្មើគ្នាក្នុងការទទួលសញ្ជាតិ ។ | ស្ត្រី និងបុរសមានមូលដ្ឋាន និងលក្ខខណ្ឌដូចគ្នាក្នុងការទទួលបានសញ្ជាតិ ។ | តើស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាក្នុងការទទួលបានសញ្ជាតិឬទេ? | • មាត្រា ៣៥នៃច្បាប់ស្តីពីសញ្ជាតិ ( សហព័ទ្ធបរទេសរបស់ពលរដ្ឋមានមូលដ្ឋាន និងលក្ខខណ្ឌដូចគ្នាក្នុងការទទួលបានសញ្ជាតិ ។ សេចក្តីលម្អិតនឹងផ្តល់ជូនដោយអាជ្ញាធរអន្តោប្រវេសន៍) ។ | អនុលោមភាពមួយផ្នែក | ទោះបីជាច្បាប់នេះអនុលោមតាមស្តូចនាករក៏ដោយវាមិនគ្រប់គ្រាន់ទេ ។ នៅក្នុងការអនុវត្តជាក់ស្តែងភរិយាជាជនបរទេសមកពីប្រទេស "ហានិភ័យខ្ពស់" ត្រូវបានតម្រូវដោយអាជ្ញាធរអន្តោប្រវេសន៍អោយបង្ហាញលក្ខខណ្ឌតម្រូវបន្ថែមដូចជាភ័ស្តុតាងនៃអត្តចរិតល្អ ការរស់នៅរយៈពេលយូរជាមួយស្វាមី និងវិជ្ជាជីវៈឬចំណូលល្អប្រសើរនៅពេលដាក់ពាក្យសុំសញ្ជាតិ ។ ប្រការនេះមិនត្រូវបានតម្រូវសម្រាប់ ស្វាមីជាជនបរទេសឡើយ ។ បញ្ញត្តិច្បាប់បន្ថែមគឺជាការចាំបាច់ ដើម្បីកុំអោយអាជ្ញាធរអន្តោប្រវេសន៍មានឆន្ទានុសិទ្ធិក្នុងការអនុវត្តមាត្រា ៣៥ ។ | បំពេញបន្ថែមមាត្រា ៣៥ ដើម្បីចែងយ៉ាងច្បាស់ថា ការដាក់លក្ខខណ្ឌបន្ថែមផ្អែកលើមូលដ្ឋាននៃយេនឌ័ររបស់បុគ្គលម្នាក់ ត្រូវបានហាមឃាត់ ។ បំពេញបន្ថែមច្បាប់ដើម្បីតម្រូវអោយមានកម្មវិធីផ្សព្វផ្សាយព័ត៌មានដល់សាធារណជន និងការជូនដំណឹងដល់អ្នកដាក់ពាក្យសុំអំពីការហាមឃាត់ដែលមានបញ្ជាក់ខាងលើ ។ |

# ការប្រើប្រាស់ឯកសារពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW

# ផ្នែកទីប្រាំ

## ការប្រើប្រាស់ឯកសារពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW

នៅក្នុងផ្នែកនេះ :

- ✓ ចាប់ពីការពិនិត្យមើលឡើងវិញរហូតដល់កំណែទម្រង់
- ✓ របៀបប្រើប្រាស់ឯកសារពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើCEDAW របស់អ្នក ដើម្បីធ្វើអោយមានការផ្លាស់ប្តូរ

### ពីការពិនិត្យមើលឡើងវិញរហូតដល់កំណែទម្រង់

ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW គឺជាឧបករណ៍ដ៏សំខាន់ ដើម្បីប្រែក្លាយប្រព័ន្ធច្បាប់អោយទៅជាប្រព័ន្ធមួយដែលទទួលស្គាល់ និងធានានូវសមភាព និងការមិនរើសអើង។ ក្នុងករណីជាច្រើនប្រការនេះមិនមែនកើតឡើងដោយស្វ័យប្រវត្តិឡើយ ។ ការតស៊ូមតិផ្នែកច្បាប់ចាំបាច់ត្រូវតែធ្វើឡើងដើម្បីធានាថា គំហើញនៃការពិនិត្យមើលឡើងវិញនាំអោយមានកំណែទម្រង់ច្បាប់ជាក់ស្តែង។

ប្រការនេះតម្រូវអោយមានការរួមផ្សំយុទ្ធសាស្ត្របំពេញបន្ថែមនានារួមមាន :[១៥]

**ការកសាងសម្ថតភាព និងបណ្តាញ**

កំណត់បុគ្គល និងក្រុមទាំងឡាយដែលជួយនៅក្នុងការតស៊ូមតិផ្នែកច្បាប់។ នេះគឺជាកត្តាសំខាន់ដោយសារការងារតស៊ូមតិផ្នែកច្បាប់ គឺជាភារកិច្ចដ៏លំបាក ។យុទ្ធសាស្ត្រនេះតម្រូវអោយមានពេលវេលា កិច្ចប្រឹងប្រែង ការប្តេជ្ញាចិត្ត និងជំនាញជាច្រើន ។

**ការរៀបចំបញ្ជីសម្រាប់ការតស៊ូមតិផ្នែកច្បាប់**

កំណត់ចំណុចបញ្ចូលសម្រាប់អន្តរាគមន៍នៅក្នុងជំហានីមួយៗនៃដំណើរការតាក់តែងច្បាប់ ។ កំណត់បុគ្គល ឬក្រុមគោលដៅដែលត្រូវទទួលរងឥទ្ធិពលនិងសម្ព័ន្ធមិត្តឬក្រុមប្រឆាំងរបស់ខ្លួន ។ កំណត់ជំនាញនិងភារកិច្ចដែលចាំបាច់សម្រាប់កិច្ចការទាំងមូលព្រមទាំងតួនាទីដែលត្រូវបំពេញដោយបុគ្គល ឬក្រុមនីមួយៗ ។

**ការកំណត់សំណើច្បាប់**

ផ្អែកលើគំហើញនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើCEDAW ធ្វើសេចក្តីព្រាងសមាសធាតុសំខាន់ៗនៃសំណើច្បាប់ ។ បង្កើនការយល់ដឹងរបស់សម្ព័ន្ធមិត្តទាំងអស់អំពីសមាសធាតុទាំងនេះ ។ ដឹងថាតើសមាសធាតុណាខ្លះមិនអាចចរចាបាន។ រំពឹងទុកជាមុននូវអំណះអំណាងដែលប្រឆាំងនឹងសមាសធាតុទាំងនេះ ព្រមទាំងត្រៀមខ្លួនដើម្បីឆ្លើយតប ។

**ព័ត៌មាន និងការស្រាវជ្រាវ**

អ្នកតាក់តែងច្បាប់ស្វែងរកទិន្នន័យ ការវិភាគ និងព័ត៌មានដទៃទៀត ដើម្បីធ្វើអោយខ្លួនឯង និងអ្នកដទៃជឿជាក់ទៅលើគុណ

---

[១៥] សូមមើលការិយាល័យច្បាប់សម្រាប់ស្ត្រី ។ *សៀវភៅណែនាំអំពីការតស៊ូមតិផ្នែកច្បាប់សម្រាប់ស្ត្រី ទីក្រុង* Quezon ឆ្នាំ២០១១ ។

សម្បត្តិនៃសំណើច្បាប់របស់ខ្លួន ។ បង្រួបបង្រួមព័ត៌មាននេះរួចផ្សព្វផ្សាយដល់សម្ព័ន្ធមិត្ត អ្នកតាក់តែងច្បាប់ និងភាគីពាក់ព័ន្ធដទៃទៀត។ ប្រសិនបើធ្វើបានល្អ ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW ដែលជាការស្រាវជ្រាវទូលំទូលាយគួរមានព័ត៌មានចាំបាច់ទាំងអស់ ។ ប្រសិនបើធ្វើមិនបានល្អទេ ត្រូវធានាថា ការស្រាវជ្រាវបន្ថែមត្រូវបានធ្វើឡើង ដើម្បីបំពេញបន្ថែមការពិនិត្យមើលឡើងវិញផ្នែកច្បាប់ ។

**ការបញ្ចុះបញ្ចូល**

នៅក្នុងការតស៊ូមតិផ្នែកច្បាប់ ការបញ្ចុះបញ្ចូល គឺជាដំណើរការនៃការជះឥទ្ធិពលទៅលើអ្នកតាក់តែងច្បាប់ ដើម្បីលើកកម្ពស់ ឬរារាំងការអនុម័តសំណើច្បាប់ ។ អ្នកត្រូវស្វែងយល់អំពីទម្លាប់អនុវត្តន៍ក្នុងការបញ្ចុះបញ្ចូលនៅក្នុងប្រទេស ឬសហគមន៍របស់អ្នក។ វាក៏មានន័យថា ជាការកំណត់ថាតើក្រុមណាខ្លះនៅក្នុងសម្ព័ន្ធភាព ឬបណ្តាញរបស់អ្នកមានបទពិសោធន៍ និងជំនាញក្នុងការបញ្ចុះបញ្ចូល និងប្រើប្រាស់អស់ពីលទ្ធភាពនូវជំនាញរបស់ពួកគេ ។

**ការអប់រំជាសាធារណៈ**

ការលើកកម្ពស់ការយល់ដឹង និងវេទយិតភាពការស្វែងយល់របស់សាធារណជនចំពោះអំពីសំណើច្បាប់ គឺជាកត្តាសំខាន់ ដោយសារមន្ត្រីសាធារណៈ និងអ្នកតាក់តែងច្បាប់មានភាពរសើបចំពោះទស្សនៈរបស់សាធារណជននិងបណ្តាញផ្សព្វផ្សាយ ។ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដូចជាទូរទស្សន៍ វិទ្យុ សារព័ត៌មាន និងអ៊ីនធឺណិត ត្រូវបានចាត់ទុកថា ជាវិធីដ៏មានប្រសិទ្ធភាព ដើម្បីផ្សព្វផ្សាយដល់ប្រជាជនកាន់តែច្រើន ។ ការអប់រំជាសាធារណៈបង្កើតនូវសម្ព័ន្ធមិត្ត និងអ្នកគាំទ្រថ្មីៗសម្រាប់ការតស៊ូមតិ ។

## ការប្រើប្រាស់ឯកសារពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើ CEDAW

ឯកសារពិនិត្យមើលឡើងវិញផ្នែកច្បាប់ផ្អែកលើCEDAW ត្រូវបានប្រើដើម្បីសម្របសម្រួលកំណែទម្រង់ច្បាប់ ។ឯកសារទាំងនេះមានការប្រើប្រាស់ដទៃទៀតផងដែរ ដូចជា :

ជាវេទិការួមសម្រាប់ការតស៊ូមតិ

ការពិនិត្យមើលឡើងវិញផ្នែកច្បាប់លើច្បាប់អាពាហ៍ពិពាហ៍(ច្បាប់លេខ១នៃ១៩៧៤) នៃប្រទេសឥណ្ឌូនេស៊ីបច្ចុប្បន្នកំពុងត្រូវបានអនុវត្តដោយគំនិតផ្តួចផ្តើមរបស់ក្រុមការងារCEDAW(CWGI)ដែលជាសម្ព័ន្ធភាពនៃអង្គការមិនមែនរដ្ឋាភិបាលដែលពិនិត្យតាមដានលើការអនុវត្ត CEDAW ដោយមានជំនួយបច្ចេកទេសពី UN WOMEN ។

- **ការប្រើប្រាស់:** ការពិនិត្យមើលឡើងវិញនេះនឹងត្រូវបានប្រើប្រាស់ជាវេទិការួមសម្រាប់ការតស៊ូមតិលើការធ្វើវិសោធនកម្មនៃច្បាប់អាពាហ៍ពិពាហ៍ឬសម្រាប់ការធ្វើសេចក្តីព្រាងច្បាប់ថ្មីមួយ ។ដើម្បីសម្របសម្រួលកិច្ចការនេះការពិនិត្យមើលឡើងវិញបានកំណត់សំណុំសូចនាករផ្នែកច្បាប់នៃ CEDAW សម្រាប់អាពាហ៍ពិពាហ៍ បានផ្តល់អនុសាសន៍សម្រាប់កំណែទម្រង់ និងបានស្នើអត្ថបទជំនួសសម្រាប់ច្បាប់អាពាហ៍ពិពាហ៍ ។

**ជាវិធីក្នុងការវាស់វែងវឌ្ឍនភាព**

រដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ក្រសួងយុត្តិធម៌ និងដោយមានការគាំទ្រពី UN WOMEN កំពុងអនុវត្តការពិនិត្យមើលឡើងវិញផ្នែកច្បាប់លើច្បាប់ស្តីពីអាពាហ៍ពិពាហ៍របស់ខ្លួនការជួញដូរ អំពើហិង្សាក្នុងគ្រួសារនិងការងារបុគ្គលិកបម្រើងការងារតាមផ្ទះដើម្បីធានាអនុលោមភាពតាមកាតព្វកិច្ចរបស់ខ្លួនក្រោម CEDAW ។

- **ការប្រើប្រាស់ :** ការពិនិត្យមើលឡើងវិញត្រូវបានធ្វើឡើង ដើម្បីវាស់វែងវឌ្ឍនភាពរបស់ពួកគេឆ្ពោះទៅរកអនុលោមភាពតាម CEDAW ជាពិសេស ទាក់ទងទៅនឹងច្បាប់ថ្មីដែលជិតមកដល់ ។ រដ្ឋាភិបាលក៏កំពុងតែធ្វើការដើម្បីដោះស្រាយផ្នែកនានាដែលមិនមានអនុលោមភាព ឧទាហរណ៍ ដើម្បីដោះស្រាយបញ្ញត្តិច្បាប់ពិសេសៗជាបន្ទាន់ ប្រសិនបើអាចធ្វើទៅបាន និងដើម្បីរួមបញ្ចូលបញ្ញត្តិដទៃទៀតទៅក្នុងច្បាប់ ឬរបៀបវារៈតាក់តែងវិធានរបស់ខ្លួន ។

**ជាជំនួយចំពោះការតាក់តែងច្បាប់**

ការអង្កេតផ្នែកច្បាប់ ដោយប្រើប្រាស់ CEDAW ជាក្របខ័ណ្ឌមួយ នឹងត្រូវបានធ្វើឡើងនៅប្រទេសទីម័រខាងកើតដោយក្រុមគាំទ្រការងារស្ត្រីនៅក្នុងសភា និងមជ្ឈមណ្ឌលធនធានយេនឌ័ររបស់ខ្លួន ។ ការអង្កេតនេះនឹងគូសបញ្ជាក់អំពីសមិទ្ធផល និងការខ្វះចន្លោះនៅក្នុងច្បាប់ ។

- **ការប្រើប្រាស់:** លទ្ធផលនៃការអង្កេតផ្នែកច្បាប់មានគោលបំណងដាក់បញ្ចូលទៅក្នុងការធ្វើសេចក្តីព្រាងច្បាប់ស្តីពីសុខភាពយេនឌ័រ ។ វានឹងជួយអ្នកធ្វើសេចក្តីព្រាងអោយកំណត់បញ្ហានានាដែលត្រូវចាត់អាទិភាព និងយកចិត្តទុកដាក់នៅក្នុងច្បាប់ខាងមុខ ។

**ជាជំនួយក្នុងការធ្វើសេចក្តីព្រាងយុទ្ធសាស្ត្រ ផែនការ កម្មវិធីសកម្មភាព និងរបាយការណ៍ជាឧបករណ៍ដើម្បីគូសបញ្ជាក់អាទិភាព**

ក្រោយពីការអនុម័តច្បាប់ស្តីពីសមភាពយេនឌ័ររបស់ប្រទេសវៀតណាមនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៦ សេចក្តីបង្គាប់អំពីច្បាប់ស្តីពីសមភាពយេនឌ័រ ត្រូវបានចេញនៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៧ ដោយកំណត់អោយមានការពិនិត្យមើលឡើងវិញលើឯកសារច្បាប់ធម្មតាដែលមានស្រាប់ ដើម្បីបញ្ចប់សព្វគ្រប់ដោយរដ្ឋាភិបាល ។ ដើម្បីជួយដល់ការពិនិត្យមើលឡើងវិញរបស់រដ្ឋាភិបាលស្របតាមសេចក្តីបង្គាប់ស្តីពីសមភាពយេនឌ័រការពិនិត្យមើលឡើងវិញផ្នែកច្បាប់មួយដែលមានចំណងជើងថា "CEDAW និងច្បាប់ : ការពិនិត្យមើលឡើងវិញផ្អែកលើយេនឌ័រ និងសិទ្ធិនៃឯកសារច្បាប់វៀតណាម តាមរយៈកញ្ចក់ឆ្លុះ បញ្ចាំងរបស់ CEDAW" ត្រូវបានធ្វើឡើងដោយUNWOMEN ប្រចាំប្រទេសវៀតណាមទាក់ទងទៅនឹងវិស័យ ប្រធានបទចំនួន១៨និងឯកសារច្បាប់ធម្មតាប្រហែល ២០០ ។ ការពិនិត្យមើលឡើងវិញផ្នែកច្បាប់ត្រូវបានពិភាក្សាជាមួយ ជនបង្គោល ចំនួន ៥៥ នាក់ មកពីក្រសួងផ្សេងៗ គណបក្សកុម្មុយនិស្ត និងអង្គការមហាជនក្នុងចំណោមអង្គការដទៃទៀត ។

- **ការប្រើប្រាស់ :** ការពិនិត្យមើលឡើងវិញផ្នែកច្បាប់មានគោលបំណងជួយរដ្ឋាភិបាលក្នុងការពិនិត្យមើលឡើងវិញលើ ច្បាប់ទាំងឡាយ ដើម្បីអោយមានអនុលោមភាពតាម CEDAW និងច្បាប់ស្តីពីសមភាពយេនឌ័រ ។ វាមានកាតព្វកិច្ចគូសបញ្ជាក់

ផ្នែកទាំងឡាយណាដែលត្រូវការការយកចិត្តទុកដាក់ជាបន្ទាន់ពីរដ្ឋ ។ទីភ្នាក់ងារអនុវត្តន៍របស់រដ្ឋបានគូសបញ្ជាក់អំពីការរួមចំណែកនៃការពិនិត្យមើលឡើងវិញផ្នែកច្បាប់ជាធនធានដ៏សំខាន់មួយដើម្បីៈ (ក) ការពិនិត្យមើលឡើងវិញរបស់រដ្ឋទៅលើយុទ្ធសាស្ត្រជាតិសម្រាប់លើកកម្ពស់ស្ត្រីរហូតដល់ឆ្នាំ២០១០ (ខ) ការបង្កើតយុទ្ធសាស្ត្រជាតិសម្រាប់សមភាពយេនឌ័រសម្រាប់ឆ្នាំ២០១១-២០២០ និងកម្មវិធីគោលដៅជាតិនៃសកម្មភាពស្តីពីសមភាពយេនឌ័រសម្រាប់ឆ្នាំ ២០១១-២០២០ (គ) ការត្រៀមរៀបចំសម្រាប់របាយការណ៍របស់រដ្ឋ CEDAW បន្ទាប់ ក្នុងដើមឆ្នាំ២០១១ និង (ឃ) ការធ្វើវិសោធនកម្ម និងការកែសម្រួលយ៉ាងទូលំទូលាយចំពោះក្រមពលកម្មក្នុងចំណោមក្រមដទៃទៀត ។

**ជាមធ្យោបាយដើម្បីរៀបចំភារកិច្ចស្រដៀងគ្នា ឬរួមគ្នា**

- នៅក្នុងតំបន់ប៉ាស៊ីហ្វិក ការពិនិត្យមើលឡើងវិញនៅនឹងកន្លែងចំនួនពីរត្រូវបានធ្វើឡើងដោយការិយាល័យ UN WOMEN ប្រចាំតំបន់ប៉ាស៊ីហ្វិក និងមជ្ឈមណ្ឌល UNDP ប្រចាំតំបន់ប៉ាស៊ីហ្វិក ដើម្បីវាយតម្លៃអនុលោមភាពផ្នែកច្បាប់ទៅនឹង CEDAW របស់ប្រទេសនៅតំបន់ប៉ាស៊ីហ្វិកចំនួន ៩ ៖ រដ្ឋសហព័ន្ធមីក្រូនេស៊ី ហ្វីជី គីរីបាទី Marshall Islands ប៉ាពួញូវហ្គីណេ សាម៉ូ កោះសូឡូម៉ូន ទូវ៉ាលូ និងវ៉ានូអាទូ ។ ការពិនិត្យមើលឡើងវិញទាំងនេះត្រូវបានធ្វើ ឡើងដើម្បីពិនិត្យមើលឡើងវិញយ៉ាងលម្អិតទៅលើច្បាប់នៃប្រទេសទាំងនេះ ។ ការពិនិត្យមើលឡើងវិញបានប្រើប្រាស់ សូចនាករផ្នែកច្បាប់នៃ CEDAW ចំនួន ១១៣ ដែលស្រដៀងគ្នាទៅនឹងប្រទេសទាំង ៩ ។ របាយការណ៍នៃការពិនិត្យ មើលឡើងវិញនៅនឹងកន្លែងត្រូវបានផ្សព្វផ្សាយជា "ការប្រែក្លាយ CEDAW អោយទៅជាច្បាប់ ៖ អនុលោមភាពផ្នែកច្បាប់របស់ ជំនឿ នៅក្នុងប្រទេសកោះប៉ាស៊ីហ្វិកចំនួន ៩" ។
- **ការប្រើប្រាស់ ៖** ក្រោយពីការពិនិត្យមើលឡើងវិញត្រូវបានធ្វើឡើង រដ្ឋាភិបាលនៅតំបន់ប៉ាស៊ីហ្វិកបានប្តេជ្ញាចិត្តក្នុងការកំណត់អាទិភាពនៅក្នុងរបៀបវារៈផ្នែកច្បាប់របស់ខ្លួននូវអនុលោមភាពតាមសូចនាករដែលកំណត់នៅក្នុងការពិនិត្យមើលឡើងវិញ ។ ការប្តេជ្ញាចិត្តចំពោះភារកិច្ចស្រដៀងគ្នា ឬរួមគ្នាត្រូវបានសម្របសម្រួលដោយការពិនិត្យមើលឡើងវិញផ្នែកច្បាប់ដោយសារវាប្រើប្រាស់សូចនាករដូចគ្នាចំពោះប្រទេសទាំង ៩ ។

# ឧបសម្ព័

## ឧបសម្ព័ន្ធទី I : បញ្ជីសូចនាករផ្នែកច្បាប់នៃ CEDAW

ខាងក្រោមនេះគឺជាបញ្ជីសូចនាករផ្នែកច្បាប់គំរូរបស់ CEDAW សម្រាប់បញ្ហានីមួយៗ។ សូចនាករនីមួយៗគួត្រូវតែបានវាយតម្លៃអំពីភាពពាក់ព័ន្ធរបស់វាចំពោះស្ថានភាពជាក់ស្តែងនៃសមភាពយេនឌ័រនៅក្នុងប្រទេសរបស់អ្នក។ បញ្ជីនេះមាន គោលបំណងជួយដល់ការកំណត់សូចនាករពាក់ព័ន្ធរបស់ប្រទេសនីមួយៗ នេះមិនមែនជាបញ្ជីពេញលេញឡើយ។

ទាក់ទងទៅនឹងបញ្ហាអំពីមាត្រា ៦-១៦ កូឡោនអំពីកាតព្វកិច្ច CEDAW គ្រាន់តែកំណត់ និងផ្តោតលើមាត្រាសំខាន់ៗរបស់ CEDAW ប៉ុណ្ណោះ។ ប៉ុន្តែនៅពេលដែលមាត្រា១-៥ សំដៅដល់កាតព្វកិច្ចទូទៅរបស់រដ្ឋ មាត្រាទាំងនេះអាចត្រូវបានរួម បញ្ចូលជាកាតព្វកិច្ច CEDAW សម្រាប់បញ្ហាទាំងនោះ។

| មាត្រា ១-៥ : ភារកិច្ចទូទៅដើម្បីលុបបំបាត់ការរើសអើង និងធានានូវសមភាព | |
|---|---|
| **កាតព្វកិច្ច CEDAW** | **សូចនាករផ្នែកច្បាប់នៃ CEDAW** |
| • មាត្រា ១-៥<br>• អនុសាសន៍ទូទៅទី ១៩<br>• អនុសាសន៍ទូទៅទី ២៥<br>• ការអង្កេតសន្និដ្ឋានអំពីប្រទេស ប្រសិនបើចាំបាច់ | *ការធានាសមភាព និងការមិនរើសអើង*<br>- តើរដ្ឋធម្មនុញ្ញធានានូវសមភាព និងការមិនរើសអើងផ្អែកលើភេទ ឬយេនឌ័រដែរឬទេ ?<br>- តើរដ្ឋធម្មនុញ្ញធានានូវសមភាព និងការមិនរើសអើងផ្អែកលើពូជសាសន៍ អាយុ ពិការភាព ជាតិពិន្ទុ ស្ថានភាព សេដ្ឋកិច្ច និងសង្គម និន្នាការផ្លូវភេទ និងមូលហេតុស្រដៀងគ្នាដែរឬទេ ?<br>- តើមាននិយមន័យអំពីសមភាពរវាងបុរស និងស្ត្រី ឬសមភាពយេនឌ័រដែរឬទេ ហើយវាអនុលោមតាមសមភាព ជាពេញលេញដែរឬទេ ?<br>- តើមាននិយមន័យអំពីការរើសអើង/ការមិនរើសអើងផ្អែកលើភេទ/យេនឌ័រដែរឬទេ ហើយវាអនុលោមតាម មាត្រា ១ នៃ CEDAW ដែរឬទេ ?<br>*ការហាមឃាត់ការរើសអើង*<br>- តើមានច្បាប់ដែលហាមឃាត់យ៉ាងច្បាស់លាស់ចំពោះការរើសអើងផ្អែកយេនឌ័រដោយអាជ្ញាធរសាធារណៈដែរ ឬទេ ?<br>- តើមានច្បាប់ដែលហាមឃាត់ចំពោះការរើសអើងផ្អែកយេនឌ័រដោយបុគ្គល សហគ្រាស និងអង្គការឯកជនដែរ ឬទេ ?<br>- តើមានទណ្ឌកម្មសម្រាប់សកម្មភាព ឬការខកខានមិនបានធ្វើសកម្មភាពដែលនាំអោយមានការរើសអើងដែរឬទេ ?<br>- តើទណ្ឌកម្មមានសភាពធ្ងន់ធ្ងរជាង ប្រសិនបើអំពើរើសអើងត្រូវបានប្រព្រឹត្តដោយមន្ត្រីសាធារណៈដែរឬទេ ?<br>- តើច្បាប់ហាមឃាត់ការរើសអើងដោយជនបរទេស និងអង្គភាពដែលកាន់កាប់ និង/ឬគ្រប់គ្រងដោយជនបរទេស ដែរឬទេ ?<br>*ការការពារផ្នែកច្បាប់ចំពោះស្ត្រី*<br>- តើមានសិទ្ធិក្នុងការស្វែងរកសំណងក្នុងករណីដែលមានការរើសអើងដែរឬទេ ?<br>- តើមានការធានានូវជំនួយផ្នែកច្បាប់សម្រាប់ករណីដែលមានការរើសអើងដែរឬទេ ?<br>- តើមានការធានានូវជំនួយផ្នែកច្បាប់សម្រាប់ស្ត្រីឬទេ ?<br>- តើមានការការពារប្រឆាំងនឹងការរើសអើងផ្អែកយេនឌ័រ ដែលគ្របដណ្តប់ដល់ជនបរទេសដែរឬទេ ?<br>*ស្ថាប័ន និងយន្តការសម្រាប់ការអនុវត្ត និងការពិនិត្យតាមដាន*<br>- តើច្បាប់ចាត់តាំងទីភ្នាក់ងារជាក់លាក់អោយទទួលខុសត្រូវចំពោះសមភាពយេនឌ័រដែរឬទេ ?<br>- តើទីភ្នាក់ងារដែលត្រូវបានចាត់តាំងសម្រាប់សមភាពយេនឌ័រត្រូវបានផ្តល់នូវអាណត្តិ អំណាច និងធនធាន សមស្របឬទេ ?<br>- តើច្បាប់តម្រូវអោយទីភ្នាក់ងាររដ្ឋដាក់បញ្ចូលនូវសមភាពយេនឌ័រទៅក្នុងប្រតិបត្តិការរបស់ខ្លួនដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានការប្រមូលទិន្នន័យដែលបែងចែកតាមភេទ និងការវិភាគយេនឌ័រប្រកបដោយលក្ខណៈប្រព័ន្ធដែរឬទេ ? |

| | |
|---|---|
| | - តើច្បាប់តម្រូវថា យុទ្ធសាស្ត្រ និងផែនការនានាគួរត្រូវបានបង្កើតឡើងដើម្បីធានានូវការលើកកម្ពស់ និងការការពារសមភាពយេនឌ័រដែរឬទេ ?<br>- តើមានគណៈកម្មការឯករាជ្យណាមួយ (ឧទាហរណ៍ គណៈកម្មការស្ត្រី គណៈកម្មការសិទ្ធិមនុស្ស ដែលពិនិត្យមើលឡើងវិញលើអនុលោមភាពរបស់រដ្ឋជាមួយសមភាពយេនឌ័រ និង/ឬ CEDAW ដែរឬទេ ?)<br>*ការដាក់បញ្ចូល និងការអនុវត្តសន្ធិសញ្ញា*<br>- តើ CEDAW ត្រូវបានចាត់ទុកថាជាច្បាប់នៅក្នុងក្របខ័ណ្ឌជាតិដែរឬទេ ?<br>- តើបញ្ញត្តិរបស់ CEDAW អាចត្រូវបានលុបចោលដោយផ្ទាល់នៅក្នុងនីតិវិធីតុលាការ ឬនីតិវិធីស្រដៀងតុលាការ ថាជាប្រភពនៃសិទ្ធិដែលអាចធ្វើសកម្មភាពបានដែរឬទេ ?<br>- ក្នុងករណីដែលមានវិវាទកើតឡើងរវាង CEDAW និងច្បាប់ក្នុងស្រុក តើ CEDAW មានឧត្តមភាពដែរឬទេ ប្រសិនបើច្បាប់ក្នុងស្រុកមានលក្ខណៈអនុគ្រោះតិចជាងចំពោះការសម្រេចបាននូវសមភាព ?<br>*វិធានការពិសេសបណ្ដោះអាសន្ន*<br>- តើច្បាប់តម្រូវអោយមានការបង្កើតវិធានការពិសេសបណ្ដោះអាសន្ន ដើម្បីពន្លឿនសមភាពភាពជាក់ស្តែងដែរ ឬទេ ?<br>- តើមាននីតិវិធីសម្រាប់អនុវត្តវិធានការពិសេសបណ្ដោះអាសន្នទាំងនេះដែរឬទេ ? |

| មាត្រា ១ និង ២ : អំពើហិង្សាផ្អែកលើយេនឌ័រ | |
|---|---|
| **កាតព្វកិច្ច CEDAW** | **សូចនាករផ្នែកច្បាប់នៃ CEDAW** |
| • មាត្រា ១-២ និង ៥<br>• អនុសាសន៍ទូទៅទី ១៩<br>• ការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ | *អំពើហិង្សាក្នុងគ្រួសារ*<br>- តើអំពើហិង្សាក្នុងគ្រួសារត្រូវបានកំណត់និយមន័យដោយច្បាប់ដើម្បីរួមបញ្ចូលរាល់ទម្រង់ទាំងអស់នៃអំពើហិង្សា (ការបង្គ្រោះថ្នាក់ និងការរំលោភបំពានផ្នែករាងកាយ ផ្លូវចិត្ត សេដ្ឋកិច្ច និងផ្លូវភេទ) ដែរឬទេ ?<br>- តើនិយមន័យនៃអំពើហិង្សាក្នុងគ្រួសាររួមបញ្ចូលទាំងការរំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍ដែរឬទេ ?<br>- តើនិយមន័យនៃអំពើហិង្សាក្នុងគ្រួសាររួមបញ្ចូលរាល់ទម្រង់ទាំងអស់នៃការបង្ខិតបង្ខំ និងការដកហូតសិទ្ធិសេរី ភាពដែរឬទេ ?<br>- តើការការពារពីអំពើហិង្សាក្នុងគ្រួសារត្រូវបានពង្រីកដល់សហព័ទ្ធ អតីតសហព័ទ្ធ បុគ្គលដែលមានកូនរួមគ្នា បុគ្គលដែលរស់នៅជាមួយគ្នា និងបុគ្គលដទៃទៀតដែលមានទំនាក់ទំនងជិតស្និទ្ធដែរឬទេ ?<br>- តើច្បាប់មានចែងអំពីវិធានការការពារបន្ទាន់សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារដែរឬទេ ?<br>• តើវិធានការនេះហាមឃាត់ជនល្មើសកុំអោយប្រព្រឹត្តអំពើហិង្សាបន្ថែមទៀតដែរឬទេ ?<br>• តើវិធានការនេះហាមឃាត់ជនល្មើសកុំអោយទាក់ទង ឬយាយីជនរងគ្រោះ ឬសមាជិកគ្រួសាររបស់ជនរងគ្រោះដែរឬទេ ?<br>• តើវិធានការនេះអនុញ្ញាតអោយមានការបណ្ដេញជនល្មើសជាបណ្ដោះអាសន្នចេញពីលំនៅដ្ឋានរបស់ជនរងគ្រោះ ដោយមិនគិតពីភាពជាកម្មសិទ្ធិលើលំនៅដ្ឋានដែរឬទេ ?<br>• តើវិធានការនេះអនុញ្ញាតអោយមានការសម្រេចចិត្តលើការគ្រប់គ្រងកូនបណ្ដោះអាសន្នដែរឬទេ ?<br>• តើវិធានការនេះអនុញ្ញាតអោយមានការបង់ប្រាក់ឧបត្ថម្ភចំពោះជនរងគ្រោះដែរឬទេ ?<br>• តើវិធានការនេះអនុញ្ញាតអោយមានការបង់ប្រាក់សម្រាប់ចំណាយវេជ្ជសាស្ត្រដែលកើតឡើងដោយសារអំពើហិង្សាដែរឬទេ ?<br>- តើអំពើហិង្សាក្នុងគ្រួសារត្រូវបានហាមឃាត់ឬទេ ?<br>- តើមានវិធានការការពារបន្ទាន់ដែលមានសុពលភាពសម្រាប់រយៈពេលគ្រប់គ្រាន់ ដើម្បីអនុញ្ញាតអោយជនរងគ្រោះអាចធានានូវសុវត្ថិភាព និងការការពារខ្លួនដែរឬទេ ?<br>- តើច្បាប់នេះអនុញ្ញាតអោយមានការចេញវិធានការការពារបន្ទាន់ក្រៅពីការដាក់ពាក្យបណ្ដឹង (ទោះបីជាជនរងគ្រោះដាក់ ឬមិនដាក់ពាក្យបណ្ដឹងក៏ដោយ) ដែរឬទេ ? |

- តើវិធានការការពារបន្ទាន់ត្រូវបានចេញដោយអាជ្ញាធរដែលងាយស្រួលចូលទៅដល់ដែរឬទេ ?
- តើវិធានការការពារបន្ទាន់ត្រូវបានចេញចំពោះភាគីតែម្ខាងដែរឬទេ ?
- តើវិធានការការពារបន្ទាន់ត្រូវបានចេញនៅថ្ងៃដដែលដូចកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំដែរឬទេ ?
- តើច្បាប់មានចែងអំពីពីសេវាស្តារនីតិសម្បទាសម្រាប់ជនល្មើសដែលប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដែរឬទេ ?
- តើច្បាប់តម្រូវអោយមានការផ្តល់សេវាផ្តល់ប្រឹក្សាដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ និងគ្រួសាររបស់ពួកគេដែរឬទេ ?
- តើច្បាប់តម្រូវអោយមានការផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ឬក្នុងតម្លៃថោកចំពោះជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារដែរឬទេ ?
- តើច្បាប់តម្រូវអោយសេវាវេជ្ជសាស្ត្រដោយឥតគិតថ្លៃ ឬក្នុងតម្លៃថោកដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារដែរឬទេ ?
- តើច្បាប់កំណត់ទីភ្នាក់ងារសមស្រប ដើម្បីផ្តល់សេវាគាំទ្រចំពោះជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ ដែរឬទេ ?
- តើច្បាប់តម្រូវអោយមានការបង្កើតកន្លែងស្នាក់នៅ ឬជម្រកសម្រាប់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ដែរឬទេ ?
- អំពើហិង្សាក្នុងគ្រួសារត្រូវបានផ្តន្ទាទោសដោយទណ្ឌកម្មសមស្របទៅនឹងកម្រិតនៃបទល្មើសដែរឬទេ ?
- តើច្បាប់តម្រូវអោយមានការរាយការណ៍ជាកំហិតអំពីអំពើហិង្សាក្នុងគ្រួសារដល់អាជ្ញាធរមូលដ្ឋាន ដោយអ្នកផ្តល់សេវាសុខភាព បុគ្គលិកសង្គមកិច្ច មន្ត្រីភូមិ និងមន្ត្រីសាធារណៈសមស្របដទៃទៀតដែរឬទេ ?
- តើការបញ្ឈប់បណ្តឹងរបស់ជនរងគ្រោះ មានន័យថាជាការបញ្ឈប់ការផ្តន្ទាទោសលើករណីព្រហ្មទណ្ឌនៃអំពើហិង្សាក្នុងគ្រួសារដែរឬទេ ?
- តើជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារមានសិទ្ធិទទួលបានសំណងដែរឬទេ ?
- តើករណីអំពើហិង្សាក្នុងគ្រួសារមិនអាចសម្របសម្រួលបានទេឬ ?
- តើច្បាប់មានចែងអំពីការកំណត់តួនាទីច្បាស់លាស់ក្នុងចំណោមទីភ្នាក់ងាររដ្ឋក្នុងការដោះស្រាយអំពើហិង្សាក្នុង គ្រួសារដែរឬទេ ?
- តើច្បាប់មានកំណត់កិច្ចសហប្រតិបត្តិការអន្តរទីភ្នាក់ងារក្នុងការដោះស្រាយអំពើហិង្សាក្នុងគ្រួសារដែរឬទេ ?
- តើច្បាប់តម្រូវអោយមានការបណ្តុះបណ្តាលមន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ បុគ្គលិកសង្គមកិច្ច និងអ្នកផ្តល់ សេវាសុខភាពអំពើហិង្សាក្នុងគ្រួសារដែរឬទេ ?
- តើច្បាប់តម្រូវអោយមានការផ្សព្វផ្សាយព័ត៌មានអំពីអំពើហិង្សាក្នុងគ្រួសារដោយទីភ្នាក់ងារពិសេសដែរឬទេ ?
- តើច្បាប់តម្រូវអោយមានការប្រមូលទិន្នន័យ និងការស្រាវជ្រាវអំពីអំពើហិង្សាក្នុងគ្រួសារដែរឬទេ ?

*ការរំលោភសេពសន្ថវៈ និងទម្រង់ដទៃទៀតនៃការបៀតបៀនផ្លូវភេទ*

- តើការរំលោភសេពសន្ថវៈ និងទម្រង់ដទៃទៀតនៃការបៀតបៀនផ្លូវភេទត្រូវបានហាមឃាត់ដែរឬទេ ?
- តើនិយមន័យនៃពាក្យ ការរំលោភសេពសន្ថវៈ ឬការបៀតបៀនផ្លូវភេទ រួមបញ្ចូលទាំង ការស៊កលិង្គទៅក្នុងមាត់ ឬរន្ធគូថរបស់មនុស្សម្នាក់ទៀតដែរឬទេ ?
- តើនិយមន័យនៃពាក្យ ការរំលោភសេពសន្ថវៈ ឬការបៀតបៀនផ្លូវភេទ រួមបញ្ចូលទាំងការស៊កវត្ថុទៅក្នុងប្រដាប់ភេទរបស់មនុស្សម្នាក់ទៀតដែរឬទេ ?
- តើច្បាប់អនុញ្ញាតអោយមានការផ្តន្ទាទោសចំពោះការរំលោភសេពសន្ថវៈ ទោះបីជាពុំមានការយល់ព្រមពីជនរងគ្រោះដែរឬទេ ?
- តើការផ្តន្ទាទោសចំពោះការរំលោភសេពសន្ថវៈត្រូវបានបញ្ឈប់ដែរឬទេ ប្រសិនបើមានការដកបណ្តឹងពីជនរងគ្រោះ ?
- តើការរំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍គឺជាបទល្មើសដែរឬទេ ?
- តើច្បាប់អនុញ្ញាតអោយមានការបញ្ឈប់ចំណាត់ការព្រហ្មទណ្ឌសម្រាប់ការរំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍ដែរឬទេ ប្រសិនបើមានការដកបណ្តឹង ឬការអភ័យទោសដោយសហព័ទ្ធ ?
- តើមានការហាមឃាត់ការប្រើប្រាស់តិរិយាបថផ្លូវភេទ ដើម្បីធ្វើអោយមានការយល់ព្រមចំពោះការរួមភេទដែរឬទេ ?

| | |
|---|---|
| | - តើមិនមានលក្ខខណ្ឌតម្រូវផ្នែកច្បាប់សម្រាប់កម្រិតធ្ងន់ធ្ងរនៃការតស៊ូផ្នែករាងកាយដោយជនរងគ្រោះចំពោះការរំលោភសេពសន្ថវៈទេឬ ?<br>- តើមិនមានលក្ខខណ្ឌតម្រូវផ្នែកច្បាប់នៃការបញ្ជាក់អះអាងនៃសក្ខីកម្មរបស់ជនរងគ្រោះ ដើម្បីផ្តន្ទាទោសដោយជោគជ័យចំពោះការរំលោភសេពសន្ថវៈទេឬ ?<br>- តើច្បាប់តម្រូវអោយមានការផ្តល់សេវាសម្រាប់ការព្យាបាលរបួសផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ចំពោះជនរង គ្រោះដែរឬទេ ?<br>- តើច្បាប់ចែងអំពីជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ឬក្នុងតម្លៃថោកចំពោះជនរងគ្រោះដោយសារការរំលោភ សេពសន្ថវៈដែរឬទេ ,<br>- តើជនរងគ្រោះដោយសារការរំលោភសេពសន្ថវៈមានសិទ្ធិទទួលបានសំណងដែរឬទេ ?<br>- តើច្បាប់ការពារអត្តសញ្ញាណ និងភាពជាឯកជននៃជនរងគ្រោះដោយសារការរំលោភសេពសន្ថវៈ និងការបៀត បៀនផ្លូវភេទដែរឬទេ ?<br>- តើច្បាប់តម្រូវអោយតុលាការបង្កើតការរៀបចំនីតិវិធីមិនទល់មុខគ្នា ដូចជាវិដេអូខន់ហ្វឺរិន ក្នុងករណីដែលសុវត្ថិភាព ឬសុខភាពរបស់ជនរងគ្រោះស្ថិតក្នុងហានិភ័យដែរឬទេ ?<br>- តើច្បាប់ចែងអំពីនីតិវិធីសម្រាប់ការពារជនរងគ្រោះដោយសារការរំលោភសេពសន្ថវៈ និងសាក្សីពីការសងសឹក ឬការបំភិតបំភ័យ ឧទាហរណ៏ កម្មវិធីការពារជនរងគ្រោះ ឬសាក្សីដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានការបណ្តុះបណ្តាលមន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ បុគ្គលិកសង្គមកិច្ច និងអ្នកផ្តល់ សេវាសុខភាពអំពីការរំលោភសេពសន្ថវៈ និងការបៀតបៀនផ្លូវភេទ រួមទាំង វិធីសាស្ត្រដែលមានវេទយិតភាព ផ្នែកយេនឌ័រក្នុងការចាត់ចែងករណីទាំងនេះដែរឬទេ ? |

| មាត្រា ៦ : ការជួញដូរ និងការធ្វើអាជីវកម្មពេស្យាចារលើអ្នកដទៃ | |
|---|---|
| **កាតព្វកិច្ច CEDAW** | **សូចនាករផ្នែកច្បាប់នៃ CEDAW** |
| • មាត្រា ៦<br>• អនុសាសន៍ទូទៅទី ១៩ កថាខ័ណ្ឌ ទី ១៣-១៦ និង ២៤<br>• ការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ | *កាជួញដូរ*<br>- តើការជួញដូរមនុស្សត្រូវបានហាមឃាត់ដែរឬទេ ?<br>- តើច្បាប់កំណត់និយមន័យជួញដូរដើម្បីរួមបញ្ចូលទង្វើទាំងឡាយណាដែលអាចបង្កើតជាការជួញដូររួមទាំងការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការលើកដាក់កំពង់ផែរ ឬការទទួលមនុស្សដែរឬទេ ?<br>- តើច្បាប់កំណត់រាល់មធ្យោបាយសម្រាប់ការអនុវត្តបទឧក្រិដ្ឋនៃការជួញដូរ រួមទាំងការគំរាមកំហែង ការប្រើកម្លាំង ទម្រង់ផ្សេងទៀតនៃការបង្ខិតបង្ខំ ការចាប់ពង្រត់ ការឆបោក ការបោកប្រាស់ ការរំលោភអំណាច ការ រំលោភតួនាទីនៃភាពងាយរងគ្រោះ ការផ្តល់ ឬការទទួលប្រាក់ ឬអត្ថប្រយោជន៏ ដើម្បីទទួលបានការយល់ព្រម ពីបុគ្គលដែលគ្រប់គ្រងលើបុគ្គលម្នាក់ទៀតដែរឬទេ ?<br>- តើច្បាប់កំណត់គោលបំណងនៃការជួញដូរ ដើម្បីរួមបញ្ចូលទាំងទម្រង់ផ្សេងៗនៃការកេងប្រវ័ញ្ច រួមទាំងការធ្វើអាជីវកម្មពេស្យាកម្ម និងទម្រង់ដទៃទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទ ពលកម្មដោយបង្ខំ ការអនុវត្តអំពើទាសភាព ឬដូចទាសភាព និងងការវះយកអវយវៈដែរឬទេ ?<br>- តើច្បាប់បង្កើតយុត្តាធិការលើបទល្មើសជួញដូរដែលប្រព្រឹត្តនៅក្នុងដែនដីរបស់រដ្ឋ និងបទល្មើសដែលប្រព្រឹត្តនៅក្រៅដែនដីរបស់រដ្ឋនៅពេលប្រព្រឹត្តដោយ ឬប្រឆាំងនឹងពលរដ្ឋរបស់ខ្លួនដែរឬទេ ?<br>- តើបុគ្គលដែលត្រូវបានជួញដូររួចផុតពីការផ្តន្ទាទោសដែរឬទេ ?<br>- តើបណ្តឹងអំពីការជួញដូរត្រូវបានលុបចោលដោយស្វ័យប្រវត្តិដែរឬទេ ប្រសិនបើបុគ្គលដែលត្រូវបានជួញដូរដកបណ្តឹង ?<br>- តើបុគ្គលដែលត្រូវបានជួញដូរមានសិទ្ធិទាមទារសំណងសម្រាប់ករខូចខាតដែលខ្លួនទទួលរងដែរឬទេ ?<br>- តើច្បាប់ការពារអត្តសញ្ញាណ និងភាពជាឯកជនរបស់ជនរងគ្រោះដោយសារការជួញដូរដែរឬទេ ? |

| | |
|---|---|
| | - តើច្បាប់តម្រូវអោយតុលាការបង្កើតការរៀបចំនីតិវិធីមិនទល់មុខគ្នា ដូចជាវិដេអូខន់ហ្វឺរិន ក្នុងករណីដែល សុវត្ថិភាព ឬសុខភាពរបស់ជនរងគ្រោះដោយសារការជួញដូរស្ថិតក្នុងហានិភ័យដែរឬទេ ?<br>- តើច្បាប់ចែងអំពីនីតិវិធីសម្រាប់ការពារជនរងគ្រោះដោយសារការជួញដូរ និងសាក្សីពីការសងសឹក ឬការបំភិតបំភ័យ ឧទាហរណ៍ កម្មវិធីការពារជនរងគ្រោះ ឬសាក្សីដែរឬទេ ?<br>- តើការជួញដូរគឺជាបទល្មើសដែលអាចធ្វើបត្យាប័នដែរឬទេ ?<br>- តើការជួញដូរត្រូវបានផ្តន្ទាទោសដោយទណ្ឌកម្មសមស្របទៅនឹងកម្រិតនៃបទល្មើសដែរឬទេ ?<br>- តើច្បាប់មានចែងអំពីសេវាស្តារនីតិសម្បទា/ការវិលត្រឡប់មករកភាពដើមវិញ និងការធ្វើសមាហរណកម្ម សម្រាប់ជនរងគ្រោះដោយសារការជួញដូរដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានការផ្តល់សេវាផ្តល់ប្រឹក្សាដល់ជនរងគ្រោះដោយសារការជួញដូរដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានការផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ឬក្នុងតម្លៃថោកចំពោះជនរងគ្រោះដោយសារការជួញដូរដែរឬទេ ?<br>- តើច្បាប់តម្រូវអោយសេវាវេជ្ជសាស្ត្រដោយឥតគិតថ្លៃ ឬក្នុងតម្លៃថោកដល់ជនរងគ្រោះដោយសារការជួញដូរដែរឬទេ ?<br>- តើច្បាប់កំណត់ទីភ្នាក់ងារសមស្រប ដើម្បីផ្តល់សេវាគាំទ្រចំពោះជនរងគ្រោះដោយសារការជួញដូរដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានការបង្កើតកន្លែងស្នាក់នៅ ឬជម្រកសម្រាប់ជនរងគ្រោះដោយសារការជួញដូរដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានការបណ្តុះបណ្តាលមន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ មន្ត្រីអន្តោប្រវេសន៍ បុគ្គលិក សង្គមកិច្ច និងអ្នកផ្តល់សេវាសុខភាពអំពីការជួញដូរ រួមទាំងការចាត់ចែងករណីទាំងនេះអោយបានសមស្របដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានការផ្សព្វផ្សាយព័ត៌មានអំពីការជួញដូរដោយទីភ្នាក់ងារពិសេសដែរឬទេ ?<br>*ការធ្វើអាជីវកម្មពេស្យាចារ*<br>- តើស្ត្រីដែលប្រកបអំពើពេស្យាចារត្រូវបានលើកលែងពីការផ្តន្ទាទោស ឬទម្រង់ណាមួយនៃការឃុំខ្លួនដោយបង្ខំដែរឬទេ ?<br>- តើការធ្វើសញ្ជរកម្មមនុស្សអោយប្រព្រឹត្តអំពើពេស្យាចារត្រូវទទួលការផ្តន្ទាទោសដែរឬទេ ?<br>- តើទង្វើទទួលប្រយោជន៍ដោយចេតនាពីអំពើពេស្យាចារលើអ្នកដទៃត្រូវបានផ្តន្ទាទោសដែរឬទេ ?<br>- តើច្បាប់ចែងអំពីការការពារអត្តសញ្ញាណ និងភាពជាឯកជនរបស់ជនរងគ្រោះដោយសារការធ្វើអាជីវកម្មពេស្យាចារដែរឬទេ ?<br>- តើច្បាប់កំណត់ទីភ្នាក់ងារសមស្រប ដើម្បីផ្តល់សេវាគាំទ្រដល់ជនរងគ្រោះដោយសារការធ្វើអាជីវកម្មពេស្យាចារដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានការបង្កើតកន្លែងស្នាក់នៅ ឬជម្រកសម្រាប់ជនរងគ្រោះដោយសារការធ្វើអាជីវកម្មពេស្យាចារដែរឬទេ?<br>- តើច្បាប់តម្រូវអោយមានទំនួលខុសត្រូវច្បាស់លាស់របស់ទីភ្នាក់ងាររដ្ឋក្នុងការដោះស្រាយអំពើពេស្យាចារដែរឬទេ ?<br>- តើចរិតសីលធម៌ល្អ ឬភាពនៅបរិសុទ្ធមិនមែនជាផ្នែកមួយនៃការរំលោភសេពសន្ថវៈ និងទម្រង់ដទៃទៀតនៃការបៀតបៀនផ្លូវភេទទេឬ ? |

| មាត្រា ៧-៨ : ជីវភាពនយោបាយ និងជីវភាពសាធារណៈ | |
|---|---|
| **កាតព្វកិច្ច CEDAW** | **សូចនាករផ្នែកច្បាប់នៃ CEDAW** |
| • មាត្រា ៧-៨<br>• អនុសាសន៍ទូទៅទី ២៣<br>• ការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ | - តើសិទ្ធិស្មើគ្នាក្នុងការបោះឆ្នោតត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ឬច្បាប់ដែរឬទេ ?<br>- តើមានភាពមានសិទ្ធិស្មើគ្នាចំពោះការបោះឆ្នោតសម្រាប់អង្គភាពដែលត្រូវបានបោះឆ្នោតជ្រើសរើសជាសាធារណៈទាំងអស់ដែរឬទេ ?<br>- តើមានបញ្ញត្តិច្បាប់សម្រាប់វិធានការពិសេសបណ្តោះអាសន្ន ដើម្បីអនុញ្ញាតអោយស្ត្រីអាចកាន់កាប់ ៣០% នៃអង្គនីតិបញ្ញត្តិដែរឬទេ ? |

| | |
|---|---|
| | - តើមានភាពមានសិទ្ធិស្មើគ្នាចំពោះការតែងតាំងមុខតំណែងសាធារណៈដែរឬទេ ?<br>- តើមានបញ្ញត្តិច្បាប់សម្រាប់វិធានការពិសេសបណ្តោះអាសន្ន ដើម្បីអនុញ្ញាតអោយស្ត្រីកាន់កាប់ ៣០% នៃមុខតំណែងសាធារណៈដែលត្រូវបានតែងតាំងដែរឬទេ ?<br>- តើពុំមានការដាក់កំហិតនៅក្នុងច្បាប់ចំពោះសេរីភាពដើរហើររបស់ស្ត្រីទេឬ ?<br>- តើស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការចូលរួមក្នុងអង្គការមហាជន អង្គការមិនមែនរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិលដទៃទៀតដែរឬទេ ?<br>- តើមានច្បាប់ដែលគ្រប់គ្រងលើការចុះបញ្ជី និងការប្រមូលផ្តុំអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជំរុញការអភិវឌ្ឍស្ត្រីដែរឬទេ ?<br>- តើច្បាប់ធានានូវលក្ខណៈវិនិច្ឆ័យដូចគ្នាសម្រាប់ការជ្រើសមន្ត្រីទូតជាស្ត្រី និងបុរសដែរឬទេ ?<br>- តើច្បាប់ធានានូវអត្ថប្រយោជន៍ និងឱកាសស្មើគ្នាសម្រាប់មន្ត្រីទូតជាស្ត្រី និងបុរសដែរឬទេ ? |

| មាត្រា ៩ : សញ្ជាតិ | |
|---|---|
| **កាតព្វកិច្ច CEDAW** | **សូចនាករផ្នែកច្បាប់នៃ CEDAW** |
| • មាត្រា ៩<br>• អនុសាសន៍ទូទៅទី ២១ កថាខ័ណ្ឌ ទី ៦<br>• ការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ | - តើស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការទទួលបាន ឬប្តូរសញ្ជាតិរបស់ខ្លួនដែរឬទេ ?<br>- តើស្ត្រីមានសិទ្ធិក្នុងការរក្សាទុកសញ្ជាតិរបស់ខ្លួនដែរឬទេ ទោះបីជារៀបការជាមួយជនបរទេស ឬមានការប្តូរសញ្ជាតិរបស់ប្តី ?<br>- តើស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការផ្ទេរសញ្ជាតិរបស់ខ្លួនទៅអោយកូនដែរឬទេ ?<br>- តើស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការផ្ទេរសញ្ជាតិរបស់ខ្លួនទៅអោយស្វាមីដែរឬទេ ? |

| មាត្រា ១០ : ការអប់រំ | |
|---|---|
| **កាតព្វកិច្ច CEDAW** | **សូចនាករផ្នែកច្បាប់នៃ CEDAW** |
| • មាត្រា ១០<br>• ការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ | - តើមានការធានានូវសមភាព និងការមិនរើសអើងនៅក្នុងការអប់រំដែរឬទេ ?<br>- តើច្បាប់ហាមឃាត់ការរើសអើងក្នុងការជ្រើសរើសអោយបម្រើការងារ ការជ្រើសរើស និងការចុះឈ្មោះចូលរៀនរបស់សិស្ស/និស្សិតដែរឬទេ ?<br>- តើមានការហាមឃាត់ផ្នែកច្បាប់ប្រឆាំងនឹងការមិនអោយចុះឈ្មោះចូលរៀន ឬការបណ្តេញចេញពីសាលារៀន ផ្អែកលើការមានគភ៌ និងមាតុភាពដែរឬទេ ?<br>- តើច្បាប់ធានានូវការទទួលបានកម្មវិធីសិក្សា ការប្រឡង បុគ្គលិកបង្រៀន និងសម្ភារសិក្សាដូចគ្នាដែរឬទេ ?<br>- តើច្បាប់ហាមឃាត់ការរើសអើងផ្អែកលើភេទ/យេនឌ័រនៅក្នុងការផ្តល់អាហារូបករណ៍ និងប្រាក់ឧបត្ថម្ភសម្រាប់ការសិក្សាដែរឬទេ ?<br>- តើមានច្បាប់ស្តីពីការធានានូវលទ្ធភាពទទួលបានការអប់រំរបស់ក្រុមស្ត្រីដែលបាត់បង់ឱកាស ដូចជាស្ត្រី និងក្មេង ស្រីជនជាតិដើម និងស្ត្រី និងក្មេងស្រីពិការដែរឬទេ ?<br>- តើមានឯកសារច្បាប់ដែលធានាថា អ្នកគ្រប់គ្រងសាលា បុគ្គលិក និងគ្រូបង្រៀនមិនរើសអើងផ្អែកលើភេទ/យេនឌ័រ ដែរឬទេ ?<br>- តើការបៀតបៀនផ្លូវភេទ ដោយអ្នកគ្រប់គ្រងសាលា បុគ្គលិក គ្រូបង្រៀន និងមិត្តរួមសាលាត្រូវបានហាមឃាត់ដែរឬទេ ?<br>- តើនិយមន័យនៃពាក្យ ការបៀតបៀនផ្លូវភេទ រួមបញ្ចូលទាំងទម្រង់នៃការបៀតបៀនផ្លូវកាយ ផ្លូវចិត្ត ពាក្យសម្តី និងរូបភាពដែរឬទេ ? |

| មាត្រា ១១ : ការងារ | |
|---|---|
| **កាតព្វកិច្ច CEDAW** | **សូចនាករផ្នែកច្បាប់នៃ CEDAW** |
| • CEDAW មាត្រា ១១<br>• អនុសាសន៍ទូទៅទី ១៣<br>• អនុសាសន៍ទូទៅទី ១៦<br>• អនុសាសន៍ទូទៅទី ១៧<br>• អនុសាសន៍ទូទៅទី ១៩ កថាខ័ណ្ឌ ទី ១៧, ១៨ និង ២៤ ( ញ និង ត )<br>• ការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ | - តើមានការធានាច្បាស់លាស់ចំពោះសមភាព និងការមិនរើសអើងនៅក្នុងការងារផ្អែកលើភេទ ជាតិសាសន៍ ជាតិពន្ធុ ស្ថានភាពសេដ្ឋកិច្ច និងសង្គម និន្នការផ្លូវភេទ និងមូលហេតុស្រដៀងគ្នាដទៃទៀតដែរឬទេ ?<br>- តើស្ត្រីមានឱកាសការងារដូចគ្នានឹងបុរសដែរឬទេ ?( តើពុំមានការកំហិតទៅលើជម្រើសរបស់ស្ត្រីចំពោះការងារទេឬ ? )<br>- តើច្បាប់ហាមឃាត់ការប្រើប្រាស់លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសខុសគ្នាសម្រាប់បុរស និងស្ត្រីដែរឬទេ ?<br>- តើច្បាប់ហាមឃាត់ការផ្សាយពាណិជ្ជកម្មជ្រើសរើសបុគ្គលិកដែលកំហិតបេក្ខជនចំពោះភេទជាក់លាក់ដែរឬទេ ( លុះត្រាតែការផ្សាយពាណិជ្ជកម្មនេះស្ថិតក្នុងស្ថានភាពនៃវិធានការពិសេសបណ្តោះអាសន្ន ) ?<br>- តើច្បាប់ចែងអំពីវិធានការពិសេសបណ្តោះអាសន្ន ដើម្បធានាអោយស្ត្រីអាចចូលរួមនៅក្នុងការងារដែលកាន់កាប់ភាគច្រើនដោយបុរសដែរឬទេ ?<br>- តើច្បាប់ហាមឃាត់ការបណ្តេញចេញដោយសារភេទរបស់បុគ្គលិកដែរឬទេ ?<br>- តើច្បាប់មានបញ្ញត្តិស្តីពីលក្ខខណ្ឌស្មើគ្នាសម្រាប់ការបញ្ឈប់ការងារដែរឬទេ ?<br>- តើមានបញ្ញត្តិច្បាប់អំពីប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារស្មើគ្នា និងសម្រាប់ការងារដែលមានតម្លៃស្មើគ្នាដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានលក្ខណៈវិនិច្ឆ័យដូចគ្នាសម្រាប់ស្ត្រី និងបុរសក្នុងការតម្លើងឋានៈដែរឬទេ ?<br>- តើច្បាប់ចែងអំពីវិធានការពិសេសបណ្តោះអាសន្ន ដើម្បីធានានូវលទ្ធភាពស្មើគ្នាដោយស្ត្រី និងបុរសក្នុងការទទួលបានមុខតំណែងជាអ្នកដឹកនាំដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសដូចគ្នាសម្រាប់ស្ត្រី និងបុរសទាក់ទងនឹងលទ្ធភាពទទួលបានការបណ្តុះបណ្តាល និងសកម្មភាពអភិវឌ្ឍសមត្ថភាពដទៃទៀតដែរឬទេ ?<br>- តើច្បាប់ចែងអំពីវិធានការពិសេសបណ្តោះអាសន្ន ដើម្បីធានានូវលទ្ធភាពស្មើគ្នារបស់ស្ត្រី និងបុរសក្នុងការទទួលបានការបណ្តុះបណ្តាល និងឱកាសអភិវឌ្ឍសមត្ថភាពដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានលក្ខណៈវិនិច្ឆ័យស្មើគ្នានៅក្នុងការវាយតម្លៃការងារដែរឬទេ ?<br>- តើច្បាប់ចែងអំពីអាយុ និងលក្ខខណ្ឌដូចគ្នាសម្រាប់ការចូលនិវត្តន៍ដែរឬទេ ?<br>- តើច្បាប់ចែងអំពីលក្ខខណ្ឌស្មើគ្នាសម្រាប់ការទទួលបានអត្ថប្រយោជន៍និរភ័យសង្គម( ដូចជាជំងឺពិការភាពឬភាពគ្មានការងារធ្វើ) ដែរឬទេ ?<br>- តើការបៀតបៀនផ្លូវភេទដោយនិយោជក និងសហការីត្រូវបានហាមឃាត់ដែរឬទេ ?<br>- តើនិយមន័យនៃពាក្យ ការបៀតបៀនផ្លូវភេទ រួមបញ្ចូលទាំង ទម្រង់នៃការបៀតបៀនផ្លូវកាយ ផ្លូវចិត្ត ពាក្យសម្តី និងរូបភាពដែរឬទេ ?<br>- តើច្បាប់ចែងអំពីការការពារស្មើគ្នាចំពោះស្ត្រី និងបុរសពីគ្រោះថ្នាក់ការងារដែរឬទេ ?<br>- តើច្បាប់ចែងអំពីសិទ្ធិស្មើគ្នាក្នុងការរៀបចំ ឬចូលរួមក្នុងសហជីពនិយោជិតកម្មករដែរឬទេ ?<br>- តើច្បាប់ហាមឃាត់ការកំហិតលើប្រភេទការងារដែលស្ត្រីអាចបំពេញបាននៅក្នុងការងាររបស់ខ្លួនដែរឬទេ ?<br>- តើច្បាប់អនុញ្ញាតអោយបុរស និងស្ត្រីធ្វើការដោយសុវត្ថិភាពនៅពេលយប់ដែរឬទេ ?<br>- តើច្បាប់ហាមឃាត់ការបណ្តេញចេញដោយសារស្ថានភាពអាពាហ៍ពិពាហ៍ ការមានគភ៌ និងមាតុភាពដែរឬទេ ?<br>- តើច្បាប់ចែងអំពីការឈប់សម្រាកលំហែមាតុភាពដោយមានប្រាក់ឈ្នួលសម្រាប់រយៈពេលសមស្រប ដោយមិនបាត់បង់អតីតភាពការងារ ឬអត្ថប្រយោជន៍ដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានការផ្តល់មណ្ឌលថែទាំកុមារនៅកន្លែងធ្វើការ ឬការឧបត្ថម្ភចំពោះការថែរក្សាកូនដែរឬទេ ?<br>- តើច្បាប់អនុញ្ញាតអោយមានពេលវេលាថែរក្សាកូនសមស្របក្នុងអំឡុងម៉ោងធ្វើការដែរឬទេ ? |

| | |
|---|---|
| | - តើច្បាប់ចែងអំពីការការពារចំពោះស្ត្រីកុំអោយធ្វើការងារធ្ងន់ ឬធ្វើការងារដែលមានគ្រោះថ្នាក់ចំពោះសុខភាពខ្លួនឯង និងសុខភាពទារកក្នុងអំឡុងពេលមានគភ៌ដែរឬទេ ?<br>- តើមានច្បាប់ឈប់សម្រាកលំហែបិតុភាពដោយមានប្រាក់ឈ្នួលសម្រាប់រយៈពេលសមរម្យដែរឬទេ ?<br>- តើច្បាប់កំណត់ស្ថាប័នណាមួយដើម្បីពិនិត្យតាមដានអនុលោមភាពតាមបញ្ញត្តិស្តីពីសមភាពយេនឌ័រនៅក្នុងការងារដែរឬទេ ?<br>- តើច្បាប់កំណត់ស្ថាប័នណាមួយដើម្បីអនុវត្តអនុលោមភាពតាមបញ្ញត្តិស្តីពីសមភាពយេនឌ័រនៅក្នុងការងារ ដែរឬទេ ?<br>- តើមានដំណោះស្រាយប្រឆាំងនឹងស្ថាប័នទទួលបន្ទុកពិនិត្យតាមដាន ឬអនុវត្តន៍ដែលត្រូវបានចាត់តាំងចំពោះការខកខានមិនបានអនុវត្តមុខងារពិនិត្យតាមដាន និងអនុវត្តន៍របស់ខ្លួនដែរឬទេ ?<br>- តើមានទណ្ឌកម្មសម្រាប់ការរើសអើងផ្នែកយេនឌ័រនៅក្នុងការងារដែរឬទេ ?<br>- តើជនរងគ្រោះដោយសារការរើសអើងនៅក្នុងការងារត្រូវបានផ្តល់សំណងសម្រាប់ការខូចខាតដែលទទួលរងដែរឬទេ ? |

| មាត្រា ១២ : សុខភាព | |
|---|---|
| **កាតព្វកិច្ច CEDAW** | **សូចនាករផ្នែកច្បាប់នៃ CEDAW** |
| • មាត្រា ១២<br>• អនុសាសន៍ទូទៅទី ១៩ កថាខ័ណ្ឌ ១៩-២០<br>• អនុសាសន៍ទូទៅទី ២៤<br>• ការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ | - តើច្បាប់ធានានូវការមិនរើសអើង និងលទ្ធភាពស្មើគ្នាក្នុងការទទួលបានការថែទាំសុខភាពផ្អែកលើភេទ/យេនឌ័រដែរឬទេ ?<br>- តើមានការធានាជាក់លាក់ចំពោះការថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជសម្រាប់ស្ត្រីដែរឬទេ ?<br>- តើមានច្បាប់ធានានូវលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានសេវាថែទាំសុខភាពសមស្របទាក់ទងនឹងការមានគភ៌ និងមាតុភាពដែរឬទេ ?<br>- តើមានច្បាប់ដែលតម្រូវអោយមានសេវាថែទាំសុខភាពឥតគិតថ្លៃ ឬក្នុងតម្លៃថោកសម្រាប់ស្ត្រីក្រីក្រ ស្ត្រីជនជាតិដើម ឬក្រុមស្ត្រីបាត់បង់ឱកាសដទៃទៀតដែរឬទេ ?<br>- តើការរំលូតកូនត្រូវបានលើកលែងទោសព្រហ្មទណ្ឌដែរឬទេ ?<br>- តើការរំលូតកូន ដើម្បីជ្រើសរើសភេទ និងការជ្រើសរើសភេទមុនពេលកើតត្រូវបានហាមឃាត់ដែរឬទេ ?<br>- តើពុំមានច្បាប់ដែលរឹតត្បិតទំហំគ្រួសារទេឬ ?<br>- តើពុំមានលក្ខខណ្ឌតម្រូវសម្រាប់ការអនុញ្ញាតរបស់សហព័ទ្ធ ឬគ្រួសារសម្រាប់ស្ត្រីក្នុងការទទួលបានសេវាថែទាំ សុខភាពទេឬ ?<br>- តើមានច្បាប់ដែលហាមឃាត់ការរើសអើងក្នុងការទទួលបានសេវាថែទាំសុខភាពផ្លូវភេទនិងសុខភាពបន្តពូជដោយសារស្ថានភាពអាពាហ៍ពិពាហ៍ដែរឬទេ ?<br>- តើមានច្បាប់ដែលធានានូវសិទ្ធិទទួលបានជម្រើសដោយសេរី និងដោយមានព័ត៌មានគ្រប់គ្រាន់ក្នុងការធ្វើផែនការគ្រួសារដែរឬទេ ?<br>- តើមានច្បាប់ដែលហាមឃាត់ ការបង្ខិតបង្ខំ ការបំភិតបំភ័យ ឬការមានឥទ្ធិពលមិនសមស្របនៅក្នុងកម្មវិធីធ្វើផែនការគ្រួសារដែរឬទេ ?<br>- តើមានច្បាប់ដែលធានានូវលទ្ធភាពទទួលបានវិធីសាស្ត្រធ្វើផែនការគ្រួសារដែលមានតម្លៃថោកមានប្រសិទ្ធភាព និងច្រើនយ៉ាងដែរឬទេ ?<br>- តើមានច្បាប់ដែលតម្រូវអោយមានការបង្ការ និងការគ្រប់គ្រងជំងឺឆ្លងតាមផ្លូវបន្តពូជ ដូចជាជំងឺកាមរោគ មេរោគអេដស៍/ជំងឺអេដស៍ មហារីកផ្លូវបន្តពូជ និងជំងឺមហារីកដែលទាក់ទងនឹងរោគស្ត្រីដទៃទៀតដែរឬទេ ?<br>- តើមានច្បាប់ហាមឃាត់ការរើសអើងប្រឆាំងនឹងបុគ្គល រួមទាំងស្ត្រីដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងជំងឺកាមរោគដទៃទៀតដែរឬទេ ?<br>- តើការបៀតបៀនផ្លូវភេទដោយអ្នកប្រកបវិជ្ជាជីវៈផ្នែកសុខភាព ត្រូវបានហាមឃាត់ដែរឬទេ ? |

| | |
|---|---|
| | - តើនិយមន័យនៃពាក្យការបៀតបៀនផ្លូវភេទ រួមបញ្ចូលទាំង ទម្រង់នៃការបៀតបៀនផ្លូវកាយ ផ្លូវចិត្ត ពាក្យសម្តី និងរូបភាពដែរឬទេ ?<br>- តើច្បាប់ការពារអត្តសញ្ញាណ និងភាពជាឯកជនរបស់អ្នកជំងឺដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានការផ្សព្វផ្សាយព័ត៌មានអំពីការថែទាំសុខភាព រួមទាំង សុខភាពផ្លូវភេទ និងសុខភាពបន្តពូជដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានការបង្រៀនអំពីសិទ្ធិផ្លូវភេទ និងសិទ្ធិបន្តពូជសម្រាប់កុមារ និងយុវជនដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានវគ្គសិក្សាដែលមានវេទយិតភាពផ្នែកយេនឌ័រអំពីសុខភាពស្ត្រី និងអំពើហិង្សាផ្អែកលើយេនឌ័រនៅក្នុងកម្មវិធីសិក្សារបស់បុគ្គលិកសុខាភិបាលដែរឬទេ ?<br>- តើច្បាប់តម្រូវអោយាមានការបង្កើតវិធានការដើម្បីលើកកម្ពស់ជំនាញរបស់គ្រូព្យាបាលបុរាណ និងឆ្មប ដើម្បីអោយពួកគេអាចផ្តល់សេវាសុខភាពដែលមានសុវត្ថិភាព ប្រសិទ្ធភាព និងក្នុងតម្លៃថោកដែរឬទេ ? |

| មាត្រា ១៣ : ជីវភាពសេដ្ឋកិច្ច និងជីវភាពសង្គម | |
|---|---|
| **កាតព្វកិច្ច CEDAW** | **សូចនាករផ្នែកច្បាប់នៃ CEDAW** |
| • មាត្រា ១៣<br>• ការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ | - តើមានការធានាសម្រាប់ការចូលរួមស្មើគ្នារបស់ស្ត្រីនៅក្នុងអាជីវកម្មដែរឬទេ ?<br>- តើស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការទទួលបានឥណទានកម្ចី និងមូលនិធិដែរឬទេ ?<br>- តើមានវិធានការពិសេសបណ្តោះអាសន្ន ដើម្បីអនុញ្ញាតអោយភាគរយនៃស្ត្រីអាចទទួលបានឥណទានកម្ចី និងមូលនិធិដែរឬទេ ?<br>- តើច្បាប់ធានានូវការមិនរើសអើងនៅក្នុងកីឡា អាហារូបករណ៍ និងប្រាក់ឧបត្ថម្ភដែរឬទេ ?<br>- តើពុំមានការរឹតត្បិតនៅក្នុងច្បាប់ចំពោះការចូលរួមរបស់ស្ត្រីនៅក្នុងព្រឹត្តិការណ៍កីឡា និងការប្រកួតកីឡាទេឬ ? |

| មាត្រា ១៤ : ស្ត្រីជនបទ | |
|---|---|
| **កាតព្វកិច្ច CEDAW** | **សូចនាករផ្នែកច្បាប់នៃ CEDAW** |
| • មាត្រា ១៤<br>• អនុសាសន៍ទូទៅទី ១៩ កថាខ័ណ្ឌ ២១<br>• អនុសាសន៍ទូទៅទី ២៤ កថាខ័ណ្ឌ ទី ២៨<br>• ការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ | - តើមានវិធានការពិសេសបណ្តោះអាសន្ននៅក្នុងច្បាប់ ដើម្បអនុញ្ញាតអោយមានភាគរយនៃស្ត្រីជនបទ ស្ត្រីជនជាតិដើម និងស្ត្រីជនជាតិភាគតិចមានលទ្ធភាពទទួលបានការអប់រំគ្រប់កម្រិត និងគ្រប់ប្រភេទដែរឬទេ ?<br>- តើមានវិធានការពិសេសបណ្តោះអាសន្ននៅក្នុងច្បាប់ ដើម្បអនុញ្ញាតអោយមានភាគរយនៃស្ត្រីជនបទ ស្ត្រីជនជាតិដើម និងស្ត្រីជនជាតិភាគតិចមានលទ្ធភាពទទួលបានសេវាថែទាំសុខភាពដែរឬទេ ?<br>- តើច្បាប់អនុញ្ញាតអោយស្ត្រីចុះបញ្ជីទ្រព្យសម្បត្តិរបស់ខ្លួនក្នុងឈ្មោះរបស់ខ្លួនដែរឬទេ ?<br>- តើមិនមានការរឹតត្បិតចំពោះសិទ្ធិរបស់ស្ត្រីក្នុងការប្រើប្រាស់ ដាក់បន្ទុក ឬលក់ទ្រព្យសម្បត្តិរបស់ខ្លួន ឧទាហរណ៍ការអនុញ្ញាតពីគ្រួសារឬទេ ?<br>- តើច្បាប់អនុញ្ញាតអោយស្ត្រីគ្រប់គ្រងទ្រព្យសម្បត្តិ/ដីរួមដែរឬទេ ?<br>- តើច្បាប់ធានាអោយមានការចូលរួមរបស់ស្ត្រីនៅក្នុងការរៀបចំ ការបង្កើត និងការអនុវត្តគោលនយោបាយស្តីពីដីធ្លី កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងគោលនយោបាយអភិវឌ្ឍដទៃទៀតដែរឬទេ ?<br>- តើច្បាប់ចែងអំពីអត្ថប្រយោជន៍និរភ័យសង្គមសម្រាប់ស្ត្រីជនបទ ស្ត្រីជនជាតិដើម និងស្ត្រីជនជាតិភាគតិចដែរឬទេ ?<br>- តើមានច្បាប់ដើម្បីធានាការតំណាងស្ត្រីជនជាតិដើម និងស្ត្រីជនជាតិភាគតិចនៅក្នុងអង្គភាពដែលត្រូវបានបោះឆ្នោតជ្រើសរើសជាសាធារណៈដែរឬទេ ? |

| មាត្រា ១៥ : សមភាពចំពោះមុខច្បាប់ | |
|---|---|
| **កាតព្វកិច្ច CEDAW** | **សូចនាករផ្នែកច្បាប់នៃ CEDAW** |
| • មាត្រា ១៥<br>• អនុសាសន៍ទូទៅទី ២១ កថាខ័ណ្ឌ ទី ៧-១០<br>• ការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ | - តើរដ្ឋធម្មនុញ្ញធានានូវសមភាពចំពោះមុខច្បាប់ដែរឬទេ ?<br>- តើស្ត្រីមានសមត្ថភាពផ្នែកច្បាប់ដូចគ្នា និងសមត្ថភាពក្នុងការធ្វើសកម្មភាពដូចបុរសនៅក្នុងគ្រប់បញ្ហាស៊ីវិលទាំងអស់ដែរឬទេ ?<br>- តើស្ត្រី (មិនគិតពីស្ថានភាពអាពាហ៍ពិពាហ៍) មានសិទ្ធិស្មើគ្នាក្នុងការចុះកិច្ចសន្យាដែរឬទេ ? (តើមានការកំហិត ផ្នែកច្បាប់ណាមួយចំពោះស្ត្រីក្នុងការចុះកិច្ចសន្យាដែរឬទេ ?)<br>- តើស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការធ្វើជាអ្នកធ្វើបណ្តាំមរតក ឬអ្នកគ្រប់គ្រងលើអចលនទ្រព្យដែរឬទេ ?<br>- តើស្ត្រីមានសិទ្ធិស្មើគ្នាទាក់ទងនឹងភាពជាកម្មសិទ្ធិ ការទិញ ការចាត់ចែង ការគ្រប់គ្រង ការប្រើប្រាស់ និងការលក់ទ្រព្យសម្បត្តិ រួមទាំងដីធ្លីដែរឬទេ ? (តើពុំមានការកំហិតចំពោះសិទ្ធិរបស់ស្ត្រីក្នុងការកាន់កាប់ ទទួលបានចាត់ចែង គ្រប់គ្រង ប្រើប្រាស់ ឬលក់ទ្រព្យសម្បត្តិរបស់ខ្លួន ឧទាហរណ៍ ការអនុញ្ញាតពីគ្រួសារឬទេ ?)<br>- តើច្បាប់អនុញ្ញាតអោយស្ត្រីអាចចុះបញ្ជីទ្រព្យសម្បត្តិរបស់ខ្លួនក្នុងឈ្មោះរបស់ខ្លួនដែរឬទេ ?<br>- តើស្ត្រីអាចដាក់បណ្តឹងទៅកាន់តុលាការតាងនាមអោយខ្លួនឯងដែរឬទេ ?<br>- នៅក្នុងច្បាប់ តើសក្ខីកម្មរបស់ស្ត្រីដែលផ្តល់អោយមានទម្ងន់ដូចគ្នាទៅនឹងសក្ខីកម្មដែលផ្តល់ដោយបុរសដែរឬទេ ?<br>- តើស្ត្រីមានសិទ្ធិសេរីភាពក្នុងការដើរហើរស្មើគ្នាដែរឬទេ ?<br>- តើស្ត្រីមានសិទ្ធិដូចគ្នានឹងបុរសក្នុងការជ្រើសរើសលំនៅដ្ឋាន និងកន្លែងស្នាក់នៅ ដោយមិនគិតពីស្ថានភាពអាពាហ៍ពិពាហ៍ដែរឬទេ ? |

| មាត្រា ១៦ : អាពាហ៍ពិពាហ៍ និងគ្រួសារ | |
|---|---|
| **កាតព្វកិច្ច CEDAW** | **សូចនាករផ្នែកច្បាប់នៃ CEDAW** |
| • មាត្រា ១៦<br>• អនុសាសន៍ទូទៅទី ១៩ កថាខ័ណ្ឌ ទី ២២-២៤<br>• អនុសាសន៍ទូទៅទី ២១<br>• ការអង្កេតសន្និដ្ឋានអំពីប្រទេសប្រសិនបើពាក់ព័ន្ធ | - តើមានការធានាផ្នែកច្បាប់អំពីសមភាពយេនឌ័រនៅក្នុងគ្រួសារ និងអាពាហ៍ពិពាហ៍ដែរឬទេ ?<br>- តើច្បាប់ធានានូវសិទ្ធិស្មើគ្នាចំពោះស្ត្រី និងបុរសក្នុងការរៀបអាពាហ៍ពិពាហ៍ដែរឬទេ ?<br>- តើមានអាយុអប្បបរមា ១៨ ឆ្នាំ ស្មើគ្នាសម្រាប់អាពាហ៍ពិពាហ៍ដែរឬដែរទេ ?<br>- តើការចុះបញ្ជីកំណើតនៅការិយាល័យអត្រានុកូលដ្ឋានផ្លូវការ គឺជាការចាំបាច់ដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានការយល់ព្រមផ្ទាល់ខ្លួនពីសហព័ទ្ធទាំងពីរសម្រាប់អាពាហ៍ពិពាហ៍ដែរឬទេ ?<br>- ប្រសិនបើជំនូន្ទាន ឬការយល់ព្រមពីឪពុកម្តាយគឺជាការចាំបាច់ តើការយល់ព្រមរបស់ឪពុកម្តាយទាំងពីរមានទម្ងន់ ស្មើគ្នាដែរឬទេ ?<br>- តើទ្វេពន្ធភាព/ពហុពន្ធភាពត្រូវបានហាមឃាត់ដែរឬទេ ?<br>- តើការប្រើប្រាស់បណ្ណាការជាលក្ខខណ្ឌសម្រាប់អាពាហ៍ពិពាហ៍ត្រូវបានហាមឃាត់ដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានការចុះបញ្ជីអាពាហ៍ពិពាហ៍នៅការិយាល័យអត្រានុកូលដ្ឋានផ្លូវការដែរឬទេ ?<br>- តើសហព័ទ្ធទាំងពីរ (ស្វាមី និងភរិយា) មានភាពស្មើគ្នានៅក្នុងកម្មសិទ្ធិ ការទិញ ការចាត់ចែង ការគ្រប់គ្រង ការប្រើប្រាស់ និងការលក់ទ្រព្យសម្បត្តិដែរឬទេ ?<br>- តើពុំមានការដាក់កំហិតណាមួយដែលតម្រូវអោយមានការយល់ព្រមពីសហព័ទ្ធសម្រាប់ការពន្យារកំណើត ឬការរំលូតកូនទេឬ ?<br>- តើសហព័ទ្ធមានសិទ្ធិស្មើគ្នាក្នុងការជ្រើសរើស និងអនុវត្តវិជ្ជាជីវៈរបស់ខ្លួនដែរឬទេ ?<br>- តើស្ត្រី និងបុរសមានមូលហេតុ និងលក្ខខណ្ឌដូចគ្នាសម្រាប់ការដាក់ពាក្យបណ្តឹងរស់នៅបែកគ្នាការធ្វើមោឃភាព ឬការលុបចោលអាពាហ៍ពិពាហ៍ ឬការលែងលះដែរឬទេ ?<br>- តើច្បាប់ចែងអំពីការបែងចែកស្មើគ្នានូវទ្រព្យសម្បត្តិ និងចំណូលដែលរកបានក្នុងអំឡុងអាពាហ៍ពិពាហ៍ ជាពិសេសការផ្តល់ទម្ងន់ |

| | |
|---|---|
| | ស្មើគ្នាចំពោះការរួមចំណែកជាហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ (ឧទាហរណ៍ ការងារផ្ទះ និងការថែទាំកូន) ចំពោះគ្រួសារដែរឬទេ ?<br>- តើច្បាប់ចែងអំពីការបែងចែកស្មើគ្នានូវទ្រព្យសម្បត្តិ និងចំណូលដែលរកបានក្នុងពេលរួមរស់ជាមួយគ្នា ដោយមិនគិតពីអត្ថប្រយោជន៍នៃអាពាហ៍ពិពាហ៍ (ការរួមរស់ជាមួយគ្នាជាក់ស្តែង) ដែរឬទេ ?<br>- តើច្បាប់ចែងអំពីការផ្តល់ប្រាក់សម្រាប់ឧបត្ថម្ភកូនក្រោយការលែងលះដែរឬទេ ?<br>- តើច្បាប់ចែងអំពីការថែទាំ ឬការឧបត្ថម្ភអតីតសហព័ទ្ធក្រោយពីការលែងលះ ផ្អែកលើតម្រូវការទ្រព្យសម្បតិ និងសមត្ថភាពរកចំណូលដែរឬទេ ?<br>- តើទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ត្រូវបានចុះបញ្ជីក្នុងឈ្មោះរបស់សហព័ទ្ធទាំងពីរដែរឬទេ ?<br>- តើច្បាប់តម្រូវអោយមានការយល់ព្រមពីសហព័ទ្ធទាំងពីរចំពោះរាល់ប្រតិបត្តិការទាំងឡាយណាក្នុងការដាក់បន្ទុក ឬលក់ទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ដែរឬទេ ?<br>- តើមានការគ្រប់គ្រង និងលទ្ធភាពទទួលបានកូនផ្អែកលើឧត្តមប្រយោជន៍របស់កូន ដោយមិនគិតពីស្ថានភាពអាពាហ៍ពិពាហ៍របស់ឪពុកម្តាយដែរឬទេ ?<br>- តើច្បាប់តម្រូវអោយឪពុកម្តាយទាំងពីរឧបត្ថម្ភ ថែទាំ និងអប់រំកូន ដោយមិនគិតពីស្ថានភាពគ្រួសាររបស់ពួកគេដែរឬទេ ?<br>- តើច្បាប់ចែងអំពីអាណាព្យាបាលស្មើគ្នាដែរឬទេ ?<br>- តើច្បាប់ចែងអំពីសិទ្ធិ និងលក្ខខណ្ឌស្មើគ្នាសម្រាប់ស្ត្រី និងបុរសក្នុងការសុំកូនចិញ្ចឹមដែរឬទេ ?<br>- តើស្ត្រី និងបុរសមានសិទ្ធិទទួលបានមរតកស្មើគ្នាដែរឬទេ ? |

## ឧបសម្ព័ន្ធទី ॥ :

### អនុសញ្ញាស្តីពីការលុបបំបាត់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW)

**ត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ន និងចូលជាសមាជិក**

តាមសេចក្តីសម្រេចលេខ ៣៤/១៨០ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ចូលជាធរមាននៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៨១ ស្របតាមបទបញ្ញត្តិមាត្រា ២៧(១)

រដ្ឋភាគីនៃអនុសញ្ញានេះ

ដោយកត់សម្គាល់ឃើញថា ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិបានអះអាងឡើងវិញនូវជំនឿលើសិទ្ធិមនុស្សជាមូលដ្ឋានទៅលើសេចក្តីថ្លៃថ្នូ និងតម្លៃរបស់មនុស្សជាតិ និងលើសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី

ដោយកត់សម្គាល់ឃើញថា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សបញ្ជាក់នូវគោលការណ៍នៃភាពមិនអាចទទួលយកបានចំពោះការរើសអើងនិងបានប្រកាសថាមនុស្សគ្រប់រូបកើតមានសេរីភាពនិងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិហើយថាមនុស្សគ្រប់រូបត្រូវទទួលបានសិទ្ធិ និងសេរីភាពទាំងអស់ ដែលមានចែងនៅក្នុងសេចក្តីប្រកាសនោះ ដោយគ្មានការប្រកាន់បែងចែកណាមួយ រួមមានការប្រកាន់បែងចែកផ្លូវភេទផង

ដោយកត់សម្គាល់ឃើញថា រដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សមានកាតព្វកិច្ចក្នុងការធានាសិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រីក្នុងការអាស្រ័យផលសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ពលរដ្ឋ និងនយោបាយ

ដោយយល់ឃើញថាអនុសញ្ញាអន្តរជាតិដែលបានអនុម័តក្រោមកិច្ចឧបត្ថម្ភរបស់អង្គការសហប្រជាជាតិនិងស្ថាប័នឯកទេសនានាដែលស្ទួយសមភាពនៃសិទ្ធិរវាងបុរស និងស្ត្រី

ដោយកត់សម្គាល់ឃើញថា សេចក្តីសម្រេចចិត្ត សេចក្តីប្រកាស និងអនុសាសន៍នានាដែលអនុម័តដោយអង្គការសហប្រជាជាតិនិងស្ថាប័នជំនាញក្នុងគោលបំណងលើកស្ទួយសមភាពនៃសិទ្ធិរវាងបុរស និងស្ត្រី

ដោយមានកង្វល់ថា ទោះបីជាមានលិខិតុបករណ៍ទាំងនេះហើយក្តី ក៏ការរើសអើងដ៏រីករាលដាលប្រឆាំងនឹងស្ត្រីភេទនៅតែបន្តកើតមាន

ដោយរំលឹកឡើងវិញថា ការរើសអើងប្រឆាំងនឹងស្ត្រីរំលោភលើគោលការណ៍សមភាពនៃសិទ្ធិ និងការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សជាឧបសគ្គចំពោះការចូលរួមរបស់ស្ត្រី ក្នុងលក្ខខណ្ឌស្មើភាពគ្នាជាមួយបុរស នៅក្នុងជីវភាពនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌នៃប្រទេសរបស់ខ្លួន ធ្វើឱ្យរាំងស្ទះដល់ការរីកចម្រើននៃភាពសំបូណ៌រុងរឿងនៃសង្គម និងគ្រួសារ ហើយបង្កឧបសគ្គដល់ការអភិវឌ្ឍពេញលេញនូវសក្តានុភាពរបស់ស្ត្រី ក្នុងការបម្រើងប្រទេសជាតិរបស់ខ្លួន និងមនុស្សជាតិ

ដោយមានកង្វល់ថា នៅក្នុងស្ថានភាពក្រីក្រ ស្ត្រីមានលទ្ធភាពតិចតួចក្នុងការទទួលបានស្បៀង សុខភាព ការអប់រំ ការ

បណ្តុះបណ្តាល និងឱកាសទទួលបានការងារ និងសេចក្តីត្រូវការផ្សេងៗទៀត

ដោយជឿជាក់ថា ការបង្កើតសេចក្តីបង្គាប់ផ្នែកសេដ្ឋកិច្ចអន្តរជាតិថ្មីផ្អែកលើសមធម៌ និងយុត្តិធម៌ នឹងរួមចំណែកយ៉ាងធំធេងដល់ការលើកកម្ពស់សមភាពរវាងបុរស និងស្ត្រី

ដោយសង្កត់ធ្ងន់ថា ការលុបបំបាត់អាប៉ាថេត គ្រប់ទម្រង់នៃពូជសាសន៍និយម ការរើសអើងពូជសាសន៍ អាណានិគមនិយម អាណានិគមនិយមបែបថ្មី ការឈ្លានពាន ការកាន់កាប់ និងការជិះជាន់ដោយបរទេស និងការជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋ គឺជាការចំបាច់សម្រាប់ការអាស្រ័យផលពេញលេញពីសិទ្ធិរបស់បុរស និងស្ត្រី

ដោយអះអាងថាការពង្រឹងសន្តិភាពនិងសន្តិសុខអន្តរជាតិ ការបន្ធូរបន្ថយភាពតានតឹងអន្តរជាតិ កិច្ចសហប្រតិបត្តិការទៅវិញទៅមកក្នុងចំណោមរដ្ឋទាំងអស់ ដោយមិនគិតពីប្រព័ន្ធសង្គម និងសេដ្ឋកិច្ចរបស់ខ្លួន ការកាត់បន្ថយសព្វាវុធជាទូទៅ និងទាំងស្រុក ជាពិសេសការកាត់បន្ថយអាវុធនុក្លេអ៊ែរនៅក្រោមការត្រួតពិនិត្យដ៏ម៉ត់ចត់ និងប្រកបដោយប្រសិទ្ធភាពរបស់អន្តរជាតិ ការបញ្ជាក់អះអាងចំពោះគោលការណ៍ស្តីពីយុត្តិធម៌ សមភាព និងអត្ថប្រយោជន៍ទៅវិញទៅមកនៅក្នុងទំនាក់ទំនងក្នុងចំណោម ប្រទេសនានា និងការសម្រេចបាននូវសិទ្ធិរបស់ប្រជាជនក្រោមការគ្របសង្កត់របស់បរទេស និងរបស់អាណានិគម និងការកាន់ កាប់របស់បរទេស ដើម្បីការកំណត់ជោគវាសនាដោយខ្លួនឯង និងភាពឯករាជ្យ ព្រមទាំងការគោរពចំពោះអធិបតេយ្យ ប្រទេសជាតិ និងបូរណភាពដែនដី នឹងជម្រុញវឌ្ឍនភាព និងការអភិវឌ្ឍសង្គម ហើយជាលទ្ធផលនឹងរួមចំណែកដល់ការសម្រេចបានសមភាពពេញលេញរវាងបុរស និងស្ត្រី

ដោយជឿជាក់ថា ការអភិវឌ្ឍពេញលេញ និងទាំងស្រុងនៃប្រទេសមួយ សុខុមាលភាពនៃពិភពលោក និងបុព្វហេតុនៃសន្តិភាពតម្រូវអោយមានការចូលរួមជាអតិបរមារបស់ស្ត្រីឈរលើលក្ខខណ្ឌស្មើគ្នាជាមួយបុរសនៅក្នុងគ្រប់វិស័យទាំងអស់

ដោយចងចាំថា ការរួមចំណែកដ៏ធំធេងរបស់ស្ត្រីចំពោះសុខុមាលភាពគ្រួសារ និងការអភិវឌ្ឍសង្គម ដែលមកទល់ពេលនេះមិនទាន់ត្រូវបានទទួលស្គាល់ពេញលេញ សារៈសំខាន់ផ្នែកសង្គមនៃមាតុភាព និងតួនាទីរបស់ឪពុកម្តាយនៅក្នុងគ្រួសារ និងក្នុងការចិញ្ចឹមបីបាច់ថែទាំកូន និងការយល់ឃើញថា តួនាទីរបស់ស្ត្រីនៅក្នុងការបង្កើតកូន មិនគួរជាមូលដ្ឋានសម្រាប់ការរើសអើង ប៉ុន្តែថា ការចិញ្ចឹមបីបាច់កូនតម្រូវអោយមានការចែករំលែកទំនួលខុសត្រូវរវាងបុរស និងស្ត្រី និងសង្គមទាំងមូលដោយជឿជាក់ថា ការផ្លាស់ប្តូរនូវតួនាទីជាប្រពៃណីរបស់បុរស ព្រមទាំងតួនាទីរបស់ស្ត្រីនៅក្នុងសង្គម និងនៅក្នុងគ្រួសារ គឺ ជាការចាំបាច់ ដើម្បីសម្រេចបានសមភាពពេញលេញរវាងបុរស និងស្ត្រី

ដោយប្តេជ្ញាចិត្តក្នុងការអនុវត្តគោលការណ៍ទាំងឡាយ ដែលមានចែងនៅក្នុងសេចក្តីប្រកាសស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី និងសម្រាប់គោលបំណងនេះ ក្នុងការអនុម័តវិធានការនានាដែលចាំបាច់ ដើម្បីលុបបំបាត់ការរើសអើងទាំងនេះនៅក្នុងគ្រប់ទម្រង់ និងការស្តែងចេញទាំងឡាយនៃការរើសអើង

បានព្រមព្រៀងដូចខាងក្រោម ៖

**ផ្នែកទី ।**

**មាត្រា ១**

សម្រាប់គោលបំណងនៃអនុសញ្ញាបច្ចុប្បន្ន ពាក្យ "ការរើសអើងលើស្ត្រី" ត្រូវមានន័យថា ភាពខុសគ្នា ការផាត់ចេញ ឬការរឹតត្បិតណាមួយដែលធ្វើឡើងផ្អែកលើមូលដ្ឋានភេទដែលមានឥទ្ធិពល ឬគោលបំណងធ្វើអោយប៉ះពាល់ ឬធ្វើមោឃភាពដល់ការទទួលស្គាល់ ការទទួលបាន ឬការប្រើប្រាស់ដោយស្ត្រីនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម វប្បធមិ ស៊ីវិល ឬវិស័យដទៃទៀត ផ្អែកលើមូលដ្ឋាននៃសមភាពរវាងបុរស និងស្ត្រីដោយមិនគិតអំពីស្ថានភាពអាពាហ៍ពិពាហ៍របស់ពួកគេឡើយ ។

**មាត្រា ២**

រដ្ឋភាគីថ្កោលទោសចំពោះការរើសអើងលើស្ត្រីនៅក្នុងគ្រប់ទម្រង់ទាំងអស់យល់ព្រមអនុវត្តគោលនយោបាយលុបបំបាត់ការរើសអើងលើស្ត្រីតាមគ្រប់មធ្យោបាយសមស្របទាំងអស់ដោយមិនបង្អែរបង្អង់ ហើយដើម្បីសម្រេចគោលដៅនេះសន្យាៈ

(ក) បញ្ចូលគោលការណ៍ស្តីពីសមភាពរវាងបុរស និងស្ត្រីនៅក្នុងរដ្ឋធម្មនុញ្ញជាតិ ឬច្បាប់សមស្របដទៃទៀតប្រសិនបើមិនទាន់ត្រូវបានដាក់បញ្ចូល ព្រមទាំងធានានូវការសម្រេចបានជាក់ស្តែងចំពោះគោលការណ៍នេះតាមរយៈច្បាប់និងមធ្យោបាយសមស្របដទៃទៀត ។

(ខ) អនុម័តវិធានការច្បាប់ និងវិធានការដទៃទៀតដែលសមស្រប រួមទាំងការដាក់ទណ្ឌកម្ម ប្រសិនបើសមស្របដោយហាមឃាត់រាល់ទម្រង់ទាំងអស់នៃការរើសអើងលើស្ត្រី ។

(គ) បង្កើតការការពារផ្នែកច្បាប់ចំពោះសិទ្ធិស្ត្រីផ្អែកលើមូលដ្ឋានស្មើភាពជាមួយបុរស និងធានានូវការការពារស្ត្រីប្រកបដោយប្រសិទ្ធភាពប្រឆាំងនឹងអំពើរើសអើងណាមួយ តាមរយៈសាលាក្តីថ្នាក់ជាតិមានសមត្ថកិច្ច និងស្ថាប័នសាធារណៈដទៃទៀត ។

(ឃ) ចៀសវាងការចូលរួមនៅក្នុងអំពើ ឬការអនុវត្តណាមួយដែលរើសអើងលើស្ត្រី ព្រមទាំងធានាថា អាជ្ញាធរ និងស្ថាប័នសាធារណៈត្រូវធ្វើសកម្មភាពស្របតាមកាតព្វកិច្ចនេះ ។

(ង) ចាត់រាល់វិធានការសមស្របទាំងឡាយដើម្បីលុបបំបាត់ការរើសអើងលើស្ត្រីដោយបុគ្គលណាម្នាក់ អង្គការ ឬសហគ្រាសណាមួយ ។

(ច) ចាត់រាល់វិធានការសមស្របទាំងឡាយ រួមទាំងនីតិកម្ម ដើម្បីកែប្រែ ឬលុបចោលច្បាប់ បទប្បញ្ញត្តិ ទំនៀមទម្លាប់ និងទម្លាប់អនុវត្តន៍ដែលមានស្រាប់ដែលបង្កើតបានជាការរើសអើងលើស្ត្រី ។

(ឆ) លុបចោលរាល់បញ្ញត្តិព្រហ្មទណ្ឌជាតិទាំងអស់ដែលបង្កើតបានជាការរើសអើងលើស្ត្រី ។

**មាត្រា ៣**

រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្របទាំងអស់ក្នុងគ្រប់វិស័យ ជាពិសេស វិស័យនយោបាយ សង្គម សេដ្ឋកិច្ច និងវប្បធមិ

រួមទាំងនីតិកម្ម ដើម្បីធានានូវការអភិវឌ្ឍ និងការរីកចម្រើនពេញលេញរបស់ស្ត្រី ក្នុងគោលបំណងធានាអោយពួកគេអាចប្រើប្រាស់ និងអនុវត្តសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ផ្អែកលើសមភាពជាមួយបុរស ។

**មាត្រា ៤**

១. ការអនុម័តដោយរដ្ឋភាគី នូវិធានការពិសេសបណ្តោះអាសន្ន ដែលមានគោលបំណងពន្លឿនសមភាពជាក់ស្តែងរវាងបុរស និងស្ត្រី មិនត្រូវបានពិចារណាថា ជាការរើសអើងដូចមានកំណត់នៅក្នុងអនុសញ្ញាបច្ចុប្បន្ន ប៉ុន្តែ ទោះតាមវិធីណាក៏ដោយមិនត្រូវបង្កអោយមានការរក្សាទុកនូវបទដ្ឋានមិនស្មើភាព ឬបទដ្ឋានដាច់ដោយឡែកពីគ្នាឡើយ ។ វិធានការទាំងនេះនឹងត្រូវបញ្ឈប់នៅពេលវត្ថុបំណងនៃសមភាពនៃឱកាស និងការប្រព្រឹត្តត្រូវបានសម្រេច ។

២. ការអនុម័តដោយ រដ្ឋភាគីលើវិធានការពិសេស រួមទាំងវិធានការទាំងឡាយណាដែលមាននៅក្នុងអនុសញ្ញាបច្ចុប្បន្នដែលមានគោលបំណងការពារមាតុភាព មិនត្រូវបានចាត់ទុកថា ជាការរើសអើងឡើយ ។

**មាត្រា ៥**

រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្របទាំងឡាយ :

(ក) កែប្រែបែបផែនសង្គម និងវប្បធម៌នៃការប្រព្រឹត្តចំពោះបុរស និងស្ត្រីដោយមានគោលបំណងសម្រេចអោយបាននូវការលុបបំបាត់បុរេវិនិច្ឆ័យ និងទម្លាប់អនុវត្តន៏ជាប្រពៃណី និងទម្លាប់អនុវត្តន៏ផ្សេងៗទៀតទាំងអស់ ដែលផ្អែកលើគំនិតអំពីភាពទន់ខ្សោយ ឬឧត្តមភាពនៃភេទណាមួយ ឬផ្អែកលើតួនាទីជាតួយ៉ាងសម្រាប់បុរស និងស្ត្រី ។

(ខ) ធានាថា ការអប់រំប្រចាំគ្រួសាររួមមាន ការយល់ដឹងត្រឹមត្រូវអំពីមាតុភាពថាជាមុខងារសង្គមមួយ និងការទទួលស្គាល់ទំនួលខុសត្រូវរួមរបស់បុរស និងស្ត្រីក្នុងការចិញ្ចឹមបីបាច់ និងអភិវឌ្ឍកូនរបស់ខ្លួនដោយយល់ថាផលប្រយោជន៏របស់កូន គឺជាការពិចារណាចម្បងនៅក្នុងគ្រប់ករណីទាំងអស់ ។

**មាត្រា ៦**

រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្របទាំងឡាយ រួមទាំងនីតិកម្ម ដើម្បីបង្ក្រាបរាល់ទម្រង់ទាំងអស់នៃការជួញដូរស្ត្រី និងការធ្វើអាជីវកម្មពេស្យាចារលើស្ត្រី ។

**ផ្នែកទី II**

**មាត្រា ៧**

រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្របទាំងឡាយ ដើម្បីលុបបំបាត់ការរើសអើងលើស្ត្រីនៅក្នុងជីវភាពនយោបាយ និងជីវភាពសាធារណៈនៅក្នុងប្រទេស ជាពិសេសត្រូវធានាចំពោះស្ត្រី ផ្អែកលើលក្ខខណ្ឌស្មើគ្នាជាមួយបុរសនូវសិទ្ធិ :

(ក) បោះឆ្នោតនៅក្នុងការបោះឆ្នោតទាំងអស់ និងការធ្វើប្រជាមតិសាធារណៈ ព្រមទាំងមានសិទ្ធិឈរឈ្មោះបោះឆ្នោតសម្រាប់ អង្គភាពដែលត្រូវបានបោះឆ្នោតជ្រើសរើសជាសាធារណៈទាំងអស់ ។

(ខ) ចូលរួមនៅក្នុងការបង្កើតគោលនយោបាយរដ្ឋាភិបាល និងកាន់កាប់មុខតំណែងសាធារណៈ ព្រមទាំងអនុវត្តរាល់មុខងារសាធារណៈទាំងអស់នៅគ្រប់លំដាប់ថ្នាក់ក្នុងរដ្ឋាភិបាល ។

(គ) ចូលរួមនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានាពាក់ព័ន្ធនឹងជីវភាពសាធារណៈ និងជីវភាពនយោបាយនៅក្នុងប្រទេស ។

**មាត្រា ៨**

រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្របទាំងឡាយដើម្បីធានាចំពោះស្ត្រីឈរលើលក្ខខណ្ឌស្មើគ្នាជាមួយបុរស និងដោយគ្មានការរើសអើងនូវឱកាសដើម្បីតំណាងអោយរដ្ឋាភិបាលរបស់ខ្លួននៅថ្នាក់អន្តរជាតិ និងចូលរួមនៅក្នុងការងាររបស់អង្គការអន្តរជាតិ ។

**មាត្រា ៩**

១. រដ្ឋភាគីត្រូវផ្តល់អោយស្ត្រីនូវសិទ្ធិស្មើគ្នាជាមួយនឹងបុរស ដើម្បីទទួលបានផ្លាស់ប្តូរ ឬរក្សាសញ្ជាតិរបស់ខ្លួន ។ រដ្ឋភាគីត្រូវធានាជាពិសេសថា ការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬការផ្លាស់ប្តូរសញ្ជាតិរបស់ស្វាមីក្នុងអំឡុងអាពាហ៍ពិពាហ៍នឹងមិនផ្លាស់ប្តូរដោយស្វ័យប្រវត្តិនូវសញ្ជាតិរបស់ភរិយា ធ្វើអោយភរិយាបាត់បង់សញ្ជាតិ ឬបង្ខំអោយភរិយាទទួលយកសញ្ជាតិ របស់ស្វាមីឡើយ ។

២. រដ្ឋភាគីត្រូវផ្តល់អោយស្ត្រីនូវសិទ្ធិស្មើគ្នាជាមួយបុរសទាក់ទងនឹងសញ្ជាតិរបស់កូន ។

**ផ្នែកទី III**

**មាត្រា ១០**

រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្របទាំងឡាយដើម្បីលុបបំបាត់ការរើសអើងលើស្ត្រីក្នុងគោលបំណងធានាអោយពួកគេនូវសិទ្ធិស្មើគ្នាជាមួយនឹងបុរសនៅក្នុងវិស័យអប់រំ និងជាពិសេស ធានានូវការឈរលើមូលដ្ឋានស្មើភាពរវាងបុរស និងស្ត្រី :

(ក) លក្ខខណ្ឌដូចគ្នាសម្រាប់មុខរបរ និងការណែនាំវិជ្ជាជីវៈ សម្រាប់ការទទួលបានការសិក្សា និងសញ្ញាបត្រនៅក្នុងគ្រឹស្ថានអប់រំគ្រប់ប្រភេទនៅក្នុងតំបន់ជនបទ ក៏ដូចជាតំបន់ក្រុង ។ សមភាពនេះនឹងត្រូវបានធានានៅក្នុងការអប់រំមត្តេយ្យសាលាចំណេះទូទៅ បច្ចេកទេសវិជ្ជាជីវៈ និងបច្ចេកទេសជាន់ខ្ពស់ ក៏ដូចជាការបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់ប្រភេទ ។

(ខ) លទ្ធភាពទទួលបានកម្មវិធីសិក្សាដូចគ្នា ការប្រឡងដូចគ្នា បុគ្គលិកបង្រៀនដែលមានគុណវុឌ្ឍិដូចគ្នា និងទីធ្លាសាលានិងឧបករណ៍សិក្សាដែលមានគុណភាពដូចគ្នា ។

(គ) ការលុបបំបាត់ទស្សនាទានជាតួយ៉ាងចំពោះតួនាទីរបស់បុរស និងស្ត្រីនៅគ្រប់លំដាប់ថ្នាក់ និងគ្រប់ទម្រង់ទាំងអស់នៃការអប់រំតាមរយៈការលើកទឹកចិត្តអោយមានការអប់រំរួមគ្នានិងប្រភេទដទៃទៀតនៃការអប់រំដែលនឹងជួយដល់ការសម្រេចបាននូវគោលបំណងនេះជាពិសេសតាមរយៈការកែសម្រួលសៀវភៅអាននិងកម្មវិធីសាលាព្រមទាំងការកែសម្រួលវិធីសាស្ត្រ

បង្រៀន ។

(ឃ) ឱកាសដូចគ្នាដើម្បីទាញយកអត្ថប្រយោជន៍អាហារូបករណ៍ និងប្រាក់ឧបត្ថម្ភដទៃទៀតសម្រាប់ការសិក្សា ។

(ង) ឱកាសដូចគ្នាសម្រាប់លទ្ធភាពទទួលបានកម្មវិធីបន្តការអប់រំរួមទាំងកម្មវិធីអក្ខរកម្មសម្រាប់មនុស្សចាស់ និងអក្ខរកម្មសម្រាប់មុខងារ ជាពិសេសកម្មវិធីដែលមានគោលបំណងកាត់បន្ថយគម្លាតក្នុងការអប់រំដែលមានស្រាប់រវាងបុរស និងស្ត្រីអោយបានឆាប់រហ័សបំផុត ។

(ច) ការកាត់បន្ថយអត្រាបោះបង់ការសិក្សាសម្រាប់សិស្ស/និស្សិតស្រី និងការរៀបចំកម្មវិធីសម្រាប់ក្មេងស្រី និងស្ត្រី ដែលបោះបង់ការសិក្សាមុនអាយុ ។

(ឆ) ឱកាសដូចគ្នាក្នុងការចូលរួមយ៉ាងសកម្មនៅក្នុងកីឡា និងកាយសិក្សា ។

(ជ) លទ្ធភាពទទួលបានព័ត៌មានអប់រំជាក់លាក់ ដើម្បីជួយធានានូវសុខភាព និងសុខុមាលភាពរបស់គ្រួសារ រួមទាំងព័ត៌មាន និងដំបូន្មានអំពីការធ្វើផែនការគ្រួសារ ។

**មាត្រា ១១**

១. រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្របទាំងឡាយ ដើម្បីលុបបំបាត់ការរើសអើងលើស្ត្រីនៅក្នុងវិស័យការងារ ដើម្បីធានានូវសិទ្ធិដូចគ្នា ឈរលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រីជាពិសេស :

(ក) សិទ្ធិធ្វើការ ដែលជាសិទ្ធិមិនអាចដកហូតបានរបស់មនុស្សគ្រប់រូប ។

(ខ) សិទ្ធិទទួលបានឱកាសការងារដូចគ្នា រួមទាំងការប្រើប្រាស់លក្ខណៈវិនិច្ឆ័យដូចគ្នាសម្រាប់ការជ្រើសរើសអោយចូលបម្រើការងារ ។

(គ) សិទ្ធិជ្រើសរើសវិជ្ជាជីវៈនិងការងារដោយសេរីសិទ្ធិទទួលបានការតម្លើងឋានៈស្ថិរភាពការងារ ព្រមទាំងអត្ថប្រយោជន៍ទាំងអស់ និងលក្ខខណ្ឌការងារ និងសិទ្ធិទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបណ្តុះបណ្តាលឡើងវិញ រួមទាំងការបណ្តុះ បណ្តាលជាកូនជាង ការបណ្តុះបណ្តាលវិជ្ជាជីវៈជាន់ខ្ពស់ និងការបណ្តុះបណ្តាលជាបន្តបន្ទាប់ ។

(ឃ) សិទ្ធិទទួលបានប្រាក់ឈ្នួលស្មើគ្នា ព្រមទាំងអត្ថប្រយោជន៍ និងសិទ្ធិទទួលបានការប្រព្រឹត្តស្មើគ្នានៅក្នុងការងារដែលមាន តម្លៃស្មើគ្នា ព្រមទាំងសមភាពនៃការប្រព្រឹត្តនៅក្នុងការវាយតម្លៃលើគុណភាពការងារ ។

(ង) សិទ្ធិទទួលបាននិរភ័យសង្គម ជាពិសេស ក្នុងករណីចូលនិវត្តន៍ ភាពគ្មានការងារធ្វើ ជំងឺ ទុព្វលភាព វ័យចំណាស់ និងអសមត្ថភាពដទៃទៀតក្នុងការបំពេញការងារ ព្រមទាំងសិទ្ធិទទួលបានការឈប់សម្រាកដោយមានប្រាក់ឈ្នួល ។

(ច) សិទ្ធិទទួលបានការការពារសុខភាព និងសុវត្ថិភាពនៅក្នុងលក្ខខណ្ឌការងាររួមទាំង ការការពារសុវត្ថិភាពមុខងារបន្តពូជ ។

២. ដើម្បីទប់ស្កាត់ការរើងអើងលើស្ត្រីផ្អែកលើមូលហេតុអាពាហ៍ពិពាហ៍ ឬមាតុភាព និងដើម្បីធានានូវសិទ្ធិប្រកបដោយប្រសិទ្ធិភាពរបស់ពួកគេក្នុងការបំពេញការងារ រដ្ឋភាគីត្រូវចាត់វិធានការសមស្របនានា :

(ក) តាមរយៈការដាក់ទណ្ឌកម្ម ហាមឃាត់នូវការបណ្តេញចេញដោយសារមូលហេតុនៃការមានគភ៌ ឬការឈប់សម្រាកលំហែមាតុភាព និងការរើសអើងក្នុងការបណ្តេញចេញផ្អែកលើស្ថានភាពអាពាហ៍ពិពាហ៍។

(ខ) ណែនាំអោយប្រើប្រាស់ការឈប់សម្រាកលំហែមាតុភាពដោយមានប្រាក់ឈ្នួល ឬដោយមានអត្ថប្រយោជន៍ផ្នែកសង្គមប្រហាក់ប្រហែលគ្នា ដោយមិនបាត់បង់ការងារពីមុន អតីតភាពការងារ ឬប្រាក់ឧបត្ថម្ភផ្នែកសង្គម។

(គ) លើកទឹកចិត្តអោយមានការផ្តល់សេវាគាំទ្រផ្នែកសង្គមដែលចាំបាច់ ដើម្បីអនុញ្ញាតអោយឪពុកម្តាយអាចរួមបញ្ចូលកាតព្វកិច្ច គ្រួសារជាមួយទំនួលខុសត្រូវក្នុងការងារ និងការចូលរួមក្នុងជីវភាពសាធារណៈ ជាពិសេសតាមរយៈការជំរុញអោយមានការបង្កើត និងរៀបចំបណ្តាញនៃមណ្ឌលថែទាំកុមារ។

(ឃ) ផ្តល់នូវការការពារពិសេសចំពោះស្ត្រីក្នុងអំឡុងពេលមានគភ៌នៅក្នុងប្រភេទការងារដែលត្រូវបានបញ្ជាក់ថា មានគ្រោះថ្នាក់ចំពោះពួកគេ។

៣. ច្បាប់ការពារទាក់ទងនឹងបញ្ហានានា ដែលគ្របដណ្តប់នៅក្នុងមាត្រានេះ នឹងត្រូវបានពិនិត្យមើលឡើងវិញជាទៀងទាត់អំពីចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ហើយនឹងត្រូវកែសម្រួលលុបចោល ឬពង្រីកបន្ថែមតាមការចាំបាច់។

**មាត្រា ១២**

១. រដ្ឋភាគីត្រូវចាត់វាល់វិធានការចាំបាច់ទាំងឡាយ ដើម្បីលុបបំបាត់ការរើសអើងលើស្ត្រីនៅក្នុងវិស័យថែទាំសុខភាព ដើម្បីធានានូវលទ្ធភាពទទួលបានសេវាថែទាំសុខភាព រួមទាំងសេវាទាក់ទងនឹងការធ្វើផែនការគ្រួសារឈរលើមូលដ្ឋាននៃសមភាពរវាងបុរស និងស្ត្រី។

២. ទោះបីជាមានបញ្ញត្តិនៃកថាខ័ណ្ឌទី ១ នៃមាត្រានេះក៏ដោយ រដ្ឋភាគីត្រូវធានាចំពោះស្ត្រីក្នុងការទទួលបានសេវាសមស្រប ទាក់ទងនឹងការមានគភ៌ ការចៀសវាងការងារមួយចំនួន និងរយៈពេលក្រោយសម្រាល ការផ្តល់សេវាដោយឥតគិតថ្លៃ ប្រសិនបើចាំបាច់ ព្រមទាំងអាហារូបត្ថម្ភគ្រប់គ្រាន់ក្នុងពេលមានគភ៌ និងការបំបៅដោះកូន។

**មាត្រា ១៣**

រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្របទាំងឡាយដើម្បីលុបបំបាត់ការរើសអើងលើស្ត្រីនៅក្នុងវិស័យផ្សេងទៀតនៃជីវភាពសេដ្ឋកិច្ច និងជីវភាពសង្គម ដើម្បីធានានូវសិទ្ធិស្មើគ្នា ដោយឈរលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រីជាពិសេស ៖

(ក) សិទ្ធិទទួលបានអត្ថប្រយោជន៍គ្រួសារ

(ខ) សិទ្ធិទទួលបានកម្ចីពីធនាគារ ការបញ្ចាំ និងទម្រង់ដទៃទៀតនៃឥណទានហិរញ្ញវត្ថុ

(គ) សិទ្ធិចូលរួមនៅក្នុងសកម្មភាពលំហែកម្សាន្ត កីឡា និងទិដ្ឋភាពទាំងអស់នៃជីវភាពវប្បធម៌។

**មាត្រា ១៤**

១. រដ្ឋភាគីត្រូវពិចារណាលើបញ្ហាជាក់លាក់ទាំងឡាយដែលស្ត្រីជនបទប្រឈមមុខ និងតួនាទីដ៏សំខាន់ដែលស្ត្រីជនបទអនុវត្តនៅក្នុងការទ្រទ្រង់សេដ្ឋកិច្ចចំពោះគ្រួសាររបស់ខ្លួន រួមទាំងការងាររបស់ពួកគេនៅក្នុងវិស័យគ្មានចំណូលនៃសេដ្ឋកិច្ច

ហើយត្រូវចាត់រាល់វិធានការសមស្របទាំងឡាយ ដើម្បីធានាអោយមានការអនុវត្តបញ្ញត្តិទាំងនេះនៃអនុសញ្ញាបច្ចុប្បន្ន ចំពោះស្ត្រី នៅក្នុងតំបន់ជនបទ ។

២. រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្របទាំងឡាយ ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីនៅក្នុងតំបន់ជនបទ ដើម្បីធានាថា ដោយឈរលើមូលដ្ឋាននៃសមភាពរវាងបុរស និងស្ត្រី ពួកគេអាចចូលរួមនៅក្នុង និងទាញយកអត្ថប្រយោជន៍ពីការអភិវឌ្ឍជនបទ និងជាពិសេសត្រូវធានាចំពោះស្ត្រីទាំងនេះនូវសិទ្ធិ :

(ក) ចូលរួមនៅក្នុងការតាក់តែង និងការអនុវត្តការធ្វើផែនការអភិវឌ្ឍន៍នៅគ្រប់លំដាប់ថ្នាក់ ។

(ខ) មានលទ្ធភាពទទួលបានសេវាថែទាំសុខភាពគ្រប់គ្រាន់រួមទាំង ព័ត៌មានការផ្ដល់ប្រឹក្សា និងសេវានានានៅក្នុងការធ្វើផែនការគ្រួសារ ។

(គ) ទទួលបានអត្ថប្រយោជន៍ដោយផ្ទាល់ពីកម្មវិធីនិរភ័យសង្គម ។

(ឃ) ទទួលបានការបណ្ដុះបណ្ដាល និងការអប់រំគ្រប់ប្រភេទទាំងក្នុងប្រព័ន្ធ ទាំងក្រៅប្រព័ន្ធ រួមទាំងការអប់រំ និងការបណ្ដុះបណ្ដាល ដែលទាក់ទងនឹងអក្ខរកម្មមុខងារ ក៏ដូចជាអត្ថប្រយោជន៍នៃសេវាសហគមន៍ និងសេវាផ្សព្វផ្សាយទាំងឡាយ ដើម្បីបង្កើនភាពស្ទាត់ជំនាញផ្នែកបច្ចេកទេសរបស់ខ្លួន ។

(ង) រៀបចំក្រុមជួយខ្លួនឯង និងសហករណ៍ដើម្បីទទួលបានលទ្ធភាពស្មើគ្នាចំពោះឱកាសសេដ្ឋកិច្ច តាមរយៈការងារ ឬការប្រកបអាជីវកម្មផ្ទាល់ខ្លួន ។

(ច) ចូលរួមនៅក្នុងសកម្មភាពសហគមន៍ទាំងអស់ ។

(ឆ) មានលទ្ធភាពទទួលបានឥណទាន និងកម្ចីកសិកម្ម សេវាផ្សព្វផ្សាយទីផ្សារ បច្ចេកវិទ្យាសមស្រប និងការប្រព្រឹត្តស្មើភាពនៅក្នុងកំណែទម្រង់ដីធ្លី និងកសិកម្ម ក៏ដូចជានៅក្នុងគម្រោងតាំងទីលំនៅឡើងវិញ ។

(ជ) ទទួលបានលក្ខខណ្ឌរស់នៅសមស្រប ជាពិសេសទាក់ទងនឹងលំនៅដ្ឋាន អនាម័យ អគ្គិសនី ការផ្គត់ផ្គង់ទឹក ការដឹកជញ្ជូន និងគមនាគមន៍ ។

**ផ្នែកទី IV**

**មាត្រា ១៥**

១. រដ្ឋភាគីត្រូវផ្ដល់អោយស្ត្រីនូវសមភាពជាមួយបុរសចំពោះមុខច្បាប់ ។

២. រដ្ឋភាគីត្រូវផ្ដល់អោយស្ត្រី ក្នុងគ្រប់បញ្ហាទាំងអស់នូវសមត្ថភាពផ្នែកច្បាប់ដែលដូចទៅនឹងបុរស និងឱកាសស្មើគ្នាក្នុងការអនុវត្តសមត្ថភាពនោះ ។ ជាពិសេសពួកគេត្រូវផ្ដល់អោយស្ត្រីនូវសិទ្ធិស្មើគ្នាក្នុងការចុះកិច្ចសន្យានិងគ្រប់គ្រងទ្រព្យសម្បត្តិ ហើយត្រូវប្រព្រឹត្តចំពោះពួកគេដោយស្មើភាពនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធីក្នុងតុលាការ និងសាលាក្ដី ។

៣. រដ្ឋភាគីព្រមព្រៀងថារាល់កិច្ចសន្យាទាំងឡាយនិងលិខិតូបករណ៍ឯកជនដទៃទៀតទាំងអស់ទោះជាប្រភេទណាក៏ដោយ

ដែលមានប្រសិទ្ធភាពផ្នែកច្បាប់ ដែលផ្តោតលើការរឹតត្បិតសមត្ថភាពផ្នែកច្បាប់របស់ស្ត្រី នឹងត្រូវចាត់ទុកជាមោឃៈ ។

៤. រដ្ឋភាគីត្រូវផ្តល់អោយបុរស និងស្ត្រីនូវសិទ្ធិដូចគ្នា ទាក់ទងនឹងច្បាប់ស្តីពីការដើរហើររបស់មនុស្ស និងសេរីភាពក្នុងការជ្រើសរើសលំនៅដ្ឋាន និងកន្លែងស្នាក់នៅរបស់ពួកគេ ។

**មាត្រា ១៦**

១. រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្របទាំងឡាយដើម្បីលុបបំបាត់ការរើសអើងលើស្ត្រីនៅក្នុងគ្រប់បញ្ហាទាំងអស់ទាក់ទងនឹងទំនាក់ទំនងអាពាហ៍ពិពាហ៍ និងគ្រួសារ ហើយជាពិសេស ត្រូវធានាផ្អែកលើមូលដ្ឋាននៃសមភាពរវាងបុរស និងស្ត្រី :

(ក) សិទ្ធិដូចគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ ។

(ខ) សិទ្ធិដូចគ្នាក្នុងការជ្រើសរើសគូស្រករដោយសេរី និងរៀបអាពាហ៍ពិពាហ៍ដោយសេរី និងគ្មានការបង្ខិតបង្ខំ ។

(គ) សិទ្ធិ និងទំនួលខុសត្រូវដូចគ្នាក្នុងអំឡុងអាពាហ៍ពិពាហ៍ និងនៅពេលរំលាយអាពាហ៍ពិពាហ៍ ។

(ឃ) សិទ្ធិ និងទំនួលខុសត្រូវដូចគ្នាក្នុងនាមជាឪពុកម្តាយ ដោយមិនគិតពីស្ថានភាពអាពាហ៍ពិពាហ៍របស់ខ្លួនក្នុងបញ្ហានានាទាក់ទងនឹងកូនរបស់ខ្លួន ។ ក្នុងករណីទាំងអស់ផលប្រយោជន៍របស់កូន គឺជាកត្តាសំខាន់បំផុត ។

(ង) សិទ្ធិដូចគ្នាក្នុងការសម្រេចចិត្តដោយសេរី និងដោយទទួលខុសត្រូវចំពោះចំនួនកូន និងការពន្យារកំណើតព្រមទាំងសិទ្ធិទទួលបានព័ត៌មាន ការអប់រំ និងមធ្យោបាយ ដើម្បីធ្វើអោយកូនអាចអនុវត្តសិទ្ធិទាំងនេះ ។

(ច) សិទ្ធិ និងទំនួលខុសត្រូវដូចគ្នាទាក់ទងនឹងភាពជាអាណាព្យាបាល ភាពស្ថិតក្រោមអាណាព្យាបាល អាណត្តិព្យាបាល-ភាព និងការសុំកូនចិញ្ចឹម និងទម្លាប់អនុវត្តន៍ស្រដៀងគ្នា ដែលតាមរយៈនេះ ទស្សនាទានទាំងនេះមាននៅក្នុងច្បាប់ជាតិ ។ ក្នុងករណីទាំងអស់ផលប្រយោជន៍របស់កូន គឺជាកត្តាសំខាន់បំផុត ។

(ឆ) សិទ្ធិផ្ទាល់ខ្លួនដូចគ្នាក្នុងនាមជាស្វាមី និងភរិយាក្នុងនាមសិទ្ធិជ្រើសរើសនាមត្រកូល វិជ្ជាជីវៈ និងមុខរបរ ។

(ជ) សិទ្ធិដូចគ្នាសម្រាប់សហព័ទ្ធទាំងពីរទាក់ទងនឹងភាពជាកម្មសិទ្ធិ ការទិញ ការចាត់ចែង ការគ្រប់គ្រង ការអាស្រ័យផល និងការលក់ទ្រព្យសម្បត្តិ ទោះជាឥតគិតថ្លៃក្តី ឬជាការតបស្នងដែលមានតម្លៃក្តី ។

២. ការភ្ជាប់ពាក្យនិងអាពាហ៍ពិពាហ៍កុមារនឹងពុំមានប្រសិទ្ធភាពផ្លូវច្បាប់ឡើយហើយវិធានការចាំបាច់ទាំងអស់រួមទាំងច្បាប់អាចត្រូវបានធ្វើឡើងដើម្បីបញ្ជាក់អំពីអាយុអប្បបរមាសម្រាប់អាពាហ៍ពិពាហ៍ និងដើម្បីធ្វើការចុះបញ្ជីអាពាហ៍ពិពាហ៍ ជាកំហិតនៅការិយាល័យអត្រានុកូលដ្ឋានផ្លូវការ ។

**ផ្នែកទី V**

**មាត្រា ១៧**

១. សម្រាប់គោលបំណងនៃការពិចារណាលើវឌ្ឍនភាពដែលធ្វើឡើងក្នុងការអនុវត្តសិទ្ធិសញ្ញាបច្ចុប្បន្ន ត្រូវបង្កើតអោយមានគណៈកម្មាធិការទទួលបន្ទុកលុបបំបាត់ការរើសអើងលើស្ត្រី (តទៅនេះហៅកាត់ថា គណៈកម្មាធិការ) ដែលរួមមាន

រដ្ឋភាគីចំនួន ១៨ នៅពេលអនុសញ្ញាចូលជាធរមាន និងរដ្ឋភាគីចំនួន ៣៥ ក្រោយពេលផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញាអ្នកជំនាញចំនួន ២៣ រូប ដែលមានកម្រិតសីលធម៌ និងសមត្ថភាពខ្ពស់នៅក្នុងវិស័យដែលគ្របដណ្តប់ដោយអនុសញ្ញា។ អ្នកជំនាញទាំងនេះនឹងត្រូវជ្រើសរើសដោយរដ្ឋភាគីពីក្នុងចំណោមពលរដ្ឋរបស់ខ្លួន ហើយត្រូវបម្រើការងារក្នុងឋានៈផ្ទាល់ខ្លួនរបស់ពួកគេ ដោយពិចារណាទៅលើរបាយផ្ទែកភូមិសាស្ត្រដែលមានសមធម៌ និងទៅលើភាពជាតំណាងនៃទម្រង់ផ្សេងៗគ្នានៃអរិយធម៌ ព្រមទាំងប្រព័ន្ធច្បាប់សំខាន់ៗ។

២. សមាជិកនៃគណៈកម្មាធិការនេះនឹងត្រូវជ្រើសរើសដោយការបោះឆ្នោតជាសម្ងាត់ពីបញ្ជីឈ្មោះបុគ្គលដែលត្រូវបានតែងតាំងដោយរដ្ឋភាគី។ រដ្ឋភាគីនីមួយៗអាចតែងតាំងបុគ្គលម្នាក់ពីក្នុងចំណោមពលរដ្ឋផ្ទាល់របស់ខ្លួន។

៣. ការបោះឆ្នោតបឋម នឹងត្រូវធ្វើឡើងរយៈពេល ៦ខែ ក្រោយកាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញាបច្ចុប្បន្ន។ យ៉ាងហោចណាស់រយៈពេល ៣ ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវផ្ញើលិខិតមួយច្បាប់ទៅកាន់រដ្ឋភាគីទាំងឡាយដោយអញ្ជើញពួកគេអោយដាក់ជូននូវបេក្ខភាពរបស់ខ្លួនក្នុងរយៈពេល ២ខែ។ អគ្គលេខាធិការត្រូវរៀបចំបញ្ជីមួយតាមលំដាប់អក្ខរក្រមនៃបុគ្គលទាំងអស់ដែលត្រូវបានតែងតាំងដោយបញ្ជាក់អំពីរដ្ឋភាគី ដែលបានតែងតាំងពួកគេ ហើយត្រូវដាក់បញ្ជីនេះជូន រដ្ឋភាគីទាំងឡាយ។

៤. ករបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការ នឹងត្រូវធ្វើឡើងនៅក្នុងកិច្ចប្រជុំរដ្ឋភាគី ដែលរៀបចំឡើងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិនៅឯទីស្នាក់ការកណ្តាលអង្គការសហប្រជាជាតិ។ នៅក្នុងកិច្ចប្រជុំនោះ ដែលពីរភាគបីនៃរដ្ឋភាគីត្រូវបង្កើតបានជាកូរ៉ុមនៃកិច្ចប្រជុំបុគ្គលដែលត្រូវបានបោះឆ្នោតជ្រើសរើសអោយចូលក្នុងគណៈកម្មាធិការគឺបេក្ខជនទាំងឡាយណាដែលទទួលបានសម្លេងឆ្នោតច្រើនជាងគេ ហើយសម្លេងឆ្នោតភាគច្រើនដាច់ខាតនៃតំណាងរបស់រដ្ឋភាគីដែលមានវត្តមាន និងចូលរួមបោះឆ្នោត។

៥. សមាជិកនៃគណៈកម្មាធិការនឹងត្រូវបោះឆ្នោតជ្រើសរើសសម្រាប់អាណត្តិរយៈពេល៤ឆ្នាំ។ប៉ុន្តែអាណត្តិរបស់សមាជិកចំនួន ៩ រូប ដែលត្រូវបានជ្រើសរើសនៅក្នុងការបោះឆ្នោតលើកទីមួយ នឹងផុតកំណត់នៅដំណាច់ឆ្នាំទីពីរ។ ភ្លាមៗក្រោយពីការបោះឆ្នោតលើកទីមួយ ឈ្មោះរបស់សមាជិកទាំង ៩ រូបនេះ នឹងត្រូវជ្រើសរើសដោយប្រធានគណៈកម្មាធិការ។

៦. ការបោះឆ្នោតជ្រើសរើសសមាជិកបន្ថែមចំនួន៥រូប នៃគណៈកម្មាធិការនឹងត្រូវធ្វើឡើង ស្របតាមបញ្ញត្តិនៃកថាខ័ណ្ឌទី ២, ៣ និង ៤ នៃមាត្រានេះ ក្រោយពីការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកនៃប្រទេសចំនួន ៣៥។ អាណត្តិរបស់សមាជិក ២ រូប ក្នុងចំណោមសមាជិកបន្ថែមដែលត្រូវបានជ្រើសរើសនៅក្នុងឱកាសនេះនឹងត្រូវផុតកំណត់ក្នុងរយៈពេល ២ ឆ្នាំ ហើយឈ្មោះរបស់សមាជិកទាំង ២ រូបនេះ នឹងត្រូវជ្រើសរើសដោយប្រធានគណៈកម្មាធិការ។

៧. សម្រាប់ការបំពេញតំណែងទំនេរបណ្តោះអាសន្ន រដ្ឋភាគីដែលអ្នកជំនាញរបស់ខ្លួនបានបញ្ឈប់មុខងារជាសមាជិកគណៈកម្មាធិការត្រូវតែងតាំងអ្នកជំនាញមួយរូបទៀតពីក្នុងចំណោមពលរដ្ឋរបស់ខ្លួន យោងតាមការឯកភាពរបស់គណៈកម្មាធិការ។

៨. សមាជិកគណៈកម្មាធិការត្រូវទទួលប្រៀវត្សរ៍ពីធនធានរបស់អង្គការសហប្រជាជាតិដោយមានការឯកភាពពីមហាសន្និបាតផ្អែកលើខនិងលក្ខខណ្ឌដែលមហាសន្និបាតអាចសម្រេចយោងតាមសារៈសំខាន់នៅទំនួលខុសត្រូវក្នុងគណៈកម្មាធិការ ។

៩. អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវផ្តល់នូវបុគ្គលិកចាំបាច់ និងមូលដ្ឋានសម្រាប់ការអនុវត្តមុខងារប្រកបដោយប្រសិទ្ធភាពរបស់គណៈកម្មាធិការនៅក្រោមអនុសញ្ញាបច្ចុប្បន្ន ។

**មាត្រា ១៨**

១. រដ្ឋភាគីសន្យាដាក់ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិសម្រាប់ការពិចារណាដោយគណៈកម្មាធិការនូវរបាយការណ៍ស្តីពីវិធានការផ្នែកច្បាប់ តុលាការ រដ្ឋបាល ឬវិធានការដទៃទៀត ដែលពួកគេបានអនុម័តដើម្បីផ្តល់ប្រសិទ្ធភាពដល់បញ្ញត្តិទាំងឡាយនៃអនុសញ្ញាបច្ចុប្បន្ន និងអំពីវឌ្ឍនភាពដែលបានធ្វើឡើងនៅក្នុងករណីនេះ :

(ក) ក្នុងរយៈពេលមួយឆ្នាំក្រោយពីការចូលជាធរមានសម្រាប់រដ្ឋសាមី ។

(ខ) បន្ទាប់នោះ យ៉ាងហោចណាស់រយៈពេលរៀងរាល់ ៤ ឆ្នាំម្តង និងបន្ថែមទៀត ប្រសិនបើគណៈកម្មាធិការស្នើសុំដូច្នេះ ។

២. របាយការណ៍អាចបង្ហាញអំពីកត្តានានានិងការលំបាកដែលប៉ះពាល់ដល់កម្រិតនៃការបំពេញកាតព្វកិច្ចក្រោមអនុសញ្ញាបច្ចុប្បន្ន ។

**មាត្រា ១៩**

១. គណៈកម្មាធិការត្រូវអនុម័តវិធាននៃនីតិវិធីផ្ទាល់ខ្លួន ។

២. គណៈកម្មាធិការត្រូវជ្រើសរើសមន្ត្រីរបស់ខ្លួនសម្រាប់អាណត្តិរយៈពេល ២ ឆ្នាំ ។

**មាត្រា ២០**

១. គណៈកម្មាធិការត្រូវជួបប្រជុំជាធម្មតាសម្រាប់រយៈពេលមិនលើសពី ២ សប្តាហ៍ជារៀងរាល់ឆ្នាំ ដើម្បីពិចារណាអំពីរបាយការណ៍ដែលត្រូវបានដាក់ជូនស្របតាមមាត្រា ១៨ នៃអនុសញ្ញាបច្ចុប្បន្ន ។

២. កិច្ចប្រជុំគណៈកម្មាធិការជាធម្មតានឹងត្រូវធ្វើឡើងនៅឯទីស្នាក់ការកណ្តាលអង្គការសហប្រជាជាតិឬនៅកន្លែងសមស្របផ្សេងទៀតតាមការកំណត់របស់គណៈកម្មាធិការ ។

**មាត្រា ២១**

១. គណៈកម្មាធិការត្រូវរាយការណ៍ជាប្រចាំឆ្នាំជូនមហាសន្និបាតអង្គការសហប្រជាជាតិតាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម អំពីសកម្មភាពរបស់ខ្លួន ព្រមទាំងអាចធ្វើសំណូមពរ និងអនុសាសន៍ទូទៅផ្អែកលើការពិនិត្យរបាយការណ៍ និងព័ត៌មានដែលទទួលបានពីរដ្ឋភាគី ។ សំណូមពរ និងអនុសាសន៍ទូទៅទាំងនេះនឹងត្រូវដាក់បញ្ចូលនៅក្នុងរបាយការណ៍របស់គណៈកម្មាធិការជាមួយនឹងមតិយោបល់ពីភាគរដ្ឋនានា ប្រសិនបើមាន ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបញ្ជូនរបាយការណ៍របស់គណៈកម្មាធិការទៅកាន់គណៈកម្មការទទួលបន្ទុកស្ថានភាពស្ត្រី ដើម្បីជ្រាបជាព័ត៌មាន ។

**មាត្រា ២២**

ទីភ្នាក់ងារជំនាញត្រូវមានសិទ្ធិទទួលបានការតំណាង ដោយពិចារណាលើការអនុវត្តបញ្ញត្តិទាំងនេះនៃអនុសញ្ញាបច្ចុប្បន្ន ប្រសិនបើស្ថិតក្នុងវិសាលភាពនៃសកម្មភាពរបស់ខ្លួន ។ គណៈកម្មាធិការអាចអញ្ជើញទីភ្នាក់ងារជំនាញអោយដាក់របាយការណ៍អំពីការអនុវត្តអនុសញ្ញានៅក្នុងវិស័យ ដែលស្ថិតនៅក្នុងវិសាលភាពនៃសកម្មភាពរបស់ខ្លួន ។

**ផ្នែកទី VI**

**មាត្រា ២៣**

ដោយកត់សម្គាល់នៅក្នុងអនុសញ្ញាបច្ចុប្បន្នត្រូវធ្វើអោយមានប្រសិទ្ធភាពចំពោះបញ្ញត្តិទាំងឡាយដែលមានលក្ខណៈអនុគ្រោះជាងចំពោះការសម្រេចបានសមភាពរវាងបុរស និងស្ត្រីដែលអាចមាននៅក្នុង :

(ក) ច្បាប់របស់រដ្ឋភាគី ឬ

(ខ) នៅក្នុងអនុសញ្ញាអន្តរជាតិដទៃទៀត សន្ធិសញ្ញា ឬកិច្ចព្រមព្រៀងដែលនៅជាធរមានសម្រាប់រដ្ឋនោះ ។

**មាត្រា ២៤**

រដ្ឋភាគីសន្យាអនុម័តរាល់វិធានការចាំបាច់ទាំងអស់នៅថ្នាក់ជាតិសំដៅសម្រេចអោយបាននូវសិទ្ធិពេញលេញដែលទទួលស្គាល់នៅក្នុងអនុសញ្ញាបច្ចុប្បន្ន ។

**មាត្រា ២៥**

១. អនុសញ្ញាបច្ចុប្បន្នត្រូវបើកចំហសម្រាប់ការចុះហត្ថលេខាដោយរដ្ឋទាំងអស់ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបានចាត់តាំងជាស្ថាប័នគ្រប់គ្រងសម្រាប់អនុសញ្ញាបច្ចុប្បន្ន ។

៣. អនុសញ្ញាបច្ចុប្បន្នត្រូវស្ថិតក្រោមការផ្តល់សច្ចាប័ន ។ លិខិតូបករណ៍នៃការផ្តល់សច្ចាប័ននឹងត្រូវរក្សាទុកជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៤. អនុសញ្ញាបច្ចុប្បន្នត្រូវបើកចំហសម្រាប់ការចូលជាសមាជិកដោយរដ្ឋទាំងអស់ ។ ការចូលជាសមាជិកត្រូវមានប្រសិទ្ធភាពតាមរយៈការតម្កល់លិខិតូបករណ៍នៃការចូលជាសមាជិកជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

**មាត្រា ២៦**

១. សំណើសុំអោយមានការកែសម្រួលលើអនុសញ្ញាបច្ចុប្បន្នអាចត្រូវបានធ្វើឡើងនៅពេលណាមួយដោយរដ្ឋភាគីតាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរផ្ញើទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. មហាសន្និបាតអង្គការសហប្រជាជាតិអាចសម្រេចលើជំហានប្រសិនបើមាន ដែលត្រូវធ្វើឡើងទាក់ទងនឹងសំណើបែបនេះ ។

**មាត្រា ២៧**

១. អនុសញ្ញាបច្ចុប្បន្នត្រូវចូលជាធរមាននៅថ្ងៃទីសាមសិប ក្រោយកាលបរិច្ឆេទតម្កល់ជាមួយអគ្គលេខាធិការអង្គការ

សហប្រជាជាតិនូវលិខិតុបករណ៍ទី ២០ នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក ។

២. សម្រាប់រដ្ឋនីមួយៗដែលផ្តល់សច្ចាប័នលើអនុសញ្ញាបច្ចុប្បន្ន ឬចូលជាសមាជិកនៃអនុសញ្ញានេះក្រោយពីការតម្កល់លិខិតុបករណ៍ទី ២០ នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក អនុសញ្ញាត្រូវចូលជាធរមាននៅថ្ងៃទសាមសិបក្រោយកាលបរិច្ឆេទនៃការតម្កល់លិខិតុបករណ៍ផ្ទាល់របស់ខ្លួននៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក ។

**មាត្រា ២៨**

១. អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវទទួល និងផ្សព្វផ្សាយដល់រដ្ឋទាំងអស់នូវអត្ថបទនៃ ខ បម្រុងដែលធ្វើឡើងដោយរដ្ឋនៅពេលផ្តល់សច្ចាប័ន ឬចូលជាសមាជិក ។

២. ខ បម្រុងដែលមិនសមស្របតាមកម្មវត្ថុគោលបំណងនៃអនុសញ្ញាបច្ចុប្បន្ននឹងមិនត្រូវអនុញ្ញាតឡើយ ។

៣. ខ បម្រុងអាចត្រូវបានដកវិញនៅពេលណាមួយ តាមរយៈការជូនដំណឹងដែលធ្វើឡើងជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលនឹងជូនដំណឹងដល់រដ្ឋទាំងអស់នៃអនុសញ្ញា ។ ការជូនដំណឹងបែបនេះ នឹងមានប្រសិទ្ធភាពនៃកាលបរិច្ឆេទដែលវាត្រូវបានទទួល ។

**មាត្រា ២៩**

១. ទំនាស់ណាមួយរវាងរដ្ឋភាគីពីរ ឬច្រើនទាក់ទងនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញាបច្ចុប្បន្នដែលមិនអាចដោះស្រាយបានដោយការចរចាទេនោះ ត្រូវដាក់ជូនសម្រាប់មជ្ឈត្តការតាមសំណើរបស់រដ្ឋភាគីណាមួយ ។ ប្រសិនបើក្នុងរយៈពេល ៦ខែ ចាប់ពីកាលបរិច្ឆេទនៃការស្នើសុំធ្វើមជ្ឈត្តការ ភាគីទាំងឡាយមិនអាចយល់ព្រមលើការរៀបចំមជ្ឈត្តការទេនោះ ភាគីណាមួយក្នុងចំណោមភាគីទាំងឡាយអាចបញ្ជូនវិវាទទៅកាន់តុលាការយុត្តិធមិអន្តរជាតិតាមរយៈសំណើដោយអនុលោមតាមលក្ខន្តិកៈរបស់តុលាការ ។

២. រដ្ឋភាគីនីមួយៗ នៅពេលចុះហត្ថលេខា ឬផ្តល់សច្ចាប័បនលើអនុសញ្ញាបច្ចុប្បន្ន ឬការចូលជាសមាជិកនៃអនុសញ្ញា អាចប្រកាសថា ខ្លួនមិនចាត់ទុកខ្លួនឯងថាជាប់កាតព្វកិច្ចដោយកថាខ័ណ្ឌទី ១ នៃមាត្រានេះឡើយ ។ រដ្ឋភាគីដទៃទៀតមិនត្រូវជាប់កាតព្វកិច្ចដោយកថាខ័ណ្ឌនេះទាក់ទងនឹង រដ្ឋភាគីណាមួយដែលបានធ្វើ ខ បម្រុងនេះឡើយ ។

៣. រដ្ឋភាគីណាមួយដែលបានធ្វើ ខ បម្រុងស្របតាមកថាខ័ណ្ឌទី ២ នៃមាត្រានេះអាចដក ខ បម្រុងនៅពេលណាមួយក៏បានតាមរយៈការជូនដំណឹងដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។

**មាត្រា ៣០**

អនុសញ្ញាបច្ចុប្បន្នជាភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្បាញ ដែលជាអត្ថបទមានតម្លៃស្មើគ្នា នឹងត្រូវតម្កល់នៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ដើម្បីជាសក្ខីភាព ភាគីហត្ថលេខីដែលត្រូវបានអនុញ្ញាតយ៉ាងត្រឹមត្រូវបានចុះហត្ថលេខាលើអនុសញ្ញាបច្ចុប្បន្ននេះ ។

## ឧបសម្ព័ន្ធទី III : ធនធានឯកសារ CEDAW ដែលត្រូវបានណែនាំ

មានធនធានឯកសារជាច្រើនអំពី CEDAW រួមទាំងធនធានឯកសារដែលជ្រើសរើសដូចខាងក្រោម។ អាទិភាពត្រូវបានផ្តល់ជូនធនធានដែលអាចរកបានតាមអ៊ីនធឺណិតដែលមានភាពងាយស្រួលជាងក្នុងការចូលទៅកាន់។

### ១. ឯកសារ CEDAW

- CEDAW Text: Office of the High Commissioner for Human Rights (OHCHR). http://www2.ohchr.org/english/law/CEDAW.htm
- CEDAW General Recommendations: Office of the High Commissioner for Human Rights (OHCHR). http://www2.ohchr.org/english/bodies/CEDAW/comments.htm
- CEDAW Concluding Observations/Comments: The United Nations Human Rights Treaties. http://www.bayefsky.com/docs.php/area/conclobs/node/2/treaty/CEDAW/opt/0

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស គឺជាលេខាធិការដ្ឋាននៃគណៈកម្មាធិការ CEDAW។ វែបសាយត៍ដែលមានរៀបរាប់នៅក្រោមចំណុច ៣.១ ក៏មានឯកសារ CEDAW ផងដែរ។

### ២. អត្ថបទបោះពុម្ពផ្សាយ

### ២.១ ព័ត៌មានទូទៅអំពី CEDAW និងការអនុវត្ត CEDAW

- American Bar Association, Central and East European Law Initiative (ABA CEELI). CEDAW Assessment Tool, 2002.
  http://www.abanet.org/rol/publications/CEDAW_assessment_tool.shtml
- GTZ and United Nations Development Fund for Women (UN WOMEN). Pathway to Gender Equality: CEDAW, Beijing and the MDGs, 2004.
  http://www.UN Women.org/materials/item_detail.php?ProductID=20
- Partners for Law in Development and UN WOMEN. CEDAW: Restoring Rights to Women. New Delhi, 2004.

  http://www.UN Women.org.in/CEDAW.pdf
- UN WOMEN. Bringing Equality Home: Implementing the Convention on the Elimination of All Forms of Discrimination against Women, New York, 1998.
  http://www.UN Women.org/attachments/products/BringingEqualityHome_eng.pdf
- UN WOMEN. CEDAW Briefing Kit, 2008.

  http://CEDAW-seasia.org/docs/general/CEDAW_Briefing_Kit.pdf

### ២.២. CEDAW សូចនាករច្បាប់ និងការពិនិត្យមើលឡើងវិញផ្នែកច្បាប់

- Cambodian Committee of Women. Violence against Women: How Cambodian Laws Discriminate against Women: A Cambow Report, 2007.

http://CEDAW-seasia.org/docs/cambodia/ViolenceWomenReport2007_ENG.pdf

- CENWOR and UN WOMEN. CEDAW Indicators for South Asia: An Initiative. Sri Lanka, 2004.
http://www.UN Women.org.in/PDF/CEDAW_Indicators.pdf
- UN WOMEN. CEDAW and the Law: A Gendered and Rights-Based Review of Vietnamese Legal Documents through the Lens of CEDAW. Bangkok, 2009.
http://CEDAW-seasia.org/docs/general/CEDAWandVietnamese_Law.pdf
- UN WOMEN. Domestic Violence Legislation and its Implementation: An Analysis for ASEAN countries based on international standards and good practices. Bangkok, 2009.
http://CEDAW-seasia.org/docs/DomesticViolenceLegislation.pdf
- UN WOMEN. Gender Equality Laws: Global Good Practice and Review of Five Southeast Asian Countries. Bangkok, 2009.
http://CEDAW-seasia.org/resource_documents.html#gel_global
- UNDP Regional Bureau for Europe and the CIS. Drafting Gender-Aware Legislation: How to Promote and Protect Gender Equality in Central and Eastern Europe and in the Commonwealth of Independent States (CIS), Bratislava, 2003.
http://europeandcis.undp.org/gender/show/67CA99C8-F203-1EE9-B3D3B9C542E18404
- UN WOMEN and UNDP Pacific Centre. Translating CEDAW into Law: CEDAW Legislative Compliance in Nine Pacific Island Countries, Suva, 2007.

  http://pacific.UN Women.org/documents/TranslatingCEDAWIntoLaw.pdf

## ២.៣. ការអនុវត្ត CEDAW សម្រាប់បញ្ហាជាក់លាក់

- Chiongson, Rea Abada. The Right to Decide If, When and Whom to Marry: Obligations of the State under CEDAW and other International Human Rights Instrument. Kuala Lumpur, IWRAW Asia Pacific, 2005.
http://www.iwraw-ap.org/aboutus/pdf/OPS_VI.pdf
- Ramaseshan, Geeta. Addressing Rape as a Human Rights Violation: The Role of International Human Rights Norms and Instruments, Kuala Lumpur, IWRAW Asia Pacific, 2007.
http://www.iwraw-ap.org/aboutus/pdf/OPS10_Final_Publication_Version_Dec_18.pdf
- UN WOMEN. Turning the Tide: CEDAW and the Gender Dimensions of the HIV/AIDS Pandemic, New York, 2001.
http://www.UN Women.org/materials/item_detail.php?ProductID=13
- UN WOMEN. Women, Peace and Security: CEDAW and Security Council Resolution 1325: A Quick Guide, 2006.
http://www.UN Women.org/attachments/products/CEDAWandUNSCR1325_eng.pdf

### ២.៤. ធនធានឯកសារ CEDAW អំពីអាស៊ីអាគ្នេយ៍


- Dairiam, Shanthi. The Status of CEDAW Implementation in ASEAN Countries And Selected Muslim Countries, Kuala Lumpur, IWRAW Asia Pacific, 2004.
http://www.iwraw-ap.org/aboutus/pdf/OPSI.pdf
- Jurnal Perempuan (in Bahasa Indonesia), No. 45, Jakarta, January 2006.
http://CEDAW-seasia.org/docs/indonesia/JP45.pdf
- UN WOMEN. CEDAW Training Manual (in Lao), 2009.
http://CEDAW-seasia.org/docs/lao/CEDAW_Training_Manual.pdf
- UN WOMEN. Going CEDAW in the Philippines, Bangkok, 2009.
http://CEDAW-seasia.org/philippines_resources.html#goingCEDAW
- UN WOMEN. The Essentials to Understanding CEDAW, How it Applies to Cambodian Context.
http://CEDAWseasia.org/docs/cambodia/Essentials_to_Understanding_CEDAWCambodian_Context_Eng. pdf
- UN WOMEN. Time for Action: Implementing CEDAW in Southeast Asia, Bangkok, 2009. http://CEDAW-seasia.

  org/resource_documents.html


## ៣. វេបសាយត៍

### ៣.១ ទូទៅ

- International Women's Rights Action Watch Asia Pacific (IWRAW Asia Pacific).
http://www.iwraw-ap.org/convention.htm
- Office of the High Commissioner for Human Rights (OHCHR)
http://www2.ohchr.org/english/law/CEDAW.htm
- United Nations Development Fund for Women (UN WOMEN).
http://www.UN Women.org/gender_issues/human_rights/
- United Nations Human Rights Treaties.
http://www.bayefsky.com/treaties/CEDAW.php
- University of Minnesota Human Rights Library.
http://www1.umn.edu/humanrts/CEDAW/CEDAW-page.htm

### ៣.២ អាស៊ីអាគ្នេយ៍

- Cambodian National Council for Women.
http://cncw.gov.kh/page.php?menu=5

- CEDAW in Action in Southeast Asia
  http://CEDAW-seasia.org/resource_documents.html#gel_global
- CEDAW-Watch Philippines.
  http://www.CEDAW-watch.org/resources.htm
- CEDAW Working Group Initiative (Indonesia).
  http://cwgi.wordpress.com/
- National Commission for the Advancement of Women in Vietnam.

  http://www.ubphunu-ncfaw.gov.vn/?lang=E&func=news&catid=191&MN=173
- UN WOMEN CEDAW Southeast Asia Programme.
  http://www.UN Women-eseasia.org/CEDAW_and_Human_Rights/in_action.html
- Women's Aid Organisation (Malaysia).
  http://www.wao.org.my/research/CEDAW.htm

# ឯកសារយោងដែលត្រូវបានជ្រើសរើស

Banda, Fareda. Project on a Mechanism to Address Laws that Discriminate against Women, (commissioned by Office of the High Commissioner for Human Rights- Women's Rights and Gender Unit), http://www.ohchr.org/EN/PublicationsResources/Pages/Publications.aspx

Bernas, Joaquin. The 1987 Philippine Constitution: A Comprehensive Reviewer, Manila, Rex Bookstore, 2006.

CENWOR and UN WOMEN. CEDAW Indicators for South Asia: An Initiative. Sri Lanka, 2004

Diaz, Noli. Statutory Construction (3rd ed.), Manila, Rex Bookstore, 2007.

IWRAW Asia Pacific. Monitoring Guide: A Model for Monitoring the Implementation of the Convention on the Elimination of All Forms of Discrimination against Women, Kuala Lumpur.

Erturk, Yakin. Promotion and Protection of All Human Rights, Civil, Political, Economic, Social and Cultural, Including the Right to Development, Report of the Special Rapporteur on Violence against Women, Its Causes and Consequences, United Nations Human Rights Council, A/HRC/7/6, 29 January 2008.

Moser, Annalise. Gender and Indicators: Overview Report, Bridge and UNDP, July 2007.

Rodriguez, Rufus. Introduction to Law, Manila, Rex Book Store, 2001.

UNDP. Drafting Gender-Aware Legislation: How to Promote and Protect Gender Equality in Central and Eastern Europe and in the Commonwealth of Independent States (CIS), Bratislava, 2003.

UNDP. Programming for Justice: Access for All: A Practitioner's Guide to a Human Rights-Based Approach to Access to Justice, Bangkok, 2005.

UN WOMEN. CEDAW and the Law: A Gendered and Rights-Based Review of Vietnamese Legal Documents through the Lens of CEDAW, Bangkok, 2009.

UN WOMEN. Indicators to Measure Violence against Women: Expert Group Meeting, (organized by UN Division for the Advancement of Women, UN Economic Commission for Europe and UN Statistical Division), Geneva, 8-10 October 2007.

UN WOMEN and UNDP Pacific Centre. Translating CEDAW into Law: CEDAW Legislative Compliance in Nine Pacific Island Countries, Suva, 2007.

Women's Legal Bureau. A Legislative Advocacy Manual for Women, Quezon City, 2001.

## កំណត់សម្គាល់ :

United Nations Entity for Gender Equality
and the Empowerment of Women

តើច្បាប់របស់យើងលើកកម្ពស់សមភាពយេនឌ័រដែរឬទេ ? សៀវភៅណែនាំសម្រាប់ការពិនិត្យមើលឡើងវិញផ្អែកច្បាប់ផ្អែកលើ CEDAW គឺជាមគ្គុទ្ទេសក៏ដែលងាយ ប្រើសម្រាប់ការពិនិត្យមើលឡើងវិញលើច្បាប់នានាដើម្បីកំណត់ថាតើច្បាប់ទាំងនេះ រើសអើងប្រឆាំងនឹងស្ត្រីដែរឬយ៉ាងណា។ ដោយប្រើប្រាស់អនុសញ្ញាស្តីពីការលុប បំបាត់រាល់ទម្រង់ទាំងអស់នៃការរើសអើងលើស្ត្រី (CEDAW) ជាក្របខ័ណ្ឌ សៀវភៅណែនាំនេះដែលត្រូវបានតាក់តែងឡើងជាពិសេស ពីបទពិសោធន៍នៅអាស៊ីអាគ្នេយ៍ ប៉ុន្តែអាចអនុវត្តបានទូទាំងពិភពលោកនាំលោកអ្នកមួយជំហានម្តងៗអោយយល់ដឹងអំពីដំណើរការនៃការវាស់វែងអនុលោមភាពតាម CEDAW នៅក្នុងច្បាប់ជាតិ។ ចាប់ពីការធ្វើផែនការរហូតដល់ការអនុវត្តការពិនិត្យមើលឡើងវិញផ្អែកច្បាប់ ដោយមានការណែនាំដើម្បីបង្កើនជាអតិបរមានូវជោគជ័យរបស់អ្នកតាមមាគ៌ានៃការពិនិត្យមើលឡើងវិញរបស់អ្នក សៀវភៅណែនាំនេះបង្ហាញរដ្ឋាភិបាល អង្គការ មិនមែនរដ្ឋាភិបាល បញ្ញាវ័ន្ត និងអ្នកអនុវត្តវិជ្ជាជីវៈដែលធ្វើការឆ្ពោះទៅសម្រេចបាន សមភាពយេនឌ័រអំពីរបៀបបង្កើតសូចនាករផ្អែកច្បាប់ផ្អែកលើ CEDAW កំណត់បញ្ញត្តិដែលមានលក្ខណៈរើសអើង និងការខ្វះចន្លោះ ដោយប្រើប្រាស់សូចនាករទាំងនេះ រៀបចំអនុសាសន៍ និងប្រើប្រាស់ការពិនិត្យមើលឡើងវិញ ផ្អែកច្បាប់ផ្អែកលើ CEDAW របស់អ្នកដើម្បីតស៊ូមតិអោយមានការផ្លាស់ប្តូរនៅក្នុងច្បាប់ សម្រាប់សមភាពយេនឌ័រ។